ក្រុមជំនុំទំនៀមទម្លាប់
COMMISSION DES MOEURS & COUTUMES

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

ឆ្នាំគំរប់ ១៣

ភាគទី ១

ភ្នំពេញ

ការផ្សាយរបស់ព្រះរាជបណ្ណាល័យ

ព.ស. ២៤៨៣

គ.ស. ១៩៤១



ប្រាសាទបាយ័ន - ទ្វារចូលខាងកើត - រូបនាងអប្សរនៅនឹងសសរមួយ ។

កាថាមុខ

*នៃវេយ្យាករណ៍សំស្រ្កឹត ភាគទី ២*

សូមឧទ្ទិសដោយគោរព បំពោះលោក

ល្វី-ហ្វីណូត៍ ដែលអនិច្ចកម្មទៅ

# កថាមុខ

ព្រះសាក្យវង្ស ហ. គាត ជាអ្នកប្រព័ន្ធសៀវភៅវេយ្យាករណ៍សំស្ក្រឹតនេះ ផ្សាយក្នុងប្រទេសកម្ពុជា ជាដំបូង ឧទ្ទិសសៀវភៅនេះជាទីរឭកដល់វិញ្ញាណក្ខន្ធលោក ល្វី-ហ្វីណូត៍ ជាអ្នកប្រាជ្ញបារាំងសែសខាងភាសាសំស្ក្រឹត ព្រោះអាស្រ័យអ្នកប្រាជ្ញនេះ, លោកក៏បានចេះដឹងភាសាសំស្ក្រឹតនេះជ្រៅជ្រះ ដែលជាភាសាសក្តិសិទ្ធិនៅប្រទេសឥណ្ឌា ។

លោក ល្វី-ហ្វីណូត៍ បានបំភ្លឺនូវការរុងរឿងនៃប្រទេសកម្ពុជាក្នុងអតីតកាលដោយការស្រាវជ្រាវរកពង្សាវតារ នៅសិលាចារឹកសំស្ក្រឹតដែលព្រះមហាក្សត្រិយ៍ខ្មែរបានចារឹកទុកមក ហេតុនោះបានជាគេបង្កើតឲ្យមានការរៀនភាសាសំស្ក្រឹតនៅសាលាបរិយត្តិជាន់ខ្ពស់ដើម្បីជួយទំនុកបំរុងខេមរជាតិឲ្យមានការចេះដឹងដែលខានមិនបាន ទឹងឲ្យយល់ច្បាស់លាស់នូវវិជ្ជារបស់ខ្លួនតទៅខាងមុខ ពីព្រោះអារ្យធម៌ខ្មែរ, ដូចយើងបានដឹងហើយ, ជារបស់ដែលផ្សាយចេញមកពីប្រទេសឥណ្ឌា សូម្បីអក្សរសាស្ត្រខ្មែរនឹងធម៌អាថ៌ក៏សុទ្ធតែជាភាសាសំស្ក្រឹត ។

ការរៀនភាសាសំស្ក្រឹតនេះ មិនមែនមានប្រយោជន៍សម្រាប់តែអ្នកប្រាជ្ញខ្មែរ ដែលត្រូវឲ្យស្គាល់ដើមកំណើតភាសាបាលីនឹងភាសាមាតុភូមិរបស់ខ្លួនដែលបរិបូណ៌ដោយពាក្យពេចន៍សំស្ក្រឹតប៉ុណ្ណោះទេ អាចនឹងនាំអ្នកប្រាជ្ញខ្មែរអស់នោះឲ្យគេឃើញនូវគោលធំដែលខ្លួនស្ទើរតែមិនយល់

សោះផង គឺ ឲ្យយល់ភាសាបាលីខាងពួកហីនយាន នឹងភាសាសំស្ក្រឹតខាងពួកមហាយាន ។ ឯគម្ពីរដីកាបែកមហាយានមានច្រើនណាស់ ។

តាមពង្សាវតារ មានសេចក្ដីដំណាលអំពីមហាវិទ្យាល័យធំៗ ក្នុងប្រទេសឥណ្ឌា ដែលមាននៅទិសខាងជើងនឹងទិសពាយព្យ, មហាវិទ្យាល័យដែលច្បងជាងគេ គឺមហាវិទ្យាល័យនៅនាលន្ទានឹងតក្កសិលា ។ ក្នុងសម័យនេះ គេបានរៀនទូវគម្ពីរព្រះពុទ្ធសាសនាជាភាសាសំស្ក្រឹតចេះដឹងជ្រៅជ្រះ ហើយយើងនៅមិនទាន់ចេះដឹងគម្ពីរអស់នោះសព្វគ្រប់ផង, គម្ពីរដើមអស់នេះវិនាសបាត់បង់ទៅច្រើន, ដោយហេតុមិនមានអ្នកប្រាជ្ញឥណ្ឌាខាងពុទ្ធសាសនាប្រែជាភាសាទីបេតាំង ឬភាសាចិនដើម្បីផ្សាយព្រះពុទ្ធសាសនានៅប្រទេសចិននឹងប្រទេសទីបេត៍ ម្យ៉ាងទៀតដោយហេតុមិនមានអ្នកនមស្សការជាតិចិនមកកាន់ក្រុងនាលន្ទាដើម្បីរៀនភាសាសំស្ក្រឹតហើយប្រែគម្ពីរព្រះពុទ្ធសាសនាជាភាសាសំស្ក្រឹតនោះៗមកជាភាសាខ្លួនផង ។ និកាយហីនយានគ្រប់និកាយសុទ្ធតែមានគម្ពីរគ្រប់និកាយ; ពួក សព៌ាស្តិវាទិន គឺពួកដែលប្រកាន់ថា "អ្វីមានទាំងអស់" តាំងនៅស្រុក គន្ធារៈ នឹង កស្មីរៈ ហើយផ្សាយធម្មវិន័យរបស់ខ្លួនទៅដល់ប្រទេសចិន នឹងប្រទេសទីបេត៍, គម្ពីរភាសាសំស្ក្រឹតសំខាន់ៗនោះ អ្នកនមស្សការឈ្មោះ ហ្យៀ-ត្សាំង បានប្រែជាភាសាចិនក្នុងរវាង ព. ស. ១២៤៣ រៀងៗមកដល់ ព. ស. ១២៨៨ ។

សព្វថ្ងៃនេះ នៅសល់តែគម្ពីរជាសំណៅគោលគម្ពីរភាសាសំស្ក្រឹតដើម ដូចយើងបានអធិប្បាយខាងដើម បើមិនមានសេចក្ដីជាសាភាចិនទេ, អ្នកប្រាជ្ញតណ្ហៀ, ជប៉ុននឹងខុរុបមិនអាចនឹងផ្ទៀបញ្ញើសៀវភៅទាំងនោះបានឡើយ ក្នុងទីនេះ យើងកាយឈ្មោះគម្ពីរខ្លះគឺ

| ឈ្មោះគម្ពីរសំស្ក្រឹត | ទំនងភាសាបាឡី |
|---|---|
| ឧទានវគ៌ | ឧទាន |
| ធម្មបទ | ធម្មបទ |
| ឯកោត្តកគម | អង្គុត្តរនិកាយ |
| ប្រាតិមោក្សសូត្រ | បាដិមោក្ខ |
| ទីឃាគម | ទីឃនិកាយ |
| សំយុក្តាគម | សំយុត្តនិកាយ |
| ក្សុទ្រកាគម | ខុទ្ទកនិកាយ |
| ស្ថវិរគាថា | ថេរគាថា |
| វិមានវស្តុ | វិមានវត្ថុ |
| ពុទ្ធវម្ស | ពុទ្ធវង្ស |

គម្ពីរឥតិវុត្តកភាសាបាឡី ក៏មាននៅក្នុងពួកគម្ពីរសំស្ក្រឹតដែរ អ្នកនមស្សការជាតិចិនឈ្មោះ ហ៊ិន-ត្សង ប្រែជាភាសាចិនក្នុងរវាង ព. ស. ១១៩៣ (ព្រមទាំងគម្ពីរវិន័យឯទៀតៗ) បើទុកជាគម្ពីរអស់នេះមានសេចក្ដី

ផ្សេងៗ គ្នាខ្លះខុសអំពីរបៀបគម្ពីរបាលី ក៏មិនឆ្ងាយអំពីគោលដើមប៉ុន្មាន; ផ្លូវសេចក្ដីធម្មវិន័យនៅដូចគ្នានឹងគម្ពីរភាសាបាលី ៗ ពួកសូត្រមិនរៀបរៀងជាបទមាតិកាត ៗ គ្នាដូចពួកសុត្តៈទេ; នៅក្នុងសំយុត្តាគមគឺនឹងសំយុត្តផ្សេងគ្នាពីគម្ពីរភាសាបាលី ហើយម្យ៉ាងទៀត សំយុត្តៈភាសាបាលីមិនមានទាំងអស់នៅក្នុងសេចក្ដីប្រែជាភាសាចិនដែលប្រែចេញមកពីគម្ពីរសំស្ក្រឹតនោះទេ តែមានសំយុត្តដែលមិនមាននៅក្នុងគម្ពីរបាលី ៗ មានគម្ពីរសំស្ក្រឹតខ្លះមានឈ្មោះដូចគ្នានឹងគម្ពីរបាលី ប៉ុន្តែមានផ្លូវសេចក្ដីខុសគ្នា ៗ នៅក្នុងសេចក្ដីប្រែជាភាសាចិន ដែលប្រែចេញពីគម្ពីរសំស្ក្រឹតមានសេចក្ដីប្រែ ១០ ប្រការ ផ្សេងពីគម្ពីរមហាបរិនិព្វាណសូត្រ, សេចក្ដីប្រែ ៣ ប្រការជាលទ្ធិហីនយាន ៧ ប្រការទៀតជាលទ្ធិមហាយាន ៗ បណ្ដាពួកគម្ពីរនៃលទ្ធិហីនយានមួយទៀតឈ្មោះ លោកោត្តរវាទិន ជានិកាយប្រកាន់ថា ព្រះពុទ្ធមនុស្សប្លែកអស្ចារ្យ, មានគម្ពីរសំខាន់មួយឈ្មោះមហាវស្តុ ជាគម្ពីរនិយាយពីពុទ្ធប្រវត្តិអស្ចារ្យ ៗ នៅក្នុងគម្ពីរនោះមានរឿង ខុទ្ទកបាឋ, រឿងពុទ្ធវង្ស, រឿងធម្មបទ, រឿងធម្មចក្កវត្តនសូត្រនឹងជាតក ប៉ុន្តែជាតកខ្លះ នឹងអវទានខ្លះ មិនមាននៅក្នុងគម្ពីរបាលីទេ ៗ គម្ពីរមហាវស្តុ ពួកលោកុត្តរវាទិន ទុកដូចជាវិនយ-បិដក ហើយបែបផែនគម្ពីរបាលីរបស់ពួកថេរវាទិន ក៏ផ្សាយចូលទៅប្រាកដនៅក្នុងមហាវស្តុនោះដែរ ទើបសមដូចគម្ពីរបាលីដូចយើង

ពោលអាងមកខាងលើនេះ ហើយមានសេចក្តីស្រដៀងគ្នានឹងគម្ពីរបែបមហាយាន ។ ពួកអ្នកប្រាជ្ញដែលបានពិនិត្យគម្ពីរមហាវស្តុ បានឃើញថា គម្ពីរនេះមានផ្ទុសេចក្តីជាន់ចាស់ច្រើន តាមដែលមាននៅក្នុងអក្សរសាស្ត្របាលី ហើយយល់ថាគេតែងគម្ពីរនេះកាលពី ព.ស. ៤៤៣ ឡើងទៅ ។

គម្ពីរលលិតវិស្តារៈ បើទុកជាគម្ពីរពួកសវ៌ាស្តិវាទិនដែលជាហីនយាន ក៏គេទុកដូចជាគម្ពីរពួកមហាយានដែរ ព្រោះមានគេបន្ថែមសេចក្តីថ្មីបញ្ចូលទៅក្នុងគម្ពីរគោលដើម ។ ក្នុងគម្ពីរនេះគេបានពិនិត្យឃើញសេចក្តីជាន់ចាស់នៅលាយក្បែរគ្នានឹងសេចក្តីជាន់ថ្មី ។ គម្ពីរនេះ គេបានប្រែជាភាសាទីបេតាំងក្នុងរវាង ព.ស. ១៣៤៣ ហើយពួកជាងចម្លាក់នៅប្រទេសឥណ្ឌៀប៉ែកខាងជើងនឹងប្រទេសជ្វា បានប្រតិស្ឋឆ្លាក់រឿងរ៉ាវពុទ្ធប្រវត្តិគ្រប់អន្លើលើផែនថ្មតាមសេចក្តីក្នុងគម្ពីរនេះ ។ រឿងពុទ្ធប្រវត្តិដែលឆ្លាក់នៅលើផែនថ្មនេះ គេទុកជាការរចនាដែលមានរូបសំខាន់ៗ នៅចុងបូព៌ាប្រទេសឆ្ងាយ ។

មានគម្ពីរសំស្ក្រឹតមួយទៀត និយាយអំពីពុទ្ធប្រវត្តិដែរ ឈ្មោះពុទ្ធចរិត អ្នកនមស្សការចិន ឦ-ត្សឹង ពោលថាគម្ពីរនេះ ទុកជាគម្ពីរមួយដែលផ្សាយទូទៅ ហើយគម្ពីរនេះមិនល្បីល្បាញនៅត្រឹមតែក្នុងប្រទេសឥណ្ឌៀទេ មានឈ្មោះល្បីរហូតទៅដល់ប្រទេសជ្វា - សុមាត្រា តាមសមុទ្រខាងត្បូង ។ អ្នកនមស្សការចិនឈ្មោះឦ-ត្សឹងយល់ថា អ្នកណាក៏អត់ទ្រាំនឹង

អានកាព្យឃ្លោងបែបនេះបាន ដោយមានព្រះពុទ្ធវចនៈនៅក្នុងគម្ពីរនោះ អាចឲ្យអានិសង្សដល់អ្នកមើលបាន ។ គេបានប្រែគម្ពីរនេះជាភាសាចិន និងភាសាទីបេតាំងតាមច្បាប់ដើមជាភាសាសំស្ក្រឹតមាន ១៧ វគ្គ, វគ្គ ១៣ ខាងដើមជាសេចក្ដីពាស់សុទ្ធឥតមានសេចក្ដីបួមទេ ។

អ្នកប្រព័ន្ធ ជាអ្នកប្រាជ្ញកវីដែលមានថ្វីមាត់ឈ្មោះ អស្វឃោសៈ ។ លោកកើតនៅក្នុងសំណាក់សាសនាព្រាហ្មណ៍ ហើយត្រឡប់មកកាន់ព្រះពុទ្ធសាសនាលទ្ធិហីនយាននិកាយ សព៌ស្តិវាទិន, លុះចំណេរតទៅ, លោកចូលទៅជាអ្នកកាន់លទ្ធិមហាយានវិញ ។ ដល់មក ព. ស. ៦៤៣ លោកបានតែងគម្ពីរពុទ្ធចរិតប្រកបដោយ "មហាកាវ្យៈ" ហើយគេទុកជាគម្ពីរធំមួយក្នុងចំណោមគម្ពីរសំស្ក្រឹត ។ លោកបានតែងកាព្យខាងពុទ្ធសាសនាមួយទៀតឈ្មោះ សៅន្ទរានន្ទកាវ្យៈ និយាយពីរឿងពិលាបរបស់ភិក្ខុនន្ទ ដែលព្រាត់ប្រាសពីនាងសុន្ទរី (ជនបទកល្យាណី) ព្រោះព្រះពុទ្ធអង្គទ្រង់បំបួសទាំងបង្ខំ ។

ការល្បីឈ្មោះលោកអស្វឃោសៈ ខ្ចរខ្ចាយទៅខ្លាំងណាស់ រហូតដល់គេយល់ខុសថា លោកបានតែងគម្ពីរឯទៀតផង ដូចគម្ពីរសូត្រាលង្ការជាដើម ដែលសព្វថ្ងៃនេះសល់នៅតែសេចក្ដីប្រែជាភាសាចិនហើយប្រាប់ថា គម្ពីរនេះតែងនៅ ព. ស. ៩៤៨ ។ អ្នកប្រព័ន្ធឈ្មោះ កុមារលាត ស្ថិតនៅក្នុងបឋមវ័យជំនាន់អ្នកប្រាជ្ញកវីឈ្មោះអស្វឃោសៈដែរ, បានតែងគម្ពីរនេះ ។

សេចក្ដីដើមជាភាសាសំស្ក្រឹតឈ្មោះ កល្បនាលំក្ឫតិក ដែលមានរឿងស្រ-ដៀងគ្នានឹងជាតក ហើយក្នុងគម្ពីរនេះ មានសេចក្ដីប្រហែលគ្នានឹងជាតកខាងបាលីដូចរឿង គិតិ ជាតកជាដើម ។ រឿងក៏ខ្លះ ដែលគេយកទៅក្រងជាពាក្យឃ្លោងសុទ្ធតែដកស្រង់មកអំពីគម្ពីរនិកាយសព្វាស្តិវាទិន, តែគង់នៅមាននិទានខ្លះនៅជាស្នាដៃមហាយានដែរ ។ អ្នកនមស្សការចិនឈ្មោះ ហ៊ាន-ត្សង់ និយាយថា អ្នកប្រព័ន្ធនេះចេញមកពីមហាវិទ្យាល័យនៅក្រុងតក្កសិលា ហើយជាអ្នកបង្កើតលទ្ធិថ្មីមួយឈ្មោះ សៅត្រានិក: ។

មានគម្ពីរកាព្យឃ្លោងដទៃទៀត ដែលគេយល់ថាជារបស់លោកអឝ្វ-ឃោឞ:ទៀតដែរ តែជារបស់អ្នកប្រព័ន្ធម្នាក់ ឈ្មោះ មាត្ឫចេត ទេ, តាមអ្នកនមស្សការចិនឈ្មោះឦ-ត្សីង យល់ថា ជាអ្នកប្រាជ្ញកវីមួយដែលមានឈ្មោះល្បោះសំឡេងក្នុងសម័យនោះ ហើយមានគេសូត្រកាព្យឃ្លោងសាសនា មិនមែនតែនៅក្នុងប្រទេសឥណ្ឌាទេ មានគេរាប់អានរហូតដល់ទៅប្រទេសឆ្ងាយៗទៀត ។ គម្ពីររបស់អ្នកកវីនេះដែលមានឈ្មោះល្បីជាងគេនោះគឺ គម្ពីរចតុ:ឝតកស្តោត្រ:និងគម្ពីរឝតបញ្ចាសតិកស្តោត្រ: ។ ប៉ុន្តែគួរស្ដាយណាស់ ព្រោះគម្ពីរនេះ នៅតែមានគោលខ្លះជាភាសាសំស្ក្រឹត ។ បើឥតមានការទាក់ទងនឹងអ្នកនមស្សការចិនឈ្មោះ ឦ-ត្សីង ទេ គេមិនអាចនឹងកាត់ថ្លៃគម្ពីរនេះបានឡើយ; អ្នកនមស្សការចិនបានកត់ត្រាទុកនូវសេចក្ដីពេញចិត្តខ្លួន ហើយទទួលស្គាល់ថា គម្ពីរ

កាព្យនេះគេបានបង្កើតដោយផ្ចិតផ្ចង់ទាំងដោយគំនិតដ៏ខ្ពង់ខ្ពស់ មានគេចូលចិត្តមើលនឹងយកតម្រាប់តែងតាម សូម្បីពុទ្ធសាសនិកបេះតែត្រឹមសីល ៥ ឬ ១០ ក៏ទន្ទេញកាព្យឃ្លោងលោក មាតុចេត រត់មាត់ទទេ, ហើយកាព្យឃ្លោងនេះលោក ត្លៀ-ត្យ៊ឹង បានប្រែមកជាភាសាចិន; គម្ពីរនេះគេបានប្រែទៅជាភាសាទីបេតាំងដែរ ។ ក្នុងរវាង ព.ស. ៨៤៣, អក្សរសាស្ត្រសំស្ក្រឹតរបស់និកាយសព៌ាស្តិវាទិនក៏ចំរើនឡើងទៀត ដោយមានអ្នកប្រាជ្ញកវីម្នាក់ឈ្មោះ អារ្យសូរៈ បានតែងគម្ពីរមួយទៀត ។ កាព្យនោះឈ្មោះ ជាតកមាលា ជាគម្ពីរមានលាយទាំងសេចក្តីរាយនឹងកាព្យឃ្លោងតាមវិធីសំស្ក្រឹតមានបែបផែន ។ ជាតក ៣៤ ដែលលោកនេះបានតែង មានជាតកខ្លះជាជាតកបាលី ។ អ្នកនមស្សការចិនឈ្មោះ ត្លៀ-ត្យ៊ឹង ពេញចិត្តនឹងសៀវភៅនោះណាស់ ព្រោះក្នុងសម័យនោះ សៀវភៅនេះផ្សាយទូទៅពេញប្រទេសឥណ្ឌា ។ គម្ពីរលោកអារ្យសូរៈ គេបានប្រែជាភាសាចិន រវាង ព.ស. ៩៧៧ ។

មុននឹងបញ្ចប់បញ្ជីឈ្មោះសៀវភៅមិនទាន់សព្វគ្រប់នៃអក្សរសាស្ត្រលទ្ធិហីនយានជាភាសាសំស្ក្រឹត ត្រូវរាប់បញ្ចូលពួកគម្ពីរអវទានដែលជាគម្ពីរជាន់ចាស់ក្នុងពួកអក្សរសាស្ត្រលទ្ធិហីនយានដែរ, ឯអវទានឯទៀតជារបស់មហាយាន ។ ( នៅមានត )

នេះ

# ច្បាប់សុភាសិត

ប្រសើរពេកពិត ប្រែពីគាថា
បន្ទូលព្រះពុទ្ធ បំហុតទេស្នា
ឲ្យអស់ទាំងមហា- ជនគផងត្រងត្រាប់ ៗ
និព្វានបច្ចយោ ហោតុ មេ ៗ

របស់

ឧកញ៉ាវង្សាសារពេជ្ញ នង ហាងហ្សាង ក្រុមរាជបណ្ឌិត្យ

ក្នុងរាជ្យព្រះបាទសម្តេចព្រះហរិរក្សរាមាឥស្សរាធិបតី

(ព្រះអង្គឌួង) ៗ

# អារម្ភកថា និងពាក្យនមស្សការ

សុគសេដ្ឋោ ឯកសដ្ឋិឯកតោ សំវច្ឆរេ ចតុនវុតិ ចន្ទវារេ អាសាឡ្ហមាសេ បុណ្ណមិយំ ។ កាយោ មយា ឧជុនាមតា មនោរថំ បីតិបយោ សីលោរត្តំ សុភា-សិតំ កាព្យការេ ។ អហំ នមា- មិសិរសា សុសម្ពុទ្ធោ តិលោកានំ សេដ្ឋអគ្គោ នរនេហ វរជាំ ។ មហាវីរោ សុវិនេយ្យោ មារសេនំ អាគច្ឆិយោ សម្ពោធិតំ អ-នុត្តរញ្ញាណំ លោកុត្តរោ ។ នកោវលៈ- មេវគុទ្ធៈ-ជម្ពូនាថោ នមាមិហំ អដ្ឋង្គិកោ អរិយបថោ ទេវជនំ ។ សន្តិការោ និយ្យានិកោ មោក្ខប្បទំ បនមាមិ អរិយ-សង្ឃំ សីលសុទ្ធំ សន្តិន្ទ្រិយោ ។ បុញ្ញក្ខេត្តំ សត្តុណំ នមស្សមានោ រតនត្តយំ ហិតំបញ្ញោ កយំទុក្ខោ នីអលត្ថំ ។ សុគមស្ស ស្វស្តិស្រីសុ កមង្គលំ ពហុ-លៈបត្តា ជយាវរំ ឯកសដ្ឋឯកំ តោតិវរេកោ ។ សក សោត្ថមំ ចុនក្ស្រត្រ ពេញបូណ៌មីខែ អាសាឍចន្ទៈ ពារៈនេវ វុឌ្ឍិវរេ សាធុការា ។

ឯអត្តអញខ្ញុំ នាម ឡុង សោតសម ចិត្តចេតនា សូមមានមនោ បរិយោសថ្ពា ព្យាយាមស្រាវហ៍ ត្រេកត្រអាកុសល ។ ដ្បិតខ្ញុំនេះណា

ទើបរៀនចង់ជា កាព្យកិច្ចការគេ គន់គិតដោយនា ប្រាជ្ញាយោបល់ ពុំ
សូវឆ្លាយយល់ ជ្រៅជ្រះកាព្យា ៗ ខ្ញុំផ្តើមទសករ កាយកបបវរ រ័ត្ន
បុស្បា បុស្សបទបង្គំ ប្រណម្យអភិវាទ វន្ទិយ៍ព្រះមហា សារពេជ្ញពុទ្ធោ ៗ
សុភឥន្ទព្រហ្ម មូលមកបង្គំ ក្រាបក្រោមបាទោ ប្រកបកង់ចក្រ លាយ
លក្ខណ៍វរពេ វរអគ្គោ ឯកឥតទុតិយំ ៗ ព្រះស្រីសម្ពុ- ទ្ធោធម៌វិសុទ្ធ
វិសេសសេដ្ឋំ ជាតិជាមកុដ អគ្គឧត្តមំ ប្រោសសត្វទួទាំង ត្រៃត្រ័យភព
ភារ ៗ សរសើរបារមី វរញាណជិនស្រី ក្រាស់ក្រៃពិស្ដារ សែន
កោដិកល្បកាត់ ផ្តាច់វដ្ដសង្សារ ផ្តួលផ្តាញ់មោហ៍មារ មានះបបបាន ៗ
ព្រះលោកុត្តរ សុពណ៌បវរ ភារកេត្រាយាន យោនយោងសត្វសល់
ដាក់ដល់និព្វាន និរនេសមិនមាន មរណ៍មកជិតដល់ ៗ ព្រះសង្ឃសីល
សុទ្ធ វិសេសពង្សពុទ្ធ- ឱរសនិមិល អស្ចារិយសង្ឃ ទ្រទ្រង់សីលសល់
អគ្គឥតអំពល់ វដ្ដសង្សារ ៗ ស្រគត់អស់ឥ - ន្ទ្រិយ៍អគ្គអចិ - ន្ត្រិយ៍ទ្រង់
ករុណា សព្វសត្វដាក់ដល់ មណ្ឌលសួគ៌ា គុណគាប់ជាតិជា ស្រូវស្រែ
បុណ្យផល ៗ ទាំងបីព្រះអង្គ ប្រសើរទ្រទ្រង់ ករុណាសត្វសល់ ផ្ទេរ
ផ្ទុកសំពៅ នាំទៅដាក់ដល់ ត្រង់ត្រើយថ្កាក់ថ្កល់ និរនេសបាបបង់ ៗ
ហេតុនោះខ្ញុំថ្វាយ បុស្សបង្គំដកាយ កបកោមលផ្គង់ សរសើរបារមី
ទាំងបីព្រះអង្គ វុងរឿងអភិវ- ន្ទលគុណថ្លៃថ្លា ៗ តេជតេជះខ្ញុំ ថ្វាត់-

ថ្វាយបង្គំ គ្រប់ត្រៃរតនា សូមទេពទិសទស សោឡសសួគ៌ា ចំរើន ទីឃា- យុយឺនក្រៃមក្សាន្ត ៗ ស្រេចខ្ញុំនឹងថ្លែង ស្រាវស្រង់សំដែង សណ្តាប់និទាន សុភាសិតសព្វ ធម៌គាប់ខ្នាន សព្វសត្វឲ្យបាន អភិ- រម្យរុបា ៗ ព្រះធម៌ប្រធាន ប្រសើរយាន រត្នរឿនសុវណ្ណា នាំសត្វ ពីក្នុង វដ្តសង្សារ ដោយដាក់ដល់នា សុខសួគ៌ាល័យ ៗ ធម៌នេះជា ច្បាប់ ប្រសើរមហាគាប់ ចូរដែនទីទៃ ស្រៀនត្រង់ត្រាប់ ជាច្បាប់ប្រ- ពៃ តាមដោយគាថានៃ បទព្រះគាថា :

១ — យោសម្បន្នំ អាយុវស្សំ ឯកាសតា អរក្ខិតំ សីលំអសា- ធុអសមា- ហិតោជនំ ។ យេចឯក ឯរឃកា- ហំ ជីវិតំ សេយ្យោរក្ខ: សីលវន្តំ សជ្ឈាយិនំ សាធុជនា ។

អានិបនេ ដើមបទបទ្វ បាលីនេះថា យោចជនោ នរអ្នកណា មួយមានជន្មា យេន្នាំប្រាកដ ៗ អរក្ខិតា បើពុំរក្សា សីលជាកំណត់ អសាធុជា ធម៌ជាឥតបទ ឥតបុណ្យប្រាកដ ពិតពុំប្រពៃ ៗ យេចឯក នរអ្នកណា ទើបកើតមួយថ្ងៃ បើមានសីលំ សេដ្ឋប្រពៃ ប្រសើរលើសក្រៃ អ្នកចាស់វិញណា ៗ ដ្បិតសីលជាយាន នាំរូបរួចបាន ចៀសចាកចតុរា- បាយបាបបានដល់ មណ្ឌលសួគ៌ា- ល័យលុះមហា- និព្វានសេដ្ឋ ៗ

# ពង្សាវតារក្រិក

(តពីភាគ ១២ ឆ្នាំ ១៩៤០)

ពួកស្ត្រីស្ប៉ាតិយ៉ាតកាលណាធាត់ធំចំរើនឡើង ក៏គោងតែរៀបការនឹងទាហានដើម្បីជាមាតារបស់ទាហានតទៅមុខទៀត ៗ ស្ត្រីអស់នេះមានចិត្តស្រឡាញ់គ្រួសារមិនសំខាន់ស្មើនឹងការស្រឡាញ់ស្រុកទេសទេ ដូចមានសេចក្ដីដំណាលថា មានស្ត្រីម្នាក់បានដំណឹងថា កូនរបស់ខ្លួនទាំង ៤ នាក់ស្លាប់ក្នុងទីចម្បាំង តែស្រុកស្ប៉ាតបានជ័យជំនះ ក៏ស្រែកហ៊ោឡើងដោយសប្បាយចិត្តជាពន្ទឹកថា "គួរឲ្យអរគុណព្រះជាម្ចាស់" ៗ មានស្ត្រីម្នាក់សម្លាប់កូនរបស់ខ្លួននឹងដៃឯង ព្រោះកូននោះរត់ទ័ពមករកម្ដាយ ៗ

តាមហេតុភេទផ្សេងៗដែលពោលមកនេះ យើងយល់ថាអាក្រក់ឬល្អក៏ដោយ ពួកស្ប៉ាតិយ៉ាតមានកេរ្តិ៍ឈ្មោះល្បីល្បាញជាប់ពង្សាវតារថា ជាមនុស្សរឹងរប៉ឹងនឹងក្លាហានបំផុតក្នុងលោក ៗ

ស្រុកអាថែន្ស – ស្រុកនេះមានពង្សាវតារប្លែកពីស្រុកស្ប៉ាតដោយប្រការទាំងពួង គឺពួកស្ប៉ាតិយ៉ាតឡើងដោយការធ្វើសង្គ្រាមលុកលុយ, ជាប្រទេសនៅលើគោក ជាជាតិទាហានគ្រប់គ្រងដោយពួកមន្ត្រី ប្រកាន់ច្បាប់នឹងចរិតប្រពៃណីបុរាណ, ឯស្រុកអាថែន្សជាស្រុកនៅមាត់សមុទ្រ ជាទីធ្វើការលក់ដូរជំនួញនានា, សិក្សារៀនរកចំណេះវិជ្ជា, ផ្លាស់ប្ដូរទំនៀមទម្លាប់ ៗ ពង្សាវតាររបស់អាថែន្ស មានសេចក្ដីសំខាន់ ២ ប្រការ គឺការ

តាំងអាណាចក្រនៅមាត់សមុទ្រម្យ៉ាង ហើយម្យ៉ាងទៀត គឺប្រជាជនគ្រប់គ្រងខ្លួនឯងដែលមានទំនងដូច្នេះ ព្រោះការលក់ដូរជំនួញខាងផ្លូវសមុទ្រជាហេតុឲ្យប្រជាជនមានទ្រព្យស្តុកស្តម្ភមាំមួនឡើង ហើយពួកអស់នេះមិនព្រមនៅក្រោមអំណាចរបស់ពួកមន្ត្រីដែលធ្វើជាម្ចាស់ទីដីធំៗ នៅទីបំផុតគេក៏នាំគ្នាដណ្តើមយកអំណាចមកវិញបាន ។

ប្រជាជននៃស្រុកអត្តិក — អាណាចក្ររបស់ក្រុងអាថែន្យ៍ ហៅថា អត្តិក ជាភូមិប្រទេសពេញដោយធម្មជាតិផែនដី បង្គាប់ឲ្យប្រជាជនរករបរខាងជំនួញឬទូក ។ អត្តិកជាជ្រោយលៀនចេញ មានសណ្ឋានជា ៣ ជ្រុង ដេរដាសទៅដោយថ្ម ហើយធ្វើការដាំដំណាំមិនល្អផង ។ ក្នុងជាន់ដំបូង កាលប្រជាជននៅតិចនៅឡើយ ល្មមរកស៊ីដាំដំណាំបាន លុះដល់មានចំនួនច្រើនក៏តោងតែងាកទៅរករបរខាងសមុទ្រវិញ ។

កន្លែងដែលមានដីដីជាតិល្អក៏មានតែមួយអន្លើប៉ុណ្ណោះ គឺត្រង់ស្រុកអាថែន្យ ។ នោះជាទីតាំងក្រុងយ៉ាងសមរម្យ សុខសម្រាន្ត ព្រោះមានខ្យល់បក់យកចំហាយទឹកសមុទ្រពីទិសខាងត្បូងធ្វើឲ្យមានសេចក្តីកក់ក្តៅក្នុងរដូវរងា ហើយបក់យកចំហាយទឹកមកធ្វើឲ្យត្រជាក់ក្នុងរដូវក្តៅ ។ នៅត្រង់កណ្តាលជាដីទួល មានកំពស់ប្រហែល ១០០ ម៉ែត្រ ត្រង់កំពូលទួលជាទីរាបស្មើល្មមនឹងកសាងជាវត្តនឹងព្រះរាជវាំង ។

**ប្រជាជនស្រុកអាថែន៍** – អ្នកស្រុកនេះច្រើនតែជាកូនកាត់ មិនប្រាកដថាចេញមកពីផៅណាខ្លះ នេះជាធម្មតារបស់ស្រុកដែលនៅតាមមាត់សមុទ្រគ្រប់អន្លើ រមែងមានជនជាតិផ្សេងលាយឡំផ្សំគ្នាជាធម្មតា ហេតុនេះហើយធ្វើឲ្យអ្នកស្រុកអាថែន៍ប៉ិនប៉ៅការងារសព្វគ្រប់ ពោលគឺមានទាំងអ្នកជំនួញ, អ្នកប្រាជ្ញខាងអក្សរសាស្ត្រ, អ្នកប្រាជ្ញខាងធម៌អាចិន្ទ័អ្នករបនាគូរឆ្លាក់ទៀតផង ។

អ្នកស្រុកអាថែន៍ជាមនុស្សពួកដំបូង ដែលបានឲ្យគំរូបែបផែនដល់លោកក្នុងការត្រួតត្រាស្រុកទេសដោយវិធីបោះឆ្នោតរើស ។ ប្រវត្តិពង្សា-វតារបរមបុរាណរបស់ជនពួកនេះ មានការប្រែប្រួលផ្លាស់ប្តូរការត្រួតត្រាស្រុកទេសមករឿយៗ ។ ជាន់ដើម នៅក្នុងកណ្តាប់ដៃក្សត្រ តមកបានទៅពួកមន្ត្រី ហើយនៅទីបំផុត ធ្លាក់មកក្នុងកណ្តាប់ដៃរបស់រាស្ត្រទំនងនេះហើយ លទ្ធិប្រជាធិបតេយ្យដែលបារាំងហៅថា ដេមោក្រាស៊ីទើបកើតឡើងចំរើនរុងរឿងនៅស្រុកអាថែន៍ជាដំបូង ។

**ការត្រួតត្រាស្រុក** – ក្នុងជាន់ដំបូង ស្រុកអាថែន៍មានទំនងដូចស្រុកបុរាណឯទៀតៗដែរ ពោលគឺអំណាចការត្រួតត្រាក្នុងគ្រួសារនីមួយៗនៅក្រោមបង្គាប់អាពុកម្តាយឬអ្នកអភិបាល តែក្នុងវេលានោះ មានពួកលោកសង្ឃគ្រប់គ្រងខាងផ្លូវសាសនា ហើយមានមេទ័ពគ្រប់គ្រងត្រួតត្រាក្នុង

វេលាមានចម្បាំងមួយចំណែកទៀតផង ។ កាលបើស្រុកមានសេចក្ដីសុខសាន្តត្រាណ មនុស្សម្នាក្នុងគ្រួសារនីមួយៗ តោងនៅក្រោមបង្គាប់មេផ្ទះចាស់ទុំក្នុងត្រកូល ប្រសិនបើមានកិច្ចធុរៈខាងផ្នែកសាសនាកើតឡើង តោងប្រគល់ដល់លោកសង្ឃ ប្រសិនបើមានសឹកសង្គ្រាមៈតោងប្រគល់ការត្រួតត្រាទាំងអស់ដល់មេទ័ព ។ តមកសម័យក្រោយទៀត គ្រួសារនីមួយៗ កាន់តែមានចំនួនច្រើនឡើង ទើបរួមតាំងជាភូមិស្រុកឡើង ភូមិស្រុកដែលៈនៅកណ្ដាលច្រើនមានកំពែងរឹងប៉ឹង មានអំណាចជាងភូមិស្រុកដទៃ ( ៈនៅខាងក្រៅ ) ឯមេភូមិមេស្រុកតាំងខ្លួនជាក្សត្រឡើងជាអគ្គដំបូងព្រះនាមថា ថេសេ ដែលអ្នកប្រាជ្ញពង្សាវតារមិនទាន់ដឹងប្រាកដថា កើតនៅឆ្នាំណា ឬសោយរាជ្យក្នុងឆ្នាំណាទេ ? ឯព្រះរាជប្រវត្តិរបស់ក្សត្រអង្គនេះ មានទំនងដូចក្សត្រអង្គដំបូងរបស់ប្រទេសទាំងឡាយដែរ គឺច្រើនមានជានិទានរឿងព្រេងជាទីអស្ចារ្យ មិនគួរជឿដល់ជនជាន់ក្រោយ ។

អំពីពួកមន្ត្រី — (L’Aristocratie) មានប្រមុខ ឬនាយករបស់ត្រកូល ១ ក្រុមដែលនិយមហៅខ្លួនឯងថា ពួកអ៊ុយប៉ាទ្រិត (Eupatrides) ប្រែថាជាពួកកើតមកល្អ ពួកនេះតាំងខ្លួនជាពួកមន្ត្រីឡើង ហើយមានអំណាចជាម្ចាស់ទឹកដីតែលើពួកនេះប៉ុណ្ណោះ ។ តមកទៀត ពួកនេះមិនត្រូវការនៅក្រោម

អំណាចក្សត្រដែលគេឯកផ្សេងទៅទៀត ទើបនាំគ្នាកំចាត់ពូជវង្សក្សត្រចេញ ហើយប្រគល់ការត្រួតត្រាស្រុកទេសដល់ពួកចៅក្រមដែលរើសយកពីពួកអ៊ឺប៉ាទ្រីត មានការរើសផ្លាស់រូបអ្នកត្រួតត្រានេះតែរៀងរាល់ឆ្នាំ ពួកឯទៀតមិនត្រូវមានអំណាចរើសយកជាក្រុមត្រួតត្រាស្រុកទេសទេ ។ កាលពួកមន្ត្រីនេះកាន់តែមានអំណាចច្រើនឡើងៗ ក៏សង្កត់សង្កិនប្រជាជនឥតអាណិតបន្តិច ។ ពួកអ្នកស្រែចំការដែលអស់ផ្លូវរកស៊ី គេងមកបង់ការខ្ចីបុលពួកនេះ កាលបើមិនមានសងត្រូវចាប់ខ្លួនដាក់គុក ចាប់ធ្វើជាខ្ញុំកំដរឬចាប់លក់ឲ្យអ្នកឯទៀតតទៅ ។ លុះកាលតមកប្រជាជនក៏តាំងបះបោរចលាចលដណ្តើមយកអំណាចពីពួកមន្ត្រីបាន ពួកមន្ត្រីក៏ប្រែគំនិតប្រើវិធីកក់ទាក់ស្រុះស្រួលជាមួយនឹងកស្ត្រវិញ ហើយប្រគល់អំណាចឲ្យអ្នកប្រាជ្ញម្នាក់ឈ្មោះ សូឡុង (Solon) ចាត់របៀបត្រួតត្រាស្រុកទេសជាថ្មីឡើង ។

**សូឡុង និងរបៀបចាត់ការរបស់លោក** — សូឡុងមិនដូចលីកៀគទេ គឺជាអ្នកមានលក្ខណៈទន់ភ្លន់ស្លូត ជាប់ជាពូជក្សត្រ ជាទីស្រឡាញ់រាប់អានរបស់ក្រិក ជាអ្នកមានចិត្តមេត្តាករុណាដល់មនុស្សទាំងពួង ធ្លាប់ធ្វើដំណើរចេញទៅកាន់ទីនានាជាច្រើនគ្រា ជាអ្នកមានទ្រព្យសម្បត្តិស្តុកស្តម្ភដោយសារជំនួញ ធ្លាប់បានសេពគប់នឹងអ្នកប្រាជ្ញខាងទ្វីបអាស៊ីជាច្រើននាក់ ។

សូឡុងជាចិន្តកវីមួយរបស់ក្រិក បទកាព្យក្លូនរបស់លោកនេះជាគ្រឿងដាស់ចិត្តពួកអាថែនឲ្យមានចិត្តស្រឡាញ់ជាតិយ៉ាងខ្លាំង ។ សូឡុងអាចតាំងខ្លួនជាស្តេចគ្រប់គ្រងអាថែនក៏បាន តែមិនត្រូវការ គិតតែធ្វើអំពើល្អ-ប្រពៃ ជួយប្រទេសជាតិប៉ុណ្ណោះ សូឡុងច្បាប់នាំទ័ពពួកអាថែនទៅច្បាំងឈ្នះពួកនៅកោះក្នុងសមុទ្រ អេស៊ីន (Egine) ។

សូឡុងតាត់រម្ញាប់ការទោសដែងរាំងពួកមន្ត្រីនឹងពួកពស្ត្រ ដោយវិធីបំបាត់ពួកដែលនៅខ្ញុំគេ ព្រោះជាប់បំណុល នោះឲ្យបានរួចខ្លួនទៅជាអ្នកជាទាំងអស់ ហើយតាំងអំពីនោះមក ហាមមិនឲ្យម្ចាស់បំណុលបង្ខំកូនបំណុលឲ្យសងដោយវិធីឃុំខាំងឬចាប់កូនបំណុលលក់ដោយដាច់ខាត ហើយបង្គាប់ឲ្យពួកមន្ត្រីចាត់ចែងចែកទឹកដីឲ្យបណ្តាពស្ត្រជាចំណែកៗ តាមសមគួរនឹងការចិញ្ចឹមជីវិត កាលសូឡុងរៀបចំធ្វើដូច្នេះ ក៏ចែកប្រជាជនអាថែនចេញជា ៤ ថ្នាក់តាមធនធានដែលមានតិចច្រើន គឺពួកដែលមានទ្រព្យច្រើនក៏មានអំណាចច្រើន តែគោងបង់ពន្ធដារក៏ច្រើនដែរ ចំណែកឯអ្នកដែលមានធនធានតិចតួចស្តួចស្តើងក៏មានអំណាចតិចឬមិនមានឡើយតែបង់ពន្ធក៏តិចឬមិនបាច់បង់ឡើយ ជាអ្នកមិនបាច់ធ្វើការងារអ្វីដល់ស្រុកទេស ។ ដូចជាមនុស្សថ្នាក់ទី៤នេះមិនមានអំណាចបោះឆ្នោតក្នុងកិច្ចការស្រុកទេស មិនបាច់បង់ពន្ធដារ មិនបាច់ធ្វើទាហានផង ។ ការបែងជាន់វណ្ណៈបែបនេះ

រមែងខុសប្លែកពីរឿងរ៉ាវដែលមានមកក្នុងពង្សាវតាររបស់ជនជាតិឯទៀតៗ ពោលគឺជនជាតិឯទៀតៗ ប្រកាន់យកកំណើតជាធំក្នុងការបែងជាន់វណ្ណៈ តែពួកអាថែន្សប្រកាន់យកត្រង់មានក្រជាប្រមាណ ទោះបីកើតក្នុងត្រកូលខ្ពស់ទាបមិនជាសំខាន់ទេ ហេតុនេះវណ្ណៈមិនសូវជាផ្លាស់ប្តូរទេសម្រាប់ជនជាតិឯទៀត តែពួកអាថែន្សផ្លាស់ប្តូរបានជានិច្ច ពោលគឺពួកអាថែន្សអាចស្ទុះឡើងកាន់វណ្ណៈខ្ពស់ឬថយចុះមកទាបវិញក៏បាន វិធីនេះព្រះចៅដែនដីក្រុងរោមទ្រង់នាំយកទៅប្រើ ដូចមានសំដែងក្នុងប្រវត្តិសាស្ត្ររបស់ក្រុងរោមនោះស្រាប់ ។

ការប្រជុំនៃពួករាស្ត្រ– តាំងអំពីលទ្ធិរបស់សូឡុងជាទីនិយមប្រើក្នុងស្រុកអាថែន្សហើយ ការគ្រប់គ្រងស្រុកអាថែន្សមានលក្ខណៈជាប្រជាធិបតេយ្យសុទ្ធ ។ មានទីប្រជុំធំនៅកណ្តាលជំនុំមហាជន ទីប្រជុំជាអ្នករើសសមាជិកឬអ្នកដំណាងរាស្ត្រ មានចំនួន ៤០០ នាក់ ឬសេនាត៍ (សភាដំណាងរាស្ត្រ) ពួកនេះជាអ្នកព្រាងច្បាប់ ឬស្នើយោបល់ដែលខ្លួនត្រូវការនឹងធ្វើជាច្បាប់ ហើយនាំចេញទៅបោះឆ្នោតក្នុងជំនុំរាស្ត្រម្តងទៀត ។ ពួកសមាជិកអស់នេះ កាលដល់កំណត់តោងចេញចាកដំណែងនាទីជាសមាជិក តែនៅមានអំណាចទទួលនាទីធ្វើជាចៅក្រមកាត់ក្តីបាន ។

អំពីកេរ្តិ៍កម្ម— តាំងអំពីសូទ្យុងបានបញ្ញត្តច្បាប់ឲ្យចែកទឹកដីដល់បណ្ដារាស្ត្រហើយ ការធ្វើស្រែចំការច្បារដំណាំក៏ក្លាយទៅជារបស់ដែលប្រជាជនទៅស្រុកអាថែន្សខំខ្វល់ខ្វាយធ្វើឡើងទៀត ឯការចិញ្ចឹមសត្វនោះមានតិចទើបពួកអាថែន្សមានសត្វចិញ្ចឹមតិច ទើបមានច្បាប់ហាមប្រាមមិនឲ្យសម្លាប់សត្វពាហនៈនឹងកូនចៀម-ពពែ ឯសេះនោះកាន់តែកម្រណាស់ទៅទៀត បើអ្នកណាមានសេះ គេរាប់ថាជាអ្នកមានទ្រព្យស្ដុកស្ដម្ភ ហើយរាប់ចូលក្នុងវណ្ណៈទី ២ នៃវណ្ណៈទាំង ៤ ដែលពោលមកហើយខាងលើនេះ ។

( នៅមានត )

# ទំនៀមទម្លាប់និងរឿងព្រេងនៅស្រុកខ្មែរ

## អំពីអ្នកតា ឃ្លាំងមឿង

តាមទំនៀមទម្លាប់ នៅក្នុងខែត្រពោធិ៍សាត់នៃក្រុងកម្ពុជា គេតែងធ្វើបុណ្យឡើងអ្នកតារ ហៅថា អ្នកតាឃ្លាំងមឿង ជារៀងកបងកបមក តាំងអំពីអតីតកាល ដ្បិតអ្នកតានេះជាអ្នករក្សាស្រុក អ្នករក្សាសន្តិភាព ជាអ្នកបង្អុរភ្លៀងឲ្យបានចំរើនផលព្រះធរណី ។

នៅក្នុងតំបន់ខែត្រពោធិ៍សាត់ ដែលជាចន្លោះទន្លេសាបនឹងជង់ភ្នំជាច្រើន ពួកខ្មាំងដែលលុកលុយចូលស្រុកក្នុងសតវត្សរ៍មុនៗនេះ បានទុកដានស្នាមគំនូសយ៉ាងជាក់ច្បាស់នៅតំបន់នោះ ។ ចាស់សព្វថ្ងៃនេះ កាលដែលខ្លួននៅក្មេង បានឮចាស់ៗជាន់ដើមដំណាល អំពីសេចក្តីទុក្ខលំបាកវេទនាក្នុងស្រុក ក្នុងពេលដែលពួកខ្មាំងសត្រូវពីក្រៅចូលមកលុក-លុយទន្ទ្រានក្នុងស្រុកម្តងៗ ។ រឿងអ្នកតាឃ្លាំងមឿងនេះ ជារឿងព្រេងចាស់យូរអង្វែងមកហើយ ប៉ុន្តែនៅតែសំដែងឲ្យឃើញការប្រែប្រួលផ្សេងៗ ក្នុងពេលមានសឹកសង្គ្រាម ។ រឿងនេះរដាច់រដោចប្រឡូកប្រ-ឡំ ពិបាកនឹងរៀបប្រមូលឲ្យបានស្រួល ប៉ុន្តែតាមដែលគេដំណាលតៗមកដូចមានខាងក្រោមនេះ

គេដំណាលថា: ក្នុងសតវត្សរ៍ទី ១៦ កាលដែលពួកខ្មាំងវាយយកក្រុងលង្វែក ពួកនេះបានធ្វើដំណើរលុកចូលមកពីទិសខាងត្បូង វាយគ្នាពាសពេញក្នុងខែត្រពោធិ៍សាត់ ធ្វើទុក្ខធ្វើបាបអ្នកស្រុកច្រើនកន្លែង ។ ពួកខ្មែរមានចិត្តក្លាហានទំទប់ទល់ខ្មាំងសត្រូវខ្លាំងណាស់ដែរ ប៉ុន្តែទប់មិនឈ្នះ ប្រជាជនក្នុងស្រុកដែលពួកខ្មាំងរឹបជាន់ដុតផ្ទះសំបែង ដុតវត្តអារាម ចេះផ្សែងងងឹតទាំងផ្ទៃមេឃ ក៏នាំគ្នារត់ប៉ាត់ប៉ាយ ។ ពេលដែលក្នុងស្រុកមានទុក្ខវេទនាយ៉ាងដូច្នេះ មានចៅហ្វាយស្រុកម្នាក់ដែលពង្សាវតារមិនបានកត់ឈ្មោះទុក ក៏ស៊ូប្តូរជីវិតជួយស្រុកទេស ដោះទុក្ខវេទនារបស់មនុស្សរួមជាតិជាមួយគ្នា ។ បើតាមធម្មតា គេយល់ថា មនុស្សលោកដែលមានភ័យម្តងៗ ត្រូវតែយកជីវិតណាមួយទៅបូជាអារក្សអ្នកតាដែលខឹងសំបារនឹងយើងនោះ ទើបបានសេចក្តីសុខស្ងប់ ។

តាមរឿងនេះមានដំណាលថា មានថ្ងៃមួយក្នុងរដូវប្រាំង ពេលដែលព្រះអាទិត្យជ្រៀងជ្រែ ចៅហ្វាយស្រុកនោះ ក៏បង្គាប់ឲ្យគេជីករណ្តៅខ្ទប ១ យ៉ាងធំហួសធម្មតា រួចចៅហ្វាយស្រុកនោះ ក៏បណ្តើរគ្នាទាំងពីរនាក់ប្តីប្រពន្ធ ស្លៀកពាក់សំពត់អាវពេញយស ចុះទៅក្នុងរណ្តៅនោះ គួរឲ្យអស្ចារ្យណាស់ ហើយក៏អង្គុយស្ងៀមទឹកផ្សងជារួចស្រេច ក៏ដេកព្រមគ្នាទាំងពីរនាក់នៅលើដីត្រជាក់នៅបាតរណ្តៅនោះ រួចបង្គាប់ឲ្យពពួកអ្នកដែលនៅជិតខាងនោះលុបរណ្តៅ តាំងពីពេលរសៀលជិត

ព្រលប់ហូតដល់យប់ អុជចន្លុះនាំគ្នាលុបតទៅទៀតទើបហើយស្រេច ។ ក្នុងពេលនោះ គង់សឹកណាន់ព្រួស្បូកង់ពេញយ៉ាងអាណោចអាធម្ម ។

បុរសស្ត្រីទាំងពីរនាក់ ដែលស៊ូប្តូរជីវិតដោយមានចិត្តស្រឡាញ់ស្រុកទេសទឹកដីជនរួមជាតិនោះក៏សន្មតថា ខ្ញុំស្លាប់ទៅនេះ ព្រលឹងខ្ញុំទាំងពីរនាក់ទៅជួបគ្នានៅស្ថានលោកនាយ ហើយនឹងអង្វរទៅដល់អ្នកតាសូមឲ្យប្រកាសប្រាប់ដល់ខ្មោចបិសាចដែលមានឫទ្ធិអានុភាពទាំងប៉ុន្មានឲ្យត្រឡប់មកក្នុងលោកនេះវិញមុន ១ អាទិត្យ ដើម្បីមកធ្វើទណ្ឌកម្មសម្លាប់ពួកខ្មាំងសត្រូវឲ្យបានយ៉ាងច្រើន ។

លុះ ៨ ថ្ងៃតមក ក្នុងពេលដែលទុក្ខវេទនាមកគ្របសង្កត់ជាពន្ទឹក ក៏ស្រាប់តែព្យុះសំឡេងមួយយ៉ាងប្លែក ស្រែកឡើងក្នុងវេលាព្រឹក ពិតដូចពាក្យសន្មតរបស់ខ្មោចចៅហ្វាយស្រុកនោះ ។ ឯសូរសព្ទដូចជាសត្វទទះស្លាបហើរយ៉ាងច្រើន ដោយមានប្រផ្លូលនេះ អ្នកស្រុកក៏មានសេចក្តីរីករាយដោយដឹងថា អ្នកតានាំខ្មោចបិសាចមកជួយសង្គ្រោះយើង ដែលមានជីវិតរស់នៅនេះហើយ ។ ក្រោយពីនោះបន្តិច ជម្ងឺអាសន្នរោគក៏បណ្តាលកើតឡើងក្នុងកងទ័ពពួកខ្មាំងសត្រូវ ដោយអំណាចមន្តអាគមរបស់អ្នកតានឹងខ្មោចបិសាច ។ ពួកខ្មាំងក៏ដកទ័ពរត់ថយខ្ចាត់ខ្ចាយចេញអំពីស្រុកទៅវិញទាំងអស់ ពួកខ្លះក៏ស្លាប់ដេកដេរដាសពាសពេញទាំងវាល ទៅជាចំណីអាហាររបស់ពួកសត្វត្មាតនឹងសត្វសាហាវ ។

តាមរឿងនេះ យើងឃើញថាពង្សាវតារនឹងរឿងព្រេងប្រឡូកប្រឡំគ្នាណាស់ ៗ បុណ្យឡើងអ្នកតានោះ គេធ្លាប់តែធ្វើនៅកលស្រែដែលហៅថា បន្ទាយជ័យ ជាទីរឭកដល់ជ័យជំនះរបស់អ្នកតានឹងពួកខ្មោច កំពែងបន្ទាយនោះប្រហែលជាធ្វើដោយដី ៗ ទំហំបន្ទាយនោះ តាមគេក ៗ មិនតូចជាង ២.០០០ ម៉ែត្រក្នុងមួយជ្រុងៗ គេមើលទៅនៅឃើញន្លួងទំនាបខ្លះ ដែលជាកន្លែងដែលគេយកដីមកធ្វើបន្ទាយនោះ ប្រសិនបើគេរុកចូលទៅក្នុងព្រៃទៀត ប្រហែលជានឹងឃើញនៅសល់គ្រឿងដំ-ណាលនៃកំពែងទុះខ្លះ ឯទីបន្ទាយនេះទៀតក៏មិនឆ្ងាយអំពីបន្ទាយជូនអីផលធ្វើដោយថ្មហើយត្រូវពួកខ្មាំងលុកលុយកាយយកកាលពីសម័យនោះ កនៅសល់តែកំទេចបាក់បែកនៃដុំថ្ម ៗ

សព្វថ្ងៃនេះ កន្លែងបន្ទាយចាស់នុះទៅជាដីដំបូកដុះព្រៃអស់ទៅហើយ ឃើញនៅតែខ្ទមស្លឹក ១ ជាគ្រឿងសំគាល់ថានៅទីនេះហើយដែលមានមនុស្សចិត្តល្អបរិច្ចាគជីវិតបូជាអ្នកតានៅក្នុងស្រុកផ្កាលើកក្រោយផ្អស់ ៗ ទីនោះហើយដែលជាលំនៅរបស់អ្នកតាឃ្លាំងមឿង សព្វថ្ងៃនេះនៅមានគេអុជធៀន-ធូបបូជានៅឡើយ ៗ ក្នុងឆ្នាំនេះ ដីដំបូកនោះក៏កាន់តែរីកធំឡើង បើតាមជំនឿរបស់ខ្មែរនឹងចិនគេថាជាប្រផ្នូលល្អ ក្នុងពេលដែលធ្វើបុណ្យឡើងអ្នកតា ពួកជនទៅជួបជុំគ្នាឈរជុំវិញខ្ទមនោះ

ទាំង ៣ ទិស ឯរូបអ្នកតានៅពីខាងកើតធ្វើពិធីសែនបូជា រូបនេះជាមនុស្ស ចាស់ម្នាក់នៅមាំមួនពួកមុខគួរគោរព មិនមែនជាមនុស្សប៉ោឡៃទេ ។ នៅខាងមុខរូបមានម្ហូប ៤ ស្ពក មានក្បាលជ្រូក ១ គូសម្រាប់បូជា លុះរូប នោះសូត្របូជាស្រេច ទើបពពួកជនដែលទៅមើលនៅជុំវិញនោះក៏ជ្រួប ទឹកដែលគេអប់ទៅលើដី រូបមានភ្លើង ១ វង់ប្រគំឡើង ហើយគេដុតក្រ-ដាសមាសក្រដាសប្រាក់បូជាដោយគោរព នៅក្រោមអាសនៈអ្នកតា ។

នៅឆ្ងាយពីនោះបន្តិច មានព្រះសង្ឃ ១ ក្រុមគង់ក្រោមពេងស៊ូក ក៏ក្រោកនិមន្តទៅបៀតខាងកើតដើរជុំវិញជំបូកនោះ រូបសូត្រធម៌ ១ ចប់ ដើម្បីសំដែងឲ្យឃើញថា ពុទ្ធសាសនាក៏មិនយល់ទាស់នឹងការសែន បូជាព្រលឹងដែលគេធ្លាប់បូជាតាំងពីបុរាណកាលមកដរាបមកដល់សព្វ ថ្ងៃនេះ ។

ការដែលលោកសង្ឃសូត្រធម៌នេះ គ្រាន់តែជាកិច្ចបំបែកសែនបូជា អ្នកតានោះទៅជាពីរលើក ដ្បិតតាំងពីនោះមក រូបអ្នកតាក៏ត្រឡប់មក ធ្វើកិច្ចបូជាឡើងវិញ ឯលោកសង្ឃក៏ត្រឡប់ទៅឯពេងរបស់លោកវិញ ដែរ ក្នុងលើកនេះ រូបអ្នកតាក៏ហៅពួកមន្ត្រីមួយក្រុមនៅឃុំជិតទីនោះ ឲ្យ មកពិសាក្រយាជាកិត្តិយសចំពោះអ្នកតា ។ ឯរបៀបពិសានេះ គឺគ្រាន់ តែធ្វើកិច្ចដូចជាពិសាប៉ុណ្ណោះទេ ។

តពីនោះមកមានកិច្ច ១ យ៉ាងប្លែក ដែលជាពិធីរំឭកដល់របៀបបុរាណ គឺមានក្មេងកំលោះ ២ នាក់ តែងខ្លួនពាក់មកុដស្នែងគោបង្គាប់គ្នា ហើយហិចហោះកំរែកជាទំនងច្បាំងគ្នាព្រមជាមួយនឹងក្មេង ១វង់ ក្នុងពេលនោះមានមនុស្សម្នាក់ទៀត ហក់ចូលមក ក៏ត្រូវគោមនុស្សនោះខឹងដេញដល់ដេញបុះ តែមនុស្សនោះមានជ័យជំនះឈ្នះគោព្រៃវិញ ហើយក៏កាត់កសម្លាប់ដោយបង្ដើះ ១ គូប ៗ ឯវិធីកំរែកពាក់ស្នែងនេះ ខ្ញុំធ្លាប់ឃើញតែក្នុងតំបន់ស្រុកពោធិ៍សាត់ប៉ុណ្ណោះ មិនដឹងជាមានគេធ្វើនៅទីដទៃដែរឬគ្មានទេ ៗ មើលទៅវិធីកំរែកនេះជាវិធី ១ ដែលត្រូវធ្វើក្នុងពេលឡើងអ្នកតា ៗ ចុះសព្វថ្ងៃនេះ ម្ដេចក៏គេត្រឡប់ជាកាន់កាំភ្លើងត្រី (កាំភ្លើងរបស់ឃុំ) ហើយយកផាវទៅជុតធ្វើជាស្គរកាំភ្លើងវិញ ? របៀបថ្មីនេះមើលទៅមិនត្រូវទំនងទេ ប្រហែលទំនៀមទម្លាប់នេះបានបាក់ឫសមាំមកជាយូរអង្វែងមកហើយ ដល់មកសព្វថ្ងៃ មុនដែលនឹងបាត់បង់សាបសូន្យទៅនោះ គេក៏នៅត្រូវធ្វើខ្លះដែរ តែធ្វើត្រឹមបន្តិចបន្តួចខុសពីរបៀបចាស់ ក្រៅពីនេះនៅមានការថ្វាយក្របី ១ ទៀតទុកសម្រាប់ប្រើក្នុងការបុណ្យនោះកាលបើត្រូវការប្រើ ៗ

ការពាក់ស្នែងនេះ ប្រហែលជាកេរ្ដិ៍ដំណែលនៃការប្រជល់ក្របីអំពីបុរាណដូចមាននៅស្រុកអណ្ណាមនិងស្រុកព្នងយួននៅសព្វថ្ងៃនេះ ៗ

ក្នុងពេលដែលគេធ្វើពិធីបុណ្យផ្សេងៗនោះ ពួកមនុស្សមកកុះករជួបជុំគ្នាលេងសប្បាយនៅទីនោះ ។ ពួកចិនក៏នាំយកទំនិញកំប៉ុកកំប៉ុកមកដាក់លក់ដេរដាស ។ ស្រីៗនិងកូនក្មេងក៏សើចលេងសប្បាយ ភ្លេងក៏ប្រគំឮសូររងំ ពួកខ្លះដាក់បាត្រលោកសង្ឃដោយសទ្ធាជ្រះថ្លាដែលដាក់ដម្រៀបគ្នាលើដើងម៉ា ៗ ជិតទីនោះមានពួកស្រីៗដាំស្លយ៉ាងប្រញាប់ប្រញាល់ ដ្បិតដល់ពេលប្រគេនចង្ហាន់លោកសង្ឃហើយ ។ ថ្ងៃក៏ចាំងពន្លឺទៅលើថ្លុកទឹកដែលទើបរាំងភ្លៀងថ្មីៗ ស្លឹកឈើត្រូវពន្លឺព្រះអាទិត្យចាំងឆ្លុះភ្លឺផ្លេកមានសណ្ឋានដូចត្បូងពេជ្រ ពពកក៏រសាត់អណ្ដែតនៅលើមេឃ ថ្ងៃនេះហើយដែលជាថ្ងៃក្សេមក្សាន្តរបស់បណ្ដាជន ។ បណ្ដាជនជាតិខ្មែរចេះរក្សាទុកបានយ៉ាងអស្ចារ្យ នូវកិរិយាសមរម្យរបស់ជាតិ និងឫកពាររបស់ខ្លួន ក្នុងពេលក្សេមក្សាន្តរបស់បណ្ដាជននេះ ។

ការធ្វើពិធីបុណ្យអស់នេះ សម្រាប់ជាទីរឭកមួយយ៉ាងធំ ដល់ហេតុគេទដែលកន្លងមកហើយ លុះកាលតៗមកពិធីនេះក៏រៀររោយទៅ តែនៅមានទ្រង់ទ្រាយបុណ្យជាន់ចាស់នោះជាប់មកជាមួយនឹងពិធីខាងលទ្ធិសាសនា ពិធីបុណ្យអស់នេះហើយដែលកកើតមកហើយជាវេលាច្រើនសតវត្សរ៍នៅកណ្ដាលព្រៃព្រឹក្សាដ៏ស្ដុកស្ទុកស្ទាញបិទបាំងប្រទេសខ្មែរ ។

# រឿងព្រេងខ្មែរ — រឿងអាឡេវ ( ទី ២ )

របស់អ្នកឧកញ៉ាប្រាជ្ញាធិបតី យិន ចាងហ្វាងក្រុមព្រះរាជនិពន្ធ

គ្រានេះនឹងពណ៌នាអំពីរឿងបរម្បរាជារឿងបុរាណដែលមាននិយាយតៗគ្នាមកថា មានបុរសម្នាក់ឈ្មោះអ្នកនេះ ប្រពន្ធឈ្មោះនាងនោះ មានកូនប្រុសម្នាក់ឈ្មោះអាឡេវ ឯកូននោះលុះធំឡើងអាយុ ៧ ឆ្នាំ ជាក្មេងមានប្រាជ្ញា ដឹងថាម្ដាយឪពុកល្ងង់ មិនចេះធ្វើការរកស៊ី ជាអ្នកក្រពិបាក ក៏និយាយនឹងម្ដាយឪពុកថា ម៉ែអើយឪអើយ ឥឡូវនេះយើងគ្មានចេះធ្វើការរកស៊ីអ្វីនឹងគេបានជាយើងក្រ បើដូច្នេះខែវស្សាយើងធ្វើស្រែ ខែប្រាំងយើងទៅធ្វើចំការ ឯខ្ញុំទៅធ្វើស្រែជាមួយនឹងឪឯង បើយើងអត់ស្លាម្លូអង្ករម្ហូបចំណីអ្វី សូមខ្ញុំមកយកពីផ្ទះនេះទៅស៊ីៗ អាឡេវនឹងឪពុកម្ដាយគិតគ្នាព្រមហើយ ក៏រៀបប្រដាប់ប្រដាឡើងទៅធ្វើស្រែ លុះទៅនៅស្រែយូរ អាឡេវនឹកចង់ស៊ីនំហើយក៏គិតថា បើដូច្នេះអញនឹងបញ្ឆោតម៉ែឪអញយកនំស៊ី គិតហើយប្រាប់ឪក៏ថា ឪៗខ្ញុំទៅផ្ទះយកស្លាម្លូមកស៊ី ឯឪពុកក៏ឲ្យកូនទៅផ្ទះ អាឡេវដើរទៅដល់កណ្ដាលផ្លូវ បានឃើញវត្តលោកសង្ឃ ក៏ចូលទៅថ្វាយបង្គំរកលោកគោរសក់ឲ្យ លុះគោររួចហើយក្រាបថ្វាយបង្គំលាលោកទៅ លុះទៅដល់ជិតផ្ទះ អាឡេវយកសំពត់ទទូរក្បាលហើយធ្វើជាយំចូលទៅក្នុងផ្ទះ ឯម្ដាយឃើញ

កូនយំដូច្នោះ ក៏សួរទៅកូនថាចុំក៏កូនយំ អាឡេវធ្វើជាយំខ្លាំងឡើងទៀត ឯម្ដាយឃើញកូនរឹតតែយំខ្លាំងឡើងដូច្នោះ ក៏ស្ទុះទៅឱបហើយបើកសំពត់អំពីក្បាលកូនចេញ ឃើញក្បាលគោររលីងរឹតតែសង្ស័យហើយសួរទៀតថា ហេតុអ្វីក៏បានជាគោរសក់ហើយយំដូច្នេះ អាឡេវប្រាប់ទៅម្ដាយថា ឪគាត់ស្លាប់ទៅហើយ នាងនោះលុះឮកូនថាដូច្នោះ ក៏គក់ទ្រូងស្រែកថ្ងូញយំស្រណោះអាឡោះអាល័យរៀបរាប់ពីកាលចាប់ដៃបានគ្នាជាប្ដីប្រពន្ធរៀងដរាបមក ឯអាឡេវឃើញម្ដាយយំសស្រែងសង្រែងដូច្នោះ ក៏អង្វរលួងលោមម្ដាយថា អ្នកម៉ែអើយ កុំអ្នកយំ បើអ្នកចេះតែយំ តើធ្វើដូចម្ដេចនឹងបានធ្វើបុណ្យឲ្យទានបញ្ជូនទៅឲ្យឪ ឯនាងនោះជាម្ដាយឮអាឡេវជាកូនអង្វរឃាត់មិនឲ្យយំហើយ សួរទៅអាឡេវថា បានរៀបបញ្ចុះខ្មោចឪឯងរួចហើយឬនៅ អាឡេវប្រាប់ម្ដាយថា ខ្ញុំបានពឹងអ្នកស្រុកឲ្យគេជួយរៀបបញ្ចុះខ្មោចឪរួចល្អល្អាច់ហើយ នាងនោះឮកូនថាដូច្នោះ ក៏ម្នីម្នារៀបធ្វើនំអន្សមនំគមចំណីចំណុកហើយនិយាយនឹងអាឡេវថា កូនអើយ ឯងយកចំណីនំនេះទៅធ្វើបុណ្យឲ្យឪឯងចុះ អញមិនទៅទេ បើអញទៅឃើញស្រែដែលឪឯងធ្វើនឹងកន្លែងដែលឪឯងនៅនឹងផ្នូរខ្មោចឪឯងនោះ ម្ដាយរឹងជាកើតទុក្ខច្រើនឡើងទៀត បើដូច្នេះឯងទៅចុះ អាឡេវឮម្ដាយថាដូច្នោះ ក៏នឹកអរក្នុងចិត្តណាស់ ដ្បិតត្រូវនឹងគំនិតខ្លួនដែលកុហកម្ដាយនោះ ហើយក៏ម្នីម្នារៀបស្រែកយកនំ

ដាក់សារ៉ែនក្នុងស្រែបក៏រែកទៅ លុះទៅដល់ពាក់កណ្ដាលផ្លូវ ដាក់អម្រែកពីលើស្មាហើយអង្គុយស៊ីនំនឹងចំណីចំណុកលុះត្រាតែឆ្អែត ហើយទៅសល់ខ្លះ អាឡេវរៀបទុកយកទៅផ្ញើឪពុក លុះទៅដល់ជិតខ្ទមឪពុកៗធ្វើជាយំទៀត ឯអ្នកនេះជាឪពុកឃើញកូនយំហើយឃើញសក់ទើបនឹងកោរថ្មីៗ ដូច្នោះក៏សួរទៅថា កូនអើយថ្វីក៏ឯងយំហើយកោរទាំងសក់ក្បាលដូច្នេះ អាឡេវប្រាប់ទៅឪពុកថា ឪអើយ ឥឡូវនេះម៉ែគាត់ស្លាប់ទៅហើយបានជាខ្ញុំកោរសក់ អស់បងប្អូនគេរៀបធ្វើបុណ្យឲ្យម៉ែ បានជាមានទាំងនំ ឥឡូវនេះខ្ញុំយកមកផ្ញើឪឯងពិសា ឯឪពុកជាមនុស្សឆោតល្ងង់ណាស់ ឮកូនប្រាប់ដូច្នោះក៏យំនឹកអាណិតប្រពន្ធ ហើយនិយាយនឹងអាឡេវថា កូនអើយ អំពីថ្ងៃនេះទៅឪពុកលែងទៅទន្លេនោះទៀតហើយ ឯអាឡេវឮថាឪពុកលែងទៅស្រុកដូច្នោះ ក៏នឹកអរក្នុងចិត្តថាត្រូវនឹងគំនិតខ្លួនគិត ៗ

លុះយូរបន្តិចទៅ អាឡេវនិយាយនឹងអ្នកនេះជាឪពុកថា ឪអើយ ឥឡូវនេះឪនៅតែពីរនាក់នឹងខ្ញុំដូចសព្វថ្ងៃនេះពិបាកណាស់ គ្មានអ្នកណានឹងដណ្ដាំបាយស៊ី គ្មានអ្នកណាដេរសំពត់អាវស្លៀកដណ្ដប់ បើដូច្នោះឪឯងរកដណ្ដឹងប្រពន្ធយកមកគ្រាន់នឹងដាំបាយដងទឹកបុកស្រូវ ទើបយើងមិនសូវនឿយហត់ដូចសព្វថ្ងៃពេកទេ ៗ (នៅមានត)

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

ឆ្នាំគំរប់ ១៣

ភាគទី ២

ភ្នំពេញ

ការផ្សាយរបស់ព្រះរាជបណ្ណាល័យ

ព.ស ២៤៨៣

គ.ស. ១៩៤១

៧:០៩

ព្រះរាជបណ្ណាល័យកម្ពុជា

# KAMBUJASURIYÂ

# កម្ពុជសុរិយា

ជាទស្សនាវដ្ដីចេញផ្សាយពីព្រះរាជបណ្ណាល័យ មួយខែពីរក្បាល

## ឆ្នាំគំរប់ ១៣

ភាគទី ២

គណៈរដ្ឋមន្ត្រីនិងសម្ដេចសង្ឃនាយកទាំងពីរគណៈ

បានអនុញ្ញាតហើយ

ភ្នំពេញ

ការផ្សាយរបស់ព្រះរាជបណ្ណាល័យ

ព.ស ២៤៨៣

គ.ស. ១៩៤០

# បញ្ជីរឿង


១ — ភិតាប្រិស្រ័យរបស់លោកអងដ្រេ-ស្វរម៉ែរ . . . . . . . . . . . . . . ៣

២ — កថាមុខ នៃវេយ្យាករណ៍សំស្ក្រឹតភាគទី ២ (តមកនឹងចប់) . . . . . . . ៧

៣ — ច្បាប់សុភាសិត របស់លោកអ្នកឧកញ៉ាវង្សាសារពេជ្ញ នង (តមក) . . . . ២៣

៤ — ពង្សាវតារក្រិក ស្រង់ បកអំពីគោលបារាំងផ្សេងៗ ក្នុងពង្សាវតារលោក (តមក) ២៧

៥ — និទានរឿងព្រេងខ្មែរ "អាល្មេវទី ២" របស់អ្នកឧកញ៉ាប្រាជ្ញាធិបតី យិន
ជាងហ្វាងក្រុមព្រះរាជនិពន្ធ (តមក) . . . . . . . . . . . . . . . . . ៣២


## រូបក្រៅរឿង


ជាគង — នេះរូបផ្ដាំក្រោមនៃរឿងទី ៥ . . . . . . . . . . . . . . . . ១

# TABLE DES MATIÈRES


Pages

1° Causerie pour les émissions de Radio-Saïgon en langue cambodgienne et thailandaise par André Surmer.......... 3

2° Introduction au volume II de la GRAMMAIRE SANSCRITE (suite et fin).......... 7

3° Chbab SUBHASIT (Poème Khmèr) par Oknhā VONGSASĀRAPÉCH (NONG).......... 23

4° Histoire de la Grèce, extraits de divers documents de l'Histoire Universelle (suite).......... 27

5° Conte populaire cambodgien inédit :

"Légende de ALÉV II" par Oknhā PRACHNHĀTHIBADEY YIN (suite).......... 32

HORS TEXTES :

Bakông — 5e étage de l'intérieur.......... 1



នេះរូបយក្ខនៅថ្នាក់ទី ៥ ប្រាសាទបាគង

# កថាប្រស្រ័យ

### របស់លោកអ៊ុងជ្រិ-ស្លូម៉ែរ

### ធ្វើដើម្បីនឹងផ្សាយតាមវិទ្យុព្រៃនគរ

### ជាភាសាខ្មែរនិងភាសាថៃ

មានវិទ្យុតាំងប្រទេសខ្លះផ្សាយបន្តិសបន្តួចរាល់តែថ្ងៃ ។ អំពីគំនិតជាគោលដើមប្រកបដោយមេត្រីចិត្តដល់មនុស្សផងគ្នារបស់បារាំងសែសនៅក្នុងប្រទេសកជនានាទីក្នុងស្រុកនេះ ។

ប៉ុន្តែបើនឹងពិនិត្យការងាររបស់មន្ត្រីបារាំងសែសក្នុងប្រទេសឥណ្ឌូ-ស៊ិន ដែលយកចិត្តទុកដាក់ខំធ្វើការយ៉ាងអស់ពីចិត្ត ដោយឥតមានស្វែងរកផលប្រយោជន៍ផ្ទាល់ខ្លួនសោះនោះ នឹងអាចឃើញបានដោយងាយ ។

សូមអស់លោកចាំស្តាប់រឿងតូចមួយ ដែលមានខាងក្រោមនេះ ដែលខ្ញុំបានដឹងបានឃើញជាពិតប្រាកដ ។

ក្នុងរដូវភ្លៀង ឆ្នាំ ១៩៣១ កូនប្រុសរបស់លោកទេសាមណ្ឌលខត្តរជានីនៅប្រទេសថៃឡង់ដ៏ខាងទិសឦសាន មានជម្ងឺឈឺក្នុងចៈទ្វារ ខ្លួនទឹងលោក្បាល ពួកគ្រូពេទ្យនៅអាក់ខែងខំព្យាយាមរក្សារោគនោះយ៉ាងអស់ពីចិត្ត លុះត្រាតែឃើញថាជម្ងឺនោះកាន់តែចំរើនខ្លាំងឡើង ស្ទើងតែអស់សង្ឃឹមទៅហើយ ក៏នាំគ្នាទៅរកលោកបាងហ្វាងពេទ្យបារាំងនៅមន្ទីរពេទ្យវៀងចន្ទន៍ឲ្យមកជួយពិនិត្យជួយបំភ្លឺផង ។ លោកបាងហ្វាង

ពេទ្យនេះជាគ្រូពេទ្យដ៏សំខាន់ ធ្លាប់មានកេរ្តិ៍ឈ្មោះ សព្វថ្ងៃនេះលោកបានធ្វើជាគ្រូបង្រៀននៅមហាវិទ្យាល័យពេទ្យក្រុងហាណូយ ។ នៅពេលដែលដំណឹងពីម៉ាក់ខែងមកដល់វៀងចន្ទន៍នោះ លោកគ្រូពេទ្យបាកំងកំពុងតែរៀបចំនឹងទទួលទានបាយល្ងាចនៅផ្ទះពួកមិត្តរបស់លោក គេបានទាំងលើកសម្លមកជូនរួចស្រេចទៅហើយផង ។ ក្នុងពេលនោះលោកគ្រូពេទ្យលះបង់អាហារភោជន ស្ទុះឡើងរថយន្តទៅទាំងពោះទទេ ដើម្បីនឹងទៅឃើញក្មេងជម្ងឺនោះឲ្យបានយ៉ាងប្រញាប់បំផុត ពេលដែលចេញដំណើរទៅនោះជាវេលាម៉ោង ៨ យប់ទៅហើយ ចម្ងាយផ្លូវគោកទៀតក៏តោងជិះរថយន្តជាវេលា ៣ ម៉ោងទើបដល់ ។

នៅទីនោះលោកគ្រូពេទ្យនៅជាមួយនឹងក្មេងជម្ងឺជាវេលា ៣ ម៉ោង ពិនិត្យទៅឃើញថាហួសកំណត់នឹងជួយសង្គ្រោះបាន តែទុកជាដូច្នោះក៏ដោយ លោកក៏បានណែនាំវិធីរក្សាប្រាប់គ្រូពេទ្យថៃឡង់ដេស៍ផងគ្នាឲ្យព្យាបាលតទៅ ។ នៅក្នុងវេលាយប់នោះលោកក៏ត្រូវតែធ្វើដំណើរត្រឡប់វិលមកវៀងចន្ទន៍វិញតាមផ្លូវរថយន្តដដែល ដោយនឿយហត់ពន់ពេក ដ្បិតនៅមន្ទីរពេទ្យក្រុងវៀងចន្ទន៍ ពួកអ្នកជម្ងឺទាំងអម្បាលម៉ានក៏ទន្ទឹងចាំតែលោកមកព្យាបាលពួកគេឲ្យដែរ ។ មួយវិញទៀតលោកមិនអាចនឹងធ្វើដំណើរទៅណាចោលមន្ទីរពេទ្យការរបស់លោកដល់ ១ ថ្ងៃបានឡើយ ។

ព្រឹកឡើងម៉ោង ៨ លោកក៏ទៅធ្វើការនៅមន្ទីរពេទ្យរៀងបន្ទាន់ដូចសព្វដង ឥតនឹកនាដល់ការនឿយហត់សោះឡើយ ។

លោកគ្រូពេទ្យនេះខំខ្នះខ្នែងតែទៅជួយសង្គ្រោះអ្នកជម្ងឺជាតិដទៃ ឥតមានការបង្ខំចិត្តសោះឡើយ មានត្រឹមតែសេចក្តីមេត្តាដល់មនុស្ស-លោកផងគ្នាប៉ុណ្ណោះ ទាំងសគុណជាលុយកាក់ប្រាក់កាសសោតទៀត លោកក៏ឥតទទួលយកបន្តិចបន្តួចឡើយ ។ ការដែលលោកធ្វើនេះគឺធ្វើដោយសេចក្តីរាប់អាន តាមផ្លូវភាតរភាព តាមផ្លូវមេត្តាចិត្តដ៏ពិតប្រាកដប៉ុណ្ណោះ ឥតស្គាល់ថាជាជាតិណាសាសន៍ណាទេ ។ កិច្ចការនេះបង្ហាញឲ្យយើងឃើញថា នានាប្រទេសនិងប្រជាជននៃប្រទេសទាំងនោះ អាចនឹងធ្វើការសម្រួលរកសេចក្តីសុខដល់គ្នានិងគ្នាបានជាដរាប គឺថាយើងមិនបាច់ទៅរករឿងបង្ខូចបង្កាច់គ្នាទេ គ្រាន់តែធ្វើកិច្ចជាអ្នកនៅជិតខាងបេះជួយទុក្ខធុរៈដល់គ្នានិងគ្នាប៉ុណ្ណោះបានហើយ ។

ប្រទេសថៃឡង់ទ៍និងប្រទេសឥណ្ឌូសុីន ធ្លាប់បានសេចក្តីសុខជាយូរអង្វែងឆ្នាំមកហើយ នៅត្រង់ប្រទល់ទាំងសងខាង មន្ត្រីរបស់ប្រទេសទាំងពីរនេះគិតតែធ្វើការចិញ្ចឹមជីវិតដោយមានមេត្រីចិត្តទាំងសងខាងជាដរាប ។ ឯការជាផលប្រយោជន៍ចំពោះអាណាប្រជាជនទាំងសងខាងសោតទៀតក៏បានរៀបចំបានស្រួលដល់គ្នានិងគ្នាជាដរាប ។ ចំណែកខាងប្រទេសថៃឡង់ទ៍ ពួកអ្នករាជការក៏ធ្លាប់តែពិគ្រោះសួរដល់ពួកអ្នក

ធ្វើការដូចគ្នាជាជាតិបារាំងសែស អំពីវិទ្យាសាស្ត្រឬការផ្សេង ៗ ដូចជាការ ១ ដែលយើងសាសព្វមកខាងលើនេះ ។ មន្ត្រីថៃសោតទៀតក៏យល់ជាក់ច្បាស់អំពីការតាប់ប្រសើរនៃរបៀបរៀបចំការពារការរដ្ឋបាលរបស់បារាំងសែស ព្រមទាំងវិទ្យាសាស្ត្របារាំងសែស និងការប៉ិនប៉ៅប្រសប់របស់គ្រូពេទ្យបារាំង ។ គ្មានការផ្សាយណាមួយអាចនឹងមករំលុបរំលាងកិច្ចការទាំងអម្បាលម៉ានដែលគេធ្លាប់ដឹងធ្លាប់ឮជាពិតប្រាកដដូចមានខាងលើនេះបានឡើយ ។

ប្រទេសឥណ្ឌូស៊ីនឥតត្រូវការសុំអ្វីអំពីអ្នកណាសោះឡើយ ឥណ្ឌូស៊ីនមានបំណងត្រឹមតែធ្វើស្ពានមេត្រីឲ្យបានយ៉ាងស្រួលបំផុតរវាងប្រទេសជិតខាងព្រមទាំងរក្សាទុកសន្តិភាព ប្រសាសនោបាយរបស់ឥណ្ឌូស៊ីនសោតទៀត ក៏ឥតមានប្រែប្រួលសោះឡើយ ប្រសិនបើមានរឿងចម្រូងចម្រាសកើតឡើងបាននោះ គឺរឿងទាំងនោះមិនមែនកើតឡើងដោយអំពើរបស់ប្រទេសឥណ្ឌូស៊ីននុ៎ះឡើយ ។

កាថាមុខ

នៃវេយ្យាករណ៍សំស្ក្រឹត ភាគទី ២

(តនឹងចប់)

សូមឧទ្ទិសបំពោះលោក ល្វី-ហ្វីណូត៍ ដែលអនិច្ចកម្មទៅ
ដោយសេចក្ដីគោរព

គម្ពីរអវទានឝតកៈនេះជាគម្ពីរមួយមានប្រយោជន៍សំខាន់ក្នុងចំណោមគម្ពីរពួកនេះ ហើយជាផ្នែកគម្ពីរសក្តិសិទ្ធនិកាយសព៌ាស្តិវាទិនផង ។ គម្ពីរនេះគេបានតែងរាវ ព. ស. ៦៤៣, គម្ពីរនេះឥតមានថ្វីដៃមហាយានទេ ហើយរឿងខ្លះគួរឲ្យមានសេចក្តីជ្រះថ្លា សុទ្ធតែតែងចេញមកពីគម្ពីរអវទានបាលីទាំងអស់ ។ មានគម្ពីរមួយទៀតដូចគ្នានឹងអវទានដែរ ឈ្មោះកម៌ឝតក, គោលដើមគម្ពីរនេះជាភាសាសំស្ក្រឹត តែបាត់បង់ទៅហើយ នៅសល់តែសេចក្តីប្រែជាភាសាទីបេតាំង ។

គម្ពីរមួយទៀត ឈ្មោះទិវ្យាវទាន គេបានតែងឡើងក្រោយគេក្នុង ព. ស. ៧៤៣ មានសេចក្តីខាងដើមជាពាក្យសូត្រមន្តមហាយាន, តែមានរឿងច្រើនដែលគួរជ្រះថ្លា គេដកស្រង់ចេញអំពីគម្ពីរផ្សេង ៗ គ្នា ជារឿងឥតតទាក់ទងគ្នា តែរបៀបប្រយោគឆាយ ប្រកបដោយវេយ្យាករណ៍សំស្ក្រឹតត្រឹមត្រូវ, មានគាថាខ្លះ មានរបៀបប្រយោគបែបថ្មី ប្រកបដោយបទពៃរ៍ ៗ នឹងបាទតិករត្តុកច្រើន ។ សេចក្តីដែលជាន់ចាស់ជាងគេ គេដកមកពីគម្ពីរបាឡី, សេចក្តីខ្លះ ដកពីវិនយបិដកលទ្ធិហីនយាននិកាយមូលសព៌ាស្តិវាទិន ឬដកចេញពីពួកគម្ពីរសំស្ក្រឹត ព្រមទាំងគម្ពីរខ្លះដែលច្បាប់ដើមជាភាសាសំស្ក្រឹតដែលវិនាសបាត់បង់ទៅ, ប៉ុន្តែនៅមានសេចក្តីប្រែជាភាសាចិនឈ្មោះហៅថា "សៀវភៅស្តេចអាសោក" ជាសៀវភៅ

មានរបៀបអក្សរសាស្ត្រយ៉ាងពិសេស ហើយប្រហែលធ្វើត្រាប់តាមកាព្យ ឃ្លោងលោក អត្ថឃោសៈផង ។ រឿងដែលដឹកនាំឲ្យជ្រះថ្លាក្នុងគម្ពីរ ទិ-វ្យាវទានៈ ឈ្មោះ តាទ្វិលគណាវទានៈ, បានប្រែជាភាសាចិនក្នុង ព. ស. ៨០៨, ក៏ជារឿងល្អមួយនៅក្នុងសៀវភៅនោះដែរ ។

ដើម្បីបញ្ចប់សេចក្ដីអធិប្បាយដោយសង្ខេប អំពីអក្សរសាស្ត្រសំស្ក្រឹត លទ្ធិមហាយាន, យើងគួរលើកគម្ពីរសំខាន់មួយទៀតឈ្មោះ អវទានកល្ប-លតា, មានសេចក្ដីប្រែជាភាសាទីបេតាំង ជាថ្មីដែលអ្នកប្រាជ្ញកវីគ្រហស្ថ ឈ្មោះ ក្សេមេន្ទ្រ, តែងក្នុង ព. ស. ១៥៩៥ ។ គម្ពីរនេះមាននិទាន ១០៧ សុទ្ធតែជារឿងល្អៗ ក្នុងផ្លូវរឿងនេះមាននិទាន ១០៨ ទៀត ប្រព័ន្ធដោយ កូនអ្នកកវីនោះឈ្មោះ សោមេន្ទ្រៈ ដែលមានប្រាជ្ញាមិនស្មើនឹងបិតាទេ, ឯទំនង ប្រយោគរបស់បិតាគេសោតទៀតក៏មិនជាពិសេសប៉ុន្មានដែរ ។ រឿងក៏ពី ព្រះពុទ្ធសាសនាដែលមានក្នុងគម្ពីរនោះ ជាទីពេញចិត្តពួកអ្នកប្រទេស ទីបេតច្រើនណាស់ ។ អ្នកប្រព័ន្ធបានរើសយកតែនិទានជាន់ចាស់ ដក ចេញពីគម្ពីរជាច្រើន ដែលមានផ្លូវរឿងសុទ្ធតែនាំឲ្យមានសទ្ធា ។

លទ្ធិមហាយាន គ្មានគម្ពីរបិដកមួយបែបទេ, តែគេមានព្រះធម៌៩ ពួក ឬគម្ពីរសាសនាដែលគេបានតែងឡើងក្នុងសម័យផ្សេងៗគ្នា ដោយ និកាយផ្សេងៗគ្នា ឈ្មោះហៅថា វៃបុល្យសូត្រ ។ គេនៅគោរពគម្ពីរ

អស់នោះដល់មកសម័យសព្វថ្ងៃនេះ នៅប្រទេសនេប៉ាល, ដូចមានបញ្ជី
កយឈ្មោះខាងក្រោមនេះគឺ:

អដ្ឋសាហស្រិកា

ប្រាជ្ញាបារមិតា

សទ្ធម្មបុណ្ឌរិកា

លលិតវិស្តរ

គណ្ឌវ្យូហ

តថាគតគុហ្យក

សមាធិរាជ

ទាឝភូមីឝ្វរ

គម្ពីរដែលសំខាន់ជាងគេក្នុងក្រុមនេះ គឺគម្ពីរសទ្ធម្មបុណ្ឌរិកា ឬ ផ្កាឈូកគឺព្រះសទ្ធម៌ ៗ សេចក្ដីជាន់ចាស់ជាងគេ មាននៅនឹងគាថាខ្លះ ដែលគេតែងក្នុងសម័យ ព.ស. ៧៤៣ ឡើងទៅ ៗ មានការបន្ថែមជាថ្មី សម័យឥឡូវនេះ, ជាហេតុនាំឲ្យសៀវភៅនេះមានសេចក្ដីវិសេសឡើង ៗ សេចក្ដីបូកក៏គឺព្រះធម៌ សុទ្ធតែតែងតាមសេចក្ដីយល់របស់មហាយាន, មានសេចក្ដីថា ព្រះពុទ្ធមិនមែនជាមនុស្សដែលស្ថិតនៅលើផែនដី ដូចគម្ពីរបាលីនោះទេ គឺជាទេវតាមួយដែលអាស្រ័យនៅស្ថានលើបំផុត

ក៏ក្រលែងជាងទេវតាទាំងឡាយឯទៀត ទ្រង់ប្រកបដោយមេត្តាចំពោះ មនុស្សលោកគ្រប់គ្នា ។ ព្រះពុទ្ធទ្រង់មានព្រះជន្មាយុកប់ទាំងកល្បៗ ហើយទ្រង់មានព្រះជន្មឋិតថេរនៅជានិច្ច ។ ទ្រង់បានបង្កើតគម្ពីរនេះឡើង ដែលបរិបូណ៌ដោយនិទានដឹកនាំឲ្យមានសទ្ធាជាច្រើន, មាននិទានខ្លះល្អខ្លាំងណាស់ ឯការធ្វើវត្តប្រតិបត្តិព្រះសារីរិកធាតុ, រូបគំនូរសាសនា ព្រមទាំងការកសាងព្រះស្តូប ក៏ទ្រង់សរសើរណាស់ដែរ ។ សេចក្តីពិត, អ្នកណាដែលបានបំពេញកុសលធម៌ហើយមានគតិល្អ តែងបានសម្រេចប្រាជ្ញាញាណដ៏ខ្ពង់ខ្ពស់ទីនិមន្តលដ៏ប្រសើរ ។ វត្ថុមួយៗ សុទ្ធតែប្រកាសឲ្យតាំងខ្លួននៅក្រោមបារមីដ៏ខ្ពង់ខ្ពស់នៃពោធិសត្វអវលោកិតេស្វរៈ ជាអ្នកប្រកបដោយមេត្តាដ៏ធំ ដែលទ្រង់អាណិតដល់សព្វសត្វ ដែលស្ត្រីបន់ស្រន់ឲ្យជួយក្នុងពេលដែលមានសេចក្តីភ័យអន្តរាយ ហើយអង្វរករសូមឲ្យទ្រង់ចុះព្រះនេត្រមកមនុស្សលោក ដើម្បីជួយស្រោចស្រង់សត្វ ។

គម្ពីរនេះ គេបានប្រែជាភាសាចិន រាវង ព. ស. ៧៦៦ ។ សេចក្តីប្រែដំបូងបាត់បង់ទៅហើយ, ប៉ុន្តែមានសេចក្តីប្រែឯទៀត ដោយលោកធម៌រក្ស ព. ស. ៨២៩, ដោយលោក កុមារជីវៈ ព. ស. ៩៤៣, ដោយលោក ញាណគុប្តៈ និង ធម៌គុប្តៈ ព. ស. ១១៤៤ ។ លោកអ្នកប្រែពីររូបក្រោយនេះ មានគម្ពីរសទ្ធម្មបុណ្ឌរីកពីរគម្ពីរផ្សេងគ្នា, លោកបាន

ប្រែតាមគម្ពីរទាំងពីរនោះ ។ សព្វថ្ងៃនេះ គម្ពីរនេះគេទុកសម្រាប់សូត្រមន្តរបស់និកាយខ្លះ នៅប្រទេសជប៉ុន ។

មានសូត្រមួយ សុទ្ធតែជាពាក្យប្រកាសឲ្យតាំងខ្លួននៅក្រោមបារមីដ៏ខ្ពង់ខ្ពស់នៃព្រះពោធិសត្វអវលោកិតេស្វរៈ, ព្រោះពោធិសត្វនេះមានបំណងចង់ស្រោចស្រង់សត្តនិករមុននឹងបានត្រាស់ជាព្រះពុទ្ធ ។ សូត្រនេះមានឈ្មោះពីរយ៉ាង មួយឈ្មោះ ការណ្ឌវ្យូហៈ ឬ អវលោកិតេស្វរៈគុណការណ្ឌវ្យូហៈ គឺសេចក្តីអធិប្បាយពយរង់អំពីតម្រាលក្ខណៈពោធិសត្វអវលោកិតេស្វរៈ ។ ការគោរពពោធិសត្វនេះចំរើនរុងរឿងឡើងរវាង ព. ស. ៨៤៣, អ្នកនមស្ការចិនឈ្មោះ ហ្វា-ហៀន ក៏យកកមាទឹងខ្យល់ព្យុះកណ្តាលសមុទ្រក្នុងពេលដែលត្រឡប់ពីប្រទេសឥណ្ឌាវិញ ព. ស. ៩៤២ បានថ្លែងថា លោកបានបន់ស្រន់ពោធិសត្វអវលោកិតេស្វរៈ ដើម្បីឲ្យជួយស្រោចស្រង់លោក ។ រូបគំនូរជាន់ចាស់ដែលមានរូបពោធិសត្វនេះកើតឡើង ព. ស. ៩៤៣ ។ មានសេចក្តីប្រែជាភាសាទីបេតាំង ពីសូត្រការណ្ឌវ្យូហៈ ពី ព. ស. ១១៩៩ បើទុកជាគេមិនដឹងឆ្នាំពិតប្រាកដអំពីការតែងសៀវភៅច្បាប់ដើមនេះ តែគេអាចកំណត់បានជាប្រហែលក្នុងរវាង ព. ស. ៨៤៣ ។

ក្នុង ព. ស. ៦៤៣ គេបានតែងគម្ពីរសំស្ក្រឹតពីរគម្ពីរទៀតឲ្យឈ្មោះដូចគ្នា, មានសេចក្តីផ្សេងគ្នា, គម្ពីរមួយមានសេចក្តីវែង, មួយទៀតមាន

សេចក្ដីទី ។ សេចក្ដីផ្សេងគ្នាទាំងពីរគម្ពីរនេះមានឈ្មោះតែមួយ គឺសុខាវតី-វ្យូហៈ សំដែងពីព្រះពុទ្ធដីកាយ៉ាងពិស្ដារថា បើអ្នកណាបានបំពេញកុសលក្នុងពេលមរណកាលនឹករឭកដល់ព្រះពុទ្ធអមិតាភៈ នឹងបានទៅកើតក្នុងភពសុខាវតី ។ គម្ពីរដែលមិនសូវពិស្ដារសំដែងតែពាក្យមួយ គឺបើបានព្រះនាមព្រះពុទ្ធហើយការនាព្រះនាមក្នុងពេលមរណកាល ក៏អាចឲ្យចូលទៅកើតក្នុងស្ថានសុខាវតីបាន ។

គេបានប្រែគម្ពីរពិស្ដារជាភាសាចិនបាន ១២ គម្ពីរ ។ សេចក្ដីប្រែចាស់ជាងគេប្រែហែលក្នុងរវាង ព.ស. ៧១០; គម្ពីរមិនពិស្ដារលោកកុមារ-ជីវៈបានប្រែជាដំបូងក្នុង ព.ស.៩៤៥; លោកគុណកទ្រៈបានប្រែលើកទីពីរក្នុងព.ស.៩៩៣; លើកទីបីលោកហ៊ាន- ត្សង់បានប្រែក្នុងព.ស.១១៩៣ ។

គម្ពីរប្រាជ្ញាបារមិតាឬប្រាជ្ញាញាណជាន់ខ្ពស់ផុតជាគម្ពីរសំស្រ្កឹតជាន់ចាស់បំផុតជាងគេរបស់ពួកមហាយាន; គម្ពីរនេះមានគោលផ្សេងៗ ប្រ-ហែលគ្នានឹងគម្ពីរបារមី ។ ក្នុង ព.ស. ៧២២ គេបានប្រែគម្ពីរនេះជាភាសាចិន ។ ក្នុងគម្ពីរនេះមានសេចក្ដីនិយាយអំពីបារមីធម៌ ៦ ប្រការ សម្រាប់ពោធិសត្វ ។

គម្ពីរគណ្ឌវ្យូហៈ សំដែងពីធម៌ផ្សេងៗ; និយាយពីសេចក្ដីខ្ពង់ខ្ពស់របស់ពោធិសត្វដែលចង់បានសំរេចជាព្រះពុទ្ធភូមិ ដើម្បីនឹងប្រាប់ផ្លូវសត្វលោក

ឲ្យបានទៅកាន់ស្ថានសួគ៌; សំដែងចិត្តបរិសុទ្ធិរបស់ពោធិសត្វទឹងរក់ស្នាដែលមិនសូវបានចួបប្រទះនឹងព្រះនាមព្រះពុទ្ធ ។ សេចក្តីចុងបញ្ចប់គម្ពីរ មានគាថាដែលទុកដូចជាមន្ត្រខ្ពង់ខ្ពស់ ហើយវិសេសតាមជំនឿអ្នកកាន់ព្រះពុទ្ធសាសនា ហើយគេបានប្រែជាភាសាចិន, ទីពេតាំង ក្នុងរវាង ព.ស. ៨៤៣ ទឹង ១៣៤៣ ។

គម្ពីរទសភូមីឝ្វរៈ ឬភូមិ ១០ ប្រការសំរាប់ឲ្យបានសំរេចជាព្រះពុទ្ធ ក៏ជាគម្ពីរសំខាន់មួយដែលអធិប្បាយអំពីធម៌នោះ ហើយគេបានប្រែជាភាសាចិន ព.ស. ៨៧០ ដោយលោក ធម៌រក្សៈ ។

គម្ពីរលង្កាវតារសូត្រ និយាយពីកាលព្រះពុទ្ធជាម្ចាស់ស្តេចទៅកាន់ទ្វីបលង្កាចួបនឹងយក្សឈ្មោះរាពណ៍ ហើយគេចោទសួរប្រស្នានឹងព្រះអង្គ, សេចក្តីនេះជាឧបាយអ្នកប្រព័ន្ធ ដែលចង់ពន្យល់អំពីលក្ខណវិជ្ជា ដែលសំដែងពីអាការៈធម្មជាតិនៃប្រាជ្ញាញាណថាមានសេចក្តីពិតក្នុងផ្លូវចិត្ត ។ បើតាមទំនងអក្សរសាស្ត្រ មិនមែនជាគម្ពីរថ្លៃថ្នូរណាស់ណាទេ, ព្រោះច្រើនសតវត្សរ៍កន្លងទៅហើយ គេបានកែផ្សេងសេចក្តីជាច្រើនដង, បើគិតទៅតាមពង្សាវតារអធ្យាត្មវិទ្យានៃប្រទេសឥណ្ឌាក្នុង ព.ស. ៨៤៣ មកដល់ ១០៤៣ វិញ ក៏ទៅជាគម្ពីរមួយថ្លៃថ្នូរណាស់ ។ គម្ពីរនេះ, គេបានប្រែជាភាសាចិន ដោយលោកគុណភទ្រៈ ព.ស. ៩៨៦, ដោយលោកពោធិរុចិ ព.ស. ១០៥៦, ដោយលោក ចិក្សានន្ទៈ ព.ស. ១២៤៣ ម្តង ។

មានគម្ពីរអធ្យាត្មវិទ្យាមួយទៀត ជាអក្សរសាស្ត្រមហាយាន មិនជាជាន់ចាស់ប៉ុន្មាន ឈ្មោះ សមាធិរាជ ឬ ស្តេចសមាធិ, ក្នុងគម្ពីរនោះ ព្រះពុទ្ធទ្រង់សំដែងពីធម៌អាថិដែល ព្រះពោធិសត្វនឹងបានសំរេចអនុត្តរសម្មា-ធិញ្ញាណ ដោយការតាំងនៅសមាធិកម្មដ្ឋាន ។

គម្ពីរឈ្មោះកព្រុបាលសូត្រ ព. ស. ១១៤៣ មានរឿងជាតកខ្លះ ៗ ប្រយោជន៍គម្ពីរនេះ គឺការសំដែងបំភ្លឺអំពីសន្តានចិត្តកិច្ចក្នុងសម័យនោះ ដោយមានបរិយាវិឃ្ឃាណាស់ នាំឲ្យអ្នកប្រព័ន្ធគម្ពីរនេះព្យាករថា ព្រះពុទ្ធ-សាសនានឹងអន្តរធានបាត់បង់មិនខាន ។

ទីបំផុត, មានគម្ពីរមួយទៀត មានប្រយោជន៍ខ្លះដែរ ក្នុងពួកគម្ពីរមហាយានជាន់ក្រោយ គឺគម្ពីរឈ្មោះ សុវណ្ណប្រភាស: ឬ ពន្លឺសុវណ្ណ ជាគម្ពីរមានសេចក្តីណាយអធ្យាត្មវិទ្យានឹងសីលធម៌ ហើយល្បីខ្លួទៅក្នុងចំ-ណោមពុទ្ធសាសនិកមហាយាន, គេបានប្រព័ន្ធឡើងរាវ ព. ស. ១០៤៣ ។ គម្ពីរនេះគេបានប្រែជាភាសាចិន ដោយលោក ធម៌ក្សេម: ព. ស. ៩៥៣ មុន, លោក បរមាថ ព. ស. ១០៩៥ មុន, ដោយលោក ឡឺ-ត្សឹង ព. ស. ១២៤៦ មុន ។ មានសៀវភៅឯទៀតជាច្រើនដែលមិនបាច់និយាយក្នុងទីនេះ ព្រោះមានប្រយោជន៍សម្រាប់តែអ្នកដែលចង់ចេះដឹងលទ្ធិមហាយានឲ្យជ្រាលជ្រៅ ។ ប៉ុន្តែគង់មានប្រយោជន៍ខ្លះដែលនិយាយពីមហាបុរសរបស់មហាយាន ។

អ្នកនមស្ការចិនឈ្មោះ ហ៊ាន-ត្សង់ និយាយពីអ្នកប្រព័ន្ធ ៤ រូប ហើយប្រៀបទុកដូចជាព្រះអាទិត្យ ៤ ដួង ដែលបំភ្លឺលោកសន្និវាស គឺ: អស្វឃោសៈ, នាគាជុនៈ, អាយ៌ទេវៈ និង កុមារលាតៈ ។

លោក នាគាជុនៈ ជាជាតិព្រាហ្មណ៍ នៅប្រទេសឥណ្ឌៀខាងត្បូង នៅក្នុងវាង ព. ស. ៧៤៣ ។ លោកជាអ្នកប្រាជ្ញត្រៃវិជ្ជា ហើយចេះចប់វេទទាំង ៤ ។ លោកជាយោគីអាចបំបាំងខ្លួនបាន, ជាអ្នកតាពសាស្ត្រ និងជាគ្រូពេទ្យ ។ ដោយលោកមានអកុសលកម្ម លោកចូលមកបួសជាភិក្ខុប្រាថ្នាឲ្យរួចទោសអំពីសេចក្ដីស្លាប់ (មហន្តទោស) ។ លោកបានបព្វជ្ជាជាភិក្ខុហើយ ៩០ ថ្ងៃ បានចាប់រៀនព្រះត្រៃបិដក តែការរៀនព្រះត្រៃបិដកនេះ នៅមិនទាន់គ្រប់គ្រាន់ទេ ។ លុះកាលលោកទៅជួបនិងព្រះថេរៈមួយអង្គទើបលោកពេញចិត្តនឹងគម្ពីរមហាយាន ។ បំណោតមកលោកជាអ្នកប្រកាសព្រះពុទ្ធសាសនាបែបមហាយានក្នុងប្រទេសលោក ហើយតាំងនិកាយ មាធ្យមកៈ ឬធម៌កណ្ដាលឡើង; លោកបានតែងគម្ពីរដើម្បីពន្យល់ធម៌នោះដែលប្រកបដោយសច្ចៈពីរប្រការ គឺសម្មតិសច្ចៈនិងអរិយសច្ចៈ អរិយសច្ចជាន់ខ្ពស់នេះនឹងបានសំរេចទៅបានក៏ដោយអាស្រ័យសច្ចៈជាខាងដើម ។ លុះកាលណាគេបានសំរេចអរិយសច្ចជាន់ខ្ពស់ហើយ ទើបគេបានសំរេចព្រះនិព្វាន ។ គម្ពីរដែលមានឈ្មោះល្បី

របស់លោកនាគាជុិនៈនោះគឺ មាធ្យមិកការិកា ឬ មាធ្យមិកសូត្រ ។ លោកគៀ-ត្សឹង ពេញចិត្តណាស់នឹងគម្ពីរលោកនាគាជុិនៈមួយឈ្មោះសុហ្ឫល្លេខៈ។ លោកជាអ្នកតែងគម្ពីរអដ្ឋកថាជាច្រើន ។ លោកអាយិទេវៈជានិស្សិតរបស់លោក ហើយធ្វើមរណកាលដោយអ្នកអន្យតិរ្ថិយបន្ទំតាក់សម្លាប់ដោយដាវក្នុងពេលដែលលោកចំរើនធម៌ក្នុងព្រៃ ។ លោក ហ៊ិន-ត្សង់ នឹងលោកគៀ-ត្សឹង ស្ម័គ្រចិត្តសំគាល់លោកនេះទុកជាម្ចាស់សាសនាមួយ ។ គម្ពីរលោកដែលគេស្គាល់ច្រើន គឺចតុះឝតកៈ, ជាគម្ពីរនិកាយមាធ្យមិកៈ, សព្វថ្ងៃនេះមាននិកាយខ្លះនៅប្រទេសជប៉ុនគោរពលោកនៅឡើយ ។

អសង្គៈ នៅក្នុងសម័យរវាង ព.ស. ៨៤៣ ជាបុត្រច្បងព្រាហ្មណ៍ម្នាក់នៅទិសពាយព្យប្រទេសឥណ្ឌា ។ ដើមឡើយលោកជាសាវកនិកាយសព្វស្តិវាទិន, ហើយត្រឡប់ទៅកាន់លទ្ធិមហាយានជាសាវកនិកាយយោគាចារដែលទទួលស្គាល់តែត្រឹមពាក្យថាមានវិញ្ញាន ។ លោកនិយាយថា អ្នកដែលប្រតិបត្តិយោគៈតែមួយយ៉ាង ទើបបានសម្រេចពោធិញ្ញាណ ។ លោកនេះបានតែងគម្ពីរអដ្ឋកថាយ៉ាងសំខាន់ ឈ្មោះថាមហាយានសូត្រាលង្ការ ។ ប្អូនលោកបង្កើតមួយជាអ្នកប្រព័ន្ធយ៉ាងល្បីនាម ខាងអក្សរសាស្ត្រហីនយាននឹងមហាយានឈ្មោះវសុពន្ធុ ជាអ្នកប្រាជ្ញធំមួយ ។ គម្ពីរលោកឈ្មោះអភិធម៌កោឝដែលនៅមានតែសេចក្តី

ប្រែជាភាសាចិនទីងទីបេតាំង ហើយគេស្គាល់បានអាស្រ័យដោយគម្ពីរអដ្ឋកថាសំស្ក្រឹត, ជាគម្ពីរសំដែងពីសេចក្ដីប្រតិបត្តិខាងសីលធម៌, ចិត្តវិទ្យានិងអភិធម៌ ។ បងលោកឈ្មោះ អសង្គៈ បានបញ្ចូលលោកឲ្យទៅកាន់លទ្ធិមហាយាន ហើយលោកបានតែងគម្ពីរជាច្រើន ដែលនៅសល់តែសេចក្ដីប្រែជាភាសាចិន, ទីបេតាំង ។ លោកមានសិស្សលោកបេះតែងគម្ពីរជាច្រើនដែរ ។

ក្នុងចំណោមគ្រូមហាយានដែលល្បីនាមជំនាន់ក្រោយ គួររាប់ព្រះអង្គម្ចាស់ឝាន្តិទេវៈមួយនៅក្នុងសម័យរវាង ព.ស. ១២៤៣, ទ្រង់ជាព្រះរាជបុត្រ លះបង់រាជ្យហើយចូលកាន់បព្វជ្ជា, ទ្រង់បានតែងគម្ពីរជាច្រើន សុទ្ធតែជាគម្ពីរវិសេស គឺគម្ពីរឝិក្សាសមុច្ចយប្មជាសេចក្ដីរួមធម្មវិន័យលទ្ធិមហាយាន និងគម្ពីរពោធិចរ្យាវតារ ប្ចគតិនៃពោធិញ្ញាណជាកាព្យឃ្លោងដ៏ចំណាន មិនចំពោះរបៀបប្រយោគយ៉ាងល្អប៉ុណ្ណោះទេ ព្រមទាំងមានសទ្ធាខ្ពង់ខ្ពស់ជឿជាក់ក្នុងលទ្ធិមហាយានផង, លោកអធិប្បាយអំពីដំណើរពោធិសត្វ ដែលសម្រេចសម្មាសម្ពោធិញ្ញាណ ដោយការគោរពចំពោះព្រះពុទ្ធអង្គទាំងឡាយផង, ដោយការសំដែងមេត្តាចិត្តផង ដូច្នេះទើបបានសម្រេចប្រាជ្ញញាណប្មគុត្តរៈ ។

ដោយពួកគម្ពីរជំនាន់ក្រោយជាច្រើនរបស់មហាយាន សេចក្ដីអន្ត-រធានព្រះពុទ្ធសាសនាចេញពីប្រទេសឥណ្ឌាក៏ពោលស្រមោលមកដល់

ពួកសូត្រ មានសេចក្ដីដូចគ្នានឹងគម្ពីរបុរាណរបស់ព្រាហ្មណ៍ ហើយមានទាំងកាព្យឃោង ឬស្តោត្រៈ និយាយសរសើរកិត្តិយសដ៏ខ្ពង់ខ្ពស់នៃទេវតាទាំងឡាយ ៗ មានស្តោត្រៈខ្លះផ្សេងដោយឡែកទុកឧទ្ទិសដល់ព្រះវិស្ណុ, ព្រះឥសូរ, ឬពោធិសត្វអវលោកិតេស្វរៈ, គម្ពីរដែលសំខាន់ជាងគេនោះគឺគម្ពីរលោកិតេឝ្វរឝតកៈ ប្រព័ន្ធដោយអ្នកប្រាជ្ញកវី ឈ្មោះវជ្រទត្តៈ រវាង ព.ស.១៣៤៣ ៗ បន្តិចៗតមក, អក្សរសាស្ត្រមហាយានក៏បណ្ដោយឲ្យគម្ពីរធារណីរុកទន្ទ្រានចូលមក ហើយធ្វើឲ្យសាបសូន្យមួយព្យាង្គម្ដងៗ ហេតុដល់ស្ដាប់សេចក្ដីមិនបាន ៗ

ទីបំផុត, ដោយឥទ្ធិពលលទ្ធិតន្ត្រៈរបស់ ឝិវៈ, តន្ត្រៈរបស់ព្រះពុទ្ធ-សាសនាជ្រាបចូលមកក្នុងអក្សរសាស្ត្រមហាយាន ទើបភាសាសំស្ក្រឹតក៏មិនសូវមានដំឡៃប៉ុន្មាន, យើងសូមកប់ឈ្មោះគម្ពីរ ៤ ពួកដែលកើតឡើងក្នុង ព. ស. ១៣៤៣មកដល់ ១៥៤៣ គឺគម្ពីរក្រិយាតន្ត្រ-ចរិយាតន្ត្រ-យោគតន្ត្រៈ និងអនុត្តរយោគតន្ត្រៈ ៗ

យើងមានបំណងថានឹងបំពេញសេចក្ដីព្យាយាមឲ្យជឿនលឿនទៅកាន់វិជ្ជាដ៏ធំទូលាយនៃអក្សរសាស្ត្រប៉ែកខាងព្រះពុទ្ធសាសនា; ទើបគប្បីផ្ដើមបោះពុម្ពវេយ្យាករណ៍នេះ នឹងបោះពុម្ពរឿងរ៉ាវសំខាន់ខ្លះៗ បែបគម្ពីរសំ-ស្ក្រឹតប៉ែកព្រះពុទ្ធសាសនា ៗ អាស្រ័យដោយគម្ពីរដីការបស់ព្រះរាជ-

បណ្ណាល័យនឹងសាលាបាឡីជាន់ខ្ពស់ នឹងអាស្រ័យដោយព្រះថេរៈទាំងឡាយជាអ្នកប្រាជ្ញសំស្ក្រឹត ដែលយកចិត្តទុកដាក់នឹងការសិក្សាខេមរជាតិ, បំណងយើងនឹងបានសម្រេចដោយស្រួលហើយនឹងដឹកនាំឲ្យមានគំនិតបំរុងបោះពុម្ពសព្វវចនាធិប្បាយ សំស្ក្រឹត-បាលី-ខ្មែរ តទៅទៀតពុំខាន ។

ស. ក.

## បញ្ជីគម្ពីរសំស្ក្រឹតប៉ែកព្រះពុទ្ធសាសនា ១៨ គម្ពីរ
## ដែលមាននៅក្នុងព្រះរាជបណ្ណាល័យ

| ឈ្មោះសៀវភៅ (អក្សរទេវនាគរី) | អ្នកប្រព័ន្ធនឹងអ្នកបោះពុម្ព | លេខរៀង (B. R.; E. S. P.) |
|---|---|---|
| ១. សព្វវចនាធិប្បាយ សំស្ក្រឹត-បារាំងសែស | ឯមីល ប៊ួរនូហ្វ (Emile Burnouf | B. R. M. 7. |
| ២. អវទាន កល្បលត | ក្សេមន្ទ្រ | E. S. P. M. 1 A. |
| ៣. ពុទ្ធចរិត | អស្វឃោឞ,លោកគរវែល (Corwel) បោះពុម្ព | E. S. P. M. 1. B.<br>E. S. P. M. III. 2 |
| ៤. បញ្ជីសៀវភៅពុទ្ធសាសនា (Catalogue of Buddhis-manuscrits) | ហស្ត្រិ | B. R. M. 6. |
| ៥. ពោធិចរ្យាវតារលោកឝាន្តិទេវ | ប្រាជ្ញាករមតិ | E. S. P. M. I. 2. |
| ៦. អឞ្ដសាហស្រិកា-ប្រាជ្ញាបារមិតា | លោក ប្រតាបចន្ទ្រឃោឞ បោះពុម្ព | E. S. P. M. 1, 5. |
| ៧. ធម៌សំគ្រហ | លោកម៉ាក-មុលល័រ (Max-Müler) បោះពុម្ព | E. S. P. M. 3, 1, E. |
| ៨. ជាតកមាលា | អាយ៌្យសូរ,លោកកេន (Kern) បោះពុម្ព | E. S. P. M. 4, 1. |
| ៩. លលិតវិស្តរ | លោក លេហ្វម៉ន (Lefmann) បោះពុម្ព | M. 1, 6, A. B. |
| ១០. លង្កាវតារសូត្រ | លោក ប៊ុន-យោនន់ជោ (Bunyio-Nanjio) បោះពុម្ព | E. S. P. M. 7. |
| ១១. លោកេឝ្វរឝតក | វជ្រទត្ត,មា-សុយសាំនការប៉ីឡែស បោះពុម្ព | E. S. P. M. 2, II. |
| ១២. មហាវស្តុ | លោកឯមីល-សេនារ៍ (Emil-Senart) បោះពុម្ព | E. S. P. M. 2, 1. A. B. C. |

| ឈ្មោះសៀវភៅ (អក្សរទេវនាគរី) | អ្នកប្រព័ន្ធនិងអ្នកបោះពុម្ព | លេខរៀង (B. R.; E. S. P.) |
|---|---|---|
| ១៣. ន្យាយ ឬ បរមត្ថវិជ្ជាពុទ្ធសាសនា ៦ ប្រការ | វត្នកីរ្តិ, លោក ហរប្រសាទ ឝាស្ត្រី បោះពុម្ព | E. S. P. M. 1, 4. |
| ១៤. ប្រាជ្ញាបារមិតា-ហ្ឫទយ-សូត្រ | លោក ម៉ក-មុលល័រ, ប៊ុនយោ-ន៉ន់ជោ បោះពុម្ព | E. S. P. M. 3, I, C. |
| ១៥. រាឞ្ដ្របាលបរិ-ប្ឫឆា | លោក ល្វី-ហ្វ៊ីណូត៍ បោះពុម្ព | B. R. M. 1. |
| ១៦. ស្រគ្ធរាស្តោត្រំ | ភិក្ខុ សវ៌ជ្ញមិត្រ, លោក សតិសុន្ទ្រ វិទ្យាភូឞន បោះពុម្ព | E. S. P. M. I, 3. |
| ១៧. វជ្រច្ឆេទិកា | កុមារជីវ, លោកម៉ក-មុលល័រ បោះពុម្ព | E. S. P M. 3, I, A. |
| ១៨. វិជ្ញប្តិមាត្រតាសិទ្ធិ | វសុពន្ធុ, លោក ស៊ីលវ៉ាំង ឡេវី (Silvain Lévi) | B. R. M. 5. |

នេះ

# ច្បាប់សុភាសិត

ប្រសើរពេកពិត ប្រែពីគាថា
បន្ទូលព្រះពុទ្ធ បំហុតទេស្នា
ឲ្យអស់ទាំងមហា- ជនផងត្រងត្រាប់ ។

និព្វានបច្ចយោ ហោតុ មេ ។

របស់

ឧកញ៉ាវង្សាសារពេជ្ញ នង ចាងហ្វាងក្រុមរាជបណ្ឌិត្យ
ក្នុងរាជ្យព្រះបាទសម្តេចព្រះហរិរក្សរាមាឥស្សរាធិបតី
(ព្រះអង្គដួង) ។

២– យោចនកេ ឆនលោកោ ក្រុតោសីលំ សុភ-មេរយ ក្រុតោសច្ចំ លោកោមំសំ ក្រុតោឧយា ។ អាថ ព្រះធ្លាលី នេះលោកស្រដី ថាអ្នកឯណា មួយលោកទ្រព្យធន ពេក ពន់មហិមា រីសីលសត្យា ពីណាទ់ន៍មាន ។ នាអ្នកប្រមឹក ស្រាស្រែក បង់ផឹក ពិតពុំគិតប្រាណ ធ្លាក់ទៅនរក ទល់ទុក្ខឥតក្សាន្ត ហើយតើ ទីន៍មាន ពាក្យសត្យពីណា ។ បើលោកចំណី ចំណង់ចង់ស៊ី សាច់ សត្វមហិមា ហើយតើរក្តី មេត្រីទយា អាស្សូរករុណា ពុំមានឯន៍ឯ ។

៣– ឧត្តិលោកេ រហោនាម បុញ្ញបាបេ ឧភកាតំ បឋមំចិត្តេ ជានេយ្យខ្មេ រក្ខានេភ ។ នាអ្នកផង់ធ្វើ កិច្ចការ អំពើ បុណ្យបាបរ៉េក កម្មកាលលោកិយ នាបីហៅជា ស្ងាត់បាត់នៅនា អាយអគ្គីមាន ។ កាលប្រថមគិត ជាដើមមានចិត្ត ឯន៍ដ៏ន៍ស្រេចបាន ជាពីរទីន៍អា- រក្ខនាសត្វហាន ទេក្តាមានញាណ ពិតពុំកំបាំង ។

៤– បង្គុំជលេ ជនិតំលោកោ នោវឧបង្គុំ ជលបាបេ ចិត្តេជនិតំ នោវឧកាម្ពុំ បាបចិត្តេ ។ លោកថាកំណើត កក់ផង់សឹន៍កើត ពីទឹកឯន៍ឯ បើទីន៍លាន៍កក់ អាក្រក់ឲ្យថៃ ឲ្យជ្រះ មានតែ ទឹកទើបជ្រះហោង ។ រីអំពើបាប ពៀរពិតផកប អកុសលផង សឹន៍កើតពីចិត្ត គំនិតធ្វើគ្គង៍ ពុំតាមគន្លង ធម៌ព្រះទេស្នា ។ បើទីន៍

ចង់ផ្ដាច់ បាបចង់សម្រេច លះលែងវេរ មានប៉ុនតែចិត្ត គន់គិតរក្សា សីលសូមប្រាថ្នា- ភិរម្យរូប ។

៥–បេមតោ ជា-យតេសោកោ បេមជាយ- តេភយំវិ- ប្បមុត្តស្ស- នត្ថិសោកោ កុតោភយំ ។ នាអ្នកផងមាន ភ័យភិតពុំក្សាន្ត សែនសោយសោក សោកសឹងកើតពី ហេតុក្ដីស្នេហា ស្រឡាញ់ទើបជា ទុក្ខទៀងក្រាស់ក្រៃ ។ ថាបើមិនមាន ស្រឡាញ់គូផង ប្រាណ ឥតក្ដីអាល័យ ហើយតើអំពល់ សោកសល់នោះនៃ ទល់ទុក្ខ ភិតភ័យ នឹងមានពីណា ។

៦– អត្តាគតោ ជិវត្តេ មិត្តពន្ធា វាសុសាបេ សុខេទុក្ខា កាម្ហំអត្តា ជគច្ចតិ ។ លោកថាទ្រព្យ ផង សឹងក្រឡាប់ វិលវិញអំពី ព្រៃព្រឹក្សពុំបាន តាមប្រាណទៅខ្លី បុត្រ ភរិយាក្ដី តាមទៅពុំបាន ។ មានតែអំពើ បុណ្យបាបបានធ្វើ ពិតពីមុន មាន ពៀរពិតនិត្យនៅ តាមទៅដោយប្រាណ ប្រាកដមិនមាន ឃ្លាត ឃ្លារូបា ។

៧– សព្វំនត្ថិ គតោឥន្ទ្រិ- យជិត្តហា នត្ថិសព្វៀ ក្ខតេទយា ឃតំចណ្ឌា- លលក្ខណំ ។ អ្នកបួសពុំមាន ពាក្យសត្យពុំបាន សន្រ្ទឹមកាយ ពុំមានទយា មេត្តាករុណា គួតេសព្វ

សព្វសត្វទាំងឡាយ ៗ លោកថាពុំមាន ផលបរិបូណ៌បាន បុណ្យ បរលោកនាយ ពុំមានតបះ គេជះសីលសាយ ជាអ្នកកាចកាយ ចណ្ឌាល លក្ខណា ៗ ។

៨– ព្រហ្មាសច្ចំ ព្រហ្មាតបំ ឥន្ទ្រិយនិគ្គហោ សព្វ-សត្តានុទយាវេ ព្រហ្មចរិយោ លក្ខណោតិ ៗ អ្នកបួសបើមាន ពាក្យសត្យសោតបាន សង្រួមឥន្ទ្រិយ មែនមានមេត្តា ករុណាខន្តី សព្វសត្វឥតបី ចង់ជាទោសា ៗ ប្រសើរឯផល បានបរិបូណ៌ដល់ ដូចដោយប្រាថ្នា មែនមានតបះ ដោយព្រះធម៌ថា ជាលក្ខណា នៃអ្នកបួសខ្ចី ៗ

៩– ឧប្បជ្ជតេ ការណំការណេ ជម្មោវុឡ្សី សចុំនយា ៖មាជម្ពុ វិណាសតី ចិត្តំគោជា ៗ លោកថាវីព្រះ ធម៌ដារជ្រៅជ្រះ កើតកបសីលា ហេតុមានសច្ចំ ទៀងទាំងទយា អាសូរខ-មា អំណត់ទឹងនៅ ៗ រីក្ដីវិនាស ដារធម៌ទិកស ពិតពុំទៀងនៅ ហេតុក្ដីកំហឹង ខេរខឹងឃោរឃៅ បាត់បទកំឡៅ មានះក្រោធ ៗ

១០– គោសសលា កុណាំកាប្បា សហាស្សចិវរ ទសសីលំ សតំសហាស្ស ពុទ្ធវន្ទេ ចអនន្តំ ៗ អ្នកណាមួយមាន ចិត្តចង់បុណ្យបាន កាត់គោរគេសំ ថ្វាត់ថ្វាយព្រះពុទ្ធ

# ពង្សាវតារក្រិក

(តមក)

អំពីឧស្សាហកម្មនិងពាណិជ្ជកម្ម — សូឡុងដឹងច្បាស់ថា ការដាំដំណាំនោះ ពួកអាថែនទឹងធ្វើតទៅឲ្យបានចំរើនមិនបានប៉ុន្មានទេ ព្រោះទីដីមានតិច ទាំងមិនមានដីជាតិល្អផង ទើបគិតរកផ្លូវទំនុកបំរុងរបររបស់ស្រុក ខាងផ្លូវឧស្សាហកម្ម ហត្ថកម្ម និងជំនួញ ដែលពួកអាថែនថ្នឹកស្ទាត់ ជំនាញនោះ ដោយឡែកទៀត ។ របរហត្ថកម្មនិងជំនួញនេះហើយ ដែលធ្វើឲ្យស្រុកអាថែនក្លាយទៅជាស្រុកស្តុកស្តម្ភទាន់ភ្នែកឃើញ ។ ពួកអាថែនបេះទៅរកដីកមុីនប្រាក់អំពីក្រុងដែលនៅជិតៗ ស្រុកបានមកជា ចំនួនច្រើន ។ តាំងអំពីដើមមក ជនជាតិតាងប្រទេសដែលចូល មកនៅក្នុងស្រុកអាថែន មិនមានអំណាចបានធ្វើជាម្ចាស់ស្រុក គឺមិន មានអំណាចដូចពួកអាថែនឡើយ តែសូឡុងបញ្ញត្តថា ជនផ្សេងជាតិ ឯណាមួយចូលមកនៅក្នុងដែនអត្តិកា (ឈ្មោះអាណាចក្ររបស់ក្រុង អាថែន) បាននាំយកវិជ្ជាជាគ្រឿងចិញ្ចឹមជីវិតថ្មីៗដែលពួកអាថែនមិន ទាន់ចេះចូលមកផង ជនផ្សេងជាតិនោះទើបមានសិទ្ធិធ្វើជាអ្នកស្រុកអា- ថែន ហើយមានសិទ្ធិនឹងបោះឆ្នោតដូចជាពួកអ្នកស្រុកអាថែនៗ បញ្ញត្តិ នេះជាគ្រឿងសំដែងឲ្យឃើញសេចក្តីឆ្លាតឆ្លៀវយ៉ាងខ្ពង់ខ្ពស់របស់សូឡុង

ហើយជាហេតុធ្វើឲ្យហត្ថកម្មក្នុងស្រុកអាថែនរ្យចំរើនឡើងជាអនេក គ្រឿងដែលធ្វើពីថ្មីដៃដែលល្បីល្បាញ គឺគ្រឿងថាន-ពែង, គ្រឿងផ្ទះ, គ្រឿងអាវុធ សំពត់ជាដើម ។ បណ្តារបស់អស់នេះ គ្រឿងថាន-ពែងទុកជារបស់ឯក ព្រោះនៅមានប្រយោជន៍រហូតដល់សព្វថ្ងៃនេះ ពោលគឺក្បាច់ក្បូរលាយលក្ខណ៍ដែលមានជាប់នៅនឹងគ្រឿងថាន-ពែងអស់នោះ នាំឲ្យជួយស្រាវជ្រាវប្រវត្តិសាស្ត្ររបស់ក្រិកបានជាច្រើន ។

សម័យទីរ៉ានី (La Tyranie) — ច្បាប់សំខាន់ស្រុករបស់សូឡុងដែលចាត់តាំងឡើង នៅមិនទាន់ជាទីគាប់ចិត្តនៃមនុស្សជាន់ទាប ពោលគឺវណ្ណៈទី ៤ ដែលគិតថាខ្លួននៅមិនទាន់បានសិទ្ធិច្រើនល្មមគ្រប់គ្រាន់ ។ ក្នុងសម័យដែលសូឡុងនៅមានជីវិតនៅឡើយនោះ មានបុរសម្នាក់ជាសែស្រឡាយមន្ត្រីឈ្មោះថា ពីស៊ីស្ត្រាត៍ (Pisistrate) មានចិត្តលោភចង់ស្វែងរកអំណាចដោយវិធីធ្វើឲ្យមនុស្សជាន់ទាបស្រឡាញ់រាប់អាន ហើយតាំងខ្លួនជាអ្នកទំនុកបំរុងពួកមនុស្សជាន់ទាប ។ ថ្ងៃមួយ មនុស្សនេះឯងតាំងប្រទូសរ៉ាយខ្លួនឯងឲ្យមានរបួសហើយរត់ចូលទៅក្នុងចំណោមប្រជាជនហើយស្រែកប្រកាសថា ខ្លួនត្រូវពួកដែលជាសត្រូវប្រទូសរ៉ាយ ។ ប្រជាជនក៏កាន់តែមានចិត្តអាណិតអាសូរពីស៊ីស្ត្រាត៍នេះ ហៅថាទីរ៉ានី សម័យនេះឯងជាសម័យសក្តិសក្តិន តែក្នុងសម័យនោះគ្រាន់តែសំដៅ

សេចក្តីថា នរណាមួយដែលមិនមែនជាអំបូរក្សត្រ តាំងខ្លួនឡើងជាក្សត្រគ្រប់គ្រងផែនដី ។ ចំណែកឯពីសិស្ត្រាត់នោះកាលបានធ្វើជាក្សត្រគ្រងរាជ្យហើយទៅជាក្សត្រមួយដ៏ប្រសើរ ធ្វើការតាមច្បាប់ដែលសូឡុងតាំងឡើង តែជាអ្នកមានអធ្យាស្រ័យល្អ មេត្តាករុណាដល់ប្រជាជន ហើយបានសាងផ្លូវថ្នល់កាន់តែច្រើនឡើង ធ្វើទីក្រុងអាថែនឲ្យកាន់តែល្អរុងរឿងជាងមុន តាំងរាជបណ្ណាល័យ ហើយទឹងប្រមូលកាព្យឃ្លោងរឿងឡើងជាដំបូងបំផុត ។

កាលក្សត្រពីសិស្ត្រាត់នេះសុគតទៅនោះ នៅមានរាជបុត្រ ២ អង្គ ឈ្មោះ ហ៊ិបពីអាស និងហ៊ិបប៉ាក បានទទួលអំណាចធ្វើការជាដំណតមក តែមិនដើរតាមលំអានរបស់ព្រះរាជបិតា បែរជាសង្កត់សង្កិនប្រជាជនទៅវិញ ទើបមានមនុស្សកំឡោះដែលមានសេចក្តីក្លាហាន ២ នាក់ ឈ្មោះ ហារម៉ូឌិយ៉ុស ១ ឈ្មោះអារិស្តូស៊ីតុង ១ បានយកកាំបិតចាក់ហ៊ិបប៉ាកស្លាប់ក្នុងខណៈធ្វើបុណ្យមួយ ។ ឯហ៊ិបពីអាសនោះគេចរត់ពីក្រុងអាថែនទៅរួចទើបរស់ជីវិតមកបាន ។ ឯអ្នកក្លាហានទាំងពីរនាក់គិតថា ខ្លួននឹងមានសេចក្តីគាប់ទទួលបំណាច់រង្វាន់ តែបែរត្រឡប់ជារាជការចាប់ខ្លួនសម្លាប់ទាំងពីរនាក់ ។

ការដែលរាជបុត្ររបស់ពីសិស្ត្រាត់អស់អំណាចទៅក្នុងគ្រានេះ ប្រជាជនអាថែនប្រកាន់ថាជាការៈសំខាន់ក្នុងប្រវត្តិហេតុ ហើយបានកសាង

អនុស្សាវរីយ៍ទុកជាទីរឭក គេនាំគ្នាប្រៀនកូនចៅហៅមានបុណ្យ ជាទំនង សេចក្តីថ្លែងអំពីជ័យជំនះដែលបានទទួលឥស្សរភាពក្នុងគ្រានេះ នាំឱ្យចំរើនលូតលាស់ឡើងក្នុងចិត្តរបស់ប្រជាជននៅស្រុកអាថែន្ស ។

តមក មាននាហ្មឺនម្នាក់ឈ្មោះគ្លិស្តេនិស នៅក្នុងក្រសួងរដ្ឋបាលមួយដែរ បានលើកអំណាចរាស្ត្រឱ្យខ្ពស់ឡើងវិញ ហើយគិតរកឧបាយការ-ពារមិនឱ្យអ្នកណាមួយតាំងខ្លួនឡើងជាក្សត្របានស្រួល ៗ ដូចមុនទៀត ទើបគ្លិស្តេនិសបញ្ញត្តវិធីម្យ៉ាងហៅថា អុស្ត្រាស៊ិស្ម (លទ្ធិសំបកខ្យង) ពេលគឺបើអ្នកណាមួយមានអំណាចច្រើនឡើងហួសពេក ឬធ្វើឱ្យស្រុកទេសកើតចលាចលឡើង គេនឹងត្រូវទោសនិរទេសខ្លួនពីស្រុកអាថែន្សជាកំណត់ ១០ ឆ្នាំ ។ ការធ្វើទោសទំនងនេះ អ្នកទទួលទោសមិនមានខូចកេរ្តិ៍ឈ្មោះអ្វីទេ គេនឹងនាំសេចក្តីនេះមកជំនុំជម្រះក្នុងកណ្តាលជំនុំប្រជាជន ពេលគឺឱ្យមហាជនបោះឆ្នោតថ្លែងយោបល់របស់ខ្លួន ហើយត្រូវជំនុំជម្រះកាត់ទោសឬមិនត្រូវទោស ស្រេចតែឆ្នោតរបស់បណ្តារាស្ត្រមានចំនួនខាងណាច្រើនជាង ត្រូវស្រេចទៅតាមឆ្នោត ។ ការធ្វើទំនងនេះ ត្រូវធ្វើទៅលើរឿងធំៗ រឿងសំខាន់ៗ ដើម្បីបង្ការអ្នកត្រូវទោសជាអ្នកមានអំណាចនោះ ព្យាបាទពួកអ្នកបោះឆ្នោតឬអ្នកធ្វើទោសបាន ដ្បិតមិនដឹងជាអ្នកណាបោះឆ្នោតចូលខាងណា ។ វិធីនេះគេនិយមប្រើនៅក្នុងនានាប្រទេស

ឬក្នុងវេជ្ជសភានានាប្រទេសរហូតមកដល់សព្វថ្ងៃនេះ ខុសគ្នាតែវេលានេះ គេប្រើក្រដាសរឹងផ្ទាំងតូចៗ ដូចកាតវិស៊ិតជំនួសសំបកខ្យងប៉ុណ្ណោះ ។

ទុកជាពួកក្រិកបែកខ្ញែកគ្នាជាអាណាចក្រតូចៗជាច្រើនប្រហែល ៥០ នគរ មិនរួមមូលគ្នាប្រណាំងប្រជែងគ្នាក៏ដោយ ពួកអស់នេះនៅនិយាយភាសាដូចគ្នា ស្រឡាញ់ជាតិក្រិកដូចគ្នា ហើយនាំគ្នារាតផ្សាយអាណាខេត្តចេញទៅតាមកោះផ្សេងៗជាច្រើន រាតទៅតាមឆ្នេរសមុទ្រអេហ្ស៊ី (Égée) ហើយនៅទីបំផុត សមុទ្រនេះទៅជានៅកណ្តាលស្រុកក្រិកទៅវិញ ។

(នៅមានត)

# រឿងព្រេងខ្មែរ — រឿងអាឡេវ ( ទី២ )

( តមក )

របស់អ្នកឧកញ៉ាប្រាជ្ញាធិបតី ( យិន ) ជាងហ្លួងក្រុមព្រះរាជនិពន្ធ

ឯអ្នកនេះជាអាពុកឆ្លើយឡើងថា ឱកូនអើយ ម្ដាយឯងស្លាប់ទៅពុំទាន់បានមួយខែទេ ឥឡូវនេះឯងឲ្យឪរកប្រពន្ធទៀត កូនមិនអាណិតម៉ែឯងទេឬ? មួយទៀត ឪខ្លាសគេ ក្រែងគេថាប្រពន្ធស្លាប់ពុំទាន់បានប៉ុន្មានថ្ងៃ ឥឡូវនេះគិតរកប្រពន្ធ ឪខ្លាសគេណាស់ ឪមិនយកប្រពន្ធទៀតទេ ។ ឯអាឡេវនេះតែអង្វរអាពុកតែសព្វថ្ងៃ ៗ ថ្ងៃមួយ អាឡេវឃើញអាពុកមកពីស្រែនឿយហត់ណាស់ វាក៏និយាយថា ឪអើយ ឥឡូវនេះឪឯងនឿយណាស់ព្រោះគ្មានប្រពន្ធនឹងជួយកំឡាំង មួយទៀត ពាក្យបុរាណលោកថា មនុស្សគ្មានប្រពន្ធដូចជាឪឯងនេះ បើទៅធ្វើការឯព្រៃបាត់ការឯផ្ទះ ធ្វើការឯផ្ទះ បាត់ការឯព្រៃ ធ្វើដូចម្ដេចនឹងបានប្រាក់ចាយបាយស៊ីនឹងគេ ហើយខ្លួនក៏នឿយណាស់ផង ៗ ឯអ្នកនេះឮកូនអង្វរដូច្នោះហើយ ក៏សួរទៅថា បាននរណាគេទៅដណ្ដឹងប្រពន្ធឲ្យឪ អាឡេវឆ្លើយឡើងថា ឪឯងកុំព្រួយចិត្ត សុំខ្ញុំទៅរកដណ្ដឹងឲ្យ ឪឯងនៅចាំរៀបរបស់ទឹងទៅការ ៗ អ្នកនេះជាអាពុកឮកូនថាដូច្នោះហើយ ក៏ថាតាមតែកូនគិតចុះ ៗ អាឡេវឮអាពុកព្រមដូច្នោះហើយ ក៏រៀបខ្លួនមីម្នាទៅផ្ទះនាង

ឆោះជាម្ដាយ នៅបានពីរបីថ្ងៃទើបវានិយាយនឹងនាងឆោះជាម្ដាយថា ម៉ែអើយ ឥឡូវនេះយើងនៅតែពីរនាក់ ខ្ញុំក៏ក្មេងមិនចេះធ្វើការរកស៊ីអ្វី ម៉ែជាស្រីហើយមេម៉ាយផង ឥឡូវមានគេចង់បានម៉ែៗ យកប្ដីទៅគ្រាន់គេនឹងចិញ្ចឹមសោះអត់ឃ្លាន យើងក៏មិនសូវពិបាក ។ ឯនាងឆោះឮអាឡូវជាកូននិយាយដូច្នោះ ក៏ឆ្លើយថា កូនអើយ ឪឯងទើបតែនឹងស្លាប់បាន៥-៦ថ្ងៃ ឥឡូវនេះកូនឲ្យម្ដាយយកប្ដីទៀតដូច្នេះមិនត្រូវទេ អ្នកផងគេនឹងសើចដំនៀលនិន្ទាថាស្រីចើកអាស ប្ដីស្លាប់ពុំទាន់បានប៉ុន្មានថ្ងៃចង់បានប្ដីទៀត ។ ឯអាឡូវឮម្ដាយថាដូច្នោះហើយឆ្លើយឡើងថា ម៉ែអើយ បើទុកជាម៉ែខ្លាចពាក្យអ្នកផងគេនិន្ទាដូច្នោះ គេក៏មិនបានរកចិញ្ចឹមយើងដែរ គេបានប្រាក់កាសគេមិនឲ្យយើងចាយទេ ។ កាលខ្ញុំនៅស្រុកស្រែ មានមនុស្សម្នាក់ មុខមាត់ខ្លួនប្រាណដូចជាខ្មោចឪ ហើយគាត់ស្រឡាញ់ខ្ញុំដូចជាកូនគាត់សួរខ្ញុំថាឯងមានម៉ែ-ឪឬ ខ្ញុំប្រាប់គាត់ថាគ្មានឪទេមានតែម៉ែ ហើយគាត់និយាយនឹងខ្ញុំថាចង់បានម៉ែឯងជាប្រពន្ធ តើម៉ែឯងព្រមឬដូចម្ដេច បើម៉ែព្រមគាត់នឹងរៀបរណ្ដាប់មានបែបបូរនាំជូនមហាខាន់ស្លាក្រយាសំពះតាមច្បាប់សណ្ដាប់ប្រពៃណីពីបុរាណមក បើម៉ែមិនព្រមខ្ញុំក៏មិនដឹងដែរ តាមតែម៉ែគិតធ្វើការរកស៊ីចុះ ។ នាងឆោះជាម្ដាយឮកូននិយាយអង្វរផ្ចូញផ្ចាល់ដូច្នោះក៏ឆ្លើយតបទៅវិញថា តាមតែចិត្តកូនគិតចុះ ។ អាឡូវឮម្ដាយថាតាមតែចិត្តដូច្នោះក៏អរណាស់ គិតក្នុងចិត្តថាអញបាននំស៊ីទៀតហើយៗ

ក៏រៀបចំផ្ទះសំបែងរួចប្រាប់នាងនោះជាម្ដាយថា ដ្បិតគេចង់រៀបការឆាប់ ខ្ញុំលាម៉ែទៅស្រែដើម្បីរកមាន់ទាបន្ទែបង្កា ហើយនឹងប្រាប់អ្នកដែលចង់បានម៉ែឯងជាប្រពន្ធនោះផងដើម្បីឲ្យគេរករណ្ដាប់រៀបការ ៗ អាឡេវក៏ម្នីម្នារៀបខ្លួនទៅស្រែ លុះទៅដល់ហើយក៏និយាយប្រាប់អ្នកនេះជាអាពុកថា ឪអើយ ខ្ញុំទៅរកប្រពន្ធឲ្យឪឯងបានហើយ នាងនោះមុខមាត់សំដីកំពស់សម្បុរដូចម៉ែ ឥឡូវនេះខ្ញុំឲ្យគាត់មកនៅផ្ទះយើងហើយ បើដូច្នេះឪឯងរៀបរណ្ដាប់ទៅការជាឆាប់ ៗ អ្នកនេះឮអាឡេវប្រាប់ថាគេឲ្យរៀបការជាឆាប់ដូច្នោះ ក៏ម្នីម្នាពឹងអ្នកស្រុកផ្ទះជិតខាងឲ្យជួយធ្វើនំនែកចំណីចំណុក ហើយខ្លួនគាត់ទៅរកទិញមាន់ទាបន្ទែបង្កាបានសព្វគ្រប់ហើយ ឯអាឡេវចេះតែស៊ីទំពល់ថ្ងៃ ហើយនិយាយនឹងអាពុកថា ប្រពន្ធដែលខ្ញុំដណ្ដឹងឲ្យឪឯងនោះមេបាបើកឲ្យរៀបការតែយប់ បើមិនព្រមដូច្នោះ មេបាមិនបើកឲ្យការទេ ៗ អ្នកនេះឮអាឡេវថាដូច្នោះហើយ ហេតុតែជាមនុស្សឆោតល្ងង់តាមតែពាក្យអាឡេវបង្គាប់ដូចម្ដេចក៏តាមទាំងអស់ ទើបរកវេលាទៅការឲ្យត្រូវតែវេលាយប់ ៗ ពេលល្ងាចអ្នកនេះក៏ពឹងអស់បងប្អូនដែលនៅជិតខាងឲ្យជួយដង្ហែអស់បណ្ណាការនាំទៅរៀបការ លុះទៅដល់កន្លែងការ ក៏រៀបដណ្ដាំបាយស្លស្លុក អ្នកខ្លះក៏រៀបផ្លែឈើចំណីចំណុកទៅជូនមេបាតាមទំនៀម ឯនាងនោះក៏ពឹងអស់បងប្អូនមករៀបបណ្ណាការទទួលតាមច្បាប់ ៗ

ឯអាឡេវគិតតែស៊ីឲ្យឆ្អែត ៗ នាងនោះឮមាត់អ្នកនេះក៏ឆ្ងល់ក្នុងចិត្តថា មាត់និយាយនោះដូចជាសំឡេងអ្នកនេះប្ដីអញ ឯអ្នកនេះឮមាត់នាងនោះ ក៏ឆ្ងល់ក្នុងចិត្តថាសំឡេងនិយាយនោះដូចជាសំឡេងនាងនោះប្រពន្ធអញ អ្នកនេះសង្ស័យណាស់ក៏ឡើងទៅលើផ្ទះឃើញនាងនោះ ក៏ថា នាងនេះ ដូចជានាងនោះប្រពន្ធអញ ឯនាងនោះថាអ្នកនេះដូចជាអ្នកនេះ ប្ដីអញ ៗ ឯអស់បងប្អូនទាំងអ្នកស្រុកគេថា អ្នកនេះហើយថាមិនអ្នកនេះ នាងនោះហើយថាមិននាងនោះ ឯអ្នកនេះនាងនោះឃើញគ្នាជាក់មែនទែន ហើយទើបដឹងថាអាឡេវបញ្ឆោត ក៏អៀនរត់ទៅដោយខ្លួនទីទៃ ៗ ៗ អាឡេវដឹងថាម្ដាយអាពុកដឹងដូច្នោះក៏រៀះពួន លុះព្រឹកឡើងអាឡេវរត់ទៅនៅវត្តធ្វើជាកូនសិស្សលោក ៗ ឯអ្នកនេះទាំងនាងនោះក៏នៅជាប្ដីប្រពន្ធទាំងគ្នាទៅ ៗ

(មានតទៅទៀត)

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

ឆ្នាំគំរប់ ១៣

ភាគទី ៣

ភ្នំពេញ

ការផ្សាយរបស់ព្រះរាជបណ្ណាល័យ

ព. ស. ២៤៨៣

គ. ស. ១៩៤១

ព:៦៧

ព្រះរាជបណ្ណាល័យកម្ពុជា.

# KAMBUJASURIYÂ

# កម្ពុជសុរិយា

*ជាទស្សនាវដ្ដីចេញផ្សាយពីព្រះរាជបណ្ណាល័យ មួយខែពីរក្បាល*

ឆ្នាំគំរប់ ១៣

*ភាគទី ៣*

គណៈរដ្ឋមន្ត្រីនិងសម្ដេចសង្ឃនាយកទាំងពីរគណៈ
បានអនុញ្ញាតហើយ

ភ្នំពេញ

ការផ្សាយរបស់ព្រះរាជបណ្ណាល័យ

ព.ស. ២៤៨៣

គ.ស. ១៩៤១

# បញ្ជីរឿង


១ — អំពីព្រះពុទ្ធសាសនាក្នុងប្រទេសឥណ្ឌូស៊ីន លោកអង់ដ្រេ មីក្វត៍ រៀបរៀង. ៣

២ — កាលពី ១៦ ខែមុននេះ . . . . . . . . . . . . . . . . . . ៩

៣ — ច្បាប់សុភាសិត របស់អ្នកឧកញ៉ាវង្សាសារពេជ្រ នង (តមក). . . . . . . ១៣

៤ — ពង្សាវតារប្រទេសក្រិក រៀបរៀងតាមគោលចារិកផ្សេងៗ នៃពង្សាវតារ លោក (តមក) . . . . . . . . . . . . . . . . . . ១៨

៥ — អនាមយកថា ខេមរង្សី រៀបរៀង . . . . . . . . . . . . . . . ២៧

៦ — និទានរឿងព្រេងខ្មែរៈ "រឿងអាឡេវទី ២" របស់អ្នកឧកញ៉ាប្រាជ្ញាធិបតី យិន ជាងហ្លួងក្រុមព្រះរាជនិពន្ធ (តមក) . . . . . . . . . . . . . ៣២


## រូបក្រៅរឿង


ឧតរវត្ត — រូបនាងអប្សរនៅទ្វារចូលទិសខាងលិច . . . . . . . . . ១

# TABLE DES MATIÈRES


Pages

1° Le Bouddhisme en Indochine par le Docteur ANDRÉ MIGOT.... 3

2° Il y a 16 mois........................................ 9

3° Chbab SUBHASIT (Poème Khmèr) par Oknhā VONGSĀSĀRAPÉCH NONG (suite)........................................ 13

4° Histoire de la Grèce, extraits de divers documents de l'Histoire Universelle (suite)........................ 18

5° ANĀMAYAKATHĀ par KHÉMARARANSĪ (suite)................. 27

6° Conte populaire cambodgien inédit :

"Légende de ALÉV II" par Oknhā PRACHNHĀTHIBADEY YIN (suite)........................................ 32


HORS TEXTE :


Angkor-Vat porte d'entrée Ouest : Apsaras.............. 1



នគរវត្ត — រូបនាងអប្សរនៅទ្វារចូលទិសខាងលិច

# អំពីពុទ្ធសាសនាក្នុងប្រទេសឥណ្ឌូស៊ីន

របស់ដុកទ័រ អង់ដ្រេ មីកូត៍

"នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស"

១.–មូលហេតុនៃការផ្សាយចូលមកនៃពុទ្ធសាសនាហីនយាន[១] និងសាសនាព្រាហ្មណ៍ (ហិណ្ឌូ) ។

ឯឫសគល់ដើមនៃលទ្ធិសាសនាក្នុងប្រទេសឥណ្ឌូស៊ីន[២] និងសារ-តារសាសនាដែលផ្សាយចូលមកក្នុងដែនដីផ្ទាំងធំនេះ ទាំងខាងសាសនានិងអារ្យធម៌របស់ឥណ្ឌានោះ សព្វថ្ងៃនេះនៅតែងងឹតមើលឃើញមិនទាន់ជាក់ច្បាស់ ដោយមិនមានគោលចារិកជំនាន់ចាស់ៗ ជាកសិណសាក្សីមាំមួន ។ តែដោយសារយើងបានដឹងប្រវត្តិពុទ្ធសាសនានៅប្រទេសឥណ្ឌា និងបណ្ដាគោលចារិកដែលធ្លាក់នៅទឹងផ្ទាំងថ្មរបស់ព្រះបាទធម្មាសោក បានបង្ហាញឲ្យយើងបានយល់អំពីការផ្សាយចូលមកនៃព្រះពុទ្ធសាសនា តាំងនៅក្នុងដែនដីឥណ្ឌូស៊ីននេះ តាំងពីសម័យដំបូង (រហូតមក) ។

---

១ ទុកជាពាក្យថា ថេរវាទ ល្អជាងពាក្យថា ហីនយាន ក៏ប៉ុន្តែពាក្យក្រោយនេះ យើងធ្លាប់ប្រើនឹងជាទីផ្ចិតផ្ចាប់ដឹងឮរាល់គ្នាច្រើនជាងពាក្យមុន ។ ២ ត្រង់ពាក្យដែលហៅថា ឥណ្ឌូស៊ីននេះ មិនមែនគ្រាន់តែរាប់រួមប្រទេសទាំងប៉ុន្មានក្នុងសព្វថ្ងៃនេះ (គឺអណ្ណាម, កម្ពុជា, តុងកឹងនិងកូសាំងស៊ីន) ទេ គឺពោលរាប់រួមទាំងប្រទេសសៀមនិងភូមាផង ។ តាមផ្លូវសាសនានិងផ្លូវចំណោះក្នុងរវាងប្រទេសអស់នេះតែងមានជាប់តមកតាំងពីដំបូងមកជាមួយគ្នា ។

ការផ្សាយចូលមកនៃលទ្ធិសាសនានេះ ដោយសារតែសេចក្ដីប្រឹង-ប្រែងរបស់គណៈសង្ឃ និងអំណាចរបស់មហាក្សត្រព្រះអង្គនេះ ដោយទ្រង់ជាមហាក្សត្រដ៏ថ្កុំថ្កើងរុងរឿង ១ អង្គ មិនមែនមានសេចក្ដីដំណាលតែក្នុងពង្សាវតារពុទ្ធសាសនាប៉ុណ្ណោះទេ សូម្បីក្នុងពង្សាវតារលោកក៏មានសេចក្ដីដំណាលដែរ ។ នៅក្នុងរជ្ជសម័យរបស់ព្រះអង្គ ព្រះពុទ្ធសាសនាមានសេចក្ដីចំរើនរុងរឿងណាស់ តាំងពីពុទ្ធសករាជ ២៧០ ដល់ ៣១៦ (ខ្លះថាពុទ្ធសករាជ ២៧៣ ដល់ ៦៣៣) ហើយតាំងពីព្រះអង្គមានព្រះទ័យជ្រះថ្លានឹងពុទ្ធសាសនា ទ្រង់តាំងព្រះទ័យទំនុកបំរុងសាសនាថ្មីនេះយ៉ាងម៉ឺងម៉ាត់ ទ្រង់រៀបចំឲ្យល្អស្អាត ទ្រង់សិក្សាឲ្យចេះដឹងជ្រៅជ្រះ ទ្រង់ឲ្យប្រកាសផ្សាយពុទ្ធសាសនាឲ្យកាន់តែចំរើនច្រើនឡើងទៀតជាអនេក មិនមែនតែក្នុងប្រទេសឥណ្ឌាតាំងមូលទេ ទុកជាខាងក្រៅព្រំប្រទល់នៃមហាណាចក្ររបស់ទ្រង់ដែលជាប្រទេសខាងក្រៅពីប្រទេសឥណ្ឌា ក៏ទ្រង់ឲ្យចាត់ការផ្សាយពុទ្ធសាសនាដែរ ។

កាលពីពុទ្ធសករាជ ២៤៥ (ខ្លះថា ព. ស. ២៩៨) នោះទ្រង់ឲ្យប្រជុំសង្ឃធ្វើតតិយសង្គាយនានៅក្នុងក្រុងបាតលីបុត្រ ខណៈនោះក្រុមជំនុំសង្ឃបានចាត់បញ្ជូនគណៈធម្មទូតជាអ្នកប្រកាសសាសនាជាចំនួនច្រើនឲ្យចេញទៅក្នុងអាស៊ីខាងមុខ នឹងបណ្ដាប្រទេសដែលមានព្រំប្រទល់តៗគ្នា

ទៅ ៗ ប្រទេសផ្សេងៗដែលគណៈធម្មទូតចេញទៅប្រកាសផ្សាយពុទ្ធសាសនាមាន៩ប្រទេស ៗ ប្រទេសដែលត្រូវព្រះថេរៈពីរអង្គ គឺព្រះសោណៈនិងព្រះឧត្តរៈចេញប្រកាសផ្សាយព្រះពុទ្ធដីការបស់ព្រះបរមសាស្តានោះចំពោះប្រទេស ១ ដែលហៅថា "សុវណ្ណភូមិ" ប្រែថាដែនដីមាស ប្រទេសនេះនៅជាខាងត្បូងឆៀងខាងកើតនៃប្រទេសឥណ្ឌា ដែលជាចំហៀងខាងកើត ស្រុកបេគូ, ដែនដីស្ទួច អ៊ីរ៉ាវ៉ាឌី និងប្រទេសភូមាក្រោម ដែលជាប្រទេសមានជនជាតិមននៅ ដែលជាជាតិមានសំដីភាសាដូចជាខ្មែរដែរ ៗ

តាមដែលពោលមកនេះមិនទាន់ធ្វើឲ្យយើងដឹងច្បាស់អំពីការទេសនាប្រកាសសាសនាដំបូងនោះនៅត្រង់កន្លែងណា នៅឡើយ ហើយហាក់ដូចជាពុទ្ធសាសនាមិនទាន់មានសេចក្តីចំរើនធំដុំទេក្នុងគ្រានោះ ៗ

មួយវិញទៀតតាមពួកអ្នកតែងរឿងជាច្រើនពោលថា ក្នុងសតវត្សរ៍ដំបូង......មានពួកព្រាហ្មណ៍ពីស្រុកការណាត បាននាំយកសាសនាព្រាហ្មណ៍មកប្រកាសផ្សាយក្នុងស្រុកអស់នេះ ៗ គេយល់ថា តាំងពីលទ្ធិសាសនារបស់ឥណ្ឌាជាន់ដើមដំបូងដែលផ្សាយចូលមកក្នុងប្រទេសឥណ្ឌូស៊ីននេះ មានសាសនាព្រាហ្មណ៍និងពុទ្ធសាសនាលាយច្របល់គ្នា ទើបយើងមើលឃើញមានលទ្ធិសាសនាទាំងពីរជាប់គ្នារហូតមកថ្មីៗនេះឯង ៗ លទ្ធិសាសនារបស់ឥណ្ឌាទាំងពីរនេះ បានផ្សាយចូលមកក្នុង

ប្រទេសកម្ពុជានឹងចម្ប៉ាមុនគេបង្អស់ ព្រោះមានសិលាចារឹកជាន់ចាស់បំផុតមួយនៅក្នុងប្រទេសឥណ្ឌូស៊ីន ផងស្រុកញ៉ាត្រាង ក្នុងស្រុកអណ្ណាមខាងត្បូង (ស្រុកចម្ប៉ាបុរាណ) ។ សិលាចារឹកនេះជាភាសាសំស្ក្រឹតតាំងពីសតវត្សរ៍ទី ២ ឬសតវត្សរ៍ទី ៣....(ពុទ្ធសករាជ ៦៤៣ ដល់ ៧៤៣) នេះហើយដែលធ្វើឲ្យយើងដឹងច្បាស់ថា ក្នុងតំបន់នេះហើយដែលមានអារ្យធម៌ឥណ្ឌៀនឹងពុទ្ធសាសនាមកតាំងនៅ ។

លុះតមកបន្តិចទៀត យើងបានប្រទះឃើញតឹកតាងមួយនៅតំបន់ស្រុកបេគូ ដែលជាស្នាដៃរបស់លោកអ្នកប្រកាសផ្សាយសាសនា ១រូបទៀត ឈ្មោះថា ពុទ្ធឃោសៈ លោកនេះជាអដ្ឋកថាចារ្យមួយដ៏ល្បីល្បាញបំផុតក្នុងសំណាក់ថេរវាទ ។ ព្រះពុទ្ធឃោសៈបានចូលទៅនៅក្នុងក្រុងអនុរាធបុរៈ ក្នុងរាជសំណាក់ស្តេចមហានាម ពោលតាមក្រមព្រះរាជនិពន្ធនៃប្រទេសស៊ីឡូនថា នៅខាងដើមនៃសតវត្សរ៍ទី៥...(ពុទ្ធសករាជ ៩៤៣) ។ កំណត់នេះត្រូវនឹងទំនៀមប្រពៃណីពីបុរាណរបស់ភូមាថា ក្នុងសម័យជាមួយគ្នានេះ ព្រះពុទ្ធឃោសៈនិមន្តមកដល់ឆ្នេរសមុទ្រមោតាបន ព្រោះហេតុនេះហើយ បានជាមានសេចក្តីដំណាលក្នុងគម្ពីរបាលីក្នុងប្រទេសឥណ្ឌូស៊ីននេះ ។

សរុបរួម — ខ្សែស្រឡាយពុទ្ធសាសនាដំបូងរបស់ប្រទេសឥណ្ឌូស៊ីននេះ ជាពួកហីនយាន សឹងមានគោលចារិកតាមភូមិសាស្ត្រនៅក្នុង

ស្រុកក្តមានឹងស្រុកសៀមស្រាប់ ៗ តំបន់នេះហើយដែលជាច្រកឲ្យជាផ្លូវចូលមកនៃលទ្ធិសាសនារបស់ឥណ្ឌា ទើបជាហេតុឲ្យពុទ្ធសាសនានឹងព្រហ្មញ្ញសាសនាផ្សាយចូលទៅក្នុងប្រទេសហ្វូណនយ៉ាងឆាប់រហ័សព្រមៗគ្នា គឺត្រង់ប្រទេសដែលហៅថាក្រុងកម្ពុជាសព្វថ្ងៃនេះ នឹងប្រទេសលាវខាងត្បូង ៗ មានព្រះថេរៈជាតិឥណ្ឌា ១ អង្គឈ្មោះព្រះនាគសេនៈ ៗ នេះហើយដែលក្សត្រប្រទេសហ្វូណនទ្រង់ព្រះនាមកោណ្ឌិញ្ញជយវរ័ន ទ្រង់បញ្ជូនទៅគាល់ស្តេចចក្រពត្តិស្រុកចិននោះ នាំឲ្យយើងបានដឹងល័ក្ខណ៍ដោយសារសេចក្តីរាយការដែលលោកបានធ្វើទុកក្នុងឆ្នាំ ៤៨៤ . . . . . . . (ពុទ្ធសករាជ ១០២៧) ៗ ក្នុងសេចក្តីរាយការនេះ ព្រះនាគសេនបានបង្អួលឲ្យឃើញច្បាស់ថា លទ្ធិសាសនាទាំងពីរនេះសាយភាយពាសពេញទាំងស្រុកហ្វូណន គឺសាសនាព្រះមហេស្វរៈ (សិវៈ) នឹងពុទ្ធសាសនា ៗ

ការផ្សាយចូលមកនៃលទ្ធិសាសនាធំៗរបស់ឥណ្ឌាទាំងពីរនេះ សឹងមានអាការស្ងប់ស្ងាត់ល្អណាស់ មានអាការសន្សឹមៗ ចូលមកក្នុងស្រុកខ្មែរដោយស្រួល ដោយលោកសង្ឃពុទ្ធសាសនាខ្លះ ដោយពួកព្រាហ្មណ៍ខ្លះ ពួកអ្នកជំនួញខ្លះ ពួកជាងរចនាខ្លះ ពួកអ្នកត្រាច់ចរខ្លះ ៗ មួយវិញទៀត សាសនាទាំងពីរនេះមានសេចក្តីចំរើនឡើងទាំងគូស្មើគ្នា នឹងមានអាការប្រែប្រួលប្រែបល់គ្នា ទើបយើងមើលឃើញច្បាស់នូវស្នាមគំនូស

នៃការប្រែប្រួលខាងលទ្ធិសាសនាក្នុងមហាអាណាចក្រខ្មែរ រហូតមកដល់សតវត្សរ៍ទី១៣ (ពុទ្ធសករាជ ១៧៤៣) ។ គេបានប្រទះឃើញក្នុងចំណោមប្រាសាទដែលបានកសាងឡើងមុនសម័យអង្គរនោះ នៅតំបន់ខ្លះមានដំកល់រូបសិវលិង្គ ឬរូបព្រះវិស្ណុ ទឹងរូបព្រះសិវៈដែលហៅថា ព្រះហរិហរៈ ជួនកាលនៅតំបន់ខ្លះមិនមានសោះ មានតែព្រះពុទ្ធរូបដូចជានៅមង្គលបុរី ។

(មានតទៅទៀត)

# កាលពី ១៦ ខែមុន

កាលពីថ្ងៃ ២៥ ខែអុិត ឆ្នាំ ១៩៣៩ វេលាម៉ោង ១៩,៣០ នាទី មានបណ្ដាជនជាច្រើនឈរនៅមុខមន្ទីរក្រុមឃោសនាការ ក្រុងព្រៃនគរ ។

មានហេតុអ្វីនៅទីនោះប្ដុំៗមួយនៅចាំស្ដាប់ការផ្សាយសេចក្ដីអ្វីប្លែកប្លែកពីធម្មតា?

ទេ! បណ្ដាជនទាំងនោះមិនមែនឈរចាំស្ដាប់ដូច្នេះទេ គឺមកមើលរថយន្តដែលជូនពួកកុមារថៃឡង់ដែសដែលមានវិជ្ជាបានសញ្ញាបត្រសាលាវិទ្យាល័យ ៨៦ នាក់ទើបនឹងមកដល់ ។ កុមារទាំងនោះ គឺជាការបារាំង-សែសដែលនៅប្រទេសឥណ្ឌូចិនបានបបួលឲ្យមកមើលស្រុកទាំងឡាយនៅដែនប្រទេសឥណ្ឌូចិន ។

លុះចុះពីរថយន្តមក ពួកកុមារទាំងនោះក៏នាំគ្នាលីលាចូលទៅកន្លែងវិទ្យុសព្ទ ។ នៅវេលាល្ងាចនោះយើងចាំច្បាស់ថា គ្រឿងវិទ្យុសព្ទរបស់យើងបានទទួលផ្សាយសេចក្ដីអធិប្បាយដោយរីករាយអំពីការមេត្រីរបស់ថៃនឹងបារាំងសែស ហើយនឹងសេចក្ដីប៉ងចង់ឲ្យប្រទេសថៃនឹងប្រទេសឥណ្ឌូចិនបារាំងសែសរួបរួមគ្នា ដើម្បីឲ្យចំណេះវិជ្ជាប្រទេសទាំងពីរនេះបានចេះដឹងដូចគ្នាឡើង ។ មានប្រទេសខ្លះចំជាមានស្មារតីគិតពន់ពេក ។

ខ្ញុំបាននិយាយថា មានកុមារី ៤៦ នាក់ ឫកពាសុភាពហើយជាអ្នកមានសញ្ញាបត្រដោយច្រើន បានចូលទៅក្នុងកន្លែងវិទ្យុផ្សាយសព្ទ មានកុមារីមួយនាក់បានមកឈរនៅមុខគ្រឿងវិទ្យុ ហើយបានថ្លែងជាភាសាបារាំង-សែសដ៏សំខាន់ ថាពួកក្រុមនាងនឹងខ្លួននាងមានសេចក្តីរីករាយជាទីបំផុត ដោយគេទទួលរាក់ទាក់គ្រប់តំបន់; ពួកក្រុមនាងនឹងនាងសង្ឃឹមថា “នឹងបានយល់មិត្តខាងប្រទេសឥណ្ឌូស៊ីន, នឹងទៅលេងនឹងនាងឯប្រទេសថៃវិញ” ហើយមុននឹងបញ្ចប់សេចក្តី នាងបានសុំតថា សេចក្តីមេត្រីរបស់បារាំងសែស · ឥណ្ឌូស៊ីននឹងថៃសុំឲ្យវឌ្ឍនាការដោយយូរអង្វែងតទៅ ។

តមក មានកុមារីមួយទៀតមានរូបល្អឯក បានចូលមកមុខគ្រឿងវិទ្យុសព្ទហើយបានអធិប្បាយជាភាសាអង់គ្លេស បើប្រសិនជាពិតដូចខ្ញុំចាំ នាងនោះប្រហែលជាអធិប្បាយសរសើរអំពីក្បាច់រចនារបស់ខេមរជាតិ ហើយថ្លែងសេចក្តីស្ញប់ស្ញែងដោយបានឃើញដំណែលប្រាសាទបន្ទាយខ្មែរ ។

ចុងបំផុត មានកុមារីមួយទៀត បានអធិប្បាយជាភាសាថៃដូចនាងមុនទាំងពីរ ដើម្បីឲ្យមាតាបិតាញាតិកានឹងមិត្តសម្លាញ់ដែលនៅឯស្រុកដឹងថា នាងទាំងឡាយដល់ទៅទីតំបន់ណា ៗ ហើយ ។

អាកាសនៅកន្លែងវិទ្យុរបស់យើងក្នុងវេលានោះត្រជាក់ត្រជុំ ជាទីរីក

ភយដ៏ប្រសើរ យើងទាំងអស់គ្នាបានជឿជាក់ថាពាក្យដែលស្រែកថាជំ-ណាន់ប្រទេសថៃឡង់ដ៍ បានថ្លែងដូចខាងលើនេះជាពិតប្រាកដតែម្តង ។

ឥឡូវនេះ យើងបានយកកាសែតដែលនិយាយអំពីដំណើរកុមារីទាំងនោះមកមើលឡើងវិញ យើងភ្ញាក់ខ្លួនដោយបានឃើញសុន្ទរកថារបស់លោកនាយកប្រទេសកម្ពុជា បានឲ្យសព្ទសាធុការពរដល់ពួកកុមារីដែលមកទាំងប៉ុន្មាន ឲ្យបានសេចក្តីសុខក្សេមក្សាន្ត ហើយបានអធិប្បាយតទៅទៀតថា:

“នៅឱកាសដែលប្រទេសនឹងប្រទេសកស្ត្រគ្នាច្រើនយ៉ាងដូច្នេះ ខ្ញុំមានសេចក្តីសោមនស្សដោយបានឃើញថាប្រទេសនាងឥតលះបង់វិជ្ជាស្រុករបស់នាងទេ ហើយថែមទាំងទទួលរៀនយកវិជ្ជាខាងបស្ចិមប្រទេសដោយសោមនស្សទៀតផង ។

នែអ្នកស្រី, នាងក្រមុំ! អ្នក, នាងទាំងឡាយកប់ថាស្រួចជាងជាតិអ្នក, នាងទាំងអស់ ព្រោះខ្ញុំទុកអ្នក, នាងទាំងឡាយដូចជាអាយតនៈសម្រាប់ភ្ជាប់អារ្យធម៌ទាំងពីរ (គឺអារ្យធម៌ថៃនឹងអារ្យធម៌បស្ចិមប្រទេស) បាននាំឲ្យជួបគ្នាហើយបានបញ្ចូលគ្នាដោយនយោបាយ ដើម្បីឲ្យបានចំ-រើនដោយស្រួល ឲ្យបានផលប្រយោជន៍ បើប្រសិនជាជួបគ្នាដោយបំ-ណងបង្អួតជាក់គ្នា អារ្យធម៌ទាំងពីរមុខជានឹងទង្គិចគ្នា ហើយនឹងឃ្លាតឆ្ងាយពីគ្នាពុំលែងឡើយ” ។

“បើគិតអំពីចំណេះវិជ្ជាវិញ បណ្ដាជនដែលយកចិត្តទុកដាក់តែងតែនឹងរកយោបល់យល់ឃើញជាដរាប បើបានព្រមព្រៀងគ្នាយ៉ាងដូច្នេះហើយ នឹងចំណេញបានចេះវិជ្ជាដែលបណ្ដាជនប្រទេសនីមួយៗ គេឃើញ” ។

“ខ្ញុំគិតថា សេចក្ដីរាងទក៏នឹងរលាយបង់ ប្រសិនណាបើបណ្ដាជនប្រទេសដទៃពីគ្នា បានស្គាល់គ្នារឿយៗ ។ ហេតុដូច្នេះ ដំណើរដែលអ្នក, នាងៈធ្វើមកប្រទេសឥណ្ឌូស៊ីននេះ នឹងនាំឲ្យចំណងមិត្តមេត្រីដែលចងប្រទេសថៃឡង់ទ៍នឹងប្រទេសកម្ពុជាកាន់តែជាប់ឡើងទៀត” ។

ពាក្យនេះឥឡូវឃើញសំខាន់ណាស់ សំខាន់ជាងកាលដែលកំពុងថ្លែងទៅទៀត ព្រោះពាក្យនេះនាំឲ្យបណ្ដាជនដែលនៅក្រៅដែនយើងគិតពិចារណា ហើយយល់ច្បាស់ថា អ្នកណាមានចិត្តប៉ងនឹងវាយអ្នកជិតខាងរបស់ខ្លួនមុន ។

នេះ

ច្បាប់សុភាសិត

ប្រសើរពេកពិត ប្រែពីគាថា
បន្ទូលព្រះពុទ្ធ បំហុតទេស្មា
ឲ្យអស់ទាំងមហា- ជនផងត្រងត្រាប់ ។

និព្វានបច្ច័យោ ហោតុ មេ ។

របស់

ឧកញ៉ាវង្សាសារពេជ្ញ នង ចាងហ្វាងក្រុមរាជបណ្ឌិត

ក្នុងរាជ្យព្រះបាទសម្ដេចព្រះហរិរក្សរាមាឥស្សរាធិបតី

(ព្រះអង្គដួង) ។

(តមក)

ចំហុតផលំ សតកប្បំ រយកប្បបាបបាត់ ៗ ពាក់បីរសប្បាន បានផល មួយពាន់ កាលកប្បទៀងទាត់ ចប់ត្រៃសរណា- គមនាផលខ្ជាត់ មួយសែនកប្បកាត់ បាបបានបុណ្យថ្លៃ ៗ នាអ្នកកាន់សីល ព្យាយាម ពុំខ្ចីល ទីងព្រះរត្នត្រ័យ បានថ្វាយបង្គំ ប្រណម្យសព្វថ្ងៃ ផលបុណ្យ បានក្រៃ ឯកអនន្តំ ៗ

១១— មិត្តសត្យោ ករុសធម្មោ សុខេនវិន្ទំ ជរុ- សេនា- រិបតាបរំ ជនសម្បន្នំ អដ្ឋចិត្តំ ៗ ពាក្យនេះ លោកថា នរអ្នកណា ចង់ចងមេត្រី ឲ្យមានពាក្យសត្យ បរមត្ថពាទី ទោះរៀនធម៌ក្តី កុំមុសាវាទ ៗ ទោះបីនឹងរៀន ចំណេះរបៀន អាគម សិល្បសាស្ត្រ ឲ្យមានត្រណម តឹងតមកុំឃ្លាត បើនឹងប្រុសប្រា- ថ្នា ចង់បានស្រី ៗ ឲ្យមានពាក្យនោះ ផ្អែមល្ហែមពីរោះ ជាមិត្រមេត្រី ចង់មានសម្បត្តិ ថេរបិតវឌ្ឍី យឺនយូរកុំបី បៀតបៀនទ្រព្យគេ ៗ

១២— យោអនង្គំ វនត្វានំ ជកកាលេ សហស្ស- ការំ បិណ្ឌំភេគេ ព្យាធិសនេ មរណំឯកំ ៗ លោកថានាកាល នៅក្មេងពេញពាល កាត់សព្វខ្លាំង បែកបាយធនធាន ជាទានសេដ្ឋ ធ្វើមួយកំឡាំង បានមួយអនន្ត ៗ លុះខ្លួនចាស់បាន ធ្វើបុណ្យឲ្យទាន មួយជាមួយពាន់ កាលខ្លួនមានព្យាធិ៍ អាពាធទុរន់ ឲ្យទានមួយគុណ បានមួយរយនៅ ៗ កាលខ្លួនមរណ៍ចាក ឃ៉ានលែងលះលោក ចេញ

ពោលកូនចៅ ធ្វើបុណ្យបន្ទោះ ចំពោះជូនទៅ មួយជាមួយនៅ ដើម
ដែលវិញណា ។

១៣ – សុទិនជំ គេហេវំ មិត្តករិយា កជ្ជិយេ
កាលេវក វរិដ្ឋា បុញ្ញោមិត្តំ ។ ព្យាធិបិន្ធុ- កាលេវ-
មិត្តោសជំ មរណកាលេ ធម្មោវំ មិត្តជាជំ បរលោកេ ។
ធម៌ជាឋានឋិត បើបានចាំងបិទ ដុំដិតគេហេ វិករិយាយំ មិត្តំពន្ធេ
ជាមិត្រវរ វរិឧត្តមោ ។ កាលណាបើបាន ចរចេញចាកឋាន ទៅ
ទូរគោ អគ្គិអនាថំ មិត្តំបុញ្ញោ វិជ្ជាសោវេជ្ជោ ជាមិត្តវំ ។ កាលកើត
អាពាធ ជារោគរូបព្យាធិ៍ បិន្ទារូបំ បៀតបៀនទល់ទុក្ខ ពុំសុខកាយំ
ឯទុសជំ ជាមិត្រមាតា ។ កាលខ្លួនមរណ៍ទៅ លះលែងលំនៅ ភូមិភព
មនុស្សា មានតែព្រះធម៌ សម្មាថ្លៃថ្លា ជាមិត្រស្នេហា ពំនាក់រុំបា ។

១៤ – អហាពស្ស សតំធាធា សហស្សបុណ្ណា
ចសង្ក្រាន្តំ សតំសហស្សា ភាហុចេដ្ឋោ ចអជន្តំ ។

លោកថាឲ្យទាន ថ្ងៃពុំសីលបាន ផលរយកំឡាំង ឲ្យទានថ្ងៃ
ពេញ បុណ្ណមីយំ សហស្សគុណំ បានបរិបូណ៌បុណ្យ ។ ថ្ងៃមហា
សង្ក្រាន្ត ឲ្យទានសោតបាន ផលមួយសែនគុណ ថ្ងៃគ្រោះបើបាន
ឲ្យទានទ្រព្យធន បានមួយអនន្ត- គុណផលសេដ្ឋំ ។

១៥- បស្សុសលា សរោសោ ភទិសម្ពុំ តស្សស-
រោ សេោរ៉ំ និត្តិយំ សោតាលា ។ មលាធាបេ សោ-
ភរេ ឧទុសក្តា- មចសោ កាមយោពន្ធា សោអាបា-
រសសោ ។ នាគារ៉និ- ច្ចយគារ៉ សោឧម្មោ តិលោកានំ
វរំសេដ្ឋោ អាចរិយោ បកាសិតា ។ វរសក្រសាល ត្រអាល
ខៀវខ្ចារ សាន្តសោមនស្ស ពុំស្មើគតទុក្ខ សាន្តសុខចិន្តា វរសរាជា
ពុំស្មើពាក្យសត្យ ។ សួរក្លិនដទៃ ពុំស្មើស្រទៀប ធ្លុះលេចឡើងខ្លាត
សេអកុសល អំពល់បាបបាត មិនក្រែអ្នកកាត់ ស្រឡាញ់បាបបាន ។
សេឯចម្បាំង សឹកសោតតតាំង គ្រឿងគ្រប់ប្រុងប្រាណ ពុំស្មើធ្មជ័យ
ពាក់វៃបាញ់បាន សេកាមាមាន មិត្រមូលពាស្អា ។ មិនក្រែទឹងក្លោះ ក្រ-
មុំកាន់កោះ ក្តួបកើតកាមា ឯអស់អាហារ ត្រកាលឧជា- សេវៃងពិសា
មិនក្រែទឹងឃ្លាន ។ វរសបង្គាប់ សេចក្តីប្រៀបប្រាប់ ពុំស្មើអ្នកមាន
ប្រាជ្ញាឈ្លាសវៃ សេក្រែកពហាន ប្រសើរសោតមាន តែព្រះធម្ម ។

១៦- ជានាសយេ កជពន្ធេ មិកយា គមេអប្ប-
ឧសតថា មិត្តនាភ វិករខ្យេ ។ ចង់ដឹងពុតអា- មាត្យតាល់
ក្សត្រា ជាម្ចាស់សិរេ បេញអន្ទ័យគាល់ ផ្ចាប់ផ្ចាល់រេះរេ ដឹងចិត្ត
ញាតិប្រៃ កាលកើតភ័យខ្នី ។ គោះខ្ទូវចង់ជាក់ ដឹងចិត្តភ្លើម្រាក់

សំឡាញ់ក្លាប្រិយ កាលកើតកម្មកល ដូចផល់មានក្តិ ចង់ដឹងពុតស្រី កាលថ្ងស់ទ្រព្យ ។

១៧– យោចពាលោ ឥត្ថីធុត្តោ អក្ខសុរា- ធុត្តោ- ជធំ លទ្ធំវិជា- សេតិបរា- ករពោមុខំ ។ នាអ្នកខ្លៅល្ងង់ វង្វេងចិត្តចង់ ស្រឡាញ់ល្បែងខ្លាំង ល្បែងស្រីល្បែងស្រា បៀបា ស្កាតាំង ធនធានដំណាំង ស្រើបស្រាលពុំធូន ។ អ្នកនោះនឹងមាន ក័យកិតព្រួយព្រាណ ដំទៀលអន្តអ- ន្តរធានខ្លាត់ខ្លាយ ខូចខាយទ្រព្យ ធន ទល់ទុក្ខទុរ័ន លុះបរលោក ។

១៨– យោរូបះយា- ពួនសម្បន្នោ វិសាលកុលំ សុសម្ភរ វិជ្ជាហីនំ ឥត្ថិគន្ធំ ឥវកឹសុកា ។ អធិអ. ធិប្បាយ បន្ទរស្រេចស្រាយ បទបាលីថា អ្នកណាមួយមាន សន្ថាន ថ្ងៃថ្លា រូបពងសោភា សុភាពពបសារ ។ បើឥតចំណេះ ប្រាជ្ញាពុំចេះ សិល្បសាស្ត្រពេហារ ពុំពេញជាមនុស្ស ទុរយសត់កការ ដូចកល់ ផ្កាចារ ឯងឥតគន្ធំ ។

១៩– ឥត្ថីជលោ រូបំយុរិសោ ជនកុលំ សប្បោធាម ពលវិសំ រជាជាមំ ជនពលោ ។ ពាក្យពិតធមិថា ស្រីយក រូបជា ទ្រព្យអន្តអគ្គា ប្រុសយកទ្រព្យា ជាក់ជាវង្សា វង្សាវពេ

(មានត)

# ពង្សាវតារក្រិក (តមក)

## វគ្គទី ៣

### អំពីសង្គ្រាមក្រិកនិងប៉ែរ្ស

ពួកក្រិករួមកំឡាំងគ្នាតទល់នឹងពួកម៉ែត្រនឹងពួកប៉ែរ្ស ក្នុងរវាងកណ្ដាលសតវត្សរ៍ គឺតាំងពីពុទ្ធសករាជ ៣៤ ដល់ពុទ្ធសករាជ ៨៥ (មុនគ្រិស្តសករាជ ៥០០ ដល់ ៤៤៩) ។ យើងបានដឹងរឿងរ៉ាវពង្សាវតារសង្គ្រាមគ្រានេះបានល្អិតល្អដោយសារអ្នកប្រាជ្ញពង្សាវតារជាតិក្រិកម្នាក់ឈ្មោះ ហេរ៉ូដូត៍ បានដំណាលសេចក្ដីយ៉ាងពិស្ដារទុកក្នុងកាលដែលខ្លួនមានជីវិតនៅឡើយ ក្នុងវេលាកើតចម្បាំង ។ សង្គ្រាមគ្រានេះ ពួកក្រិកបានប្រុងប្រៀបការពារសេរីភាពរបស់ខ្លួនយ៉ាងក្លាហាន ហើយមានជ័យជំនះយ៉ាងប្រពៃ ដែលគួររាប់ថាជាគ្រាដំបូងដែលពួកឦរុបមានជ័យជំនះពួកអាស៊ី ដែលគួររាប់ថាពួកប្រជាធិបតេយ្យមានជ័យជំនះពួករាជាធិបតេយ្យ តែគង់មិនមែនពួកមានអារ្យធម៌ឈ្នះពួកអនារ្យធម៌ ដូចមានក្នុងពង្សាវតាររបស់បារាំងខ្លះនោះទេ ព្រោះតាមដោយពិត ពួកម៉ែត្រនឹងពួកប៉ែរ្សក្នុងសម័យជាមួយគ្នានេះ មានសេចក្ដីចំរើនប្រហែលក្រិកឬជាងក្រិកទៅទៀត ។

ហេតុដែលកើតចម្បាំងឡើងក្នុងគ្រានេះ ដោយហេតុពួកក្សត្រប៉ែរ្ស៍ត្រូវការរកអាណាខេត្តរបស់ខ្លួនទៅទិសខាងលិច ព្រោះខេត្តរបស់ក្សត្រដារិយុស របស់ប្រទេសប៉ែរ្ស៍នោះ មានសមុទ្រខ្សាច់នឹងសមុទ្រទឹកព្រមទាំងភ្នំដែលធ្ងន់កាត់បានដោយលំបាកស្ទាក់នៅពីខាងមុខ ៗ ផ្លូវដែលស្រួលជាបំផុតនោះគោងផ្សាយអាណាខេត្តមកខាងប្រទេសក្រិក ៗ ហេតុនេះបានជាប្រទេសប៉ែរ្ស៍ផ្តើមចាប់យកពួកក្រិកដែលនៅក្នុងអាស៊ីមករួមនៅក្នុងអំណាចទាំងអស់ ហើយនៅមានបំណងចង់ផ្សាយអំណាចចូលមកដល់អាណាខេត្តរបស់ក្រិកថែមទៀត ដែលពួកម៉ែត្ស៍និងពួកប៉ែរ្ស៍យល់ថាគង់នឹងវាយយកបានដោយស្រួល ព្រោះប្រទេសក្រិកទាំងឡាយក្រៅពីស្រុកស្ប៉ាតមួយចេញ មិនមានប្រទេសណារឹងប៉ុងក្នុងកំឡាំងចម្បាំង ៗ ទុកជាស្រុកអាថែនខ្លាំងពូកែតែខាងហត្ថកម្មនិងពាណិជ្ជកម្មក្រៅពីនេះហាក់ដូចជាមិនមានអាណាចក្រដទៃរឹងប៉ឹងល្មមនឹងទប់ទល់នឹងកំឡាំងរបស់ប្រទេសប៉ែរ្ស៍បាន ៗ

សង្គ្រាមរវាងពួកក្រិកនឹងពួកប៉ែរ្ស៍នេះ ចែកចេញជា ៣គ្រា គឺៈ

១ សម័យក្សត្រដារិយុស – សង្គ្រាមកើតឡើងកាលពីពុទ្ធសករាជ ៤៣ កើតនៅស្រុកមិលេត៍ៗ នេះជាស្រុកតូចៗមួយនៅក្នុងអាស៊ី ប្រជាជនជាពួកអ៊ីអូនីយ៉ែនដែលជាចំណុះពួកប៉ែរ្ស៍នោះតាំងបះបោរចលាចលឡើង ៗ ឯពួកអាថែនដែលចាំតែគន់មើលចន្លោះឱកាសនឹងផ្តាច់អំណាចរបស់ពួក

ប៉ែរ្សក៏ចូលជួយកំឡាំងពួកបះបោរ ហើយនាំគ្នាដុតបំផ្លាញមន្ទីររដ្ឋបាលរបស់ប៉ែរ្សចេញអស់ ហើយនៅឱកាសនេះឯង ស្រុកក្រិកដទៃៗទៀតដែលនៅក្នុងអំណាចរបស់ប្រទេសប៉ែរ្សក្នុងទ្វីបអាស៊ី ក៏នាំគ្នាបះបោរឡើងដែរ ដោយមានសង្ឃឹមថាស្រុកក្រិកធំៗដូចអាថែនឬស្ប៉ាតនឹងចូលមកជួយជាកំឡាំងតទៅ តែដារីយុសក្សត្រប្រទេសប៉ែរ្សបានអាស្រ័យកំ-ឡាំងជំនួយពីពួកហ្វេនិសៀន ទើបប្រាបប្រាមពួកក្បត់បានក្នុងរយៈវេលា ៦ ឆ្នាំ ។

ការដែលស្រុកក្រិកតូចៗកើតបះបោរចលាចលឡើង ដោយបានកំឡាំងជំនួយពីស្រុកធំៗដូចជាអាថែនជាដើមដូច្នេះ ទើបដារីយុសមានព្រះទ័យចង់ព្យាបាទអាថែន លុះតមក ៣ ឆ្នាំទៀត ក្នុងពុទ្ធសករាជ ៥១ ក៏បញ្ជូនកងទ័ពចេញពីប្រទេសប៉ែរ្សជាដំបូង តែទូកដែលផ្ទុកទាហាននោះត្រូវខ្យល់ព្យុះបក់បោកបែកកណ្ដាលផ្លូវអស់ទៅ ។

លុះពីរឆ្នាំតមក ក្នុង ព. ស. ៥៣ ដារីយុសក៏បញ្ជូនរាជទូតទៅកាន់ស្រុកផ្សេងៗរបស់ក្រិក ដើម្បីឲ្យស្រុកក្រិកទាំងឡាយព្រមនៅជាចំណុះដោយស្រួល កុំបីគិតគួរបះបោរចលាចលឡើយ ។ ស្រុកខ្លះដែលខ្លាចបុណ្យអំណាចរបស់ប្រទេសប៉ែរ្សក៏មិនហ៊ានរឹងទទឹង ព្រមនៅជាចំណុះ លើកលែងតែអាថែននឹងស្ប៉ាតដែលបែរត្រឡប់ជាចាប់អគ្គ-រាជទូតប្រទេសប៉ែរ្សសម្លាប់ចោលទៅ ជាគ្រឿងសំដែងថានឹងប្រកាស

សង្គ្រាម ហេតុនេះជាវេលាមិនយូរប៉ុន្មាន ក៏មានទូកចម្បាំងរបស់ប៉ែរ្ស ចំនួន ៦០០ នាំពាហានមកឡើងនៅទីវាលមួយ ហៅថា ម៉ារ៉ាតុង មាន ចំងាយពីស្រុកអាថែន ៧ គីឡូម៉ែត្រប៉ុណ្ណោះ ។

ក្រុងអាថែនបានពោលមកហើយថាមិនមានកំឡាំងខ្លាំងពូកែខាងពិ-ជ័យសង្គ្រាមប៉ុន្មានទេ ទាំងដឹងខ្លួនច្បាស់ថាមិនអាចនឹងទប់ទល់តដៃនឹងកំឡាំងទ័ពដ៏ធំសំបើមរបស់ប៉ែរ្សតាមទំនើងខ្លួនឯងបាន ទើបខំព្យាយាមសុំជំនួយពីស្រុកឯទៀត តែមិនសម្រេចតាមបំណង ក្រុងអាថែនក៏ត្រូវតែខំប្រឹងតទល់តែម្នាក់ឯង ។ ចួនជាមានគ្រោះល្អណាស់ ក្រុងអាថែនបានមេទ័ពម្នាក់យ៉ាងចំណាប់ ឈ្មោះ មិល្ទីអាត បានខំព្យាយាមទប់ទល់ ពាល់តែប៉ែរ្សវាយយកជ័យជំនះពុំបាន ក៏លើកលែងច្បាំងហើយលើកទ័ពត្រឡប់ទៅស្រុកវិញ ។ គ្រានេះហើយដែលក្រុងអាថែនឈ្មោះថាបានជួយស្រោចស្រង់ពួកក្រិកទាំងពួងឲ្យមានឥស្សរភាពឡើងវិញ (មុន គ.ស. ៤៩០ ព.ស. ៥៣) នេះគួរកប់ថាជាគ្រាផុតចម្បាំងលើកទី ១ ។

២ សម័យដែលដារីយុសទិវង្គតទៅក្នុង ព. ស. ៥៨ — ក្សត្រអង្គនេះមិនទាន់បានធ្វើការសងសឹកទេ ប៉ុន្តែក្សែរសែស រាជបុត្ររបស់ដារីយុសបានធ្វើតាមលំអានព្រះរាជបិតា ហើយបានប្រុងប្រៀបត្រៀមច្បាំងមិនមែនត្រឹមតែគិតច្បាំងយកស្រុកអាថែនប៉ុណ្ណោះទេ ថែមទាំងមានចេតនាប៉ុនប៉ងនឹងទំលាយបន្ទូរកំឡាំងកងទ័ពរបស់ក្រិកទាំងអស់ឲ្យវិនាសទៅផង ទើបពាក់

បញ្ជូនកងទ័ពដ៏សំបើមមហិមា ។ អ្នកប្រាជ្ញពង្សាវតារក្រិកពោលទុកថា កងទ័ពដែលក្សែរសែសលើកមកគ្រានោះ មានចំនួនមនុស្សដល់ទៅ ៥.០០០.០០០នាក់ ក្នុងចំនួននេះមានទាហានប្រមាណ ២.៦០០.០០០ ក្រៅពីនេះជាមនុស្សបំរើរបស់ទាហាន ។ ស្រុកចំណុះផ្សេងៗរបស់ប៉ែរ្ស៍ ក្នុងទ្វីបអាស៊ី ដូចជាហ្វេនីស៊ីនឹងអេស៊ីប្ដ៍ជាដើម ត្រូវកេណ្ឌឲ្យចាត់បញ្ជូនទូកចម្បាំង ១.២០០ នឹងទូកផ្ទុកស្បៀងអាហារចំនួន ៣.០០០ ពួកហ្វេនីសៀងជាមេទ័ពជើងទឹក ដែលអាចយកជ័យជំនះទូកចម្បាំងក្រិកបានយ៉ាងពិតប្រាកដ ។

គ្រានេះជាគ្រាសំខាន់បំផុត ក្នុងការដែលពួកក្រិកត្រូវរួមសាមគ្គីគ្នាធ្វើការតទល់ការពារស្រុកទេសយ៉ាងម៉ឺងម៉ាត់ ហេតុនេះ អាថែន្ស៍នឹងស្ប៉ាត ទគរធំទាំងពីរ ពីដើមធ្លាប់ជាគូប្រណាំងប្រជែង ឫស្យាឈ្នានីសគ្នា ដល់មកឥឡូវនេះបែរមុខមករកគ្នា ពិគ្រោះប្រឹក្សាកិច្ចការជាមួយគ្នា តាំងទីប្រជុំធំនៅស្រុកកូរិន្ធ៍ ចំណែកខាងពួកអាថែន្ស៍ដឹងខ្លួនជាក់ថា កំឡាំងទាហានទឹងថ្មីដែលទាហានរបស់ខ្លួនស៊ូពួកស្ប៉ាតមិនបាន ក៏យល់ព្រមឲ្យពួកស្ប៉ាតធ្វើជាមេទ័ពធំត្រួតត្រាកងទ័ពទូទៅ ហើយបានជួយទំនុកបំរុងដោយកំឡាំងធនធាន ចំណាយទ្រព្យកសាងទូកចម្បាំង ២០០ ។ ហេតុដែលអាថែន្ស៍លះបង់អតិមានះ ទិដ្ឋិរឹងត្អឹង ព្រម

នៅក្រោមបង្គាប់បញ្ជាពួកស្ប៉ាតដោយស្រួលនេះ ព្រោះអាស្រ័យសំដីថ្វីមាត់របស់មនុស្សស្រុកអាថែនម្នាក់ ហៅថា ថេមីស្តូក្លេ ។

លុះដល់រដូវដើមឈើលាស់ស្លឹក ព.ស.៦៣ (មុន គ.ស.៤៨០) ពួកប៉ែរ្ស៍លើកទ័ពចេញដំណើរមកជាវេលា ៧ យប់ ៧ ថ្ងៃក្នុងការឆ្លងឈូងដាដាណែល ដោយវិធីចងទូកតាបគ្នាជាស្ពាន ហើយតអំពីនោះទៅក៏លើកទ័ពដើរកាត់ដែន ត្រាស និងម៉ាសេដ្វាន ។ ចំណែកខាងកងទ័ពក្រិកដែលរង់ចាំទទួលទប់ទល់កងទ័ពប៉ែរ្ស៍ក្នុងខណៈនោះមានចំនួនត្រឹម៧.០០០នាក់ប៉ុណ្ណោះ ហើយមានទាហានមានថ្វីដៃឯកៗរបស់ស្ប៉ាតត្រឹម ៣០០នាក់ មានព្រះបាទឡេអូនីដាស ក្សត្រស្រុកស្ប៉ាតជាអ្នកបញ្ជាការទ័ព ពួកក្រិកដឹងខ្លួនថាចំនួនកងទ័ពខ្លួនមានទាហានតិចជាងពួកប៉ែរ្ស៍ ពេកណាស់ ទើបមិនចេញច្បាំងក្នុងទីវាលស្រឡះ បាននាំគ្នាចូលមកទប់ទល់ការពារសឹកនៅត្រង់ច្រកតូចមួយ តែក្នុងទីបំផុតនៅតែមិនអាចទប់ទល់កំឡាំងទ័ពដ៏ធំសំបើមរបស់ប៉ែរ្ស៍បាន ទើបព្រះបាទឡេអូនីដាសទ្រង់បង្គាប់ឲ្យថយទ័ព ឯព្រះអង្គក៏ប្រតិបត្តិតាមច្បាប់របស់ស្ប៉ាតដែលហាមផ្តាច់មិនឲ្យមេទ័ពថយរត់ដោយដាច់ខាត មានទាហានដែលមានចិត្តស្ម័គ្រស្មោះត្រង់នឹងព្រះអង្គបន្តិចបន្តួច បានខំស៊ូតទល់នឹងសឹកសត្រូវត្រាតែស្លាប់ទៅទាំងអស់គ្នាឥតសល់ម្នាក់ ។

ខណៈនោះ កងទ័ពជើងទឹកប៉ែរ្ស៍មានទូកចំនួន ៤០០ បានវាយចំណាយទូកចម្បាំងក្រិកខូចខាតអស់ទៅជាច្រើននៅត្រង់ឈូងឆកមួយអទ្វើ ហើយនៅវេលាដែលក្សត្រក្សែរសែសកំពុងរុករានលុកលុយខែត្រអត្តិគី នឹងដុតបំផ្លាញស្រុកអាថែន្សនោះ កងទ័ពជើងទឹករបស់ប៉ែរ្សក៏នាំគ្នាមកប្រជុំនៅខាងមុខកោះសាឡាមីន ។ គ្រានោះ គួរកត់ថាជាគ្រោះល្អរបស់ពួកអាថែន្ស បួនជាមានមនុស្សពូកែម្នាក់ឈ្មោះ ថេមីស្តូក៏ ជាពួកមន្ត្រីជាអ្នកយកចិត្តទុកដាក់ក្នុងការសាងទូកចំបាំងរបស់ក្រិក នឹងបង្ហាត់ទាហានជើងទឹកស្រុកអាថែន្សឱ្យចេះស្ទាត់ក្នុងចម្បាំងជើងទឹក នៅទីបំផុត បានប្រមូលទូកចម្បាំងក្រិកបានចំនួន ២០០ នាំចេញច្បាំងតទល់នឹងទូកចម្បាំងប៉ែរ្សដែលមានចំនួនដល់ ៤០០ គ្រាតែមានជ័យជំនះ ។ ការដែលប៉ែរ្សបរាជ័យចម្បាំងជើងទឹកគ្រានេះ ជាការសំខាន់ណាស់ គ្រាតែធ្វើឱ្យជ័យជំនះខាងជើងគោកនោះមិនមានប្រយោជន៍ឡើយ ហើយព្រះបាទក្សែរសែសក៏ស្តេចវិលត្រឡប់ទៅកាន់ទ្វីបអាស៊ីវិញ ។

កាលព្រះបាទក្សែរសែសស្តេចត្រឡប់ទៅវិញហើយ កងទ័ពប៉ែរ្សមានសេសសល់នៅក្នុងដែនដីក្រិកដល់ ៣០០.០០០ ឈប់បង្អង់រង់ចាំឱ្យផុតរដូវរងា តែគ្រានេះពួកក្រិកជឿជាក់ថា ខ្លួនអាចនឹងច្បាំងតទល់នឹងកងទ័ពប៉ែរ្សបាន ទើបប្រមូលគ្នាបានចំនួន ១២០.០០០ នាក់ មានពួកស្ប៉ាតជាមេទ័ព លើកចេញទៅច្បាំងនឹងកងទ័ពប៉ែរ្ស បានច្បាំងតទល់គ្នា

ជាច្រើនលើក ហើយនៅទីបំផុត កងទ័ពប៉ែរ្សក៏បាក់បែកខ្ចាត់ខ្ចាយអស់ទៅ បណ្ដាលឲ្យពួកក្រិកនៅក្នុងអាស៊ីនាំគ្នាបះបោរចលាចលតទល់នឹងពួកប៉ែរ្សទៀត បណ្ដាលឲ្យចម្បាំងគ្រានោះប្រែត្រឡប់បាតដៃជាខ្នងដៃ គឺពួកក្រិកជាអ្នកច្បាំងរុករាន ពួកប៉ែរ្សគ្រាន់តែច្បាំងទប់ទៅវិញបាត់ជាសង្គ្រាមលើកទី ២ ។

៣ សម័យរួបរួមគ្នាដោយសាមគ្គីធម៌ — តែការដែលនឹងលើកទ័ពទៅច្បាំងនឹងប្រទេសប៉ែរ្សនោះ ធ្វើបានតែមួយផ្លូវ គឺផ្លូវសមុទ្រ ពួកស្ប៉ាតដឹងខ្លួនច្បាស់ថាខ្លួនស្ទាត់ជំនាញតែខាងដើរគោក ឯខាងដើរទឹកស៊ូពួកអាថែនមិនបាន ទើបប្រគល់មុខក្រសួងមេទ័ពឲ្យពួកអាថែនជាអ្នកចង្ហាបបញ្ជាកងទ័ពគ្រានេះអាណាចក្រក្រិកទាំងឡាយក៏ចុះចូលរួបរួមគ្នាដោយសាមគ្គី តាំងសំណាក់ការនៅស្រុកដេឡោស មានសេចក្ដីយល់ព្រមមូលគ្នាថាត្រូវធ្វើសង្គ្រាមនឹងប្រទេសប៉ែរ្សយ៉ាងម៉ឺងម៉ាត់ គេងជួយចេញធនធាននឹងបាត់ថែនរកទូកចម្បាំង នឹងគ្រឿងប្រដាប់ឯទៀតៗសម្រាប់ជួយជាកំឡាំងដល់សង្គ្រាមគ្រានោះ ។ ខណៈនេះមានអ្នកស្រុកអាថែនម្នាក់ទៀតឈ្មោះអារិស្ទីដ ជាដើម ជាគូវិវាទនឹងថេមីស្តូក្លេ គ្រាតែត្រូវបោះស្លាកសំបកខ្យង

ឲ្យបញ្ចេញខ្លួនចេញពីស្រុកអាថែន្សនោះ ឥឡូវត្រឡប់ចូលមកក្នុងស្រុកសុំធ្វើការជួយស្រុកទេស ។ បុរសនេះឯងជាអ្នកតាក់តែងធ្វើច្បាប់១និយាយពីស្រុកណា ត្រូវជួយទំនុកបំរុងក្នុងការសង្គ្រាមគ្រានេះយ៉ាងណាខ្លះ ។ ពួកក្រិកបានចាត់តាំងស៊ីម៉ុង បុត្ររបស់មិលស្យាទ៍ ជាមេទ័ពធំលើកទ័ពទៅបណ្ដេញពួកប៉ែរ្ស៍ ឲ្យថយចេញពីស្រុកត្រាសនឹងកោះផ្សេងៗក្នុងសមុទ្រអេសេ នឹងតាមមាត់សមុទ្រអាស៊ីតូច ។

(មានតទៅទៀត)

# អនាម័យកថា

## ១. ស.

### អ្នកប្រែនិងរៀបរៀង

ទើបត្រូវដឹងថា អ្វីជាតួនាំចម្លងរោគមកកាន់កាយយើងបាន ។

វត្ថុផ្សេងៗដែលនឹងពោលតទៅនេះជាគ្រឿងនាំឬចម្លងមេជម្ងឺផ្សេងៗ មកកាន់កាយមនុស្សយើងបានគឺ:

១) អាកាស — តាមធម្មតា មេរោគឬមេជម្ងឺច្រើនតែអណ្តែតទៅតាមអាកាស ដូចមេជម្ងឺទ្យូប៉ែស្ត, កញ្ជ្រិល, ផ្តាសាយជាដើម បើមិនមានអាកាសនៅជាចន្លោះខ្លួនយើងនឹងមេជម្ងឺទេ យើងក៏មិនកើតរោគអស់នេះដែរ ប្រសិនបើយើងការពារខ្លួនយើងមិនឲ្យកើតរោគអស់នេះ យើងត្រូវតែនៅកន្លែងអាកាសល្អបរិសុទ្ធមិនស្អុះស្អាប់ ដូចបានពោលមកក្នុងបទមុននេះ ព្រោះអាកាសល្អនេះ ក្រៅពីធ្វើឲ្យយើងមានកំឡាំងតទល់នឹងមេជម្ងឺបាន នៅមានប្រយោជន៍ជាថ្នាំពិសសំលាប់បំពុលមេជម្ងឺផ្សេងៗទៀតផង ។ កាលបើមេជម្ងឺត្រូវអាកាសល្អគង់តែនឹងស្លាប់អស់ទៅមិនខាន ។

២) ទឹក — មេជម្ងឺផ្សេងៗរមែងមកកាន់កាយយើងតាមផ្លូវទឹក ដូចជាជម្ងឺអាសន្នរោគ, ជម្ងឺមួលជាដើម ។ វិធីការពារ គឺត្រូវផឹកទឹកដែលស្អាត គឺដាំឲ្យពុះជាមុនសិមផឹក ។

៣) គ្រឿងបរិភោគ — មេជម្ងឺផ្សេងៗ ក្រៅអំពីមានមកតាមផ្លូវទឹក នៅមានជាប់មកនឹងគ្រឿងស៊ីគ្រឿងបរិភោគ បង្កើតទៅជារោគ គតាន់ឬខាន់-ស្លាក់ គ្រុនរាកជាដើម ហេតុនេះ ត្រូវតែយើងប្រយ័ត្នគ្រឿងស៊ីនេះឲ្យមាំមួន របស់ដែលរែកលក់ឬរុញលក់តាមផ្លូវតាមថ្នល់ ឬដាក់លក់តាមចិញ្ចើមថ្នល់ ឬរបស់ដែលមិនទាន់ឆ្អិនល្អក៏គួរចៀសវាងដែរ ដើម្បីរក្សាខ្លួនយើងឲ្យផុតស្រឡះពីជម្ងឺធ្ងន់ធ្ងរនោះ ។

៤) សំលៀកបំពាក់ — មេជម្ងឺបំពួកខ្លះ ដូចជាកមរមាស់ ស្រែង ក្ញីយូន់ទឹងកាមរោគជាដើម រមែងជាប់នៅនឹងសំពត់ស្លៀកពាក់ ហេតុនេះគ្រឿងស្លៀកពាក់យើងមិនត្រូវខ្ចីគេប្រើទេ ទាំងសំពត់អាវរបស់យើងក៏មិនត្រូវឲ្យអ្នកដទៃខ្ចីប្រើដែរ ។

៥) មូស — មូសជាសត្វនាំជម្ងឺគ្រុនចាញ់ មកកាន់មនុស្សយើងចូនកាលធ្វើឲ្យយើងស្លាប់ដោយសារជម្ងឺនេះក៏មានច្រើន ឯវិធីបង្ការមូសមិនឲ្យខាំយើងបាននោះ ជាការលំបាកណាស់ ទុកជាយើងព្យាយាមកំចាត់វាឲ្យអស់ពីផ្ទះយើងទៅបាន គង់តែមានមូសមកពីផ្ទះជិតខាងយើងបានទៀត ឬមានមកពីទីដទៃដែលស្មោកគ្រោក ។ ហេតុនេះ ត្រូវយើងប្រើមុងជាគ្រឿងបង្ការមូសជាបណ្ដោះអាសន្នទៅសិនចុះ ទម្រាំប្រជាជនខ្លួនទៅចេះវិធីកំចាត់នឹងបង្ការមូសសព្វគ្រប់ ។

៦) ចំពួកសត្វល្អិតៗ – ដូចជាសត្វរុយតែងនាំមេជម្ងឺអាសន្នរោគ គ្រុនពិស និងរោគឯទៀតៗមកកាន់មនុស្ស ដោយវាហើរទៅទំលើរបស់ស្មោកគ្រោក ហើយវាហើរមកទំលើគ្រឿងបរិភោគរបស់យើង ។ សង្កើចនាំឲ្យកើតរោគឃ្លង់និងរោគឯទៀតៗ ។ ចៃកណ្ដុរនាំឲ្យកើតជម្ងឺកាឡរោគ (ប៉េស្ដ៍) ។ ហេតុនេះ ត្រូវយើងដេញកំចាត់ចេញឲ្យអស់ហើយគ្របបិទគ្រឿងបរិភោគឲ្យជិតល្អ រៀបចំសំអាតដំណេកឲ្យស្អាតបាតកុំឲ្យសង្កើចអាស្រ័យនៅបាន ។

៧) មនុស្ស – មនុស្សខ្លះដែលកើតរោគឆ្លង តែងចម្លងរោគនោះមកកាន់មនុស្សផងគ្នាជាច្រើនយ៉ាង ដូចជាកាមរោគ (ស្វាយ ប្រមេះ ទីមឡ្យ និងអាសន្នរោគជាដើម ។ ហេតុនេះ យើងត្រូវប្រយ័ត្នឲ្យមែនទែនក្នុងការសេពគប់សមាគមនឹងមនុស្សផងគ្នា ។

## បទទី ៥

# និយាយពីមហាយុទ្ធសង្គ្រាមក្នុងរាងកាយរបស់យើង

មុននឹងនិយាយពីមហាយុទ្ធសង្គ្រាមក្នុងកាយនេះ យើងនឹងថ្លែងអំពីបក់តេរីទាំងឡាយដោយសង្ខេបជាមុនសិន ដើម្បីឲ្យអ្នកមើលយល់សេចក្ដីច្បាស់អំពីមហាយុទ្ធសង្គ្រាមនេះ ដែលយើងនឹងថ្លែងជាលំដាប់តទៅ ។

# បាក់តេរី

មុននឹងដឹងស្គាល់តួបាក់តេរីនេះ មានជាតិហូឡង់ម្នាក់ជាជាងធ្វើកែវឆ្លុះឬកែវពង្រីក គេល្បងឆ្កេះអាចម៍ធ្មេញបន្តិចមកលាយទឹក ហើយឆ្លុះមើលដោយកែវយឹតទើបពិនិត្យមើលឃើញជីវិតិន្ទ្រិយមានរូបផ្សេងៗ ជាចំនួនច្រើនស្អេកស្កះ ជីវិតិន្ទ្រិយអស់នេះហើយដែលហៅថា បាក់តេរី ។

លុះតៗមកទើបមានគ្រូពេទ្យនានាបានព្យាយាមស្រាវជ្រាវរកទៅជួបប្រទះនឹងបាក់តេរីចំពួកផ្សេងៗទៀតជាច្រើន តែការប្រទះឃើញនេះក៏នៅតែមិនទាន់មានប្រយោជន៍ដល់មនុស្សយើងប៉ុន្មានទេ លុះតមកដល់សម័យលោកគ្រូពេទ្យប៉ាស្ទ័រជនជាតិបារាំងសែសម្នាក់ដែលជាមនុស្សដំបូងដែលបានខំសិក្សារកឲ្យឃើញលំនៅ និងការចិញ្ចឹមជីវិតរបស់បាក់តេរីទើបធ្វើឲ្យយើងស្គាល់វិធីបំផ្លាញវាបានក្នុងកាលជាលំដាប់ៗមក ។

បាក់តេរី ជាវត្ថុមានជីវិតិន្ទ្រិយតែយើងនឹងមើលដោយភ្នែកទទេមិនឃើញឡើយ សឹងមាននៅទូទៅសព្វអន្លើ គឺចំពួកខ្លះនៅក្នុងអាកាស ចំពួកខ្លះនៅក្នុងទឹក ចំពួកខ្លះនៅក្នុងដី ចំពួកខ្លះនៅក្នុងកាយមនុស្សនិងសត្វ តែតាមធម្មតាវាចូលចិត្តនៅក្នុងរបស់ស្មោកគ្រោក មានសម្រាមនិងផង់ល្អងធូលីជាដើម ។ វត្ថុអស់នេះសឹងមានរូបរាងផ្សេងៗគ្នា ចំពួកខ្លះមានរូបរាងដូចបាល់ ចំពួកខ្លះមានរូបរាងជាកំណាត់ៗ ដូចជាកំណាត់

ឈើ ហើយសឹងមានច្រើនជាងចំពូកដទៃ ៗ ហេតុនេះទើបគេសន្មត់ហៅថា ប័កតេរី (ប្រែថាកំណាត់ឈើ) ។

ប័កតេរីអស់នេះ លុះតែយើងពង្រីកខ្លួនវាឲ្យរីកធំឡើងដល់ទៅ ១.០០០ ភាគ ទើបយើងមើលឃើញខ្លួនវាប៉ុនសរសៃសក់ប៉ុណ្ណោះ ដោយហេតុខ្លួនវាតូចដល់ម្ល៉េះ បានជាយើងមើលដោយភ្នែកទទេពុំឃើញតោងប្រើកែវពង្រីកឆ្លុះមើលទើបឃើញ ។ ប័កតេរីចំពូកខ្លះឲ្យទោសចំពោះសត្វ ចំពូកខ្លះឲ្យទោសចំពោះមនុស្ស តែចំពូកដែលមានប្រយោជន៍ដល់មនុស្សក៏មានខ្លះដែរ ដូចជាចំពូកជួយរំលាយកាកអាហារក្នុងពោះវៀន ៗ ចំពូកដែលជួយរំលាយគ្រឿងអសុក ដើម្បីឲ្យដើមឈើបានទទួលវ៉ែធាតុអំពីអសុកនោះមកដុបលៀងដើមឲ្យបានលូតលាស់ឡើងក៏មាន ៗ

កាលបើយើងសំឡឹងមើលជុំវិញខ្លួនយើងនឹងឃើញប័កតេរី ឬមេរោគផ្សេងៗទូទៅ ចុះហេតុដូចម្ដេចទើបយើងមិននាំគ្នាឈឺតាប់កល់គ្នាទៅ ?.. សេចក្ដីតទៅនេះជាសេចក្ដីឆ្លើយប្រស្នាខនេះ

(នៅមានត)

# រឿងព្រេងខ្មែរ – រឿងអាឡេវ (ទី២)

## (តមក)

របស់អ្នកឧកញ៉ាប្រាជ្ញាធិបតី (យិន) ចាងហ្វាងក្រុមព្រះរាជនិពន្ធ

អាឡេវនៅរៀនអក្សរនឹងលោកគ្រូសង្ក្រាជ លុះនៅយូរទៅ អាឡេវគិតថា អញនឹងបញ្ឆោតលោកសង្ឃណាដែលមានប្រាក់ច្រើនយកទៅឲ្យម៉ែឪអញ អាឡេវគិតដូច្នោះហើយ ក៏ទៅនិយាយនឹងលោកសង្ឃកំឡោះមួយអង្គដែលមានប្រាក់ច្រើនថា លោកគ្រូ មានស្រីម្នាក់ស្រឡាញ់លោកគ្រូ ស្រីនោះក្រមុំល្អណាស់ លោកនោះឮអាឡេវថាដូច្នោះ ក៏មានចិត្តអរចង់បាន ហើយនិយាយនឹងអាឡេវថា បើប្រាកដដូចឯងថាដូច្នោះមែន អញនឹងឲ្យប្រាក់ឯងមួយបាទ ។ អាឡេវថាចាំដល់ពេលយប់ងងឹតលោកទៅចាំនៅទីកន្លែងត្រង់នោះចុះ ខ្ញុំករុណានឹងនាំស្រីនោះមក ហើយវាលាលោកចុះពីកុដិដើរតម្រង់ទៅផ្ទះចិន គិតទៅនិយាយបញ្ឆោតចិនទៀត លុះទៅដល់ផ្ទះចិនហើយវាដើរចូលទៅក្នុងផ្ទះ និយាយនឹងចិនថា ចឹកៗចង់បានស្រីក្រមុំល្អៗមកដេកឬទេ ចិនឆ្លើយថា អើអញចង់បាន អាឡេវថាបើចឹកឯងចង់បាន តើឲ្យប្រាក់អញប៉ុន្មាន ចិនថាអញឲ្យមួយបាទ អាឡេវថាតិចណាស់ បើឲ្យអញពីរបាទនោះអញរកស្រីក្រមុំសៗល្អឲ្យចឹកឯង ចិនថាអើ អាឡេវថា បើដូច្នោះចាំពេលយប់ងងឹតអញនឹងនាំមកឲ្យចឹកឯង ហើយអាឡេវក៏ត្រឡប់ទៅវត្តវិញ លុះដល់វេលាយប់

ងងឹតមើលគ្នាមិនស្គាល់ វាក៏នាំលោកសង្ឃនោះឲ្យទៅអង្គុយចាំក្នុងពេង មួយស្អាត ហើយវានិយាយផ្តាំលោកសង្ឃថា បើខ្ញុំព្រះករុណានាំស្រី នោះមកដល់ លោកយកចីពរទទូរក្បាលឲ្យជិត អាឡេវផ្តាំលោកនោះរួច ហើយ ក៏ដើរចូលទៅក្នុងផ្ទះចិន ហៅចិននោះចេញមកហើយនិយាយថា ឥឡូវនេះអញរកស្រីក្រមុំឲ្យចឹកឯងបានហើយៗ វាផ្តាំចិនថា បើចឹកឯង ចូលទៅដេកនឹងស្រីនោះត្រូវទទូរក្បាលឲ្យជិត ទើបវានាំចិននោះទៅទៀប ពេងដែលលោកសង្ឃនៅចាំ ហើយវាខ្សឹបទារប្រាក់ពីចិនថាស្រីនៅក្នុង នេះហើយ ឯចិនមើលទៅក្នុងពេងឃើញលោកសង្ឃអង្គុយទទូរចីពរនៅ នោះ គិតស្មានថាជាស្រីមែន ក៏ឲ្យប្រាក់ទៅអាឡេវ ៗ ឯអាឡេវបាន ប្រាក់ហើយ ក៏រៀះជាប្រញាប់ត្រឡប់ទៅវត្តវិញ ឯចិនទឹងលោកសង្ឃ បានជួបគ្នាហើយ គិតស្មានថាស្រី ក៏ប្រចាប់គ្នា ចិនថាលោកសង្ឃជាស្រី លោកសង្ឃគិតថាចិនជាស្រី ក៏ប្រចាប់គ្នាប្លុល ឯលោកសង្ឃអត់ចង្ហាន់ ល្ងាចមិនសូវមានកំលាំងក៏ដួលដេកទៅ ហើយចិនក៏សើយស្បង់ឡើង ឃើញស្អាស់លោកសង្ឃ ក៏ដឹងថាអាឡេវកុហក ៗ ឯលោកនឹងចិនលុះ ដឹងថាអាឡេវបញ្ឆោតហើយក៏អៀន ទៅក្នុង-ផ្ទះដោយខ្លួនទទេៗទៅ ៗ អាឡេវនៅចាំលោកឯកុដិនោះ លុះលោកមកដល់កុដិហើយ វាក៏ទារប្រាក់ អំពីលោកៗនោះថា អាឡេវឯងបញ្ឆោតអញ ហើយឯងមកទារប្រាក់

ពីអញទៀត អញមិនឲ្យឯងទេ ៗ អាឡូវក្លាយថា បើលោកមិនឲ្យប្រាក់ ខ្ញុំករុណា ៗ ទឹងទៅពិតលោកគ្រូថា លោកនៅដេកទឹងស្រែ ហើយទៅប្រាប់ អស់បាសក តាយក អ្នកស្រុក ក្នុងភូមិទាំងអស់ឲ្យគេដឹង បើគេដឹងហើយ គេមិនឲ្យបាយលោកឆាន់ទេ ហើយលោកក៏ខ្មាសគេទឹងនៅវត្តទឹងគេពុំ បាន មួយទៀត បើខ្ញុំករុណាទៅប្តឹងដល់ក្រុមសង្ឃការី មុខជាគេទឹងមក ចាប់លោកយកទៅជំនុំជំរះពិចារណាតាមដំណើរដែលលោកដួលខ្ញុំករុណា ឲ្យទៅកស្រែហើយលោកថាឲ្យប្រាក់ខ្ញុំមួយបាទ ឥឡូវនេះលោកបានដេក ទឹងស្រែហើយលោកគេចថាមិនឲ្យវិញ ឯខ្ញុំករុណាមិនលែងទេមុខជាទឹង ទៅពិតលោកគ្រូហើយ ៗ

(មានតទៀត)

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

ឆ្នាំគំរប់ ១៣

ភាគទី ៤

INSTITUT BOUDDHIQUE

ភ្នំពេញ

ការផ្សាយរបស់ព្រះរាជបណ្ណាល័យ

ព. ស. ២៤៨៣

គ. ស. ១៩៤១

៧:០១

ព្រះរាជបណ្ណាល័យកម្ពុជា

# KAMBUJASURIYÂ

# កម្ពុជសុរិយា

ជាទស្សនាវដ្ដីចេញផ្សាយពីព្រះរាជបណ្ណាល័យ មួយខែពីរក្បាល

## ឆ្នាំគំរប់ ១៣

ភាគទី ៤

គណៈរដ្ឋមន្ត្រីនិងសម្ដេចសង្ឃនាយកទាំងពីរគណៈ
បានអនុញ្ញាតហើយ

ភ្នំពេញ
ការផ្សាយរបស់ព្រះរាជបណ្ណាល័យ
ព.ស. ២៤៨៣
គ.ស. ១៩៤១

# បញ្ជីរឿង


១ — ប្រទេសឡាវជាស្រុកមួយនៅក្នុងឧភទប្រទេសឥណ្ឌូស៊ីន លោក ឡាភើទយ: រៀបរៀង . . . . . . . . . . . . . . . . . . . . . . ៣

២ — អំពីព្រះពុទ្ធសាសនាក្នុងប្រទេសឥណ្ឌូស៊ីន លោកដុកទ័រ អង់ដ្រេ មីក្លូត៍ រៀបរៀង . . . . . . . . . . . . . . . . . . . . . . ៩

៣ — ពង្សាវតារប្រទេសក្រិក រៀបរៀងតាមគោលចារឹកផ្សេងៗក្នុងពង្សាវតារលោក (តមក) . . . . . . . . . . . . . . . . . . . . . ១៦

៤ — ច្បាប់សុភាសិត របស់អ្នកឧកញ៉ាវង្សាសារពេជ្ញ នង (តមក). . . . . . . ២៣


## រូបក្រៅរឿង


ប្រាសាទបាយ័ន — រូបរាជសីហ៍នៅទ្វារចូលទិសខាងជើង . . . . . . ១

# TABLE DES MATIÈRES


Pages

1° Le Laos partie intégrante de l'Indochine par LAVODAYA...... 3

2° Le Bouddhisme en Indochine par le Docteur ANDRÉ MIGOT (suite)........................................ 9

3° Histoire de la Grèce, extraits de divers documents de l'Histoire Universelle (suite)........................... 16

4° Chbab SUBHĀSIT (Poème Khmèr) par Oknhā VONGSĀSARAPÉCH NONG (suite)...................................... 23


HORS TEXTE :


Bayan — porte d'entrée du nord : le lion................ 1



ប្រាសាទបាយ័ន – រូបភផសីហ៍នៅទ្វារចូលទិសខាងជើង ។

# អំពីស្រុកឈាវដែលជាស្រុកមួយនៅក្នុងឱរាទប្រទេសឥណ្ឌូស៊ីន

សេចក្តីតែងរបស់លោក ឈាភេទយៈ

កាសែតឈ្មោះ "ឥណ្ឌូស៊ីន" បានចេញសេចក្តីតវ៉ាជំនួសខេមរជាតិជាមិត្រយើង ចុះឈ្មោះកម្ពុបុត្រជាអ្នកតែង, តបក្រមឃោសនាការខ្លះដែលយករឿងផ្សេងៗពីស្រុកខ្មែរទៅនិយាយយកជាប្រយោជន៍ខ្លួន ។

ឥឡូវនេះដល់ពេលយើងវិញហើយ យើងត្រូវនិយាយឲ្យដឹងថា ហេតុដូចម្តេចបានជាយើង-ជាឈាវ មិនព្រមរួមចូលជាមួយនឹងបងប្អូនថៃដែលនៅត្រើយម្ខាងទន្លេមេគង្គ?

ក្រមឃោសនាការខ្លះបានសំដែងគំនិតគិតរួមជាតិជាប្រមាណ តែរឿងនេះនឹងមានដម្លៃលុះត្រាតែនិយាយចំពោះទៅដល់ពួកថៃទាំងអស់ ព្រមទាំងថៃនៅស្រុកចិនប៉ែកខាងត្បូង, ថៃនៅស្រុកភូមាហើយនឹងនៅក្នុងកោះហៃណាំផង, បើគ្រាន់តែតម្រង់មកសាសន៍ឈាវនៅប្រទេសឥណ្ឌូស៊ីនបារាំងសែសប៉ុណ្ណោះទេ សំដីនោះក៏គ្មានដម្លៃអ្វីឡើយ ដោយហេតុគេយល់ឃើញថា ជាពាក្យតែងថ្មីសម្រាប់ប្រើការក្នុងកិច្ចនយោបាយ ។

តាមភូមិសាស្ត្រ ទំនាបទន្លេមេគង្គត្រូវបានមកប្រទេសឥណ្ឌូស៊ីនបារាំងសែស ហេតុនេះបើទុកជាខំឃោសនាយ៉ាងដូចម្តេចក៏ហាមឃាត់ទឹកទន្លេមេគង្គដែលជាទន្លេមួយយ៉ាងធំនៅក្នុងទ្វីបមិនឲ្យហូរពីឧត្តរទៅទក្សិណ

បានឡើយ មិនឲ្យក្ឋំពាល ហឿរជាន់, ត្រង់និញ ទឹងបូលូវែន ជុះនៅក្រោយស្រុកលាវនឹងស្រុកយួនអណ្ណាមនោះបានឡើយ ។ មួយយ៉ាងទៀត កំពង់មាត់សមុទ្រនៅកណ្ដាលស្រុកយួន (អណ្ណាម) ដែលនៅចំផ្លូវទៅកាន់នានាប្រទេស ហើយមានចម្ងាយពីទន្លេមេគង្គដាច់កណ្ដាល ចំនួន បើធ្វើដំណើរតាមរថយន្តឬតាមរថភ្លើងមិនដល់មួយថ្ងៃផង នោះឃើញជាស្រួលអនេកជាងក្រុងបាងកកដែលនៅឆ្ងាយ គឺនៅមាត់ទន្លេរបស់គេ ហើយថែមទាំងនៅចុងឈូងសមុទ្រទៅទៀត ប្រៀបដូចជានៅបាតការុង ។

ពួកលាវបានតាំងស្រុកតាមមាត់ទន្លេមេគង្គ ស្រុកទាំងនេះពិតមែនតែធ្លាប់នាំសាអាករឡើងប្រទេសនៅជិតៗ គ្រប់ទិសទាំងបួនដែលមានឫទ្ធិខ្លាំងពូកែ ប៉ុន្តែនៅបែកដោយឡែកជាដកប ។ មិនជាយូរប៉ុន្មានទេ ក្នុងគ្រិស្តសករាជ ១៨២៧ បងប្អូនថៃបានវាយក្រុងវៀងចន្ទន៍កំទេច ឧបមាបីដូចជាមនុស្សព្រៃ ហើយបានលួចយកព្រះកែវមរកតនឹងកៀរយកមនុស្សទៅស្រុករបស់គេជាច្រើន បងប្អូនថៃបានរឿងទាំងនេះពីប្រទេសលាវទៅហើយ បានជាថាយើង "បងប្អូន" ។ ឯការៈទាំងនេះគឺការៈពន្យាគារ ការៈផែនដី ការៈសេដ្ឋការ នឹងការៈមនុស្សជាតិ ជាហេតុបង្អុលឲ្យឃើញច្បាស់កុំឲ្យប្រកែករួច ។

គេបានសង្កេតឃើញថាពួកលាវដែលនៅពីហ្លួងព្រះបាងមកដល់ចំ-ប៉ាស័ក មានជាតិកំណើតនិងកិច្ចរដ្ឋប្រសាសនោបាយរួមតែមួយ, ពួកលាវទាំងនេះបានចងគ្នាជាបាច់ដើម្បីថ្ងៃមុខនឹងមានកំឡាំងច្រើន មិនមែនបែកខ្ញែកគ្នានោះទេ ។

ប៉ុន្តែលើហេតុ ការៈសេដ្ឋការ និងការៈមនុស្សជាតិ មានការៈទំនៀមទំលាប់ជាធំទៅទៀត ។ ហេតុនេះបានជាពួកព្រះវង្សានុវង្សស្តេចគង់នៅនគរហ្លួងព្រះបាង បាន[illegible]ងមហាប្រទេសបារាំងសែសឲ្យជួយការពារសេចក្តីអន្តរាយ ការៈទំនៀមទម្លាប់សម្រាប់ពង្សនៅស្រុកលាវ ។ ឯចំណែកខាងអាណាប្រជាកស្ត្រលាវបានតាំងចិត្តទៀងត្រង់នឹងប្រទេសបារាំងសែស តាមកិច្ចសន្យាពីថ្ងៃមុន ដោយសេចក្តីកតញ្ញូ ព្រោះប្រទេសបារាំងសែសមានឧបការគុណដល់ពួកលាវទាំងនោះ ។

ការនេះមកពីយើងពល់គ្នាស្ម័គ្រចិត្ត បានជាយើងសុំឲ្យប្រទេសបារាំងសែសជួយដឹកនាំកេផ្លូវផលប្រយោជន៍របស់យើងទៅមុខ ដោយយើងស្រឡាញ់ទុកចិត្តប្រទេសបារាំងសែសជាប្រាកដ; ហេតុនេះយើងត្រូវរៀសរាំងពីកណ្តាប់ដៃសៀមសង្កត់យើងការតែធ្ងន់ឡើង! ហើយត្រូវបំបាត់សេចក្តីបលាបលក្ខណ៍ស្រុកយើងដែលសៀមនាំបង្កនោះ ។ ឯប្រទេសបារាំងសែសបានពាត់ដំណាងម្នាក់ឈ្មោះលោក "អូគុស្ត-ប៉ាវី" ជាអ្នកប្រសប់លលួងចិត្តយើង លោកនេះជាដំណាងអារ្យធម៌របស់បស្ចិមប្រទេស

ដែលយើងមិនអាចនឹងលះបង់បាន ព្រោះចិត្តយើងប្រដៅមិនឲ្យលះបង់ ។ រឿងយ៉ាងដូច្នេះកម្រឃើញមានក្នុងពង្សាវតារប្រទេសចំណុះនោះណាស់ ។

កិច្ចដែលបារាំងសែសទទួលធ្វើនៅស្រុកលាវនោះមិនមែនស្រួលទេ ដើមឡើយ ពីព្រៃនគរទៅហ្លួងព្រះបាង ត្រូវទៅដោយកប៉ាល់បើកតាមទន្លេមេកុងចំនួន ៤-៥ ថ្ងៃទើបបានដល់ដោយលំបាកផង ។ ឥឡូវក្រុមគមនាគមន៍ធ្វើផ្លូវទឹងក្រុមធ្វើផ្លូវរថភ្លើងនៅប្រទេសឥណ្ឌូស៊ីនបានចាត់ចែងធ្វើផ្លូវចេញចូលស្រុកលាវបានដោយស្រួល ការទាំងនេះបើប្រសិនជាសង្កេតទើបបានឃើញថាវិសេសមែន ។

មួយវិញទៀត ចំនួនមនុស្សនៅក្នុងស្រុកលាវមានតិចពេក ពិបាកនឹងរិះគិតធ្វើសេដ្ឋកិច្ចនិងកិច្ចផ្សេងៗក្នុងស្រុកឲ្យមានដម្លៃឡើង បើកាលណាកិច្ចទាំងនេះគ្មានដម្លៃ ធ្វើដូចម្តេចស្រុកនោះនឹងចម្រើនទៅបាន? ។ ពិតមែនតែពិបាកដូច្នេះ តែស្រុកទាំងប៉ុន្មានដែលនៅក្នុងអភិបាលប្រទេសឥណ្ឌូស៊ីនបានជួយប្រទេសបារាំងសែសធ្វើឲ្យសម្រេចកិច្ចដ៏ប្រសើរដល់បណ្តាជននៅស្រុកលាវបាន ។ មហាប្រទេសបារាំងសែសបានចាត់ឲ្យរៀបចំឡើងជាថ្មីការពេដការក្នុងស្រុកដែលបោះបង់ចោល ដើម្បីឲ្យបានសេចក្តីសុខក្សេមក្សាន្តពលរូប ។ បានបង្កើតក្រសួងពេគាភិបាលសម្រាប់ជួយស្រោចស្រង់បណ្តាជនកើតជម្ងឺអាសន្នរោគនឹងជម្ងឺរបល់ដែលបំផ្លាញជីវិតប្រជាជនជាច្រើន, ព្រោះបណ្តាជនជាតិលាវមិនសូវមានច្រើនផង ។

ដោយស្ថិតិនេះ ប្រទេសបារាំងសែសក៏បានធ្វើផ្លូវជាច្រើនកាត់ជនព្រៃព្រឹក្សា និងកាត់ជនភ្នំ នគរវៀងចន្ទន៍ធ្វើជាថ្មីឡើងវិញ ចេញអំពីផេះដែលសៀមវាយកំទេចជាន់មុន និងក្រុង ១០ ទៀតនៅខែត្រក្រៅបានកើតព្រមគ្នាតែម្តង កិច្ចផែនទីសភាពដី, ផែនទីសំគាល់ជាតិធរណី, ផែនទីសំគាល់ជាតិលោហធាតុ-ការដែលខំសង្កេតរកអំពីក្សេត្រការ-អំពីលក្ខណៈដីល្អអាក្រក់-អំពីព្រៃព្រឹក្សា កិច្ចការទាំងនេះនាំឲ្យគេពិចារណាឃើញច្បាស់ថា នៅថ្ងៃមុខស្រុកលាវនឹងមានភោគសម្ប័ទ ។

ប្រទេសបារាំងសែសជាប្រទេសកាន់សាសនាគ្រិស្ត ប៉ុន្តែបានជួយទំនុកបំរុងដោយស្មោះសរទូវសាសនារបស់យើង គឺពុទ្ធសាសន៍ បានជួយសង់វត្តអារាមដែលបាក់បែកដោយសង្គ្រាម ឬទ្រុឌទ្រោមដោយវត្តនោះកើតជាអង្វែងមកហើយ វត្តដែលបារាំងសែសជួសជុលដំបូងបង្អស់ គឺវត្ត "ថាតលួង" នៅវៀងចន្ទន៍ ដែលបងប្អូនថៃវាយបាក់បែកក្នុងគ្រិស្តសករាជ ១៨២៧ វត្តនេះ ឥឡូវគេហៅវត្តព្រះកែវ ។

បារាំងសែសបានបង្កើតសាលាបាលីជាច្រើន និងមន្ទីរពុទ្ធសាសនបណ្ឌិត្យ ១ បានកែរបៀបរៀនធម៌ពុទ្ធសាសនារបស់យើង ហើយបោះពុម្ពសៀវភៅរៀនពុទ្ធសាសនាជាច្រើនជាភាសាលាវ ។

ឯកិច្ចទាំងនេះ ប្រទេសបារាំងសែសជាប្រទេសទំនុកបំរុង ឥតបានផលប្រយោជន៍អ្វីឡើយ ព្រោះកិច្ចទាំងនោះជាកិច្ចក្នុងពុទ្ធសាសនា ហេតុ

នេះកាលទឹងបន្ទុលឲ្យឃើញច្បាស់ តបទឹងអ្នកពោលតាមកាសែតទឹង តាមក្រុមឃោសនាការដែលប្រកាសឲ្យជននៅក្នុងទ្វីបទឹងខ្លួនឃើញដឹងថា “ យើងជាមនុស្សវេទនា - ជាខ្ញុំគេ - ជាមនុស្សពាញ់បញ្ឆោតប្រទេសដទៃ ” ពាក្យពោលទាំងនេះមិនពិតទេ ។

មនុស្សក្នុងទ្វីបគេដឹងអស់ហើយ ឯចំណែកយើងៗ មិនចាំគិតច្រើនទេ បើចង់ដឹងច្បាស់ថា “បងប្អូនយើងនៅឯណា? យើងគ្រាន់តែនឹករកថាអ្នកណារំលាយក្រុងវៀងចន្ទន៍ ទឹងវត្តព្រះកែវ គិតតែប៉ុណ្ណឹងយើងដឹងហើយ ។

# អំពីពុទ្ធសាសនាក្នុងប្រទេសឥណ្ឌូស៊ីន

របស់ដុកទ័រ អង់ដ្រេ-មីកូត៍ (តមក)

*នៅសម័យដំបូងនៃលទ្ធិពុទ្ធសាសនាបែបហីនយាននៅក្នុងប្រទេសឥណ្ឌូស៊ីននេះ ផុតអស់ទៅក្នុងសតវត្សរ៍ទី ៧ ព.ស. ១.១៤៣ ឬខាងដើមសតវត្សរ៍ទី ៨ (ព.ស. ១.២៤៣) ។ យើងបានដឹងសេចក្ដីពិតនេះ ដោយលោកអ្នកដើរធុតង្គមួយរូបឈ្មោះ យី-ឈិង (ជាតិចិន) ពោលទុកថា ក្នុងសម័យនោះ ក្សត្រប្រទេសហ្វូណនកាន់សាសនាសិវៈ ឯពុទ្ធ-សាសនាលទ្ធិហីនយានត្រូវគេបៀតបៀនយ៉ាងខ្លាំង ហើយពួកលោកសង្ឃពុទ្ធសាសនាជាច្រើនក៏ត្រូវកំចាត់ចេញអស់ ។*

## ២ — ការផុសកើតឡើងនិងសេចក្ដីចំរើនយ៉ាងធំទូលាយ នៃលទ្ធិមហាយាននិងលទ្ធិហិណ្ឌូ

*កាលពីខាងចុងសតវត្សរ៍ទី ៨ (ព.ស. ១២៤៣) នោះ មានសែស្រឡាយពុទ្ធសាសនាមួយថ្មី ផុសកើតឡើងក្នុងប្រទេសឥណ្ឌូស៊ីននេះ ហៅថាពុទ្ធសាសនាបែបមហាយាន ផ្សាយចេញមកពីមហាវិទ្យាល័យដ៏ល្បីល្បាញ ១ នៅស្រុកនាឡន្ទា ក្នុងដែនទន្លេគង្គា (ប្រទេសឥណ្ឌា) ។ ពុទ្ធសាសនាបែបនេះ ឆាប់ជ្រួតជ្រាបចូលទៅក្នុងចិត្តគំនិតរបស់ប្រជា-ជនធម្មតាទូទៅ ច្រើនជាងលទ្ធិហីនយានដែលប្រើផ្លូវសតិបញ្ញា ហើយផ្សាយចេញទៅយ៉ាងរហ័សក្នុងចំណោមប្រទេសឥណ្ឌូស៊ីន និងផ្សាយ*

ចូលទៅយ៉ាងខ្លាំង ក្នុងបណ្ដាប្រទេសឥណ្ឌូនេស៊ី (កោះផ្សេងៗដែលនៅជាចន្លោះឥណ្ឌូចិនអូស្ត្រាលី) មហានគរដែលកាន់ពុទ្ធសាសនាបែបនេះ ហៅថា ស្រីវិជ័យ (គឺប្រជាយប្រទេសមលេ) លុះតមកបន្តិចទៀត មានពុទ្ធសាសនាមួយផ្នែកដែលផ្សាយចូលមកក្នុងឥណ្ឌូស៊ីននេះ ដោយត្រូវមុស្លីម៉ាន់វាយកំចាត់កំចាយបណ្ដេញមកពីប្រទេសឥណ្ឌា ។

មានលក្ខខ័ណ្ឌជាច្រើនដែលបង្ហាញឲ្យឃើញបានដឹងច្បាស់ពីសេចក្ដីប្រែប្រួលយ៉ាងធំនៃលទ្ធិពុទ្ធសាសនាបែបមហាយាននេះ គឺមុនដំបូងកាលពីខាងចុងសតវត្សទី ៩ (ព. ស. ១៣៤៣) ក្សត្រខ្មែរ ១ អង្គព្រះនាមយសោវរ្ម័ន ទ្រង់កសាងវត្តពុទ្ធសាសនា ១ ឡើង រួចតមក ក្សត្រព្រះនាម ឥន្ទ្រវរ្ម័នទី ២ ទ្រង់កសាងវត្តដុង-យឿង ឡើង ក្នុងប្រទេសចាមកាលពីឆ្នាំ ៨៧៥ (ព. ស.១៤១៣) ។ ក្នុងសម័យនោះ សំគាល់ឃើញជាការច្របូកច្របល់គ្នារវាងពុទ្ធសាសនាលទ្ធិមហាយានទឹងសាសនាហិណ្ឌូលទ្ធិសិវៈនោះកាន់តែខ្លាំងឡើងហើយ ។ គេសង្កេតមើលឃើញជារឿយៗ អំពីមនុស្សម្នាក់កសាងវត្តពីរផ្សេងៗគ្នា គឺវត្តមួយឧទ្ទិសបូជាដល់ព្រះសិវៈ វត្តមួយទៀតឧទ្ទិសបូជាដល់ព្រះពុទ្ធ ឬដល់ព្រះពោធិសត្វ អវលោកិតេ-ស្វរៈ ។ មានវត្តដទៃទៀតនោះ ដូចជាវត្តដុង-យឿង គេធ្វើបូជាដល់ព្រះសិវៈលិង្គផង ដល់ព្រះពុទ្ធផង ។

តាំងពីសតវត្សរ៍ទី ១០ (ព. ស. ១៥៤៣) មក លទ្ធិសាសនាព្រាហ្មណ៍ (ហិណ្ឌូ) ក៏មានសេចក្ដីប្រែប្រួលព្រមជាមួយនឹងសេចក្ដីប្រែប្រួលនៅប្រទេសឥណ្ឌាដែរ (ពីដើម) ធ្លាប់គោរពបូជាព្រះសិវៈ ផ្លាស់ជាគោរពបូជាព្រះវិស្ណុវិញ និងការអវតារ (បែងភាគ) ដូចជាអវតារជាព្រះរាមនិងព្រះក្រិស្ណៈ ។ ការគោរពកាន់ព្រះវិស្ណុនេះហើយជាហេតុឲ្យមានការសាងវត្តយ៉ាងល្អឆើតឡើងសម្រាប់ឧទ្ទិសបូជា គឺនគរវត្ត សឹងមានក្បាច់ចម្លាក់យ៉ាងវិសេសៗ ជារឿងរាមាយណៈ ។ ប្រាសាទនេះហើយជាបែបរចនាយ៉ាងឯក ដែលបានកសាងឡើងក្នុងរាជ្យស្ដេចសុរ្យវរ្ម័នទី ២ ព. ស. ១៦៥៥ ដល់ ១៦៩៥ (គ. ស. ១១១២ ដល់ ១១៥២) ប៉ុន្តែមានអ្នកតែងរឿងខ្លះយល់ថា ប្រាសាទនគរវត្តជាប្រាសាទបូជាព្រះសពរបស់ក្សត្រ ហើយមានរឿងរ៉ាវចំឡាក់រចនាខ្លះធ្វើឡើងខាងក្រោយក្សត្រទិវង្គតទៅក៏មាន ។

ក្រោយដែលក្សត្រសុរ្យវរ្ម័នទី ២ ទិវង្គតទៅ រាជសម្បត្តិស្រុកខ្មែរបានធ្លាក់ទៅក្នុងកណ្ដាប់ដៃនៃពួកក្សត្រកាន់ពុទ្ធសាសនាវិញ ក្សត្រដែលមានព្រះនាមល្បីល្បាញជាបំផុតនោះ គឺព្រះបាទជយវរ្ម័នទី ៧ ដោយទ្រង់បានរៀបចំអាណាចក្ររបស់ទ្រង់ឲ្យមានវត្តកាន់តែកើនឡើងនិងទំនុកបំរុងលទ្ធិសាសនា ។ ឯការដែលជាសំខាន់បំផុត ដោយមិនមានសង្ស័យនោះ គឺទ្រង់កសាងទីក្រុងមួយធំ ដែលហៅថានគរធំ ចាប់

សាងឡើងខាងចុងរជ្យរបស់ទ្រង់ កាលពី ព.ស. ១៧២៥ ដល់ ១៧៤៤ (១១៨២ ដល់ ១២០១) ព្រមទាំងប្រាសាទបាយ័ន មានព្រហ្មមុខ ៤ នៅជុំវិញយ៉ាងធំសំបើមផង ទុកជាបែបកសាងមួយខាងកិច្ចការស្ថាបនាខាងលទ្ធិសាសនា ។

បណ្ដាប្រាសាទពុទ្ធសាសនាទាំងអស់ក្នុងសម័យនោះ សេចក្ដីគោរពបូជាព្រះពុទ្ធតែងជាប់ទាក់ទងនឹងព្រះពោធិសត្វអវលោកិតេស្វរៈយ៉ាងខ្ជាប់ខ្ជួន តាមឈ្មោះដែលគេស្គាល់ច្បាស់ក្នុងស្រុកខ្មែរ ហៅថា ព្រះលោកេស្វរៈ ប្រែថា ព្រះជាម្ចាស់លោក; ឯប្រាសាទដទៃទៀតខ្លះ ដូចជាបាយ័ន នាគព័ន្ធជាដើម សុទ្ធតែគេសាងឧទ្ទិសថ្វាយដល់សាសនាទាំងអស់ ។

តាមដោយពិត ក្នុងចំណោមប្រាសាទអង្គរ សុទ្ធតែជាបែបរចនាខ្មែរយ៉ាងល្អឆើត សឹងសំដែងឲ្យឃើញសេចក្ដីចំរើនយ៉ាងធំទូលាយនៃលទ្ធិសាសនាហិណ្ឌូនឹងពុទ្ធសាសនាបែបមហាយាននៅស្រុកខ្មែរយើងនេះ ។ ដល់អំណើះតមកគេមិនឃើញមានស្នាមលំអាននៃការគោរពបូជាព្រះសិវៈនឹងព្រះវិស្ណុទៀតឡើយ វៀរលែងតែនៅវត្តបាមខ្លះ នៅមានមនុស្សគោរពបូជាលិង្គនឹងរូបវិស្ណុនឹងព្រះសិវៈ ប៉ុន្តែសេចក្ដីប្រកាន់នេះក៏បាត់ទៅទៀត ដោយមិនយល់បំណងដាន់ដើមនោះដូចម្ដេច គ្រាន់តែយល់ថាជារូបធៀបដូចជារូបទេវរាជប៉ុណ្ណោះ ។ ឯលទ្ធិពុទ្ធសាសនាបែប

មហាយានក៏ផុតរលត់បាត់ក្នុងកាលតមកមិនយូរប៉ុន្មានដែរ មុនលទ្ធិពុទ្ធសាសនាបែបហីនយានត្រឡប់កើតឡើងទឹងមានសេចក្ដីចំរើនយ៉ាងធំឡើង ។

## ៣– អំពីការកើតឡើងថ្មីទៀតនៃលទ្ធិហីនយាន (ថេរវាទ)

គ្រានោះ នៅប្រទេសសៀមទើបកើតមានពុទ្ធសាសនាបែបថ្មីមួយឡើង មិនយូរប៉ុន្មាន ពុទ្ធសាសនាបែបនេះក៏ចូលមកក្នុងស្រុកខ្មែរទឹងស្រុកលាវ កំចាត់បង់នូវលទ្ធិសាសនាដទៃហោលអស់ ហើយផ្សាយចូលមកតាំងនៅយ៉ាងស៊ប់សួនរហូតមកដល់សព្វថ្ងៃនេះ ទុកជាសាសនាសម្រាប់ជាតិក្នុងប្រទេសទាំងពីរនេះ ។ ឯការផ្សាយចូលមកនៃលទ្ធិហីនយាននេះ ធ្វើឲ្យកើតចម្បាំងជាច្រើនលើកច្រើនគ្រាណាស់ ដែលសៀមបានធ្វើដល់ស្រុកខ្មែរ ។

យើងមានគោលចារឹកដ៏ពិតប្រាកដ អំពីកំណត់នៃសេចក្ដីប្រែប្រួលខាងផ្លូវសាសនានេះ ដោយមានរឿងរ៉ាវរបស់កដទូតចិនឈ្មោះ ចៅ–តា–កួន ដែលបានចូលមកមើលប្រទេសកម្ពុជា នៅចុងឆ្នាំនៃសតវត្សរ៍ទី ១៣ (ព. ស. ១៧៤៣) ក្រោយស្ដេចស្រិន្ទ្រវរ៉ន្ទឡើងសោយរាជ្យបន្តិច កាលពី (១២៩៦–១៣០៧) ព. ស. ១៨៣៩–១៨៥០ ។ មានគោលចារិកមួយទៀតនឹងសិលាចារិករបស់ក្សត្រដដែលនេះ ដែលលោក សឺដែស បានរកឃើញ ។ សិលាចារិកនេះសុទ្ធតែនិយាយពីរឿង

នេះ ហើយបារីកជាភាសាបាលីនិងភាសាសំស្ក្រឹត គឺជាជាពាក្យបាលីដំបូងបង្អស់ដែលបានរកឃើញក្នុងប្រទេសឥណ្ឌូស៊ីន និងមានសេចក្ដីថា "សេចក្ដីប្រែប្រួលរវាងពុទ្ធសាសនាជាន់ចាស់របស់ខ្មែរជាភាសាសំស្ក្រឹត និងពុទ្ធសាសនាជំនាន់ថ្មីបែបសិង្គលេសជាភាសាបាលីដែលបានមកពីស្រុកសៀម" ។

ឯពួកកងទ័ពសៀមដែលចូលមកលុកលុយស្រុកខ្មែរជាន់នោះ ជាពេលដែលជនជាតិខ្មែរកំពុងទន់ខ្សោយថយកំឡាំងនិងហិនហោចដោយការខំប្រឹងកសាងជាវត្ថុធំសំបើមជាអនេកនិងវត្ថុអាកាមធំៗ ក្នុងសម័យអង្គរ ទើបជាហេតុឲ្យប្រជាជនជាតិខ្មែរនាំគ្នាបោះបង់ការគោរដ៏លើសវិស័យមនុស្ស ដែលបានទទួលបង្គាប់ពីរាជការក្សត្រនិងពួកព្រាហ្មណ៍ ថែមទាំងបានបន្ថយការចំណាយយ៉ាងធំសំបើមក្នុងការកសាង ថែរក្សា ថែមទាំងពួកប្រជាជនអ្នកបួសដែលត្រូវកំណែន ក៏បានបន្ថយចេញដែរ ។ ទើបពួកប្រជាជននាំគ្នាទទួលយកសាសនាលទ្ធិហីនយានដោយសេចក្ដីស្ម័គ្រចិត្តដែលពួកមានជ័យជំនះនាំចូលមកផ្សាយក្នុងនគររបស់ខ្លួន លទ្ធិសាសនាថ្មីនេះ ជាសាសនាសុភាព រៀបចំកិច្ចការរបស់ប្រជុំជនតាមបែបប្រជាធិបតេយ្យ ជាសាសនាប្រកបដោយសន្តិភាពនិងស្ងប់ស្ងាត់ជាយ៉ាងល្អ ទាំងគណៈសង្ឃក៏មានចិត្តសន្ដោស ស្ម័គ្រចិត្តនៅក្នុងផ្ទះស្ទុកនិងបាយ១

បាត្រ ៗ មួយវិញទៀត ការសិក្សារៀនសូត្ររបស់ប្រជាជន ជាមុខក្រសួងរបស់លោកសង្ឃជាប់ដោយឡែក ទើបធ្វើឲ្យលទ្ធិសាសនាថ្មីនេះមានសេចក្ដីចំរើនលូតលាស់ឡើងយ៉ាងធំទូលាយដោយឆាប់ ៗ លទ្ធិហីនយានដែលបាត់ការផ្សាយបានសម្រេចផលល្អនេះ ដោយមានអ្នកនាំមកផ្សាយ ថែមទាំងមានអ្នកជួយបន្ថែមឲ្យឆាប់ចំរើនឡើងទៀត ដោយពួកអ្នកកាន់ពុទ្ធសាសនាក្នុងស្រុកផង ៗ

យើងនឹងពោលដោយគ្រួសៗ ត្រង់ដែលនិយាយពីការដែលស្រុកសៀមជាប្រទេសជិតខាង លើកទ័ពចូលមកលុកលុយក្នុងស្រុកខ្មែរនឹងស្រុកលាវ តាំងពីសតវត្សរ៍ទី១៤ ដល់សតវត្សរ៍ទី ១៦ (ព.ស. ១៨៤៣ ដល់ ២០៤៣) ព្រោះពង្សាវតារត្រង់នេះមិនសូវមានប្រយោជន៍ក្នុងរឿងដែលយើងកំពុងនិយាយនេះទេ ៗ តាំងពីសតវត្សរ៍ទី១៧(ព.ស.១៩៤៣) ពួកជនជាតិខ្មែរជាអ្នកមានគ្រោះថ្នាក់ គិតតែរៀបចំការពារប្រទេសជិតខាងពីទិសខាងកើត គឺពួកចាមដែលត្រូវយួនបណ្ដេញចេញពីប្រទេសរបស់ខ្លួន ហើយត្រូវច្បាំងតទល់នឹងពួកយួនទៀតផង ឯពួកយួនក៏ត្រូវ

(មានត)

# ពង្សាវតារក្រិក

(តមក)

កាលប្រទេសពែរ្សឃើញពួកក្រិកប្រឹងទឹងធ្វើសង្គ្រាមយ៉ាងម៉ឺងម៉ាត់ ដូច្នេះ ក៏បែរជាព្រមនិយាយសម្រួលតាមផ្លូវរាជទូត លើកលែងធ្វើសង្គ្រាមនឹងគ្នាក្នុង ព.ស. ៩៤ (មុន គ.ស. ៤៤៩) ហើយរៀបចំធ្វើខសន្យា ១ ហៅថាខសន្យាស៊ីម៉ុង ។ តាមសញ្ញាច្បាប់នេះ ប្រទេសពែរ្សត្រូវទទួលដឹងថា សមុទ្រអេសេជារបស់ក្រិក ហើយត្រូវទទួលរ៉ាប់រងថា នឹងមិនឲ្យទូកចម្បាំងចូលជិតមាត់សមុទ្រ ហួសរយៈកំណាត់តាមផ្លូវទូកដើរ ៣ ថ្ងៃ ។

ចុះហេតុអ្វីប្រទេសពែរ្សមានកំឡាំងកងទ័ពធំសំបើមជាងទ័ពក្រិកជាច្រើនភាគ តែត្រឡប់ជាបរាជ័យ ហើយពួកក្រិកមានជ័យជំនះយ៉ាងប្រពៃ? នេះជាប្រស្នាដែលតបបានដោយងាយទេ គោលគឺទាហានរបស់ក្រិក ជាជាតិក្រិកសុទ្ធ ៗ ហើយខំច្បាំងការពារប្រទេសជាតិ ស្រុកកំណើតរបស់ខ្លួន ។ ចំណែកឯពួកទាហានរបស់ប្រទេសពែរ្ស ជាពួកទាហានផ្សំលាយឡំច្របល់គ្នា ព្រោះពែរ្សយកមនុស្សស្រុកចំណុះមកធ្វើជាទាហាន ក្នុងក្រុមទាហាន ១ ក្រុម ៗ មានជាតិអេស៊ីរី, ជាតិអារ៉ាប់, ជាតិហ្វេនីស៊ាង នឹងពួកទាហានពែរ្សលាយច្របល់គ្នា ទើបបាញ់គ្នាឆ្ងាយដោយកំឡាំងទឹកចិត្ត ។

ក្រោយសង្គ្រាមក្រិកនឹងប៉ែរ្ស៍ — សង្គ្រាមរវាងក្រិកនឹងប៉ែរ្ស៍នេះបានធ្វើសេចក្ដីចំរើនដល់ពួកក្រិកយ៉ាងច្រើនពន្លឹក ទីក្រុងអាថែនដែលត្រូវពួកទាហានប៉ែរ្ស៍ដុតបោលទៅនោះ ក៏បានចាប់កសាងឡើងថ្មីយ៉ាងស្រស់ មានតាំងលំអទីងទំហំសំបើមជាងមុន ៗ ចំណែកខាងអក្សរសាស្ត្រក៏ចំរើនឡើងជាអនេកដែរ ដូចជានៅកន្លែងកប់ខ្មោចទាហានស្ប៉ាត ១ អន្លើ មានចារឹកគំរូជាអក្សរទុកនៅទីនោះថា "អ្នកដែលដើរកាត់ (ទីនេះ) សូមឲ្យទៅប្រាប់ស្រុកស្ប៉ាតថា មានសព ៣០០ ជាសពអ្នកស្រុកស្ប៉ាត ជាអ្នកជឿស្ដាប់បង្គាប់តាមច្បាប់ កប់នៅទីនេះ" ព្រះបាទលេអូនីដាសជិតនឹងក្ស័យព្រះជន្មក្នុងខណៈច្បាំងតទល់នឹងទាហានប៉ែរ្ស៍ក្នុងច្រកភ្នំនោះ អស់កំឡាំងនឹងតស៊ូតទៅទៀតហើយ ទើបព្រះបាទក្សែរសែសទ្រង់មានបន្ទូលឲ្យហុចអាវុធមកជាការសំដែងថាព្រមចុះចាញ់ ៗ តែព្រះបាទលេអូនីដាសត្រឡប់មានបន្ទូលតបទៅវិញថា "អញ្ជើញមកចាប់លមើលចុះ" ៗ អារិស្ទីដជាគូប្រណាំងប្រជែងនឹងថេមិស្តូក្លែ ត្រាតែត្រូវបំបរបង់ចេញពីស្រុកអាថែន្សនោះ បានចូលមករកថេមិស្តូក្លែហើយពោលថា "រឿងឈ្លោះទាស់ទែងគ្នារបស់យើងទាំងពីរនាក់នេះ លើកទុកនិយាយគ្នាវេលាក្រោយវិញចុះ ខណៈនេះ យើងត្រូវប្រណាំងគ្នាថា អ្នកណានឹងធ្វើគុណប្រយោជន៍ដល់ស្រុកទេសរបស់ខ្លួនបានច្រើនជាងគ្នា" សំដីអស់នេះសំដែងឲ្យឃើញថា

ជនជាតិក្រិកមានចិត្តស្រឡាញ់ប្រទេសជាតិខ្លាំងណាស់ ទាំងមានសេចក្តីក្លាហានអង់អាចនឹងមានគំនិតខ្ពង់ខ្ពស់ផង ។

សង្គ្រាមគ្រានេះធ្វើឲ្យស្រុកអាថែនមានកេរ្តិ៍ឈ្មោះល្បីល្បាញថាជាស្រុកសំខាន់បំផុតរបស់ក្រិក ព្រោះក្រិកមានជ័យជំនះប្រទេសពែរ្ស៍គ្រានេះ ទុកជាបានអាស្រ័យស្រុកស្ប៉ាតនឹងស្រុកឯទៀតៗចូលមកជួយជាច្រើនក៏ដោយ ក៏នៅតែអាថែនទទួលធ្វើការធ្ងន់ទឹងច្រើនជាងគេទាំងអស់ ហើយមានការបង្ហាត់ច្រើនជាងគេទាំងអស់ ហេតុនេះ អាថែនទើបមានដំណែងខ្ពង់ខ្ពស់ជាងប្រទេសក្រិកដទៃទៀត គួរយើងស្វែងរកវិជ្ជាចំណេះដែលមាននៅស្រុកនេះ ដូចមានពោលជាលំដាប់តទៅ ។

## អំពីអារ្យធម៌របស់ក្រិក

ក. អំពីទំនៀមទម្លាប់ក្រិក — ជនអ្នកស្រុកអាថែនបែងចែកជីវិតឬការងាររបស់ខ្លួនចេញជាពីរផ្នែក គឺជីវិតនៅក្រៅផ្ទះនឹងនៅក្នុងផ្ទះ ពោលគឺជនពួកនេះអាចចេញទៅធ្វើការអ្វីៗបានក្នុងវេលាថ្ងៃ ដូចការទៅកាន់រដ្ឋសភា, ទៅសាលា, ទៅវត្ត, ទៅមើលវិធីហាត់កាយកម្ម ។ ល ។ កាលត្រឡប់មកដល់ផ្ទះវិញ គេមិនប្រាប់ប្រពន្ធថា ខ្លួនទៅណា ឬទៅធ្វើអ្វីទេ ។ ចំណែកខាងភរិយា មានមុខងារគ្រាន់តែជាមេផ្ទះ មិនមានអំណាចដឹងឮ ឬជួយធុរៈការងាររបស់ស្វាមីដែលនៅខាងក្រៅផ្ទះឡើយ ។ ទុកជាមានទំនងដូច្នេះក៏ដោយ ឋានៈរបស់ស្ត្រីក៏មិនមែនថោកទាបពេកដូចជាប្រទេស

ខ្វះនោះទេ ពោលគឺមានច្បាប់បញ្ញត្តអំពីរបៀបរៀបការទុកថា ស្វាមីត្រូវមានទ្រព្យសម្បត្តិទុកឲ្យភរិយាឲ្យមានចំនួនល្មមគ្រប់គ្រាន់នឹងចិញ្ចឹមជីវិតកាលបើស្វាមីលះលែងមិនទទួលចិញ្ចឹមតទៅ ភរិយាមានអំណាចពេញទីកន្លែងផ្ទះនឹងមានអំណាចស្ដីបង្គាប់បាវព្រាវទាំងឡាយបាន អាចចេញទៅក្រៅផ្ទះហើយទទួលមិត្រសំឡាញ់របស់ខ្លួនក៏បាន តែហាមសេពគប់នឹងមនុស្សប្រុស កិច្ចធុរៈដ៏សំខាន់របស់ភរិយាគឺការជាមេផ្ទះ ។

តាមទំនងនេះ ឃើញថាឋានៈរបស់ស្ត្រីស្រុកអាថែន្សខុសគ្នាឆ្ងាយពីស្ត្រីស្រុកស្ប៉ាត ស្ត្រីក្រមុំស្រុកស្ប៉ាតត្រូវឃុំខាំងលាក់បំពួនមុខយ៉ាងម៉ឹងម៉ាត់ ហើយការសិក្សារបស់ស្ត្រីក្រមុំមានត្រឹមតែហាត់ប្រៀង-កាយក្មេង-រៀនធ្វើម្ហូបចំណីនឹងរៀនដេរប៉ាក់ កាលដល់អាយុគ្រប់ការ មាតាបិតាក៏ចាត់ចែងរៀបការនឹងបុរសណាមួយដែលឃើញសមគួរ ដោយមិនបាច់សួរចិត្តកូនក្រមុំមួយម៉ាត់ ។

កូនប្រុសកាលមានអាយុ ៦ ឆ្នាំហើយរមែងផុតពីមុខក្រសួងរបស់ម្ដាយ ហើយមានគេនាំខ្លួនក្មេងទៅសាលារៀន អ្នកដែលនាំក្មេងទៅសាលានេះតាមធម្មតាជាបាវ គេហៅថា ប៉េដាគូគ៍ ។ ការសិក្សានៅស្រុកអាថែន្សនោះមាន ២ ផ្នែក គឺរៀនតន្ត្រី ១ ផ្នែក រៀនពលសិក្សា ១ ផ្នែក ផ្នែកតន្ត្រីនេះមិនមែនរៀនត្រឹមផ្លុំប៉ី កាយក្មេង ប្រៀងប៉ុណ្ណោះទេ នៅមានការរៀនលេខ-អក្សរ ទន្ទេញកាព្យឃ្លោងដូចកាព្យរបស់អ្នកប្រាជ្ញហូមែរ

ជាដើមជង ។ លុះក្មេងមានអាយុដល់ ១៤ ឆ្នាំឡើងទៅ ត្រូវរៀនពល-សិក្សាយ៉ាងម៉ឺងម៉ាត់ ព្រោះមនុស្សប្រុសជាតិក្រិកតែងនិយមរាប់អានថា តោងមានរូបឆោមល្អនិងមានកាយខែងរែង-រឹងប៉ឹង ។ លុះក្មេងអាយុដល់ ១៨ ឆ្នាំ ត្រូវបញ្ជូនខ្លួនទៅសិក្សាវិជ្ជា ១ ផ្នែកទៀត ហៅថា អេហ្វបឺ គឺវិជ្ជាទាហាន, ទទួលយកគ្រឿងអាវុធនិងស្បថរួចហើយទើបមានសិទ្ធិជាមនុស្សពេញច្បាប់ ហើយមានអំណាចបោះឆ្នោតរើសដំណាងក្រសួងនិងកិច្ចការដទៃទៀតតាមច្បាប់ ។

ប្រជាជនធម្មតាមែនមានពេលច្រើនសម្រាប់ធ្វើការងារផ្សេងៗបាន ព្រោះកិច្ចការផ្ទាល់ខ្លួននោះ មានពួកបាវៗ ចាត់ចែងធ្វើជំនួស ពួកបាវឬខ្ញុំនេះស្ទើរតែមានគ្រប់ៗផ្ទះ បាវឬខ្ញុំក្នុងស្រុកអាថែន្សនោះមាន ៣ ពួក គឺកូនដែលកើតពីម្ដាយអាពុកជាខ្ញុំនៅក្នុងផ្ទះ១ ឈ្លើយសឹកដែលចាប់ខ្លួនមកពីសង្គ្រាម ១ ខ្ញុំដែលទិញបានមកពីផ្សារ ១ (ផ្សារដែលលក់ខ្ញុំនេះមុខគួរឲ្យអាណោចអាធម្មណាស់ ក្នុងសម័យបុរាណ) ។ អ្នកមានគ្រាន់បើ មានខ្ញុំកំដរច្រើន សូម្បីប្រជាជនដែលទ័លក្រក៏គង់មានខ្ញុំកំដរម្នាក់ឬពីរនាក់ ព្រោះខ្ញុំកំដរនេះអាចទិញដូរបានដោយថ្លៃថោកៗមិនលើសពី ២០០ ក្រ-ណោត (ឬ ២០ រៀល) ។ ខ្ញុំនេះជាសម្បត្តិមួយយ៉ាងរបស់នាយចៅ-ហ្វាយៗអាចនឹងធ្វើទោសឬលក់ដូរតទៅទៀតបាន វៀរលែងតែសម្លាប់ ច្បាប់ស្រុកអាថែន្សហាមផ្តាច់មិនឲ្យសម្លាប់ខ្ញុំរបស់ខ្លួន ។ តែតាមធម្មតា

ជនជាតិអាថែន្យមានចិត្តអាណិតមេត្តាដល់ខ្ញុំកំដររបស់ខ្លួន ច្រើនប្រើឲ្យធ្វើការក្នុងពេលធ្វើការហើយឲ្យប្រាក់ខែផង ហេតុនេះបានជាមានពាក្យពោលទុកថា របៀបវេទនានឹងការកសាងផ្សេងៗ ចំរើនរុងរឿងច្រើនបំផុតនោះអាស្រ័យស្នាដៃរបស់ខ្ញុំកំដរអស់នោះដោយច្រើន ។ ពួកអ្នកស្រុកអាថែន្យដឹងរឿងនេះច្បាស់ ទើបគេខំបាយជន្ទចិត្តបារដោយវិធីផ្សេងៗ ដូចជាខ្ញុំណាមានថ្វីដៃពូកែ ធ្វើការល្អ ក៏ឲ្យរួចជាអ្នកជាបាន ដែលជារង្វាន់ខ្ពស់បំផុតរបស់ខ្ញុំកំដរក្នុងសម័យនោះ ។

ពួកក្រិកពេញចិត្តនឹងការជុបលៀងគ្នាយ៉ាងអឹកធឹក គេអញ្ជើញបក្ខពួកមកស៊ីលៀងជាចំនួនច្រើន តាមរូបគំនូរដែលមានជាប់នៅនឹងពានប៉ាន់ដែងនោះ នឹងឃើញថាការជុបលៀងរបស់ពួកក្រិកនេះជាចំឡែកណាស់ ពោលគឺមនុស្សម្នាក់ៗមានគ្រែវែង១ មានតុអាហារ១ ដាក់ពីខាងមុខ ដេកផ្អៀងសណ្ដូកជើងដៃឆ្វេងច្រត់លើខ្នើយ ដៃស្ដាំលូកចាប់អាហារទទួលទានតែមិនប្រើសមទេ វេលាកំពុងបរិភោគអាហារនេះ គេនាំគ្នានិយាយជជែកពីប្រសាសនោបាយ ឬពីធម៌អាថ៌កំបាំង ។

ទំនៀមធ្វើបុណ្យខ្មោចជាពិធីអ៊ឹកធឹករបស់ក្រិកមួយដែរ ហើយក្នុងពិធីនេះច្រើនមានស្ដ្រីចូលមកបាត់ការផង គឺស្ដ្រីជាអ្នកផ្ងូតទឹកគាក់តែងសព លើកសពដាក់ដំកល់លើគ្រែ១ មានញាតិមិត្រមកប្រជុំសំដែងសេចក្ដីអាឡោះអាល័យយំសោកនៅចំពោះមុខសព ។ ដល់ពេលព្រលឹម

មុនអរុណរះក៏នាំគ្នាហែសពចេញទៅ   សពនោះមានមនុស្សពាក់អាវខ្មៅ ជាច្រើននាក់លើកដាក់ស្នាសែងដើរទៅ  បើមិនធ្វើដូច្នេះ  គេលើកដាក់រថ សពហែក៏មាន  បណ្ដាញាតិជិតៗក៏ស្លៀកពាក់កាន់ទុក្ខដើរតាមសពទៅ បន្ទាប់ពីសព  មានមនុស្សផ្លុំប៉ីខ្លុយជាមួយនឹងភ្លេង  វេលាដើរហែពួកញាតិ ក៏យំទ្រហឹងអឺងកង ៗ  ទីកប់សពនោះ  គេមិនជីកដីធម្មតាទេ  គេជីកថ្ម ជើងភ្នំ លុះដាក់សពទៅក្នុងរណ្ដៅហើយក៏យកថ្មដុំធំបិទជួប់ទៅ ៗ ប្រសិន បើជាអ្នកមានស្ដុកស្ដម្ភ  គេយកថ្មកែវកេះឆ្លាក់ជាក្បាច់រចនាយ៉ាងល្អ  តមក មានពួកកូនចៅត្រូវនាំយកអាហារភោជនទៅឲ្យនៅទីកប់ខ្មោចនោះតាម កាលសម័យ  ប្រហែលទំនៀមរបស់អេស៊ីប្ដ៏  ព្រោះគេប្រកាន់ថាបើមិន ធ្វើដូច្នេះទេ  វិញ្ញាណរបស់អ្នកដែលស្លាប់ទៅតោងទៅររកអាហារទទឹងលំ-បាកវេទនាច្រើន  ជំនឿនេះមិនមែនមានត្រឹមប្រជាជន  សូម្បីរាជការក៏ជឿ ប្រកាន់តាមផងដែរ  ដល់ទៅមានច្បាប់ដាក់ទោសដល់កូនចៅរបស់អ្នក ស្លាប់ ដែលមិនបាននាំយកអាហារភោជនទៅឲ្យសពក្នុងវេលាដ៏សមគួរ ៗ ធ្លាប់មានគួយ៉ាង ១ ដំណាលថា  មានមេទ័ពម្នាក់ទៅច្បាំងមានជ័យជំនះ យ៉ាងធំសំបើម  តែត្រឡប់ជាត្រូវទោសប្រហារជីវិត ព្រោះមិនព្រមគំនាប់ សពពាហានដែលស្លាប់ក្នុងចម្បាំង ៗ

(មានតទៅទៀត)

នេះ

ច្បាប់សុភាសិត

ប្រសើរពេកពិត ប្រែពីគាថា
បន្ទូលព្រះពុទ្ធ បំហុតទេស្នា
ឲ្យអស់ទាំងមហា- ជនផងត្រងត្រាប់ ។

និព្វានប្បច្ចយោ ហោតុ មេ ។

របស់

ឧកញ៉ាវង្សាសារពេជ្រ នង ចាងហ្វាងក្រុមរាជបណ្ឌិត

*ក្នុងរាជ្យព្រះបាទសម្តេចព្រះហរិរក្សរាមាឥស្សរាធិបតី*

*(ព្រះអង្គដួង)* ។

(តមក)

ត្រកូលថ្លៃថ្លា ។ ពស់ពាលសាហាវ យកពិសប្រហារ ជាតជាពលា ក្សត្រាយកទ្រព្យ ប្រដាប់ឲ្យជា រទ្ធាទ់យោធា ជាតជាកំឡាំង ។

២០- នារីកុលេ ចតុលោកេ ចសុទាកំ សុវចនៈ រក្ខធនំ បតិរក្ខំ គហានេភា ។ លោកថាបើស្រី ណាចេះ ផ្គាប់ប្ដី ចេះរៀបបណ្ណា- ការស្ងួផណ្ដាំ ភ្ញាញ់សាប់សា កបកើតឲជា- រសរក្សាប្ដី ។ រៀបពប់រក្សា ធនធានទ្រព្យា- ករកបសំដី មិនឲ្យមាន អាក់ អន់ប្រាក់ចិត្តប្ដី ប្រសើរជាស្រី ស្មោះស្មើទេក្តា ។

២១- យោបុត្តលោ លទ្ធិវញ្ញោ កុតោយសា លទ្ធិ- គុរុ កុតោបញ្ញា លទ្ធិករិយា កុតោមុត្តិ ។ បទបន្ទូថា នរអ្នកណា ប្រមូលអប្រិយ ខ្ជិលផ្គាប់ព្រះមហា- ក្សត្រាធិបតី បាន បុណ្យបទអ្វី អំបួអង្គអាស្រូវ ។ វិសិស្សតំអឹង ចិត្តពោរពែងរឹង ខ្ជួញ ខ្ជិលទីងគ្រូ ទឹងបានពីណា ប្រាជ្ញាមូទូ អំបួអង្គឯទូរ អសារសូន្យ សោះ ។ មួយថាស្វាមី បើចិត្តខ្លាសស្រី អន់អៀនពុំស្មោះ ខ្ជិលពុំ ស្នេហា ចិន្ដាកាន់កោះ តើទឹងមានមោះ កូនកើតទឹងអ្វី ។

២២- អសន្តោសោ យតិនដ្ឋោ មហិបតិ សន្តុ- ដ្ឋោស: លជ្ជាគណិ- កានលជ្ជី កុលំនភា ។ ទិទាន បន្ទូ បាលីថាឯ ភិក្ខុឯណា មួយមិនសន្ដោស ពោសទុក្ខពុំជា ប្រយោជន៍ អង្គអា- សារសោះសូន្យសុល ។ មួយទីក្សត្រា- ធិរាជបេស្ដា រ័ក្សក្រស្ត្រ

មណ្ឌល បើមានសន្តោស ទុក្ខទោសអំពល់ អំពើពុំស្គល់ រាជរម្យរដ្ឋ ។ មួយស្រីថ្លាមាស បើមានចិត្តខ្មាស ពេកពុំបានជា ប្រយោជន៍នៃប្រាណ ពុំបានទ្រព្យ អន្ទឥតអ្នកណា ចូលចង់អន្ទប្រាណ ។ មួយនីអ្នកណា មួយមានពន្ស្រ ត្រកូលសន្តាន បើមិនមានខ្មាស ពញាសណ្ឋានពាន អ្នកនោះនឹងមាន ប្រយោជន៍ពីអ្វី ។

២៣ – ធនសារធំ អប្បម្សៀតំ ក្សាបការី- វជិក្ខយំ បហុតម្បី សាធុការី- វអេធ្វេខ្ញុំ ។ លោកថាធនធាន ទ្រព្យនៃអ្នកមាន សប្បុរសសេដ្ឋី ទោះតិចក្តីណា ហេតុសន្ធាខ្ញាំង ចែកជាទាន ឲ្យដល់អ្នកផង ។ នេះទូវគ្គនា ដូចកល់តគ្គា អណ្តូងគេជងពិតពុំហែងហួត រីងស្ងួតឡើយហោង នៃនរអ្នកផង អាស្រ័យសឹងបាន ។ រីទ្រព្យរបស់ អ្នកឥតសប្បុរស ទោះច្រើនប៉ុនាន ទ្រព្យនោះសឹងត្បូយ អាស្រ័យពុំបាន ហេតុពុំឲ្យទាន ធ្វើបុណ្យឡើយនៃ ។ នេះទូវគ្គនា ដូចកល់ទឹកមហា- សមុទ្រសោតប្រៃ សឹងសូទ្យអសារ ឥតការពេកក្រៃ ឥតអ្នកអាស្រ័យ បានបរិភោគ្គ ។

២៤ – កក្កុជាធំ ឆត្តិសិរំ សបព្វាធាធា ឆតប្អូធិ កក្កុជជជា ឆត្តិនរមា- វមញ្ញតី ។ ពាក្យពិតឧបមា ក្តាមឥតក្បាលក់- បេះដើរកេស៊ី ពស់សោតឥតជើង បេះឡើងឈើខ្ពស់ មាន

ជាបក្សី សត្វសោកគ្មានដោះ ៗ ចិញ្ចឹមកូនបាន រស់រូបមិនមាន ក្សិណក្ស័យសូន្យសោះ មនុស្សផងទាំងឡាយ កុំមើលងាយស្មោះ ដ្បិតមានបុណ្យនោះ ពុំយល់កំបាំង ៗ

២៨ – ធិរំតិក្ខោ វចាវកោ តិក្ខោធិរំ ធុវចនា មហាតិក្ខំ ធិរចារកំ មហាតិក្ខា ៗ លោកថាព្រះ សូរ្យសែងរឿងរះ កណ្ដាលវេហាស៍ ក្ដៅក្ដាត់បំហាយ សូរ្យសាយមហិមា មោះពុំស្មើនា កំដៅអគ្គី ៗ នាអ្នកកាន់កាច ពោលពាក្យកំណាច ពិតពុំមេត្រី នោះក្ដៅក្រៃលែង សូរ្យសែងរង្សី ក្រៃលែងអគ្គី ក្ដៅក្ដាត់មហិមា ៗ

២៩ – មធុសុណិ ជាលបត្តិ- កាសុណិដ្ឋា- លា- ពុទ្ធេសៈ សុណិសាស្ត្រា ចចន្ទិមា សុណិបុណ្ណមី ៗ លោកថាឃ្មុំ ខ្មីឃ្មាតខិតខំ យកគេសរក្រើ តៃម្វ៉ៃតើបាន ប៉ុន្មានមួយទី ចាបជាបក្សី សត្វសោកចង់បាន ៗ ខិតខំរកធ្វើ សំបុកម្វ៉ៃតើ បានច្រើនប៉ុន្មាន នេះដូចអ្នកណា ប្រាជ្ញាញេយ្យញាណ រៀនខំឲ្យបាន ចេះតែមួយថ្ងៃ ៗ តើបានប៉ុន្មាន ហេតុនោះឲ្យមាន ការព្យាយាមនៃ ដូចកល់ព្រះចន្ទ្រ សោភ័នថ្ងាថ្ងៃ ទើបកើតតៃម្វ៉ៃ តើពេញបុណ្ណមី ៗ

(មានត)

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

ឆ្នាំគំរប់ ១៣

ភាគទី ៩

INSTITUT BOUDDHIQUE

ភ្នំពេញ

ការផ្សាយរបស់ព្រះរាជបណ្ណាល័យ

ព. ស. ២៤៨៣

គ. ស. ១៩៤១

# TABLE DES MATIÈRES

Pages

1° Qu'est-ce qu'un métier? par KHEMARARANSI ................ 3
តើអ្វីហៅថាមុខរបរ ? ដោយ ខេមររង្សី

2° Note de contre propagande en Cambodgien ................ 8
សេចក្ដីទាស់ការឃោសនា ជាភាសាខ្មែរ

3° Chbab SUBHASIT (Poème Khmèr) par Oknha VONGSASARAPÉCH
ច្បាប់សុភាសិត (កំណាព្យខ្មែរ) ដោយ ឧកញ៉ា វង្សសារពេជ្រ នង (ត)
NONG (suite) ................ 11

4° ANAMAYAKATHA par KHEMARARANSI (suite) ................ 15
អនាមយកថា ដោយ ខេមររង្សី (ត)

5° Conte populaire cambodgien inédit: រឿងនិទានប្រជាប្រិយខ្មែរ មិនទាន់បោះពុម្ព

"Légende de ALÉV II" par OKNHA PRACHNHATHIBADEY
រឿង អាឡេវ ភាគ II ដោយ ឧកញ៉ា ប្រាជ្ញាធិបតី យិន (ត)
YIN (suite) ................ 21

HORS TEXTE : រូបក្រៅអត្ថបទ

Luong Prabang — Jeune fille de Luong Prabang ........ 1
លួងព្រះបាង — ក្មេងស្រីលួងព្រះបាង



ក្រុងហ្លួងព្រះបាង . បែកភាពស្ត្រីក្រមុំក្រុងហ្លួងព្រះបាង ។

# អាជីវកម្មគឺអ្វី ?

## វគ្គទី ១

ការដែលមនុស្សយើងមានជីវិតយឺនយូរហើយមានសេចក្ដីសុខកាយសប្បាយចិត្តបាននោះ តោងអាស្រ័យការបរិភោគនិងមានវត្ថុផ្សេងៗដែលមាននៅក្នុងលោក វត្ថុអស់នោះមានបំពួកខ្លះរកបានច្រើន ទាំងមានចំនួនច្រើនរកងាយ ដូចជាអាកាសជកដង្ហើម រមែងមានប្រើគ្រប់គ្រាន់មិនខ្វះខាត នៅទីណាក៏មានគ្រប់អន្លើ យើងមិនបាច់នឿយហត់ដើររកទេ ជាវត្ថុសាធារណៈដេរដាសសល់ផល តែវត្ថុបំពួកខ្លះមានចំនួនតិចជាងសេចក្ដីត្រូវការរបស់មនុស្ស ត្រូវតែយើងប្រឹងខ្វល់ខ្វាយរកទើបបានមក វត្ថុបំពួកនេះយើងហៅថា "ទ្រព្យ" ។ ពាក្យថា "ទ្រព្យ" មានពីរយ៉ាងគឺ ភោគ-ទ្រព្យ បានខាងអាហារចំណីផ្សេងៗ រួមហៅថា "គ្រឿងបរិភោគ" និងគ្រឿងប្រើប្រាស់ផ្សេងៗ រួមហៅថា "គ្រឿងឧបភោគ"១ ធនទ្រព្យ បានខាងមាសប្រាក់ពេជ្រនិលចិន្តានានាប្រការ១ ។ ទ្រព្យអស់នេះយើងត្រូវតែប្រឹងខ្វល់ខ្វាយប្រើកំឡាំងកាយនិងកំឡាំងទ្រព្យជាដើមទុន ទើបបានមកបរិភោគប្រើប្រាស់ ការស្វែងរកទ្រព្យដើម្បីយកមកចិញ្ចឹមជីវិត និងទំនុកបំរុងសេចក្ដីសុខកាយសប្បាយចិត្តនេះហើយហៅថា "អាជីវកម្ម" ។

ការចិញ្ចឹមជីវិតនេះជារបស់សំខាន់បំផុតក្នុងជីវិតរបស់មនុស្សយើង ហេតុដែលមនុស្សយើងមានក្រនឹងមានសេចក្ដីសុខទុក្ខផ្សេងៗ ក៏ព្រោះរបរចិញ្ចឹមជីវិតនេះឯង អ្នកឯណាមានសេចក្ដីខ្នះខ្នែងឧស្សាហ៍ព្យាយាមច្រើន មានចំណេះចេះដឹងប៉ិនប្រសប់ ក៏រកទ្រព្យបានច្រើន ទៅជាអ្នកមានស្តុកស្តម្ភ ជាសេដ្ឋី គហបតី ។ ឯអ្នកដែលខ្ជិលច្រអូសមិនមានចំណេះចេះដឹងនឹងគេ ក៏រកទ្រព្យពុំបាន ទៅជាមនុស្សគោកយ៉ាក ដែលហៅថាអ្នកទ័លក្រឥតទ្រព្យអ័ប្បប្រាជ្ញា ។ មនុស្សយើងទុកជាអ្នកមានឬអ្នកក្រ ក៏ត្រូវតែធ្វើការជាដរាប ទើបមានគ្រឿងស៊ីគ្រឿងប្រើប្រាស់ ល្មមឲ្យរស់ជីវិតនឹងមានសេចក្ដីសុខសប្បាយតទៅមុខបាន ។ មនុស្សដែលមិនធ្វើការរកស៊ី គោងអាស្រ័យអ្នកដទៃជួយចិញ្ចឹមខ្លួន ដោយមិនមានអ្វីឲ្យតបទៅគេវិញ លោកប្រៀបដូចបញ្ញើក្អែក គួររាប់ថាជាមនុស្សឥតប្រយោជន៍ ។ ប្រសិនបើក្នុងគ្រួសារណាឬក្នុងត្រកូលណាមានមនុស្សទំស៊ីច្រើន (អ្នកធ្វើការតិច) វង្សត្រកូលនោះនឹងទៅជាក្រីក្រមិនខាន ឯស្រុកទេសក៏មានទំនងដូចគ្នាដែរ ប្រសិនបើមានមនុស្សស៊ីច្រើនជាងអ្នកធ្វើការ ក៏មិនមានសេចក្ដីចំរើនរុងរឿងច្រើនដែរ ទើបរដ្ឋបាលយកចិត្តទុកដាក់នឹងរបរចិញ្ចឹមជីវិតរបស់ប្រជាជន បើអ្នកឯណាមិនយកចិត្តទុកដាក់ធ្វើការចិញ្ចឹមជីវិតជាឡាក់ហ៊ាន លោកហៅថាជាមនុស្ស

ដែលគោល អ្នកផងគេមិនត្រូវការសេពគប់ សូម្បីញាតិមិត្តក៏មានចិត្តរង្កៀសដែរ ។

អាជីវកម្មនេះ មានយុវជនជាច្រើនដែលមើលមិនឃើញច្បាស់ឬនឹកមិនឃើញថា របរជារបស់សំខាន់ត្រឹមណា ព្រោះមាតាបិតាឬអ្នកគ្រប់គ្រងជាអ្នករក ជាអ្នកធ្វើ យកមកចិញ្ចឹមយើង ៗ គ្រាន់តែជាអ្នកស៊ី-អ្នកប្រើប្រាស់ ទើបយល់ថាជាការស្រួលសប្បាយ តែថាបើគិតឲ្យជ្រៅបន្តិចទៅ នឹងយល់ច្បាស់ថា គ្រឿងស៊ីគ្រឿងប្រើអស់នោះ លោកបានមកដោយខំធ្វើការរកជីវកម្មទាំងអស់ ។ បើសិនបើឈប់ធ្វើការចិញ្ចឹមជីវិតកាលណា គ្រឿងស៊ីគ្រឿងប្រើក៏គ្មាន ទុកជាមានរបស់ចាស់សេសសល់នៅខ្លះក៏គង់រេចរិលអស់ទៅជាលំដាប់ ។ ហេតុនេះ ត្រូវតែយុវជនយើងជួយមាតាបិតាឬអ្នកអភិបាលខ្លួនធ្វើការងារផ្សេង ៗតាមកំឡាំងនឹងកាលវេលា ព្រោះយើងធំឡើងត្រូវតែធ្វើការងារ ដើម្បីចិញ្ចឹមខ្លួន-គ្រួសាររបស់ខ្លួននឹងមាតាបិតា តបស្នងសងគុណអ្នកមានគុណជាដើមតទៅទៀត ។ កិច្ចអស់នេះយើងបៀសវាងមិនរួច ហើយយើងសង្ឃឹមពឹងអ្នកដទៃតែម្យ៉ាងក៏មិនបានដែរ មាតាបិតាក៏គ្រាន់តែចាស់ជរាទៅរាល់ថ្ងៃ យើងត្រូវតែធ្វើការងារជំនួសលោក ដើម្បីដំកល់វង្សត្រកូលឲ្យចំរើនឡើង ទើបសមនឹងមុខគ្រួសារខ្លួនដែលជាបុត្រល្អ ដែលលោកហៅថា អតិជាតបុត្ត ។

របរចិញ្ចឹមជីវិតក្នុងលោក បើយើងមិនមានសេចក្ដីឧស្សាហ៍ប្រឹងប្រែង ទាំងមិនមានវិជ្ជាស្ទាត់ជំនាញហើយ យើងនឹងធ្វើឲ្យគ្រាន់បើប្រហែលឬល្អជាងមាតាបិតារបស់ខ្លួនពុំបានឡើយ លុះមកដល់សម័យនេះ ការចិញ្ចឹមជីវិតគ្រប់ចំណែកកាន់តែចង្អៀតឡើងជានិច្ច ព្រោះមានមនុស្សផ្សេងជាតិផ្សេងភាសាមកដណ្ដើមការធ្វើ ទាំងរបររកស៊ីឯទៀតៗគ្រប់ចំណែក បើយើងមិនមានចំណេះទាំងស្ទាត់ជំនាញសមតាមសម័យហើយ មុខជាស៊ូទាំងគេមិនបានដោយដាច់ខាត ហើយបានសេចក្ដីលំបាកវេទនាទៅថ្ងៃក្រោយមិនខាន ។

ការដែលយើងមានសេចក្ដីចេះដឹងស្ទាត់ជំនាញលុះតែអាស្រ័យការសិក្សារៀនសូត្រជាមុនសិន ហើយឱកាសដែលយើងត្រូវរៀនសូត្រឲ្យចេះដឹងល្អ ក៏គឺពេលដែលខ្លួននៅក្មេង ព្រោះឱកាសនេះយើងមិនសូវមានកង្វល់ទាំងរបរចិញ្ចឹមជីវិត មាតាបិតាឬអ្នកអភិបាលបញ្ជូនខ្លួនយើងឲ្យទៅរៀនសូត្រក្នុងសាលា ដើម្បីឲ្យយើងមានចំណេះវិជ្ជា កាលធំចំរើនឡើងនឹងនាំយកចំណេះអស់នោះទៅធ្វើការចិញ្ចឹមជីវិតបានស្រួល តែចំណេះវិជ្ជាដែលយើងត្រូវឲ្យរៀននោះមានច្រើនយ៉ាងច្រើនប្រការ បើរួមឲ្យខ្លីទៅមាន ២ ប្រការគឺ សាមញ្ញវិជ្ជា បានខាងចំណេះដែលត្រូវចេះពល់គ្នា ដូចវិជ្ជាអក្សរ លេខ ចរិយា អនាម័យ ជាដើមប្រការ ១ ម្យ៉ាងទៀត គឺវិសាមញ្ញវិជ្ជា បានខាងចំណេះវិជ្ជាណាមួយដែលត្រូវរៀនឲ្យចេះ

ស្ដាត់ដោយឡែក គឺវិជ្ជាអាជីវកម្មប្រការ ១ ៗ យើងមុននឹងចេញពីសាលា
រៀន ត្រូវគិតរៀនវិជ្ជាអាជីវកម្មឲ្យបានសម្រេចជាមុនសិនសិមចេញទៅ
ធ្វើការរកទទួលទានតាមភូមិប្រទេសរបស់ខ្លួនឬតាមវិជ្ជាការរបស់ខ្លួន
ទើបសម្រេចបានដូចបំណង ៗ តាមធម្មតាមនុស្សយើងត្រឹមម្នាក់ៗ
មិនអាចនឹងធ្វើការងារនានាបានគ្រប់យ៉ាងទេ តោងអាស្រ័យផ្លាស់ប្ដូរគ្នា
ទៅវិញទៅមក ដូចនឹងពោលក្នុងបទតទៅនេះ

(មានត)

# សេចក្ដីផ្សាយតទល់នឹងសេចក្ដីឃោសនា

តាមផ្លូវវិទ្យុពីថ្ងៃ ៨ ខែឃ្មុំគិរិយេររនេះ

សព្ទវិទ្យុខ្មាំងបានគកឲ្យដំណឹងមកបណ្ដាអ្នកស្រុកតំបន់ឥណ្ឌូស៊ីនច ខ្មាំងបារាំងសែសចាត់អាកាសយន្តនាំគ្រាប់បែកទៅទម្លាក់នៅខែត្រណា ខនជាណាំ ១ មុខជាហាន ១ បានជាខ្មាំងថៃចាត់ឲ្យអាកាសយន្តយកគ្រា បែកមកទម្លាក់ខ្មាំងខែត្រណា-ខ្មែរជាការសងសឹកគ្នាវិញ ហើយកជការ ថាឲ្យយើងជាអ្នកស្រុកនាំគ្នាជញ្ជូនទ្រព្យសម្បត្តិរត់ចេញពីទីក្រុងទីមួយ កុំឲ្យនៅជិតពួកបារាំងដែលត្រូវគ្រាប់ស្លាប់ ។

នេះយើងខ្មាំងខ្មែរបានដឹងយល់កិច្ចការនឹងគំនិតរបស់ពួកការថៃច្បាស ណាស់ឥតមានឆ្ងល់ត្រង់ណាទេ ពីព្រោះគំនិតរបស់ថៃគិតតែសម្លាប់យើ ហើយប្រើឧបាយនិយាយពាក្យផ្អែមបញ្ឆោតយកគុណសែលើយើងទៀ យើងគ្មានអរគុណទេ ។

សព្វថ្ងៃនេះបើថៃមិនបានឲ្យអាកាសយន្តយកគ្រាប់បែកទៅទម្លា សម្លាប់យើងជាមុន នេះបារាំងសែសគ្មានរកហេតុតបវិញសោះ ។ ប៉ុ ខ្មាំងថៃបានធ្វើលោកទៅលើយើងខ្លាំងហួស ទើបបានជាបារាំងសែសត វិញ ។

ជាកល់ជង់នេះយើងបានសំគាល់ឃើញអាកាសយន្តរបស់ថៃហោះទៅធ្វើបាបខ្មែរឲ្យមានស្លាប់របួសជាមុន រួចរំលងបាន ១ ថ្ងៃ ឬ ២ ថ្ងៃទើបបារាំងសែសធ្វើតបវិញ ខាងបារាំងសែសមិនដែលផ្តើមហេតុសោះ ។

មួយទៀតថៃមានពាក្យថាអាណិតខ្មែរ មិនចង់ឲ្យខ្មែរស្លាប់ទេ ប៉ុន្តែយន្តហោះរបស់ថៃនាំគ្រាប់បែកទៅទម្លាក់សំដៅតែលើវត្តអារាម លើទីប្រជុំផ្សារក្រុងណាដែលសំឡឹងឃើញមានមនុស្សច្រើនទើបទម្លាក់ ពីព្រោះគំនិតថៃធ្វើនេះប្រាថ្នាចង់ឲ្យព្រះសង្ឃនិងបណ្តារាស្រ្តខ្មែរមានស្លាប់ច្រើនដើម្បីឲ្យកើតភិតភ័យផ្អើលភ្ញាក់ចលាចល ហើយក្លែងបង្កាច់ថាពីព្រោះខាងបារាំងទៅទម្លាក់គ្រាប់បែកក្នុងដែនថៃជាមុន ។

ប្រាជ្ញថៃដើរគំនិតយ៉ាងហ្នឹងមិនល្អសោះឡើយ ទុកជាមនុស្សចិត្តអាក្រក់ខុសពីទម្លាប់អ្នកកាន់សាសនាព្រះពុទ្ធខ្លាំងពេកណាស់ គឺចិត្តចង់ដណ្តើមយកទឹកដីខ្មែរ ធ្វើរំលោភឲ្យស្លាប់ខ្មែរឥតហេតុថែមទៀត មិនតែប៉ុណ្ណោះនិយាយក្លៀវក្លួមអួតថាខ្លួនអាណិតខ្មែរណាស់ គិតជួយដោះទុក្ខខ្មែរឲ្យបានរួចខ្លួនជាមនុស្សឥស្សរៈ ។

នេះហៅថាអាគតខ្មែរហើយនិយាយពាក្យផ្អែមលើសស្ករ ប្រមាទខ្មែរថាល្ងង់ដូចសត្វតិរច្ឆាន ។

ម្ល៉េះហើយយើងជាខ្មែរមានសេចក្ដីឈឺចាប់ក្នុងចិត្តណាស់ ពីព្រោះយើងមិនបានធ្វើអាក្រក់ទៅលើថៃសោះ មិនគួរថៃមកកេបង្កើតហេតុធ្វើបាបយើងឲ្យមានទុក្ខវេទនាដល់ម្លឹងៗ ។

តើឈ្មោះ ប៉ុក-គុន បានដឹងកិច្ចការនេះច្បាស់ឬទេ បានជាគ្មានខ្មាសហើយហាមាត់និយាយតាមគំនិតអាក្រក់របស់ថៃបានទៀត ។

បើទុកជាថៃជួលផ្សាទ់ទំហំធំយ៉ាងណា ក៏មិនគួរលេបទៅរួចសោះ ពីព្រោះថៃប្រាថ្នាប្លន់យកស្រុកកំណើតរបស់ខ្លួនហើយថែមទាំងសម្លាប់ជាតិខ្លួនទៀតផង ។

នេះ

ច្បាប់សុភាសិត

ប្រសើរពេកពិត ប្រែពីគាថា

បន្ទូលព្រះពុទ្ធ បំហុតទេស្នា

ឲ្យអស់ទាំងមហា- ជនផងត្រង់ត្រាប់ ។

និព្វានប្បច្ចយោ ហោតុ មេ ។

របស់

ឧកញ៉ាវង្សាសារពេជ្រ នង ចាងហ្វាងក្រុមរាជបណ្ឌិត្យ

ក្នុងរាជ្យព្រះបាទសម្តេចព្រះហរិរក្សរាមាឥស្សរាធិបតី

(ព្រះអង្គដួង) ។

(តមក)

២៧– និសេនត្ថិ គិរីមិ ខិតំគិរី ឆាមនិសេ ឆត្ថិការី តាតាតិតិ ចបណ្ឌិតា ។ លោកថាទីឋាន ណាមួយមិនមាន ភ្នំធំឡើយណា មានតែដំបូក សោតលោកហៅថា ភ្នំវិញប្រះប្រា- កដ កបស័ងបាន ។ មួយទីលោកថា ប្រទេសឯណា សូន្យសោះមិនមាន អ្នកប្រាជ្ញបណ្ឌិត គន់គិតរិះធ្យាន ប្រែងប្រែពុំបាន បាលីគាថា ។ មាន តែអ្នកខ្លៅ ពិតពុំចេះជ្រៅ អ័ប្បឥតប្រាជ្ញា ដូចជាតិតៃឡៃ(១) ចេះតែ កកា កិកីហៅថា អ្នកប្រាជ្ញបានខ្ញី ។

២៨– យំភ្ញុទេសំ ភ្ញុជ្ជិមជំ ពន្ធភ្ញុជ្ជិ តំភ្ញុធារ: ភ្ញុជ្ជភូមិ ទូរេបរិ- វិវជ្ជយេ ។ បទបន្ទថា ប្រទេសឯណា កាប់ កលរិះរេ មួយបើមនុស្សកាច កំណាចរៀចរេ មួយញាតិផងប្រែ ចិត្ត កាចកិច្ចកល ។ មួយបើកិរិយា កាចកិច្ចកើតជា កំហឹងកំហល់ មួយ ស្តេចកំណាច កាន់កាចឥតកល លោកពុំឲ្យយល់ ចៀសឲ្យទូរគោ(២) ។

២៩– បត្តតោភា· កេចត្តុសា· តរភាកេ មិត្តទុក្ខា ភាភកតោ វិយន្តកោ បញ្ញានន្តំ ។ លោកថាវ័ក្ខ ចរែញ្ចងធារ ធំ ក្រាស់ក្រៃទៀងទាំង មហាសមុទ្រ បួនគម្ពីរ ធ្ងន់ឥតឧបមំ ឧប-

---

១ ថោតៃឡ, ក្រៃឡក្រឡ ។ ២ ឲ្យឆ្ងាយ ។

មេឃស្រឡើយណា ។ អ្នកទ្រស្តមិត្រ សំឡាញ់ស្នេហ៍ស្និទ្ធ ជូនក្រៃ លែងសា- គរគម្ភីរ៍ ក្រៃទឹងបព្វតា ស្មើនឹងបញ្ចា- នន្ទរិកោ ។

៣០ – បឋវីសា- គ្រាធការ: ផលវហោ ធរាធរ: យេចសិនេហូ ត្តុនហោ តរោកាក ។ នេះលោកស្រដី ជាប្រឹថពី កម្រាស់គណនា ពីរសែនយោជន៍ជួន ប្តាយបួនហ្មឺនជា ទម្ងន់លោកថា ពុំធ្ងន់ឡើយនៃ ។ រីទឹកនព្វមហា- សមុទ្រគណនា ជម្រៅជ្រៅក្រៃ ប្រាំបីហ្មឺនស្បាន់ បួនពាន់យោជន៍នៃ លោកឧប- មេយ្យ ថាស្រាលវិញណា ។ រីសិស្សកំណាច ចិត្តពោរកៀចកាច ទ្រស្តគ្រូអាត្មា បាបធ្ងន់ក្រាស់ក្រៃ លែងនៃក្រឡា បឋវីសា- គរគម្ភីរ៍ ។

៣១ – បតិមាយេ នេវក្កុព្វេ- ជវិសាសំ ចលោតវ សព្វត្ថាំ ចរេកាលំ វឌុស្សកេ ។ នរអ្នកណា មួយមានប្រាជ្ញ គិតគាប់ជូនថៃ គួរកុំបីកប់ ប្រសព្វស្នាលស្នេហ៍ ស្និទ្ធទុកចិត្តឯ មិត្រ កាចកំឡៅ ។ គួរនាដូចឯ ពស់ពិសកាចគេ រក្សាលង់ទៅ ខឹងខាំ ម្ចាស់ឯង ឥតក្រែងពក់ជ្រៅ ហេតុដូតកំឡៅ កំឡាំងមោហោ ។

៣២ – ចង្កុល្ណា:- មិយោឃក: សសិក:ត្រា កិ- លាសកាខ្យំ សិលម្កកាមោ នាត្រសពោ សុរសេធា ។

គជេន្ទ៍ស្ស:- លង្ការុទ្ធ:- រសបេស្តា ឥត្ថិសោឡ្ស:- ស-
វសិកា តំសុករណា សយោបុត្តំ ។ លោកថាព្រះ ចន្ទថែង
រឿងរះ ពេញបុណ្ណមិយំ ពុំល្អប្រែព ស្មើថ្ងៃឯកំ មិគិត្តិយំ មួយ
កេចឡើយហោង ។ មួយទីនៃអ្នក បេះសំល្បសំទ្ធិស័ក្តិ គាថាមន្តផង
បើពុំចាំមាត់ ស្មើស្មូត់ជាមន្ត ពុំប្រសើរហោង ជាបេះឡើយណា ។
រីអ្នកទាហាន សេនាថ្កើងថ្កាន សាហ័សក្លៀវក្លា បើគ្មានថ្វីដៃ ឥតជ័យ
ចេស្តា ពុំរាប់ហៅថា ទាហានឡើយនៃ ។ មួយសោតគជសារ ធាត់
ធំធ្មារ ខ្លោះខ្លាំងនិរភ័យ បើបានចូលសឹក ពន្លឹកជាញជ័យ រែងមាន
តេជដៃ ទើបប្រសើរហោង ។ មួយសោតលោកថា ស្រីមានរូបា
សោឡសឆ្នាំផង ពុំហៅល្អល្អះ ត្រចះហ្មត់ហ្មង លុះមានគូទម្ពង សុ-
សោភគេ(១) ។

៣៣ — មណ្ឌុកោសំ- របទុមំ បុប្ផគន្ធេ អលិវស្ស-
ក្ខ- មរោទ្ធរេ បុប្ផគន្ធេ ឧលិប្បតិ ។ ពាក្យពិតលោកថា
កង្កែបឯងអា- សាស្នូឡអប្រិយ នៃបទិត្យនៅនា បទុមាស្រះស្រី ពុំ
ត្រឹបត្រង់វី- សេសសុគន្ធ ។ រីឯកន្ទង់ នៅឆ្ងាយត្រាច់ត្រង់ ត្រឹប
ត្រង់កេសរ លំអងបុប្ផា បទុមាឈ្ងុកឈរ ក្ដិនបុប្ផាករ- កាយជាត់គន្ធា ។

១ រឹងរឹតតែល្អឡើង, ល្អជាងពីក្រមុំ ។ (មនត)

ខ. ស.

អ្នកប្រែនឹងរៀបរៀង (តមក)

# វិធីតទល់នឹងមេជម្ងឺ

បណ្ដាចុលិន្ទ្រិយដែលធ្វើឲ្យយើងកើតរោគផ្សេងៗនោះ ទោះបីជាបាក់តេរីបំពួកណាក៏ដោយ កាលបើបានចូលទៅក្នុងរាងកាយរបស់អ្នកឯណាមួយហើយ នឹងធ្វើឲ្យអ្នកនោះមានអាការផ្សេងៗ ហើយអាការរោគនឹងទៅចំរើនឡើងជាលំដាប់រហូតដល់ថ្នាក់ស្លាប់ជាទីបំផុត ឬបើមិនស្លាប់ អាការរោគក៏នឹងធូរថយចុះមកជាលំដាប់រហូតដល់សះជាជាទីបំផុត តែងមានទំនងដូច្នេះជាធម្មតា ប៉ុន្តែទោះបីដល់ស្លាប់ឬត្រឡប់រស់ឡើងវិញនេះ ស្រេចតែការតទល់គ្នារវាងរាងកាយយើងនឹងបាក់តេរី ប្រសិនបើបាក់តេរីចាញ់យើងតាំងអំពីផ្ដើមតទល់គ្នា យើងក៏មិនបាច់កើតរោគ ទាំងអាការរបស់រោគក៏មិនមានប្រាកដ ។ ប្រសិនបើយើងចាញ់ប្រៀបបាក់តេរីជាដំបូងវិញ ហើយតមកទើបមានជ័យជំនះ យើងក៏កើតរោគនោះហើយអាការរបស់រោគក៏ប្រាកដឡើង តមកទើបស្បើយៗ គ្រាន់បើឡើងជាលំដាប់ នៅទីបំផុតក៏បានសះជាពាករោគនោះ ។ ប្រសិនបើយើងច្បាំងចាញ់មេរោគអស់ទោះតាំងអំពីពេលចាប់ផ្ដើមតទល់គ្នារហូតដល់ទីបំផុតនៃសង្គ្រាម មេរោគមានជ័យជំនះលើរាងកាយយើងតាំងពីផ្ដើមតទល់គ្នារហូតដល់ទី

បំផុត គឺដាក់ធ្វើកងកាយយើងឲ្យទាល់តែស្លាប់ទៅ ទើបឃើញថាមាន តែ ២ ផ្លូវប៉ុណ្ណោះ គឺ "មិនជាក៏ស្លាប់" ។ កាលបើសេចក្តីពិតមានទំនងដូច្នេះ យើងត្រូវតែបន្ថែមកំឡាំងរបស់យើងឲ្យខ្លាំងក្លាឡើង ដើម្បីឲ្យមានកំឡាំងតទល់នឹងមេរោគយ៉ាងម៉ឺងម៉ាត់ ដោយវិធីបន្ថែមពលកម្លាំងនឹងស្បៀងអាហារទៅជួយពួកយើងនៅទីចម្បាំង ត្រាតែយើងមានជ័យជំនះសត្រូវជាទីបំផុត ។

កងទ័ពគ្រប់ៗប្រទេសក្នុងលោកនេះ ដែលបានហាត់រៀបចំឲ្យមានក្រម ; កង នឹងមុខក្រសួងផ្សេងៗគ្នា ។ ល ។ នោះបម្រុងនឹងសម្រួលកិច្ចការតទល់នឹងពួកសត្រូវដោយម៉ឺងម៉ាត់ ទាំងមិនឲ្យបាញ់ប្រៀបខាងសត្រូវផង ។ ប្រសិនបើយើងប្រៀបធៀបវិធីហាត់កងទ័ពក្នុងកាយយើង ដែលបានរៀបចំបម្រុងទុកសម្រាប់តទល់នឹងប័កតេរី នឹងឃើញថាមានរបៀបរៀបរយមុខគួរឲ្យស្ញើចណាស់ ។ ប្រសិនបើសឹកសត្រូវមានចំនួនតិចល្មមសមគួរទេ យើងច្បាំងមានជ័យជំនះគ្រប់គ្រា នៅវេលាជាធម្មតានេះ រាងកាយយើងតែងច្បាំងតទល់នឹងប័កតេរីជានិច្ចជានិរន្តរ៍ សព្វថ្ងៃនេះដែលយើងមានជីវិតរស់នៅបានមិនឈឺថប់ ក៏ព្រោះកងទាហានរបស់យើងតែងធ្វើការតទល់នឹងខ្មាំងសត្រូវគ្រប់ពេលវេលា ហេតុនេះពាក្យថា "មានជីវិតរស់នៅឬនៅជាសុខសប្បាយ" បានសេចក្តីថា យើងកំពុងមានជ័យជំនះប័កតេរី ។ ឯការដែលធ្វើឲ្យយើងមានជ័យជំនះជានិច្ច

ដូច្នេះ ត្រូវតែយើងទំនុកបំរុងកំឡាំងរបស់យើងឲ្យខ្លាំងក្លាឡើង កុំឲ្យទន់ខ្សោយទ្រុឌទ្រោមដូចបានពោលមកហើយខាងដើម ។

ឥឡូវនេះ នឹងពោលអំពីវិធីធ្វើសង្គ្រាមក្នុងកងកាយ ប្រៀបធៀបនឹងវិធីធ្វើសង្គ្រាមក្នុងសម័យបច្ចុប្បន្ននេះ ដើម្បីសំដែងឲ្យឃើញថា ក្នុងកងកាយយើងនេះមានមហាសង្គ្រាមជានិច្ច ហើយជាសង្គ្រាមធំក្រៃលែងជាងមហាសង្គ្រាមលោកក្នុងឆ្នាំ ១៩១៤–១៩១៨ នោះទៅទៀត ។

## ការយាត្រាទ័ព

កាលបើប្រកាសសង្គ្រាមហើយ សឹកសត្រូវក៏កេណ្ឌទាហានលើកទ័ពរុករានទន្ទ្រានចូលមកទាំងផ្លូវគោក-ផ្លូវទឹក ដើរទ័ពចូលមកក្នុងខេត្តដែនរបស់យើង តែចួនជាមានទេសកាលស្រាប់តែកើតខ្យល់ព្យុះបក់ផាត់ទូកកប៉ាល់បាក់បែកឬរសាត់អណ្តែតទៅឬក៏មានរោគធំនឹងចូលបៀតបៀនទាហានឡើងគោកពុំរួច ឬមួយមានឧបសគ្គមករាំងរាធ្វើឲ្យកងទ័ពផ្សេងៗគោងឈប់ខាន មិនបានប្រាំងតទល់គ្នាក៏មាន ។

ចំណែកឯក្នុងកងកាយរបស់យើងវិញ កាលបើបាក់តេរីដែលជាមេរោគមកប៉ះពាល់ដល់សាច់ស្បែករបស់យើង ដោយអណ្តែតមកតាមអាកាសក្តី ឬមួយរាងកាយរបស់យើងទៅប៉ះពាល់វាក្តី ហើយវាមិនទាន់

បានធ្វើអន្តរាយដល់ខ្លួនយើង ស្រាប់តែញើសហូរចេញមក ឬយើងទៅងូតទឹកជម្រះលាងខ្លួនចេញ កងទ័ពបាក់តេរីនោះក៏ត្រូវតែថយទ័ពលើកត្រឡប់ទៅវិញ ដោយហេតុទាស់ផ្សេងៗដូចបានពោលមកខាងលើនេះ ។ ប្រសិនបើមិនមានហេតុទាស់ទំនងដូចបានពោលមកហើយទេ បើខាងណាលើកទាហានរំលងចូលមកក្នុងខេត្រដែនហើយ គង់តែមានការច្បាំងគ្នាជាដរាប ។ បំណែកឯបាក់តេរីជាមេរោគ កាលបើបានបោះខ្ជាប់នៅនឹងកងកាយរបស់យើងហើយ ក៏ចាប់ផ្តើមប្រទូសរ៉ាយកងកាយយើងៗ ក៏ធ្វើការតទល់នឹងពួកវាឲ្យត្រាតែដល់ចាញ់ឈ្នះគ្នា ។

## ការត្រៀមខ្លួន

កាលបើមានអ្នកណាមួយចូលទៅកាន់កន្លែងដែលមានជម្ងឺឆ្លង ដូចជាជម្ងឺគ្រុនចាញ់ អាសន្នរោគ ការ្យរោគ ។ល។ អ្នកនោះនឹងជាប់រោគឆ្លងនោះៗ មកខ្លះមិនខាន តែមិនមែនជាប់ឈឺភ្លាមមួយរំពេចនោះទេ រមែងចាប់ផ្តើមជម្ងឺនេះឡើងតាមកំណត់ពេលវេលា មានឧទាហរណ៍ដូចជាជម្ងឺគ្រុនចាញ់ តោងមានមេជម្ងឺឆ្លងជាប់មកដល់ ១២ ថ្ងៃទើបអាការរោគប្រាកដជាក់ស្តែងឡើង ដោយហេតុមេជម្ងឺត្រូវការប្រុងត្រៀមខ្លួនជាច្រើនវេលាដែរ គឺថាត្រូវការបន្ថែមកំឡាំងឲ្យមានច្រើនល្មមគ្រប់គ្រាន់ ដោយ

ត្រូវការបង្កើនពួកពក់ឲ្យមានគ្នាច្រើនឡើង   ឯវិធីបង្កើតដើម្បីបង្កើនពួកពក់ឲ្យបានគ្នាច្រើនឡើងនេះ គឺខ្លួន១ កើតទៅឡើងជា២ ពីរទៅឡើងជា៤ តាមទំនងនេះយ៉ាងរហ័សរួសរាន់   ប័កតេរីមួយអាចបង្កើតពួកពក់ឡើងបានដល់ទៅចំនួន៤លានក្នុង២៤ម៉ោង ។ សូមឲ្យគិតមើលចុះ បើប័កតេរីចំពួកខ្លះត្រូវការពេលត្រៀមខ្លួនដល់ទៅ១០ថ្ងៃ ក្នុង១ថ្ងៃ១តួកើតឡើងដល់ទៅ៤លានតួ ។ ក្នុងថ្ងៃគំរប់២នោះ ចំនួន៤លានតួនោះនឹងកើតទៅឡើងទៀតមានចំនួនដល់ទៅ៤លានភាគ បើគិតដល់ទៅថ្ងៃជាគំរប់១០នោះតើនឹងមានចំនួនប៉ុន្មានទៅ ? — បើប័កតេរីមានចំនួនពលកប់មិនកើតដូច្នេះតើនឹងមិនហៅថា មហាយុទ្ធសង្គ្រាម ដូចម្ដេចបាន ? - កាលបើកងទ័ពប័កតេរីមានកំឡាំងល្មមធ្វើការបានហើយ   ក៏ចូលលុកលុយប្រទូស-រ៉ាយដល់កងកាយយើងមួយរំពេច   ខណៈនេះធ្វើឲ្យយើងដឹងខ្លួនច្បាស់ថា ដូចជាមិនសូវស្រួលខុសប្រក្រតី ។

កងទ័ពមនុស្សដែលលើកចូលទៅក្នុងខេត្រដែនរបស់សត្រូវក៏មានទំនងដូចគ្នាដែរ   គឺត្រូវប្រុងត្រៀមខ្លួនទំនុកបំរុងកងទ័ពឲ្យមានកំឡាំងមាំមួន តាំងសន្សំគ្រឿងអាវុធយុទ្ធភណ្ឌឲ្យមានចំនួនល្មមគ្រប់គ្រាន់ហើយរើសរកទីកន្លែងសម្រាប់តាំងឋានទ័ពឲ្យមាំមួនបានជាមុនសិន   ទើបច្បាំងតទល់គ្នា ។

ចុះហេតុដូចម្តេចបានជាមនុស្ស ២ នាក់ដើរចូលទៅក្នុងកន្លែងមួយជាមួយគ្នា ម្នាក់ជាប់ជម្ងឺឆ្លងនោះកើតរោគឡើង ម្នាក់ទៀតមិនកើតរោគនោះ។ អ្នកដែលមិនជាប់ជម្ងឺឆ្លងនេះ ដោយហេតុកំឡាំងតស៊ូរបស់រាងកាយខ្លាំងពូកែ ទើបពួកសត្រូវលើកទ័ពចូលមកចោមរោមមិនសម្រេច ដោយមានហេតុច្រើនប្រការ គឺដោយខ្វះខាតស្បៀងអាហារឬមានកំឡាំងតិចមិនគ្រប់គ្រាន់នឹងធ្វើការ ហើយកំឡាំងតទល់របស់រាងកាយមាំមួនល្អទាំងប្រជាជនក៏មានសាមគ្គីស្រុះស្រួលជួយជាកំឡាំង ទើបធ្វើឲ្យសត្រូវលើកទ័ពចូលលុកមិនបាន ។

(នៅមានត)

# រឿងព្រេងខ្មែរ – រឿងអាឡេវ ទី ២

(តមក)

របស់អ្នកឧកញ៉ាប្រាជ្ញាធិបតី (យិន) ចាងហ្វាងក្រុមព្រះរាជនិពន្ធ

ទើបឯលោកសង្ឃនោះឮអាឡេវថាដូច្នោះហើយក៏គិតភ័យណាស់ យកប្រាក់មួយបាទឲ្យទៅអាឡេវជាប្រញាប់ អាឡេវមិនព្រមទទួលយក រាថា កាលលោកនិយាយនោះថាឲ្យប្រាក់មួយបាត្រដែលឆាន់បាយសព្វថ្ងៃ ឥឡូវត្រូវលោកយកប្រាក់មករាល់ក្នុងបាត្រឲ្យពេញ ទើបខ្ញុំករុណាទទួលយក បើលោកមិនរកឲ្យទេ នឹងទៅពិតលោកគ្រូថា លោកទៅដេកនឹងស្រីពីយប់មិញ លោកគ្រូជ្រាបហើយនឹងចាប់លោកទៅវាយបណ្ដេញមិនឲ្យនៅក្នុងវត្ត មួយទៀតខ្ញុំករុណានឹងទៅប្ដឹងលោកអ្នកឧកញ៉ាព្រះស្ដេចជាធំក្នុងក្រុមសង្ឃការីឲ្យមកចាប់លោកយកទៅ ហើយពួកសង្ឃការីគេយកសម្ពត់ចោកក្បាលលោកផ្សឹកចេញពីសង្ឃ ដាក់ជាពលពជនិមន្ត បើពុំនោះសោតដាក់ជាពលបោចស្មៅដំរី ៗ ឯលោកនោះឮអាឡេវថាដូច្នោះក៏គិតភ័យណាស់ អង្វរអាឡេវថាចាំរកប្រាក់ឲ្យ កុំឲ្យទៅពិតលោកគ្រូហើយប្ដឹងសង្ឃការីឡើយ ហើយខំរកប្រាក់ លក់ទាំងស្បង់ចីពរផ្សេងផ្សំឲ្យអាឡេវ ៗ ឯអាឡេវឃើញលោកសង្ឃលក់ស្បង់ចីពរផ្សេងផ្សំប្រាក់ឲ្យដូច្នោះ ក៏និយាយនឹងលោកថា ល្ហើយចុះ លោក

គេប្រាក់ឲ្យខ្ញុំករុណាល្មមតែស្ពាយទៅផ្ទះរួចបានហើយ ឯលោកសង្ឃត្រ អាឡៀវថាដូច្នោះក៏មានចិត្តត្រេកអរណាស់ រៀបរេបប្រាក់មួយសំពាយឲ្យ អាឡៀវហើយនិយាយអង្វរអាឡៀវថា កុំឲ្យនិយាយប្រាប់គេឲ្យដឹង ឯង អាណិតយកតែបុណ្យទៅចុះ ៗ អាឡៀវថាលោកកុំព្រួយព្រះទ័យ ខ្ញុំមិន ប្រាប់គេទេ ហើយទទួលយកប្រាក់ពីលោកដើរទៅផ្ទះ ។

អាឡៀវទៅដល់ផ្ទះជួបនឹងម្តាយក៏ស្រែកប្រាប់ទៅម្តាយថា ម៉ែដេរថង់ៗ នាងនោះឮហើយក៏សួរទៅថាដេរធ្វើអី អាឡៀវបង្ហាញប្រាក់ដែលស្ពាយ នាងនោះជាម្តាយឃើញអាឡៀវបានប្រាក់មួយសំពាយដូច្នោះ ក៏ស្ទុះទៅ ប្រាប់អ្នកនេះជាប្តី អ្នកនុះមកបានឃើញអាឡៀវបានប្រាក់មួយសំពាយក៏ បាត់ខឹងនឹងអាឡៀវដែលបញ្ឆោតអំពីមុននោះ អានឹងអាឡៀវទាំងម្តាយទាំង អាពុក ហើយអ្នកនេះសួរទៅអាឡៀវថាកូនបានប្រាក់នេះពីណា កូនធ្វើ ដូចម្តេចបាន ៗ អាឡៀវប្រាប់ទៅឪពុកថា ក្រអីសព្វបើប្រាក់ គ្រាន់តែទៅ បង្ហាញកេរ្ត៍ខ្មាសឲ្យអ្នកផ្សារមើលគប់គ្នា ខ្លះគេឲ្យមួយបាទខ្លះពីរបាទតែ ពល់គ្នាដូច្នេះទៅក៏បានច្រើនហើយ បើឪឯងចង់បានប្រាក់ច្រើន ទៅ បង្ហាញកេរ្ត៍ខ្មាសឲ្យអ្នកផ្សារមើលម្តងម្នាក់ទៅឪឯងយកប្រាក់មិនអស់ ៗ អ្នកនេះជាអាពុកឮអាឡៀវថាដូច្នោះហើយ ហេតុតែជាមនុស្សឆោតល្ងង់ ក៏ ទៅធ្វើតាមពាក្យអាឡៀវ លុះទៅដល់ផ្សារក៏ឈរនៅមាត់ទ្វារផ្ទះ បង្ហាញ កេរ្ត៍ខ្មាស ឯអ្នកផ្ទះឃើញដូច្នោះក៏អៀនខ្មាស បបួលគ្នាដេញវាយ ៗ

អ្នកនេះចេញពីផ្ទះមួយចូលទៅផ្ទះមួយទៀតហើយបង្ហាញកេរ្តិ៍ខ្មាសគេទៀត គេដេញវាយស្ទើរតែទឹងស្លាប់ អ្នកនេះក៏យក៏រត់ទៅផ្ទះ ៗ ឯអាឡេវចាំមើលអាពុកកណ្ដាលផ្លូវ ឃើញអាពុករត់មកពីផ្សារហើយជូនជាមានផ្កាស្ពាយទំនិញព្រៃហូលប្រអប់ប្រាក់មាសជាច្រើនមកអំពីចម្ងាយ ក៏ប្រាប់ទៅអ្នកនេះជាអាពុកថា នែ៎ឪ អ្នកផ្សារគេតាមមកវាយឪឯង បើដូច្នេះឪឯងរត់កាត់វាលនេះទៅទើបរួចខ្លួន ៗ អ្នកនេះឮកូនប្រាប់ដូច្នោះ ក៏ក្រឡេកមើលទៅឃើញមនុស្សដើរអំពីចម្ងាយដំរង់មកមែន គាត់គិតស្មានថាជាអ្នកផ្សារគេតាមមកវាយទៀតក៏ភ័យណាស់ រត់តាមពាក្យអាឡេវទៅទៀត លុះរត់ទៅឆ្ងាយល្មមតែមើលឃើញ ឯផ្កាដែលស្ពាយទំនិញនោះក៏មកដល់ អាឡេវគិតបញ្ឆោតផ្កានោះទៀតវានិយាយប្រាប់ថា បងធម្មអើយមានគេដេញក្ដាន់បាក់ជើងម្នាក់ ប៉ុន្តែអ្នកដេញនោះតែម្នាក់ឯងទឹងខ្ញុំចាប់ពុំបាន បើដូច្នេះបងធម្មឯងរត់ទៅជួយចាប់ បើបានទឹងយកមកចែកគ្នាស៊ី ៗ ឯផ្កាឮអាឡេវប្រាប់ដូច្នោះក៏ក្រឡេកមើលទៅតាមពាក្យអាឡេវ ឃើញមនុស្សរត់ គិតស្មានថាជាមនុស្សដេញក្ដាន់មែន ក៏យកសំពាយផ្ញើទុកនឹងអាឡេវទាំងអស់ ហើយបបួលគ្នារត់ទៅតាមអ្នកនេះៗរត់បណ្ដើរក្រឡេកមើលមកក្រោយបណ្ដើរ ឃើញផ្ការត់តាមក្រោយ ក៏គិតស្មានថាជាគេដេញចាប់ខ្លួន ប្រឹងរត់ទៅទៀត ៗ ឯអាឡេវបានសំពាយទ្រព្យរបស់ផ្កាហើយក៏ជញ្ជូនយកទៅលាក់ទុកឲ្យម៉ែវា

ហើយភៀសរត់អំពីនោះទៅទៀត ឯផ្កាផល់ដឹងថាអាឡេវបញ្ឆោតដូច្នោះ ក៏ត្រឡប់មកវិញ រកសំពាយទំនិញនឹងអាឡេវពុំឃើញ ទឹកស្តាយរបស់នោះណាស់ នឹងរកចាប់អ្នកឯណាពុំបាន ក៏ខំដើរទៅរកអាឡេវ ។

សេចក្ដីនេះនឹងឈប់ស្ដេះត្រឹមណេះសិន

យើងចាប់និយាយពីរឿងអាឡេវដែលរត់ទៅនោះវិញ

ឯអាឡេវកាលក្រោយនោះ រត់ដល់ស្រុកមួយឆ្ងាយណាស់ហើយបាន ជួបនឹងដូនចាស់ម្នាក់កំពុងរៀបទូកផ្ទុករបស់ទ្រព្យនឹងចៅក្រមុំម្នាក់ ដើម្បីទៅនៅស្រុកឯទៀត ឲ្យជិតជួបជុំនឹងអស់បងប្អូនញាតិសន្តាន ដ្បិតចៅគាត់ពេញក្រមុំល្មមឲ្យមានប្តីហើយ ។ អាឡេវឃើញចៅដូនចាស់នោះ ក៏មានចិត្តស្រឡាញ់ហើយជួយជញ្ជូនរបស់ទ្រព្យដាក់ទូក ឯដូនចាស់ឃើញអាឡេវជួយឈឺឆ្អាលដូច្នោះ គាត់សួរថាចៅនឹងទៅណា? អាឡេវប្រាប់ថាខ្ញុំសូមដោយសារយាយទៅផង ។ ឯដូនចាស់នោះសួរថាចៅឯងឈ្មោះអី ។ អាឡេវជំរាបថា ខ្ញុំឈ្មោះដ៏ចៅប្រសា បើយាយនឹងទៅណា ខ្ញុំសូមដោយសារទៅផង ។ ឯយាយចាស់ឮអាឡេវសុំដោយសារដូច្នោះក៏មានចិត្តអរនឹកថាបានគេជាគ្នា គ្រាន់នឹងជួយចែវទូកទៅ លុះរៀបរបស់ទ្រព្យរួចស្រេចកាលណា អាឡេវក៏សុំខ្លួនចែវទូក ឯដូនចាស់អង្គុយអុំក្បាល ចៅក្រមុំអង្គុយកណ្ដាល ។ អាឡេវនឹងចៅក្រមុំចេះតែរំពៃមើលមុខគ្នា ហើយញញឹមទៅមករកគ្នា ។ លុះចែវបន្តិចទៅអាឡេវធ្វើជាក្អួចកាប៉ិត ក៏

និយាយថា ៗ យាយអើយ ខ្ញុំក្អួចកាំបិតចោលនៅលើគោកឯក្រោយនោះ ដ្បិតខ្ញុំរវល់តែផញ្ញើរបស់យាយ បានជាខ្ញុំក្អួចកាំបិតខ្ញុំ ឯកាំបិតនោះជារបស់គេក្ដែកោះពីម៉ែឪជូនតាមក ដូច្នេះខ្ញុំសុំត្រឡប់ទូកទៅយកវិញ ដូនតាសក៏ព្រមត្រឡប់ទូកទៅវិញ លុះដល់កំពង់អាឡេវនិយាយនឹងដូនតាសថាយាយអាណិតឡើងទៅយកកាំបិតឲ្យចៅបន្តិច ខ្ញុំទុកត្រង់គល់ឈើខាងលើច្រាំងនៅប្របផ្លូវដែលយើងផញ្ញើរបស់មកនោះ អាឡេវបញ្ឆោតយាយតាសឲ្យតែគាត់ឡើងទៅផុតកាលណានឹងចេញទូកអុំតែយកចៅក្រមុំ ៗ ឯដូនតាសឡើងទៅដល់មាត់ច្រាំងល្មមកំបាំងភ្នែក អាឡេវក៏ម្នីម្នាថយទូកជាប្រញាប់ចោលដូនតាសនោះ ហើយខំចែវបណ្ដោយតាមទឹកហូរទៅ ៗ ឯយាយតាសនោះលុះរកកាំបិតពុំឃើញក៏ត្រឡប់មកទូកវិញ បាត់ទាំងអាឡេវបាត់ទាំងទូក ក្រឡេកមើលទៅក្រោមទឹកឃើញវាកំពុងខំមិតចែវទូក ដូនតាសក៏យំណាស់យកដៃគក់ទ្រូង ស្រែកទ្រហោយំតែតាមទៅ ហើយស្រែកប្រាប់អ្នកស្រុកថាឲ្យជួយដ្បិតដីចៅប្រសាពង្រត់យកចៅក្រមុំខ្ញុំទៅតែបណ្ដើរស្រែកឲ្យអ្នកស្រុកគេជួយតាមបណ្ដើរថាដ្បិតដីចៅប្រសាវាលួចពង្រត់ចៅក្រមុំទៅ ៗ អស់អ្នកស្រុកគេឮថា ចៅប្រសានាំពង្រត់ចៅក្រមុំដូច្នោះ គ្មាននរណាគេជួយ គេគិតថាប្រពន្ធរបស់អាឡេវ ៗ លុះដល់ដូនតាសតែតាមពុំទាន់ ទើបនិយាយដំណើរប្រាប់អ្នកស្រុកថាអាដែល

អាលួចចៅក្រមុំខ្ញុំនោះអាឈ្មោះជីចៅប្រុស អាមិនមែនជាចៅប្រុសខ្ញុំទេ អាលួចពង្រត់ចៅក្រមុំនឹងរបស់ទ្រព្យខ្ញុំទៅ ៗ លុះដល់អ្នកស្រុកគេដឹងពល់គ្នាជាអាឡេវអាបញ្ញោតលួចពង្រត់ចៅក្រមុំនឹងរបស់ទ្រព្យដូច្នោះក៏មិនដឹងធ្វើដូចម្ដេច នឹងទៅតាមមិនទាន់ ដ្បិតទៅយូរណាស់ហើយ ឯអាឡេវខំបែរលុះដល់វេលាយប់និយាយលួងលោមនាងក្រមុំនោះថា បានជាបងខំពង្រត់នាងមកដ្បិតបងស្រឡាញ់នាងណាស់ ឥឡូវនេះបងយកនាងធ្វើជាប្រពន្ធ ៗ នាងក្រមុំនោះចេះតែកន្ទក់កន្ទេញរកជីដូន ដ្បិតធ្លាប់នៅតែពីរនាក់ ហើយនិយាយប្រាប់អាឡេវថា ម៉្លះសូមជីដូនគាត់រកខ្ញុំមិនឃើញគាត់នឹងលោតទឹកសម្លាប់ខ្លួនក៏មិនដឹង មួយទៀតសមគាត់នឹករកខ្ញុំសង្រែងសង្រៃ អត់ទាំងបាយទៅជាឈឺស្លាប់អសារឥតការ បើដូច្នេះអ្នកជូនខ្ញុំទៅវិញ បើអ្នកមិនជូនទៅខ្ញុំនឹងលោតទឹកសម្លាប់ខ្លួន ៗ ឯអាឡេវឮនាងនោះនិយាយដូច្នោះ ក៏អាគត់ខូកបួលបតក្នុងព្រៃស្ងាត់លួងលោមនាងនោះថា បងស្រឡាញ់នាងណាស់ហើយបានជាបងនាំពង្រត់យកមកធ្វើជាប្រពន្ធ បើនាងលោតសម្លាប់ខ្លួនដូច្នោះ តើបងបាននរណាធ្វើជាប្រពន្ធ ៗ ឯនាងនោះឆ្លើយឡើងថា បើអ្នកស្រឡាញ់ម្ដេចក៏អ្នកមិនដណ្ដឹងតាមច្បាប់ អាឡេវឆ្លើយឡើងថា ឱ នាងអើយ បើចាំដណ្ដឹងតាមច្បាប់ធ្វើដូចម្ដេចនឹងធ្លាប់បានដូចចិត្ត បើគេឲ្យនោះក៏បាន បើគេមិនឲ្យនោះនឹងទទេឥតអំពើ ៗ

(មានតទៅទៀត)

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា នឹងអក្សរសាស្ត្រ

ឆ្នាំគំរប់ ១៣

ភាគទី ៦

INSTITUT BOUDDHIQUE

ភ្នំពេញ

ការផ្សាយរបស់ព្រះរាជបណ្ណាល័យ

ព. ស. ២៤៨៣

គ. ស. ១៩៤១

ព្រះរាជបណ្ណាល័យកម្ពុជា.

# KAMBUJASURIYÂ

# កម្ពុជសុរិយា

ជាទស្សនាវដ្ដីចេញផ្សាយពីព្រះរាជបណ្ណាល័យ មួយខែពីរក្បាល

ឆ្នាំគំរប់ ១៣

ភាគទី ៦

គណៈរដ្ឋមន្ត្រីនិងសម្ដេចសង្ឃនាយកទាំងពីរគណៈ

បានអនុញ្ញាតហើយ

BIBLIOTHÈQUE ROYALE DU CAMBODGE

ភ្នំពេញ

ការផ្សាយរបស់ព្រះរាជបណ្ណាល័យ

ព. ស. ២៤៨៣

គ. ស. ១៩៤១

# បញ្ជីរឿង


ទំព័រ

១ — ការឆ្លើយតបនឹងវិទ្យុបាងកក កាលពីថ្ងៃ ១៦-១-៤១ . . . . . . . . . . . ៣

២ — អំពីព្រះពុទ្ធសាសនាក្នុងប្រទេសឥណ្ឌូស៊ីន របស់ដុកទ័រ អង់ដ្រេ-មីក្លូត (តមក) ៦

៣ — អាជីវកម្មគឺអ្វី ? របស់ខេមររង្សី (តមក) . . . . . . . . . . . . . ១២

៤ — ច្បាប់សុភាសិត របស់អ្នកឧកញ៉ាវង្សាសារពេជ្ញ នង (តមក) . . . . . . ១៥

៥ — ពង្សាវតារក្រិក ស្រង់យកអំពីគោលចារឹកផ្សេងៗក្នុងពង្សាវតារលោក (តមក). ១៩

៦ — រឿងព្រេងខ្មែរ: "រឿងអាឡេវទី ២" របស់អ្នកឧកញ៉ាប្រាជ្ញាធិបតី យិន (តមក). ២៥


## រូបក្រៅរឿង


សាមនឿ (ប្រទេសលាវ) — ពិធីបុណ្យស្រង់ព្រះពុទ្ធរូប . . . . . . . . . . ១

# TABLE DES MATIÈRES


Pages.

1° La réponse à Radio-Bangkok du 11-1-41 .................. 3

2° Le Bouddhisme en Indochine par le Docteur ANDRÉ MIGOT (suite et fin) .................. 6

3° Qu'est-ce qu'un métier ? par KHÉMARARANSĪ (suite) ........ 12

4° Chbab SUBHĀSIT (Poème Khmèr) par Oknhā VONGSĀSĀRAPÉCH (NONG) (suite) .................. 15

5° Histoire de la Grèce, extraits de divers documents de l'Histoire Universelle (suite) .................. 19

6° Conte populaire cambodgien inédit :

"Légende de ALÉV II" par Oknhā PRACHNHĀTHĪBADEY (YIN) (suite) .................. 25


HORS TEXTES :


SAM-NUA (LAOS)-ondoiement de la statue du BOUDDHĀ ... 1



សាមនឿ (ប្រទេសលាវ)— ពិធីបុណ្យស្រងព្រះពុទ្ធរូប ។

# ចម្លើយតបនឹងសព្ទវិទ្យុពីបាងកក

ចុះថ្ងៃ ១១ ខែយ៉ាំងវិយេរ ១៩៤១

ពីខាងថៃពោលថា ពីថ្ងៃ១០ខែយ៉ាំងវិយេរនេះ មានអាកាសយន្ត ៣ ពីខាងបារាំងសែសហោះទៅខាងថៃត្រង់តម្បន់ទិសខាងជើងប្រុងនឹងទម្លាក់គ្រាប់បែក ថាបណ្ដាយន្តហោះទាំង ៣ នេះ មានយន្តហោះ ១ ហោះតំរង់ទៅខាងជើងបាងកកប៉ងនឹងទម្លាក់គ្រាប់បែក ប៉ុន្តែថាយន្តហោះខាងថៃហោះដេញខ្វាត់ខ្វាយអស់មកវិញ ហើយថាបានប្រើអាកាសយន្ត ១២ ហោះមកទម្លាក់គ្រាប់បែកនៅសៀមរាបផ្លាស់គ្នាវិញ ពាក្យនេះជាពាក្យកុហកស្ដែងណាស់ ដែលថៃពោលក្លែងបង្អាប់សន្សំរកហេតុទុកជាមុន ពីព្រោះថៃមានគំនិតគិតធ្វើលោភលើស្រុកខ្មែរតទៅទៀត ដូចមានកំហែងក្នុងពាក្យដែលសេនាបតីក្រសួងយន្តហោះខាងថៃបានពោលតាមវិទ្យុក្នុងថ្ងៃជាមួយនេះស្រាប់ ។

បើខាងបារាំងសែសមានបំណងឲ្យទៅទម្លាក់គ្រាប់បែកលើក្រុងបាងកក ដូចសំដីថៃមែន នេះមិនមែនប្រើឲ្យតែអាកាសយន្ត ១ ឬ ៣ ទៅឡើយ តោងប្រើអាកាសយន្តយ៉ាងតិចណាស់ក៏ឲ្យបានលើសពី១០ឡើងទៅ ទើបបានកើតការខ្ទះ ពីព្រោះក្រុងបាងកកជាក្រុងធំ ដ្បិតកាលទៅទម្លាក់គ្រាប់បែកនៅខេត្តសៀមរាប ខាងថៃបានប្រើយន្តហោះដល់ចំនួន ១១ ហើយ

ថៃពប់ជាទីក្រុងតូចតាចផង ។ ហេតុនេះបើចង់ធ្វើតបផ្ចាល់ដល់ក្រុងបាងកកវិញមែន គោងតែប្រើយន្តហោះឲ្យលើសពីចំនួនយន្តហោះដែលទៅទម្លាក់គ្រាប់បែកនៅសៀមរាបទើបបានជូនទឹងការ ។

ខាងបាំងសែសមិនមែនល្ងង់សោះឡើយ ប៉ុន្តែគឺគ្មានគំនិតប្រើឲ្យយន្តហោះមកធ្វើអំពើផ្ដើមហេតុជាមុនដូចពាក្យថៃពោលនោះសោះឡើយ ។

ប៉ុន្តែខាងថៃចេះតែពោលបង្កាច់កេ្ងរករឿងហេតុតាមអំពើចិត្តឥតពិចារណាសោះ គិតតែនិយាយកំហែងធ្វើឲ្យបណ្ដារាស្ដ្រខ្មែរមានសេចក្ដីភិតភ័យជ្រួលជ្រើមកាលណា ថៃទឹងបានឆាយបៀតបៀនកាលនោះ ៗ ខាងខ្មែរយើងឥឡូវនេះ បានយល់គំនិតទុច្ចរិតរបស់ថៃសព្វគ្រប់ហើយ ៗ យើងឥតមានបារម្ភអ្វីទៀតសោះ យើងបានដំនុំគ្នាមូលចិត្តគំនិតទុកស្រេចជាមុនអស់ហើយ ថាបើថៃធ្វើរំលោភទៅលើស្រុកយើង ៗ ក៏ឥតមានធុញថប់ឡើយ យើងរួមកំឡាំងជាមួយទឹងបាំងសែសជាព្យា-បាលតយុទ្ធទឹងថៃឲ្យអស់ពីចិត្ត មិនមែនល្ងង់ល្ងើចាញ់ប្រាជ្ញថៃ ដូចគំនិតថៃស្មានសោះឡើយ ។

យើងគ្មានគំនិតអាក្រក់លក់ស្រុកកំណើតលក់ខ្លួនដូចឈ្មោះប៉ុក - គុននោះទេ កុំឲ្យថៃសង្ស័យទៀត ។

មួយយ៉ាងទៀតពីថ្ងៃ ១០ ខែយ៉ាំងវិយេ ខាងថៃពោលជាភាសាថៃថាបាំងសែសភ័យខ្លាចថៃឲ្យយន្តហោះ ៗ ទៅទម្លាក់គ្រាប់បែកនៅជាឡាក់

ភ្នំពេញនឹងព្រៃនគរណាស់ បានជាពជការបារាំងសែសប្រញាប់ផ្សាយដំណឹងតាមផ្លូវវិទ្យុស័ព្ទថា មិនបានប្រើយន្តហោះឲ្យទៅធ្វើអំពើយាយីដល់ក្រុងបាងកកទេ ។

ពាក្យត្រង់នេះទៀតក៏ឃើញថាសុទ្ធសឹងជាឧបាយកលភូតកុហកទាំងស្រុង អ្នកទាំងឡាយដែលបានស្ដាប់សេចក្ដីខាងថៃពោលទាំងប៉ុន្មានក៏ល្មមយល់បាន ថាបើបារាំងសែសខ្លាចថៃដល់ម្ល៉ឹង។ តើហេតុដូចម្ដេចក៏ប្រើយន្តហោះតែមួយឲ្យហោះទៅធ្វើអំពើផ្ដើមហេតុដូចក្មេងលេង ជាទីបណ្ដាលឲ្យខាងថៃខឹងធ្វើអំពើតបផ្ដាលមកវិញដូច្នោះ គួរគេប្បីយល់បានថាថៃភូតកុហកឲ្យតែរួចពីមាត់ ឥតគិតក្រែងពាក្យអ្នកជងនិន្ទាសោះឡើយ ហើយមកពីគំនិតគិតស្មានថាខ្មែរសុទ្ធតែល្ងង់ដូចឈ្មោះ ប៉ុក-គុន នោះដែរ ។

បើថៃសំរេចចិត្តគិតលើកលុកមកខាងខ្មែរៗ ក៏បានប្រុងជាមួយនឹងបារាំងសែសស្រេចដែរ ពួកថៃមុខជានឹងមានខូចខាតជាច្រើនប្រាកដមិនលែង ។

# អំពីព្រះពុទ្ធសាសនាក្នុងប្រទេសឥណ្ឌូស៊ីន

របស់ដុកទ័រ អង់ដ្រេ-មីកូត (តមក)

ពួកចិនបៀតបៀនជាច្រើនលើកច្រើនគ្រា រួចត្រូវពួកឧរុបដែលមកក្រោយៗបៀតបៀនទៀត គឺពួកអេស្ប៉ាញ៉ុល ហុល្ល័ងដេស៍, ពរទុគេស៍ ។ ការច្បាំងកាំងដល់ជាយូរអង្វែងនេះ នៅទីបំផុតមានការច្បាំងគ្នារវាងសៀមនឹងយួនដោយយកប្រទេសខ្មែរជាទីចម្បាំង ទើបផុតចប់ក្នុងឆ្នាំ ១៨៤៧ (ព.ស.២៣៩០) ក្នុងរាជ្យព្រះបាទអង្គដួងដែលទ្រង់បានឡើងសោយរាជ្យដោយមានអ្នកដំណាងប្រទេសសៀមនឹងយួនមកជាអធិបតីក្នុងពិធីរាជាភិសេក ។ តមក ទើបក្សត្រអង្គនេះទ្រង់សុំជំនួយពីមហានគរបារាំងសែសឲ្យជួយទំនុកបំរុងទ្រង់ ក្នុងឆ្នាំ ១៨៦២ (ព. ស. ២៤០៥) ដល់មករជ្ជកាលព្រះបាទនរោត្តម ទើបមហានគរបារាំងសែសធ្វើជាអាណាព្យាបាលក្រុងកម្ពុជាពេញទីរហូតមក ។

## ៤— អំពីពុទ្ធសាសនាសម័យបច្ចុប្បន្ន នៅប្រទេសខ្មែរនិងលាវ

កាលបើពិនិត្យមើលចិត្តគំនិតរបស់ប្រជាជនជាតិខ្មែរក្នុងរវាង ៤ សតវត្សរ៍នេះច្រើនតែមានចិត្តព្រួយបារម្ភខ្លាចសឹកសត្រូវដែលលុកលុយចូល

មកតាំងខាងសៀមនិងខាងយួនជានិច្ច តោងតែរកផ្លូវគេចរត់ពីមុខពួកដែលរុកកទន្ទ្រានចូលមក ហើយត្រូវដេញចេញពីផ្ទះរបស់ខ្លួន មិនមានលំនៅទៀងទាត់ (រស់តែរត់ទ័ពឥតស្រាក) ។ ហេតុដូច្នេះ ទើបចិត្តគំនិតរបស់ប្រជាជនមានតែសេចក្ដីភិតភ័យឥតស្រាកឃ្លាន់ៗគ្នាជាលំដាប់មក នាំឲ្យជាប់គំនិតខ្លាចគេដរាបដល់សព្វថ្ងៃនេះ ។ ទុកជាមានសន្តិភាពមកជាយូរអស់វេលា ៦០ ឆ្នាំហើយ ក៏លក្ខណៈនិស្ស័យចិត្តគំនិតរបស់ប្រទេសខ្មែរនឹងប្រទេសលាវនៅតែមើលឃើញតាមទំនងដែលពោលមកនេះដែរ ។

ទុកជាដូចម្ដេចក៏ដោយ ប្រជាជនដែលមានគ្រោះថ្នាក់ដោយចម្បាំងនិងទៅជាជាតិនៅក្រោមបង្គាប់គេមកជាយូរនេះក៏នៅតែរក្សាកំឡាំងមួយទុកនៅក្នុងប្រទេសរបស់ខ្លួនរហូតមកបាន គឺកំឡាំងសីលធម៌និងចិត្តវិជ្ជារបស់ពុទ្ធសាសនាលទ្ធិថេរវាទ ទុកជាប្រទីបមួយជួយបំភ្លឺផ្លូវចិត្តនិងជាធម៌មួយជួយដោះទុក្ខក្នុងខណៈដែលមានទុក្ខសោកជាទម្ងន់ ។ ហើយនៅមានរឿងដែលគួរសរសើរមួយទៀត ដែលគេបានរក្សាទុកមកដោយសាមគ្គីធម៌រហូតមកដល់សព្វថ្ងៃនេះ គឺគណៈសង្ឃដែលមាននៅក្នុងប្រទេសខ្មែរវេលានេះមាន ២ និកាយ គឺមហានិកាយ និងធម្មយុត្តិ មិនមានបែកសាមគ្គីគ្នាទេ គ្រាន់តែមើលឃើញស្រមោលខាងក្រៅផ្សេងគ្នាប៉ុណ្ណោះ ។ ប៉ុន្តែនិកាយទី ២ មានការផ្សាយចូលទៅក្នុងប្រជាជនបានតិចជាងនិកាយទី ១

ដោយគណៈធម្មយុត្តិកើតឡើងពីពួកអ្នកធំជាដំបូង និងប្រព្រឹត្តទៅតាមបែបសៀមសុទ្ធ ៗ

លទ្ធិសាសនាជាន់ដើមដែលបានរក្សាទុកមកនោះ ស្ទើរតែមិនមានរឿងប៉ះពាល់ដល់ពង្សាវតារសោះ ដែលយើងទើបនឹងពោលដោយព្រួសៗនេះ ៗ ប្រហែលជាពួកប្រកាន់លទ្ធិថេរវាទមានអធិករណ៍កើតឡើងដោយមានគំនិតយោបល់ខ្លះ មិនទាន់ជ្រួតជ្រាបចូលទៅក្នុងចិត្តគំនិតរបស់ពួកឧបាសកឧបាសិកា ឬមួយមិនទាន់មានក្នុងចិត្តគំនិតរបស់ពួកលោកសង្ឃខ្លះផង ៗ ប៉ុន្តែមិនត្រូវភ្លេចថាលទ្ធិសាសនាព្រាហ្មណ៍និងមហាយានមានជាប់ជាច្រើនសតវត្សរ៍នោះព្រមផ្លាស់រូបរាងទៅជាដទៃ ហើយការផ្សាយចូលមកនៃលទ្ធិសាសនាទាំង ៣ មិនបានបោលស្នាមគំនូសទុកក្នុងចិត្តគំនិតដ៏ទៀងត្រង់និងដោតខ្ជាប់របស់ប្រជាជនខ្មែរនិងលាវដ៏ស្លូតត្រង់ទាំងគ្រហស្ថទាំងបព្វជិតសោះនោះមិនមែនឡើយ ៗ

ហេតុនេះបានជាក្នុងឆ្នាំ ១៩៣០ ព. ស. ២៤៧៧ លោកគូវែរណេរសេណេរ៉ាល់ប៉ាស្គីយេបង្កើតពុទ្ធសាសនបណ្ឌិត្យឡើងនៅក្រុងភ្នំពេញ ដើម្បីសើរើលទ្ធិហីនយានដែលបរិសុទ្ធស្អាតឲ្យកើតឡើងវិញ ៗ ការបង្កើតសាលាបាលីជាន់ខ្ពស់និងក្រុមជំនុំប្រែព្រះត្រៃបិដក ដើម្បីសើ-

ពិនិត្យគម្ពីរដីកាយកមករៀនសូត្រនាំឲ្យគណៈសង្ឃមានសេចក្ដីចេះដឹង នឹងសតិបញ្ញាចំរើនឡើង ៗ នៅទីបំផុតការប្រែព្រះត្រៃបិដកជាភាសាខ្មែរហើយផ្សាយគម្ពីរព្រះត្រៃបិដកឲ្យមានពាសពេញស្រុកខ្មែរ ដើម្បីឲ្យប្រជាជនមានចំណេះចេះដឹងឡើង នឹងយល់ស្គាល់ព្រះពុទ្ធដីកាបានជាក់ច្បាស់ ៗ

## ៥– ពុទ្ធសាសនានៅអណ្ណាមនិងតុងកឹង

តាមរឿងរ៉ាវដែលយើងពោលមកហើយ យើងមិនទាន់បានពោលដល់ចំណែកមួយនៃប្រទេសឥណ្ឌូស៊ិន គឺប្រទេសតុងកឹង អណ្ណាមនិងកូសាំងស៊ីននៅឡើយ ៗ ប្រទេសទាំង ៣ នេះមានកំផែងមួយខាំងដាច់ស្រឡះពីប្រទេសខ្មែរនិងលាវ ជាកំផែងកំណត់ទៅតាមភូមិសាស្ត្រ តាមជាតិ តាមសំដីភាសា តាមទំនៀមប្រពៃណីនិងរបៀបសាសនា ៗ ដូចយើងបានឃើញហើយថា ប្រទេសខ្មែរនិងលាវ (រួមទាំងភាគ ១ នៃប្រទេសចម្ប៉ាឬអណ្ណាមខាងក្រោម) សុទ្ធតែកាន់តាមអារ្យធម៌និងសាសនាដែលបានមកពីឥណ្ឌៀស្ទើរទាំងអស់ ដែលមានផ្លូវចូលមកតាមប្រទេសភូមានិងប្រទេសសៀម ៗ ឯប្រទេសអណ្ណាម តុងកឹង កូសាំង-

ស៊ីន[១] មានរបៀបទំនងសេចក្ដីចំរើនទៅតាមអារ្យធម៌របស់ចិន ដោយចិនមានអំណាចត្រួតត្រានាំចូលមកផ្សាយ ។

ពង្សាវតារសាសនា ឬសាសនាយួននេះនៅតែងងឹតងងល់មិនសូវមានគេដឹងឮច្រើនទេ ។ រឿងនេះជារឿងស្មុគស្មាញណាស់ នឹងញែកឲ្យស្រឡះពុំទាន់បានក្នុងវេលានេះ ទាំងការប្រឡូកប្រឡំគ្នាខាងផ្លូវសាសនានេះក៏មានច្រើនណាស់ ប៉ុន្តែនៅមើលឃើញថា ពុទ្ធសាសនាមានកំឡាំងនឹងមានដំកៀងជាងគេ ។ ពង្សាវតារនៃពុទ្ធសាសនា ឬរឿងដែលយើងដឹងនោះ កាលពីដើម លទ្ធិពុទ្ធសាសនាជាសាសនាដែលមានពាសពេញស្រុកអស់ហើយ គឺតាំងពីសតវត្សរ៍ទី ១ នៃគ្រិស្តសករាជនោះ ព្រះពុទ្ធ-សាសនាបានផ្សាយចូលទៅក្នុងស្រុកចិនហើយ ក្នុងរាជ្យស្ដេចចក្រពត្តិចិនព្រះនាម មិង-ទី ព.ស. ៦០១ ដល់ ៦១៨ (៥៨-៧៥...) ដល់មករាជវង្សក្សត្រ វូ-ហាន់ បានចាត់ឲ្យនិមន្តលោកសង្ឃពុទ្ធសាសនា

---

១ កាលបើនិយាយពីដែនដីស្រុកកូសាំងស៊ីននេះ កាលពីដើមមកជាចំណែកមួយស្ទើរតែទាំងអស់ជារបស់ស្រុកខ្មែរតាមភូមិសាស្ត្រនិងតាមពង្សាវតារ ។ ពួកខ្មែរបានកើតមកពីប្រជា-ជនជាតិហ្វូណន ដែលមានអាណាចក្រដ៏ធំគ្រប់ទៅលើប្រទេសកូសាំងស៊ីនសព្វថ្ងៃនេះស្ទើរតែជិតអស់ ជារបស់ប្រទេសខ្មែររហូតមកដល់សតវត្សរ៍ទី ១៦ (ព. ស. ២០៩៣) ។ លុះមកដល់ចុងសតវត្សរ៍ទី ១៧ ទើបយួនយកប្រទេសនេះបាន ហើយគេមកបានទៅមហានគរបារាំងសែស ហើយរៀបចំត្រួតត្រាស្រុកកូសាំងស៊ីននេះដោយឡែកពីស្រុកដទៃ ។ ដូង...

ពីប្រទេសបេង្គ័ល ហើយទ្រង់កសាងវត្តថ្វាយសង្ឃនៅក្នុងក្រុងឡាវ-យ៉ាង (គឺស្រុកយុន-ណាន-ហ្វូ សព្វថ្ងៃនេះ) អាពមដំបូងដែលកសាងឡើងហៅថា វត្តសេះស ។ ប្រហែលជាកន្លែងដែលព្រះពុទ្ធសាសនាផ្សាយចូលមកជាដំបូងនៅស្រុកតុងកឹងនិងអណ្ណាមនោះ ដោយសារតែជនជាតិចិនបានមកត្រួតត្រាលើខេត្រអស់នេះ ពីព្រោះសេចក្ដីចំរើនរបស់ពុទ្ធសាសនា១ផ្នែកទៀតដែលមានឫសគល់ដើមនៅប្រទេសឥណ្ឌា ហើយផ្សាយចូលទៅក្នុងប្រទេសចាមតាំងពីសតវត្សរ៍ទី ២ និងទី ៧ (ព. ស. ៦៤៣ និង ៧៤៣) យើងបានពិនិត្យឃើញថា អំណាចពុទ្ធសាសនាផ្នែកនេះមិនមានស្រមោលជាប់នៅនឹងប្រជាជនជាតិយួនទិសខាងជើងនោះឡើយ ។

---

ទុកជាប្រជាជនក្នុងសាំងស៊ីនស្ទើរតែមានតែជាតិយួនពេញស្រុកក៏ដោយ ប៉ុន្តែនៅចំណែកទិសខាងលិចនឹងទិសខាងត្បូងឆៀងខាងលិច នៅមានពួកអំបូរជាតិខ្មែរសុទ្ធ ហើយប្រើភាសាខ្មែរសុទ្ធ កាន់សាសនាព្រះពុទ្ធ លទ្ធិហីនយាន ដែលមានលោកសង្ឃខ្មែរកាន់កាប់ត្រួតត្រានិងរៀបចំការសាសនារហូតមកដល់សព្វថ្ងៃនេះ ។

(មាគត)

# អាជីវកម្មគឺអ្វី?

(តមក)

## វគ្គទី ២

## ប្រភេទរបស់អាជីវកម្ម

ការចិញ្ចឹមជីវិតរបស់មនុស្សយើងមានច្រើនយ៉ាងច្រើនប្រការផ្សេងៗគ្នា ស្រេចតែអ្នកឯណាមានចំណេះចេះស្ទាត់ខាងផ្លូវណា ក៏ធ្វើការខាងផ្លូវនោះ ដើម្បីឲ្យបានទ្រព្យមកចិញ្ចឹមជីវិតចាយវ៉ាយទុកជាស្រេច កាលបើគេទ្រព្យបានមកល្មមស៊ីចាយហើយ ដែលសេសសល់ទាំងប៉ុន្មានក៏ចែកចាយចំណាយផ្លាស់ប្តូរគ្នា ។ ប្រភេទនៃការចិញ្ចឹមជីវិតរបស់មនុស្សយើងនេះ ស្រេចតែភូមិប្រទេសឬទីតម្បន់ដែលខ្លួននៅ គឺថាបើនៅជិតសមុទ្រ, ទន្លេ, ស្ទឹង គេតែងរកបរនេសាទត្រី ។ អ្នកដែលនៅកន្លែងមានមីនរ៉ែផ្សេងៗក្នុងដី ក៏ធ្វើការជីកយករ៉ែ ដែលហៅថា "លោហកិច្ច" ។ អ្នកដែលនៅជិតព្រៃ ក៏ធ្វើការកាប់ឈើក្នុងព្រៃយកឈើមកលក់ ។ អ្នកដែលនៅលើដីរាបមានទឹក មានដីជាតិក៏ធ្វើការកសិកម្ម ដូចធ្វើស្រែចំការច្បារដំណាំនិងចិញ្ចឹមសត្វ ។ ឯអ្នកដែលនៅក្នុងទីប្រជុំជន ដូចទីផ្សារ ក៏ធ្វើការលក់ដូរ ដែលហៅថា "ពាណិជ្ជកម្ម" និងចាត់ចែងធ្វើគ្រឿងឧបភោគបរិភោគ តាមសេចក្តីត្រូវការរបស់មនុស្សទូទៅ ហើយចេញជា

ជំនួញ ដែលហៅថារបរ "ហត្ថកម្មនិងសិល្បកម្ម" ។ ឯការហត្ថកម្មផ្សេងទៀតក៏មានច្រើនប្រភេទ ដូចជាធ្វើជាងឈើ, ជាងគំនូរ, ជាងស្មិត, ជាងក្បាច់, ជាងក្រឡឹង, ជាងប្រាក់, ជាងមាស, និងការត្បាញ, ការដេរប៉ាក់, និងការថ្វីដៃឯទៀតៗ រហូតដល់ការកសាង ការតាំងរោងអារឈើ, ម៉ាស៊ីនកិនស្រូវ, គ្រឿងតំបាញនិងគ្រឿងប្រើប្រាស់ជាដើម ក្រៅពីនេះ នៅមានរបរចិញ្ចឹមជីវិតដទៃៗទៀតជាច្រើនយ៉ាង ដូចជាពេទ្យ ស្មាក្តី ល្ខោននិងការស៊ីឈ្នួលជាដើម ក៏ហៅថារបរចិញ្ចឹមជីវិតទាំងអស់ ។

អាជីវកម្មទាំងឡាយដែលពោលមកនេះ ជារបរដែលត្រូវធ្វើជាប្រយោជន៍ផ្ទាល់ខ្លួនក៏មាន របស់បរិសទ្យសមាគមក៏មាន រួមហៅថា "ករណីយកិច្ច" ព្រោះជាកិច្ចដែលយើងត្រូវធ្វើខានពុំបាន ។ នៅមានការងារម្យ៉ាងទៀត ដែលជាការងារនៅក្នុងក្រសួងរាជការរដ្ឋបាល ដែលយើងត្រូវធ្វើការនៅក្រោមបង្គាប់ជាជាន់ៗ ថ្នាក់ៗ តាំងពីអធិបតីថ្នាក់ខ្ពស់បំផុតរហូតមកដល់ស្មៀនថ្នាក់ងារថ្នាក់ទាប ការធ្វើរាជការនេះជារបរចិញ្ចឹមជីវិតមួយដែរ ព្រោះអ្នកធ្វើការនេះរមែងបានប្រាក់ខែជាគ្រឿងចិញ្ចឹមជីវិតរាល់ខែ ប៉ុន្តែអ្នកដែលធ្វើរាជការនេះ តោងតែជាអ្នកមានចំណេះវិជ្ជាខ្ពង់ខ្ពស់ក្នុងនាទីជាមុខក្រសួងនោះៗ តាមព្រះរាជបញ្ញត្តិ ។ របរចិញ្ចឹមជីវិតដែលពោលមកនេះ រាប់ជាជាកិច្ចការចិញ្ចឹមជីវិតដ៏ត្រឹមត្រូវតាមសេចក្តីនិយម

ក្នុងលោក ហើយមិនខុសនឹងធម្មនិយម ចាត់ជាសម្មាអាជីវៈ គឺការចិញ្ចឹមជីវិតត្រូវ មិនខុសនឹងច្បាប់សម្រាប់ស្រុក គួរតែយើងរើសរកធ្វើតាមចំណេះវិជ្ជារៀងខ្លួន ៗ មានការចិញ្ចឹមជីវិតម្យ៉ាងទៀត ខុសទាំងខាងលោកនិយមទាំងខាងធម្មនិយម ខុសនឹងច្បាប់សម្រាប់ផែនដី ដូចជាការឆបោក កុហកបញ្ឆោត លួចប្លន់ជាដើម របរចិញ្ចឹមជីវិតបែបនេះចាត់ជាមិច្ឆាអាជីវៈ គឺចិញ្ចឹមជីវិតខុសទំនងគន្លងធម៌ដែលយើងមិនត្រូវប្រព្រឹត្ត ព្រោះនាំឲ្យខូចប្រយោជន៍អ្នកដទៃ ទាំងកើតទុក្ខទោសដល់ខ្លួនផង ។

ហេតុនេះ តោងយើងចៀសវាងរបរជាមិច្ឆាអាជីវៈ ចិញ្ចឹមជីវិតតាមសម្មាអាជីវៈទើបល្អ ៗ (មាឧត)

នេះ

# ច្បាប់សុភាសិត

ប្រសើរពេកពិត ប្រែពីគាថា

បន្ទូលព្រះពុទ្ធ បំហុតទេស្នា

ឲ្យអស់ទាំងមហា- ជនផងត្រងត្រាប់ ។

និព្វានបច្ចយោ ហោតុ មេ ។

របស់

ឧកញ៉ាវង្សាសារពេជ្រ នង ចាងហ្វាងក្រុមរាជបណ្ឌិត្យ

ក្នុងរាជ្យព្រះបាទសម្ដេចព្រះហរិរក្សរាមាឥស្សរាធិបតី

(ព្រះអង្គដួង) ។

(តមក)

៣៤- ពហុសេលំ ចបព្វតំ មណិជាតា ចទុល្លភោ មហាទុល្លភា អរញ្ញវនា ពហុរុក្ខា ។ ចន្ទជាតា ច-ទុល្លភា មហាទុល្លភោ ឧតវេច ពហុនរេ សប្បុរិសោ ចទុល្លភា ។ លោកថាថ្នំ ដេរដាសដោយភ្នំ ច្រើនឥតគណនា ទោះនឹងរើសរក កម្របានជា មណីរ័ត្នថ្លៃថ្លា ក្រៃក្រនឹងមាន ។ មួយសោតរីឈើ ច្រើនព័ណ៌អន្ទើ ដុះដោយសព្វឋាន សុះសព្វឈ្មួងផករិះរកក្របាន ជាខ្លឹមចន្ទន៍មាន ដំឡៃឡើយហោង ។ រីឯនគរ មនុស្សផងវិករ ច្រើនក្រៃកន្លង ក្រនឹងមានមនុស្ស សប្បុរសស្នេហ៍ស្នង ខ្លួនខ្លាចបាបផង ក្រមានឯងឯង ។

៣៥- សិរីបញ្ញ ហត្ថំអស្ស ឧសហត្ថេ សតហត្ថំ គជំនាមេ ចឧស្សត្ថេ ពិទូរជនា ។ សត្វណាមានស្នែង លោកឲ្យគិតក្រែង ចៀសចេញកាំងកាំ បានប្រាំហត្ថគត់ កំណត់ធម៌ថា កុំបរយាត្រា ទៅទៀបឡើយហោង ។ រីសេះសោតណា ឲ្យចៀសកាំងកាំ ដប់ហត្ថជាមួង រីគជសារ ដំរីមាតារើសយួង ឲ្យចៀសរំលង ចេញបានរយហត្ថ ។ នាអ្នកទូរជន ដូជាតិអគ្គអ-ន្ធពាលអសត្យ លោកឲ្យលះលាក ចៀសចាកចេញថ្ងាត់ កើដុះខ្ចាយខ្ចាត់ រកកុំមិទៀតខ្ញុំ ។

៣៦- មាតាភិសកោ ភ្ញារចាលោ ហុតោលិក្ខំ-តោពាណិជ្ជា មហាសេដ្ឋី ករំសី- តោនិច្ចយោ ។

កជាសេដ្ឋំ សមណាកុលំ ការិក្ខុ វិរុឡ្ហនៈ- ការោចោ-
សោ ឥមជនោ មិត្តាវឡ្ហតិ ។ ធម៌នេះលោកថា ឲ្យអ្នកផង
ជា មិត្រមានមេត្រី អ្នកប្រាជណ្ដប់ ឲ្យគ្រប់កុំបី បង់ចិត្តជាក្ដី ប្រមាទ
ឡើយណា ។ មួយម្ដាយមួយគឺ ពេទ្យមើលជម្ងឺ មួយគឺហោរា មួយគឺ
អ្នកកត់ កំណត់ត្រួតត្រា មួយអ្នកទ្វារមហា- ក្សត្រាធិបតី ។ មួយគឺ
អ្នកនាយ សំពៅទាំងឡាយ មួយគឺសេដ្ឋី មួយគឺសុភា ពិចារណាក្ដី
មួយគឺមន្ត្រី អគ្គអគ្គសេនា ។ មួយគឺព្រះវង្ស មួយទីគឺអគ្គ ព្រះមហា-
ក្សត្រា មួយគឺអ្នកបួស ទ្រង់ផ្នួសបរិយា មួយអ្នកឯណា មានគុណ
ស្ងួនគ្រង់ ។ មួយគឺអ្នកប្រាជ្ញ បណ្ឌិតឯងអាច បេះធម៌អាចផង មួយ
គឺអ្នកជា គ្រូអាត្មាហោង គិតគួរកុំចង់ ចិត្តជាទោសំ ។

៣៧- សត្តពិន្ទុង្គិរៈ- លស្មាសត្តមៈ- តាលបតាលំ
ចន្ទក្រុលេ រវេជាតំ ឆិរជនំ ឆបស្សតិ ។ ទោះអ្នកឯណា
ទំហំអគ្គ ប្រាំពីរជំរី កំពស់សុរិល ប្រាំពីរគោតក្ដៈ រូបកង់ឥន្ទ្រិយ
ជាតជំមហិមា ។ សន្ដានអម្ពរ ជាមួយព្រះសូរ្យ នឹងព្រះចន្ទ្រា ថា
បើពុំមាន ធនធានទ្រព្យា អគ្គឥតអ្នកណា មួយនឹងយល់ឡើយ ។
លោកិយប្រធាន ប្រសើរសោតមាន តែទ្រព្យជាត្រើយ[១] ជាញាតិ
ជាមិត្រ ស្នេហ៍ស្និទ្ធឯងហើយ ឥតអ្វីទៀតឡើយ ទ្រព្យជានាថា ។

---

១ ទ្រព្យដែលបានមកដោយសុចរិត ឬ អរិយទ្រព្យទាំង ៧ មានសទ្ធាជាដើម ទើបឈ្មោះជាទ្រព្យប្រសើរ ។

៣៨— តិលមត្តំ ចកាយមំ ពហុធនោ បគា សេដ្ឋំ ហាធំទ្ធរតោ មិត្តំវកោ ចសព្វទា ៗ, បើតបទបាលី នេះលោកស្រដី អាថ៌ឧបមា អ្នកមួយតូចលទ់ ខ្លួនប៉ុនល្ងណា មោះ មានទ្រព្យ មានប្រាក់ធនធាន ៗ មានពាក្យប្រពៃ ចូលចិត្តនរនៃ អ្នកផងសព្វហ៊ាន ឆ្ងាយជិតក្ដីណា យាត្រាមកប្អាន រិះរកបំអាន នៃ អ្នកនោះហោង ៗ សួរសាករកទៅ សឹងជាញាតិផៅ សន្ទានទាក់ ទង សឹងស្គាល់ជាមិត្រ ស្នេហ៍ស្និទ្ធស្នាលស្នូង ឥតឯឲ្យហ្មង នៃអ្នក នោះណា ៗ

៣៩— យស្សរុក្ខំ ឆាយាយនិ- សីទយា សយ- យនះ តស្សសាខា កញ្ជយា មិត្តទុព្ភោ ៗ ទ្រព្រឹក្សា មួយមានសាខា ស្រោមស្ទឹករុក្ខា ទោះអ្នកឯណា ចិន្ដាមោហោ មោហះ ពាលោ ពាលពន់វិស័យ ៗ ចូលចតសំណាក់ អាស្រ័យពឹងពាក់ ក្រោមម្លប់ព្រឹក្សព្រៃ នោះហើយមានចិត្ត គំនិតកាចក្រៃ កាន់កាប់ កាប់ទៃ ស្រោមស្ទឹកសាខា ៗ លោកហៅទ្រឹស្ដិទ្រុះ មិត្រមានបាប លុះ បទចិត្តមោហា ធ្លាក់ទៅនរក អាក្រក់ឈឺផ្សា ខ្លោចខ្លួនទៅនា ក្ខុមិភ័យនិរយំ ៗ

(មានត)

# ពង្សាវតារក្រិក

(តមក)

១ – អំពីរបៀបត្រួតត្រាស្រុក – បានពោលពីខាងដើមរួចមកហើយថា អ្នកស្រុកអាថែនប្រើរបៀបត្រួតត្រាស្រុកដែលហៅថា ប្រជាធិបតេយ្យ ពោលគឺរាស្ត្រមានអំណាចបោះឆ្នោតរើសអ្នកត្រួតត្រាស្រុក, ចៅក្រម, អ្នករាជការគ្រប់ដំណែងរហូតដល់មេទ័ពក៏តោងឲ្យរាស្ត្ររើសតាំងឡើងដែរ មានអ្នកប្រាជ្ញជាតិបារាំងសែសម្នាក់ពោលទុកថា "ក្នុងស្រុកអាថែន ការងារគ្រប់យ៉ាងស្រេចតែរាស្ត្រទាំងអស់ ប៉ុន្តែបណ្តារាស្ត្រនឹងវិនិច្ឆ័យសម្រេចយ៉ាងណានោះ ស្រេចតែអាវុធមាត់របស់អ្នកនិយាយ" នេះត្រូវនឹងពាក្យសុភាសិតខ្មែរ ១ បទថា "មាត់ជាឯក លេខជាទោ" ។ ហេតុនេះ អ្នកដែលមានអំណាចធំនៅក្នុងស្រុកអាថែននោះ គឺអ្នកពូកែនិយាយ អ្នកណាប៉ិននិយាយ មុខជារាស្ត្រនឹងរើសខ្លួនឡើងធ្វើធំមិនខាន ៗ ក្នុងចំណោមពួកអ្នកប៉ិននិយាយនោះ មានមនុស្សសំខាន់ម្នាក់ឈ្មោះ ប៉េរីក្លេស ជាពូជអំបូរក្សត្រពីបុរាណរបស់ស្រុកអាថែន បានសិក្សារៀនសូត្រក្នុងសំណាក់អ្នកប្រាជ្ញមកជាច្រើន មាននិស្ស័យពិតជាមនុស្សស្លូតត្រង់ នឹងមិនចេះខ្លាចរកើបនឹងសេចក្តីលំបាក ឬវិបត្តិអន្តរាយទាំងពួង ចេះធ្វើឲ្យអ្នកផងជឿទុកចិត្តខ្លួននឹងស្ញប់ស្ញៀម ៗ សុន្ទរកថារបស់លោកនេះ

សុទ្ធតែជាគ្រឿងផាស់ចិត្តអ្នកស្រុកអាថែនឲ្យមានមានះព្យាយាមក្នុងការពង្រីកអាណាខេត្ត នឹងឲ្យខំទំនុកបំរុងឲ្យបានចំរើនខាងអក្សរសាស្ត្រនឹងរបៀបរបនា ហេតុនេះ បានជាមានពាក្យពោលថា សម័យចំរើនរុងរឿងបំផុតរបស់អាថែននោះ ហៅថា "សម័យប៉េរីក្លេស" ។

បណ្ដាអ្នករាជការស៊ីវិលរបស់ស្រុកអាថែននោះ មានពួកចៅក្រមជាចំនួនច្រើនបំផុត ព្រោះក្នុង ១ ឆ្នាំៗ មានបោះឆ្នោតរើសតាំងចៅក្រមដល់ចំនួន ៦.០០០ នាក់ ចំនួនចៅក្រម ៥.០០០ នាក់ជាអ្នកធ្វើការប្រចាំដំណែងបែងចេញជា ១០ ក្រុម ក្នុង ១ ក្រុមៗ មានចំនួន ៥០០ នាក់ កាលបើមានក្ដីកើតឡើង ត្រូវចៅក្រមដែលពិភាក្សាកាត់សេចក្ដីនេះនាំគ្នាចាប់ស្លាកមុនក្ដីឡើងមកដល់សាលា តាមគំនងនេះ គូក្ដីទាំងសងខាងមិនដឹងថាលោកចៅក្រមណាមកជម្រះកាត់ក្ដីរបស់ខ្លួន ។ ដើមចោទនិងចុងចំឡើយតោងតស៊ូក្ដីដោយខ្លួនឯង មិនមានស្មាក្ដីនិយាយតវ៉ាជំនួសខ្លួនទេ បើមិនអាចទៅថ្លែងសេចក្ដីចំពោះមុខចៅក្រមដោយខ្លួនឯង ត្រូវទន្ទេញពាក្យថ្លែងការណ៍ឲ្យចាំមាត់ហើយទៅថ្លែងឲ្យចៅក្រមស្ដាប់ តាមសំណៅដែលគេស៊ីតែងពាក្យក្ដីប្រគល់ឲ្យ ។ ការជំនុំជម្រះក្ដីនេះប្រើវិធីរាប់ដុំក្រួស គឺពួកចៅក្រមយកដុំក្រួសដាក់ទៅក្នុងភាជន៍ ១ ឯដុំក្រួសនោះមាន ២ ព័ណ៌ គឺព័ណ៌ខ្មៅជាស្លាកកាត់សេចក្ដីឲ្យចំឡើយចាញ់ ព័ណ៌សជាស្លាកកាត់សេចក្ដីឲ្យចំឡើយឈ្នះ កាលបើបោះស្លាករួចហើយក៏យកស្លាកមករាប់

មើល  ហើយកាត់សេចក្ដីទៅតាមចំនួនស្លាកដុំក្រួសពណ៌ណាដែលមាន ច្រើនជាងគេទុកជាស្រេច ។

ដោយហេតុក្រុងអាថែនត្រូវការកងទ័ពជាច្រើនសម្រាប់បង្ការស្រុក១ ត្រូវការទំនុកបំរុងក្រុងអាថែនឲ្យកាន់តែល្អរុងរឿងឡើង១  ត្រូវការចំ-ណាយផលប្រយោជន៍ឲ្យអ្នកពលការស៊ីវិលមានចំនួនច្រើនលើសលុប ១ កិច្ចអស់នេះរដ្ឋបាលអាថែនត្រូវការប្រាក់ជាច្រើន  ឯផលប្រយោជន៍ របស់អាថែនមាន ៣ ផ្លូវ  គឺបានរ៉ែប្រាក់ (មីនប្រាក់) អំពីភ្នំលោរីយ៉ុម នឹងបានរ៉ែមាសអំពីស្រុកត្រាស ១  បានទទួលគ្រឿងបណ្ណាការអំពីស្រុក ចំណុះទាំងឡាយ ១  បានពីកាស៊ីអាករពន្ធដារ។ នេះមានពីរប្រភេទ  គឺ ប្រភេទធម្មតានឹងប្រភេទពិសេស ។  ប្រភេទធម្មតា  បានដល់វេលា ស្រុកទេសសាន្តត្រាណ  រដ្ឋការយកកាស៊ីជំនួញផ្សេង១ នឹងយកកាស៊ី ពីមនុស្សផ្សេងជាតិដែលចូលមកនៅស្រុកអាថែន ។  បើជាវេលាមាន សឹកសង្គ្រាម  រដ្ឋការត្រូវយកកាស៊ីពីអ្នកមានទ្រព្យតាមចំនួនទឹកប្រាក់ ដោយឡែកទៀតផង  ប្រភេទពិសេសនេះ  តោងបង់ពន្ធចំពោះអ្នកមាន ប៉ុណ្ណោះ  នឹងមានពន្ធដារច្រើនយ៉ាងដទៃទៀត  ដូចជាពន្ធសម្រាប់ទំនុក បំរុងទ័ពជើងទឹក ពន្ធសម្រាប់មានល្ខោនលេងឲ្យរាស្ត្រមើល ។ ការដែល រដ្ឋការស្រុកអាថែន  យកពន្ធដារពីរាស្ត្រជាច្រើនមុខដូច្នេះជាការ

ចំឡែកណាស់ដែរក្នុងសម័យបុរាណ តែជនពួកនេះមិនមានសេចក្ដីក្ដៅក្រហាយ ព្រោះគេប្រកាន់ថា ជីវិត កាលវេលា នឹងទ្រព្យសម្បត្តិទាំងឡាយរបស់ក្សត្រ ទុកជារបស់ប្រទេសជាតិទាំងអស់ ។

គ — អំពីការរចនានិងអក្សរសាស្ត្រ — សម័យប៉េរីក្លេសជាសម័យចំរើនរុងរឿងនៃក្រុងអាថែន ដោយហេតុលោកនេះបានចំណាយប្រាក់របស់រដ្ឋបាលជាច្រើន ដើម្បីរកការឲ្យរាស្ត្រអ្នកក្រធ្វើ ការដែលឲ្យមនុស្សអស់នេះធ្វើ គឺការកសាងប្រាសាទ មន្ទីររាជការជាដើម ដែលជាសម្បត្តិរបស់ស្រុក ៗ ថាវត្ថុដែលបានកសាងឡើងក្នុងសម័យប៉េរីក្លេសនោះនៅមានសេសសល់ហូតមកដល់សព្វថ្ងៃនេះ ទុកជាបាក់បែកទ្រុឌទ្រោមទៅជាច្រើនហើយ ក៏នៅមានរបស់សេសសល់ឲ្យមើលឃើញលំអនឹងថ្វីដៃក្នុងការកសាងយ៉ាងវិសេស ៗ ពួកអាថែនពេញចិត្តកសាងថាវត្ថុរបស់ស្រុកឲ្យបានល្អលើសគេហស្ថានដែលខ្លួននៅ ហេតុនេះបានជាគេហស្ថានផ្ទាល់ខ្លួនមិនសូវមានក្បាច់របនាច្រើនទេ ប៉ុន្តែបើជារបស់សម្រាប់នគរវិញ គេខំព្យាយាមកសាងយ៉ាងផ្ចិតផ្ចង់ ជនស្រុកអាថែនទុកជាទ័លក្រយ៉ាងណា ក៏នៅតែមានសេចក្ដីសប្បាយចិត្តនឹងលំអស្រុកទេសរបស់ខ្លួន ៗ ក្រៅពីការកសាង ពួកនេះចេះសូនរូបយ៉ាងចំណាប់ផង ៗ

ក្រៅពីកិច្ចការដូចពោលមកខាងលើនេះ ប៉េរីក្លេសបានបណ្ដុះបណ្ដាល

អក្សរសាស្ត្រជាតិក្រើកឲ្យចំរើនឡើងជាអនេក កើតអ្នកប្រាជ្ញកវីនិពន្ធមានកេរ្តិ៍ឈ្មោះល្បីល្បាញឡើងជាច្រើន ត្រាតែនិយមជាគោលនៃអក្សរ-សាស្ត្ររបស់លោករហូតមកដល់សព្វថ្ងៃនេះ មានចំនួនអ្នកប្រាជ្ញជាច្រើននាក់ដែលគួរស្គាល់ឈ្មោះទុកនោះដូចមានតទៅនេះ

១ — អេស៊ិល កើតក្នុង ព. ស. ១៨ អនិច្ចកម្មកាលពីអាយុ ៧០ ឆ្នាំ បានទទួលសេចក្តីនិយមរាប់អានថាជាបិតានៃបទល្ខោន ។

២ — សូហ្វុក្ល កើតក្នុង ព. ស. ៤៨ អនិច្ចកម្មក្នុងអាយុ ៩០ ឆ្នាំ ជាអ្នកតែងបទល្ខោនដែរ គេសរសើរថាជាកវីចេះតែងរឿងត្រឹមត្រូវតាមសេចក្តីពិត ចេះប្រើពាក្យងាយៗស្រណុកស្តាប់ ឃ្លោងរបស់លោកនេះនៅក្នុងចំពូកពិរោះជាប់ចិត្តជាបំផុត ។

៣ — អ៊ឺរីពីដ៍ កើតក្នុង ព. ស. ២៣ អនិច្ចកម្មក្នុងអាយុ ៧៤ ឆ្នាំ ជាអ្នកតែងបទល្ខោនយ៉ាងល្បីល្បាញ ១ ដែរ ។

៤ — អារិស្តូហ្វាន ឆ្នាំកើតនិងស្លាប់មិនប្រាកដ ជាកវីល្បីល្បាញក្នុងការតែងរឿងត្លុក ។

៥ — ហេរ៉ូដូត កើតក្នុង ព. ស. ៥៩ អនិច្ចកម្មក្នុងអាយុ ៦០ ឆ្នាំ ជាអ្នកប្រាជ្ញពង្សាវតារ បានតែងពង្សាវតារក្រិកនិងពង្សាវតារប្រទេសដទៃៗទៀតមានអេស៊ីប្តជាដើម ។

៦- ធុយស៊ីឌីដ៍ កើតក្នុង ព. ស. ៨៣ អនិច្ចកម្មក្នុងអាយុ ៦៤ ឆ្នាំ ជាអ្នកប្រាជ្ញពង្សាវតារដែរ សៀវភៅជាស្នាដៃឯករបស់លោក គឺរឿងចម្បាំងប៉េលោប៉ូណែស ។

៧— សេនោហ្វុង កើតក្នុង ព. ស. ១១៦ អនិច្ចកម្មក្នុងអាយុ ៧៤ ឆ្នាំ ជាអ្នកប្រាជ្ញពង្សាវតារដ៏ល្បីល្បាញ ១ ដែរ ។

ក្រៅពីពោលរៀបរាប់មកនេះ ក្រុងអាថែនក្នុងសម័យប៉េរិក្លេស មានកើតអ្នកប្រាជ្ញខាងវិស្វកម្ម អ្នកប្រាជ្ញគំនូរ អ្នកប្រាជ្ញរចនាចម្លាក់ អ្នកប្រាជ្ញខាងវិជ្ជាធម៌អាថ៌ អ្នកប្រាជ្ញប្រដៅសីលធម៌ដែលសំខាន់បំផុត គឺ សូក្រាត ។ ស្រុកអាថែនក្នុងសម័យប៉េរិក្លេសនេះគេអាចពោលបានថា " ក្រុងអាថែនជាសាលាបង្រៀនរបស់ជាតិក្រិក" ។

# រឿងព្រេងខ្មែរ – រឿងអាឡេវ ទី ២

(តមក)

របស់អ្នកឧកញ៉ាប្រាជ្ញាធិបតី (យិន) ចាងហ្វាងក្រុមព្រះរាជនិពន្ធ

ដូច្នោះបានជាបងនាំពង្រត់នាងទៅស្រុកម៉ែឪដូនតានឹងរៀបការតាមច្បាប់ នាងកុំតូចចិត្ត បងនឹងជូនទៅសួរដីដូននាងជាប្រញាប់ កុំនាងថប់បារម្ភឡើយ នាងក្រមុំក៏ព្រមព្រៀងចិត្តដេកជាមួយគ្នា ។

លុះព្រឹកឡើងអាឡេវក៏បែរទូកទៅទៀត ប្រទះនឹងចោរ ៥០០ នាក់ ឯចោរទាំង ៥០០ នោះតែងនៅចាំប្លន់អ្នកទូក អ្នកដំណើរ ដែលដើរទៅរកស៊ីតែសព្វថ្ងៃ លុះឃើញទូកបែរទៅដល់ក៏គិតប្លន់យកទ្រព្យរបស់ ។ អាឡេវដឹងថាចោរចង់ប្លន់យករបស់ខ្លួនដូច្នោះ ក៏ចូលទូកទៅកណ្ដាលពួកចោរ ហើយឡើងទៅនិយាយនឹងមេចោរថា អស់អ្នកពលគ្នាហ៊ានប្លន់តែអ្នកទូកអ្នកដំណើរដែលដើររកស៊ីដាច់ដោចឆ្ងាយពីស្រុកពីភូមិគេ ហើយលើកគ្នាទៅទាំងហ្វូង ៗ ផង ឯខ្លួនខ្ញុំមិនចេះប្លន់អ្នកដើររកស៊ីដាច់ដោចដូច្នេះទេ ខ្ញុំប្លន់តែអ្នកស្រុកអ្នកនគរ ហើយខ្លួនខ្ញុំតែម្នាក់ឯង បានជាខ្ញុំហ៊ានដូច្នេះដោយខ្ញុំចេះអាគមកាប់មិនមុតដុតមិនឆេះ ហើយចេះទាំងអាគមបថមំបថមីនប៉ែតជានសាជាន មហាស្រឡប់មហាស្រឡាយ នាពយណ៍បែងភាគ នាពយណ៍កាឡា ខ្ញុំចេះអស់មិនសល់ នេះខ្ញុំទើបមកពីប្លន់

ស្រុកគេ យកបានទាំងកូនក្រមុំគេម្នាក់មកផង បើអ្នកឯងមិនជឿអ្នកសួរ ស្រីនោះចុះ ។ ឯអស់ពួកចោរបានស្ដាប់អាឡេវអួតប្រាប់ពីសិល្បសាស្ត្រ អាគមវិជ្ជាការដូច្នេះហើយ ក៏ចង់រៀន ទើបនិយាយនឹងអាឡេវថា បើ ដូច្នោះសូមអ្នកបង្ហាញអាគមសិល្បសាស្ត្រដល់យើងកល់គ្នាផង យើងសុំ អ្នកធ្វើជាគ្រូឲ្យបង្ហាញប្រុះដាំហើយនៅធ្វើការរកស៊ីជាមួយគ្នា ។ អាឡេវ ថាបើអស់អ្នកចង់រៀនក៏ខ្ញុំបង្ហាញបាន ប៉ុន្តែការរកទីធ្វើពិធីចូលគ្រូណាម នោះក្រណាស់ មានតែរកកោះដាច់ពីស្រុកពីភូមិគេ ហើយនៅកណ្ដាល ទន្លេ ឆ្ងាយពីត្រើយនោះទើបធ្វើបាន ហើយអាឡេវនឹងចោរក៏នាំគ្នាទៅ រកកោះកណ្ដាលសមុទ្រ បានឃើញកោះមួយមានដក្ខខ្សាច់ល្អក៏ឡើងទៅ លើកោះនោះ រកមើលទីកន្លែងសមគួរឆ្ងាយពីកន្លែងចតសំពៅ អាឡេវ ប្រាប់ថាបើអ្នកចង់រៀនអាគមឲ្យពូកែនោះត្រូវស្ដាប់ខ្ញុំ បើខ្ញុំបង្គាប់ឲ្យធ្វើអ្វី ត្រូវធ្វើតាមពាក្យខ្ញុំទាំងអស់នោះទើបបានអាគមពូកែធុតធាប់ ។ ឯអស់ ចោរទាំង ៥០០ ក៏ទទួលព្រមធ្វើតាមទាំងអស់ ហើយអាឡេវបង្គាប់ឲ្យ ធ្វើពេនពិធីមានបាយសី មានទៀនធូបផ្កា ហើយមានរានវតិចត្រទង់ សង់ជាពានថ្នាក់ ៧ ជាន់ ហើយវាឲ្យជីករកាយដីខ្សាច់ជាអណ្ដូងធំជ្រៅឲ្យ មានទឹកល្មមផុតលិចក្បាល លុះធ្វើស្រេចហើយវាបង្គាប់ចោរទាំង ៥០០ នាក់ឲ្យកោរសក់ ឲ្យស្រាតសំពត់ចេញទាំងអស់គ្នា ហើយវានិយាយ

(មានត)

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

ឆ្នាំគំរប់ ១៣

ភាគទី ៧

ភ្នំពេញ

ការផ្សាយរបស់ព្រះរាជបណ្ណាល័យ

ព.ស. ២៤៨៣

គ.ស. ១៩៤០

...: 01

ព្រះរាជបណ្ណាល័យកម្ពុជា

# KAMBUJASURIYÂ

# កម្ពុជសុរិយា

ជាទស្សនាវដ្ដីចេញផ្សាយពីព្រះរាជបណ្ណាល័យ មួយខែពីរក្បាល

ឆ្នាំគំរប់ ១៣

ភាគទី ៧

គណៈរដ្ឋមន្ត្រីនឹងសម្ដេចសង្ឃនាយកទាំងពីរគណៈ
បានអនុញ្ញាតហើយ

ភ្នំពេញ
ការផ្សាយរបស់ព្រះរាជបណ្ណាល័យ
ព.ស. ២៤៨៣
គ.ស. ១៩៤០

# បញ្ជីរឿង


ទំព័រ

១ — និយាយអំពីអារ្យធម៌របស់ប្រទេសឥណ្ឌៀសម័យបុរាណ . . . . . . . . . ៣

២ — អំពីពន្ធ (ក្នុងប្រទេសឥណ្ឌូស៊ីន) . . . . . . . . . . . . . . . ៥

៣ — អនាមយកថា របស់ទេវមរង្សី (តមក) . . . . . . . . . . . . . . ៨

៤ — ច្បាប់សុភាសិត របស់អ្នកឧកញ៉ា វង្សាសារពេជ្ញ នង (តមក) . . . . . . ១៣

៥ — ដំណឹងផ្សេងៗ . . . . . . . . . . . . . . . . . . . . . ១៧

៦ — រឿងព្រេងខ្មែរ: "រឿងអាល្មេវទី ២" របស់អ្នកឧកញ៉ាប្រាជ្ញាធិបតី យិន (តមក). . . . . . . . . . . . . . . . . . . . . . . ២៤


## រូបក្រៅរឿង


ហ្លួងព្រះបាង — ក្បួនហែព្រះរាជទ្រព្យកំពុងហែចូលទៅវត្តតាតាដើម្បីស្រង់ព្រះពុទ្ធរូប . . . . . . . . . . . . . . . . . . . . . . . ១

# TABLE DES MATIÈRES


Pages.

1° Quelques notes sur la civilisation de l'Inde antique........ 3

2° Causerie radiophonique de Radio-Saïgon au sujet de l'impôt. 5

3° Anāmayakathā par Khémararansī (suite)................ 8

4° Chbab Subhāsit (Poème Khmèr) par Oknhā Vongsāsārapéch (Nong) (suite)........................................ 13

5° Informations diverses................................ 17

6° Conte populaire cambodgien inédit:
"Légende de Alév II" par Oknhā Prachnhāthībadey (Yin) (suite)........................................ 24

HORS TEXTES:

Luong - Prabang — Cortège Royale se rendant à la pagode pour la cérémonie de l'Abhiséka des statues du Bouddhā. 1



ហ្លួងព្រះបាង – ក្បួនហែព្រះរាជទ្រព្យកំពុងហែចូលទៅកាន់វត្តនានា ដើម្បីស្រង់ព្រះពុទ្ធរូប ។

# អារ្យធម៌ប្រទេសឥណ្ឌា

កាលពីពុទ្ធសករាជ ១១៨៩ ដល់ ១១៩១ មានអ្នកធុតង្គជាតិចិនម្នាក់ឈ្មោះ ហួន-ស្តង់ ធ្វើដំណើរទៅមើលប្រទេសឥណ្ឌា ហើយបានទៅចងមេត្រីជិតស្និទ្ធនឹងរាជសំណាក់នៃក្សត្រហាសៈ ( Harsa ) មុនឡើងគ្រងរាជ្យបល្ល័ង្ក ក្សត្រអង្គនេះទ្រង់បានសាកសួរព្រះពោធិសត្វអវលោកិ-តេស្វរៈ ដោយទ្រង់ព្រះតម្រិះថា ទ្រង់នឹងបានទទួលជម្នូនយ៉ាងវិសេសអំពីព្រះពោធិសត្វអង្គនោះ ។ មានព្រះភគិនីរបស់ក្សត្រអង្គនោះ ជាស្ត្រីដែលមានសតិបញ្ញាវាងវៃ យល់ច្បាស់ ចេះដឹងជ្រៅជ្រះក្នុងលទ្ធិពុទ្ធ-សាសនាបែ៉កខាងសម្មតិយរបស់ហីនយាន ។ ឯព្រះភគិនីអង្គនោះទ្រង់ធ្វើការងារដ៏សំខាន់មួយដែលមានប្រយោជន៍ជាសាធារណៈ គឺបុណ្យហែព្រះពុទ្ធរូបមាស ១ អង្គ ។ លោក ហួន-ស្តង់ ក៏បានចូលហែនឹងគេដែរ ។ គ្រានោះ ក្សត្ររបស់ឥណ្ឌាពីរអង្គ ទ្រង់តែងព្រះអង្គដោយគ្រឿងសម្លៀកបំពាក់ដូចជារូបព្រះឥន្ទ្រ ក្សត្រ ១ អង្គទៀតតែងព្រះអង្គជាព្រះព្រហ្ម ហើយទ្រង់ឈរអមព្រះពុទ្ធរូបនោះ នៅខាងក្រោយក្បួនហែនោះ មានដំរីខ្នាតធំៗ ពីរផ្ទុកកញ្ជើផ្កា ។ ក្សត្រហាសៈជាក្សត្រ ១ អង្គដែលទ្រង់ជ្រះថ្លានឹងព្រះពុទ្ធសាសនាយ៉ាងមាំមួន ទ្រង់ចាត់ឲ្យមានការសន្និបាតឡើង មានចំនួនព្រះភិក្ខុសង្ឃដល់ទៅ ៣.០០០ រូប មានលោកសង្ឃព្រាហ្មណ៍នឹងជែនៈចំនួន ២.០០០ រូប ហើយស្តេចយាងចូលទៅ

កាន់ព្រះយាគ: (ព្រះពជភាំង?) ទើបទ្រង់ប្រជុំអស់លោកនោះដើម្បីទ្រង់ធ្វើទានជាព្រះពជកុសល ។ ថ្ងៃទី ១ ទ្រង់ធ្វើសក្ការបូជាដល់ព្រះពុទ្ធ ថ្ងៃទី ២ ទ្រង់ធ្វើសក្ការបូជាដល់ព្រះអាទិត្យ ថ្ងៃទី ៣ ទ្រង់ធ្វើសក្ការបូជាព្រះឥសូរ ។ ទ្រង់ឲ្យសាងរោងទានសម្រាប់ចែកអាហារភោជនទឹងគ្រឿងថ្នាំផ្សេងៗ ។ ការឲ្យទាននេះ តែងមានជានិច្ចមិនដែលខាន ។

លោក ហ្វួន-ស្តង់ បានទទួលដំណឹងដែរ ក្នុងការដែលមានគេមកប៉ងប្រទូសរ៉ាយដល់ព្រះបាទហាសៈ ។ ទ្រង់សួរអ្នកប្រទូសរ៉ាយដោយព្រះអង្គលោក ទោសនោះឆ្លើយដាក់ពួកព្រាហ្មណ៍ដែលមានចិត្តប្រណែនឈ្នានីសដែលទ្រង់ទំនុកបំរុងលោកសង្ឃពុទ្ធសាសនាច្រើនជាងពួកព្រាហ្មណ៍ ។

*

* *

នៅក្នុងខាងចុងឆ្នាំពុទ្ធសករាជ ១៥៨៥ នោះ មានគណៈអ្នកផ្សាយសាសនារបស់ឥណ្ឌាយ៉ាងល្បីល្បាញ ១ រូប លោកនេះឈ្មោះ អតីស បួសជាភិក្ខុកាលពីអាយុ ២៩ ដល់អាយុ ៥៩ ចេញទៅប្រទេសទីបេត៌ ហើយបានត្រាច់ចារិកទៅសព្វអន្លើ ។ បន្ទាប់ក្រោយលោកនេះមក ប្រទេសឥណ្ឌាមិនមានផ្សាយអារ្យធម៌ទៅប្រទេសទីបេត៌ទៀតឡើយ រលំតែទឹងចម្បាំងដែលត្រូវច្បាំងតទល់នឹងមុស្លីម៉ានតាំងពីពុទ្ធសករាជ ១៧២៣ ម្ល៉ោះហើយវត្តអារាមពុទ្ធសាសនា ក៏ត្រូវពួកមហាម៉ាត់កំទេចចោលទៅ ព្រះសង្ឃក៏ត្រូវចាប់ខ្លួនសម្លាប់ លទ្ធិពុទ្ធសាសនាក៏ឥន្ទ្រាយអស់ទៅ ។

# អំពីពន្ធ

មន្ទីរវិទ្យុនានាប្រទេសមួយកន្លែង បាននិយាយបង្អាប់ទើបនឹងរួចថា នៅប្រទេសខ្មែរ ពន្ធសព្វសារពើនឹងឡើងទ្វេមួយជាពីរដើម្បីនឹងឲ្យទឹកប្រាក់ក្រសួងកាន់ប្រាក់ចំណូលចំណាយនៅនគរបារាំងសែសបានចម្រើន កើនឡើងទៀត ។

ពិតមែនតែឈ្មោះមន្ទីរវិទ្យុប៉ុណ្ណោះ ល្មមធ្វើឲ្យអ្នកស្ដាប់ការនិយាយ ពោលផ្សាយដំណឹង មានចិត្តស្ទើរតែជឿតិចណាស់ យើងត្រូវនិយាយឡើងនូវសេចក្ដីជាក់ច្បាស់អំពីរឿងពន្ធខាងលើនេះខ្លះ ជាការមិនឥតប្រយោជន៍ទេ ។

មុនដំបូងគឺជាការពិតប្រាកដ ដដែលប្រកែកមិនកើត គឺថាពន្ធផ្ទាល់ខ្លួនទាំងអស់ ដូចយ៉ាងពន្ធថ្លៃខ្លួនដាក់យ៉ាំងប៊ុតសេសម្រាប់ប្រទេស ហើយសម្រាប់តែតាយកុងប្រទេសតែប៉ុណ្ណោះ ។ កាស៊ីអាករខ្លះ ហើយនិងពន្ធអនុញ្ញាតក្រសួងគយករងទាំងអស់ដាក់យ៉ាំងប៊ុតសេរួមទូទៅ (budget-général) ហើយសម្រាប់បើកឲ្យប៊ុតសេប្រទេសឥណ្ឌូស៊ីនទាំងមូល ។ តែស្រុកចំណុះ ឬស្រុកនៅក្រោមអាណាព្យាបាលបារាំងសែស មិនដែលទទួលចេញសោហ៊ុយចំណាយជាចំណែករបស់នគរបារាំងសែសណាមួយសោះ លើកមួយតែចំណាយក្នុងការរបស់ស្រុកចំណុះនោះមួយ ។

រួចពីនេះមក ដំណើរជាពន្ធទាំងឡាយនឹងឡើងទ្វេមួយជាពីរនោះ ខុសទេ ។ នេះគឺជាសេចក្ដីករកុហកដែលនាំឲ្យរវល់គិតខ្វល់ខ្វាយក្នុងគំនិត ។

អំពីកិច្ចការនៅក្នុងនគរបារាំងសែសនោះ ជាការស្រួលបួលធម្មតារបស់នគរដែលច្បាំងទើបនឹងរួច ដូចគ្រាដែលយើងកន្លងរួចមកហើយនេះ ។ រាជការរបស់មេសិក ( ប៉េតាំង ) បានបើកប្រាក់ទុកឲ្យចំណាយរាប់ប្រមាណរយៈកោដិត្រៃណោតរួចហើយ, បើគិតជាទឹកប្រាក់យើងត្រូវច្រើនរយៈកោដិទៀត សម្រាប់ជួសជុលឬសង់ផ្ទះសំបែងបាក់បែកសព្វសរ-ពើទាំងអស់ក្នុងទឹកដែនទទួលបាបគ្រោះដែលសត្រូវចូលមកប្លន់ដណ្ដើមកំទេចគ្មានសល់ សង់ផ្ទះជាថ្មីរាប់ហ្មឺន, សង់ស្ពានរាប់រយ, ធ្វើផ្លូវថ្នល់ឬផ្លូវរទេះភ្លើងរាប់ហ្មឺនគីឡូម៉ែត្រ ។ អ្នកធ្វើការក្នុងការដូចរៀបរាប់ខាងលើនេះរាប់សែននាក់ ។ តាំងពីប៉ុន្មានខែមកហើយ ជំនួញតាមរទេះភ្លើងបានចាប់ដើរតាមធម្មតាឡើងវិញនៅនគរបារាំងសែស ។ គេបានធ្វើស្ពានបណ្ដោះអាសន្នជាច្រើន ដើម្បីឲ្យរទេះភ្លើងនឹងរថយន្តបរសិន ចាំកំពុងធ្វើស្ពានធំៗខ្លះជាថ្មីឡើងវិញ ។ ជំនួញតាមជើងកប៉ាល់បានដើរទៅមកនគរបារាំងសែស នឹងមហាប្រទេសចំណុះឡើងវិញ ។

មានរឿងមួយទៀតដែលយើងចង់និយាយសរសោះអន្ទូង គឺថានគរបារាំងសែសបានចាយប្រាក់អស់ច្រើនណាស់ក្នុងប៉ុន្មានឆ្នាំនេះ ដើម្បីនឹង

ឲ្យសេដ្ឋកិច្ចហើយនឹងការខាងប្រជាគមរបស់មហាប្រទេសចំណុះបារាំងសែសបានកើនឡើងទៀត ។ ប្រាក់ចងការឲ្យរាជការ ដែលបានយកមកធ្វើទេះភ្លើងទាំងឡាយនៅប្រទេសឥណ្ឌូស៊ីន ជាតិបារាំងសែសនៅនគរបារាំងសែសបានចុះឈ្មោះសុខចិត្តចងការប្រាក់ឲ្យរាជការច្រើនជាងគេ ។ សោហ៊ុយចំណាយក្នុងការទាហានសឹកនៅប្រទេសឥណ្ឌូស៊ីនប៉ិតសើនគរបារាំងសែសចេញទាំងអស់ហើយ ប៉ិតសើប្រែប្រួលទៅរបស់ប្រទេសឥណ្ឌូ-ស៊ីនទាំងមូល សងមួយភាគតូចក្នុងការចំណាយទាំងអស់នេះ ។ សោហ៊ុយចំណាយក្នុងការថែរក្សាគាំពារកប៉ាល់ចម្បាំងរបស់ប្រទេសឥណ្ឌូស៊ីននគរបារាំងសែសចេញទាំងអស់ ។ បើដូច្នោះគឺជាតិបារាំងសែសនៅនគរបារាំងសែសដែលបង់ពន្ធសព្វសារពើសំពប់យកមករៀបចំស្រុកចំណុះបា-រាំងសែសឲ្យមានដំឡៃច្រើនឡើង ហើយជួយការពារសត្រូវឲ្យបានសេចក្តីសុខ ។ ប៉ុន្តែស្រុកចំណុះទាំងប៉ុន្មាននេះមិនដែលជួយចេញប្រាក់ឲ្យប៉ិត-សើនគរបារាំងសែសវិញទេ ។ នេះគឺនគរបារាំងសែសបានធ្វើប្រមកហើយ ៗនឹងធ្វើឲ្យអ្នកឯងកល់គ្នាតទៅទៀត ។

នៅសេចក្តីបញ្ចប់ ចូរអ្នកកល់គ្នាកុំស្តាប់សេចក្តីក្បាតរបស់ឃោសនា-ការផ្សាយដំណឹងរបស់ប្រទេសដទៃៗដែលសមតែស្អប់ខ្ពើមចៀសវាង ។

## អនាមយកថា

### ១. ស.

អ្នកប្រែនិងរៀបរៀង (តមក)

ដោយលំបាក ត្រូវតែដកទ័ពថយលើកត្រឡប់ទៅវិញ ដែលពោលមកនេះមានឧបមាយ៉ាងណា សេចក្ដីឧបមេយ្យក៏មានទំនងដូចគ្នាដែរ ។

## ប្រជារាស្ត្រភ្ញាក់ផ្អើល

កាលបានដំណឹងថាសឹកសត្រូវលើកទ័ពចូលមកក្នុងខែត្រដែនហើយ ពួកប្រជារាស្ត្រក៏គិតភ័យភ្ញាក់ផ្អើល នេះត្រូវនឹងពេលដែលចាប់ផ្ដើមកើតឡើងយ៉ាងស្រាល ៗ ក្នុងកងកាយ ៗក៏កើតកោលាហលឡើង អវយវៈផ្សេងៗធ្វើការខុសប្រក្រតី ដឹងខ្លួនថាមិនសូវស្រួលខ្លួន, មិនឃ្លានបាយ, ស្រៀវស្រាញ, ឈឺក្បាលជាដើម ប្រសិនបើកងកាយអាចទប់ទល់នឹងខ្មាំងសត្រូវត្រឹមប៉ុណ្ណោះបាន អាការរោគក៏ប្រាកដឡើងត្រឹមប៉ុណ្ណោះ ហើយសន្សឹមៗបាត់អស់ទៅ ត្រឡប់សះជាដូចប្រក្រតីវិញ ប៉ុន្តែមានជម្ងឺខ្លះទៀតស្រាប់តែចាប់កើតឡើងមានអាការឈឺធ្ងន់តែម្ដង ធ្វើឲ្យអ្នកជម្ងឺដុនដាបចុះមួយរំពេចមិនដឹងខ្លួនប្រាណក៏មាន ក្នុងកងកាយក៏កើតកោលាហលយ៉ាងខ្លាំងត្រាតែមានអាការសន្លប់សន្ធិនឬដល់នូវសេចក្ដីស្លាប់ក៏មាន នេះមានទំនងដូចជាការកើតចលាចលបះបោរឡើងក្នុងនគរ មិនមែនត្រឹមតែធ្វើឲ្យប្រជារាស្ត្រមានសេចក្ដីភ្ញាក់ផ្អើលប៉ុណ្ណោះទេ ។

# អាការរបស់រោគ

មានអាការរោគបំពួកខ្លះធ្វើឲ្យអ្នកជម្ងឺឈឺជាបជាខ្លាំងមួយរំពេច ហើយទ្វេឡើងដល់ថ្នាក់ធ្ងន់បំផុត កាលបើមកដល់ថ្នាក់នេះហើយនៅតែមិនទាន់ស្លាប់ទេ ក៏នឹងបែរជាសះស្បើយឡើងវិញត្រាតែសះជាស្រឡះទៅ ។ បើបែរជាដល់នូវសេចក្ដីស្លាប់វិញ ក៏គឺថាពួកប៉ាក់តេរីដែលជាខ្មាំងសត្រូវនោះមានចំនួនច្រើនលើកទ័ពចូលរុកកញ្ចាំញីសម្លាប់កងទ័ពដែលតាំងទប់ទល់ការពារនោះត្រាតែបាក់បែកខ្ចាតខ្ចីអស់ទៅ ឬមួយថាបើបែរជាមិនស្លាប់ត្រឡប់ជាធូរថយគ្រាន់បើឡើងវិញ ក៏គឺថាកងទ័ពបំផុតបម្រុងនោះយើងមានជ័យជំនះឡើងវិញ កងទ័ពខ្មាំងសត្រូវដកទ័ពថយពីស្រុកទៅអស់ ។ បើសត្រូវមានកំឡាំងតិច អ្នកជម្ងឺក៏មានអាការឈឺតែបន្តិចៗសន្សឹមៗធ្វើឲ្យយើងមានពេលព្យាបាលបានដោយស្រួល ។

កាលបើសឹកសត្រូវដកទ័ពថយចេញទៅផុតពីខេត្តដែនរបស់យើងហើយ យើងត្រូវតែព្យាយាមកសាងនឹងជួសជុលរបស់ដែលខូចខាតបាក់បែកទៅទាំងប៉ុន្មាននោះឲ្យល្អជាដូចដើមឡើងវិញ ។ មានចួនកាលសឹកសត្រូវដែលដកទ័ពថយទៅវិញនោះបានធ្វើទ្រព្យសម្បត្តិនឹងស្បៀងអាហាររបស់យើងឲ្យវិនាសខូចខាតអស់ទៅ ត្រាតែយើងមានកំឡាំងថយខ្សោយពន់ពេកមិនអាចតាំងខ្លួននៅជាជាតិមួយដូចដើមវិញបានក៏មាន អ្នក

ដែលមានជម្ងឺធ្ងន់ៗហើយបានសះជាឡើងវិញថ្មីៗនោះ ក៏មានទុំទន់ដូចគ្នាដែរ អ្នកជម្ងឺធ្ងន់មានអាកាសថយខ្សោយកំឡាំងអស់កាលយូរថ្ងៃ ជួនកាលបែរជាស្លាប់ព្រោះហេតុនេះក៏សឹងមានខ្លះដែរ ។

## អំពីហេតុផ្សេងខាងក្រៅ

មានជួនកាលមិនមែនត្រឹមតែកើតរោគនោះមួយមុខប៉ុណ្ណោះទេ នៅមានហេតុផ្សេងក្រៅបន្ថែមលើរោគនោះទៀត មានឧទាហរណ៍ដូចយើងឈឺគ្រុន ហើយមានខ្ទុះក្នុងត្រចៀក ឬក្អកពិការ ឬរបេះដូងពិការ ឬមួយកើតរោគផ្តាសាយ ហើយក្លាយទៅជាកើតរោគសួតពិការថែមទៀត ។ល។ នេះកើតឡើង ពីព្រោះតែកងកាយរបស់យើងទន់ខ្សោយកំឡាំង ទើបបណ្តាលឲ្យកើតរោគដទៃៗថែមជួនឡើងទៀត ។ រឿងនេះ មានឧទាហរណ៍ដូចជាយើងកំពុងធ្វើសង្គ្រាមនឹងប្រទេស១ ក្នុងខណៈដែលស្រុកទេសមានកំឡាំងខ្សោយនោះ ស្រាប់តែមានប្រទេសជិតខាងដែលមិនត្រូវនឹងយើងចាំតែពេលចន្លោះនោះ រករឿងបង្កហេតុឡើង លើកពលចូលមកវាយថែមជួនជាពីរត្រួត ឬពុំនោះសោត កញ្ច្ររបស់យើងកើតបះបោរបោលចលឡើង វាយដណ្តើមប្លន់យកទ្រព្យសម្បត្តិរបស់ប្រជាជនផ្ទះជាដើម ។

# អំពីយុទ្ធវិធីរបស់ប៉ាក់តេរី

ផ្លូវដែលប៉ាក់តេរីចូលមកលុកលុយក្នុងរាងកាយរបស់យើងបាននោះ មាន ៣ ផ្លូវ គឺ:

ក) លើកចូលមកតាមអាកាសដែលយើងដកដង្ហើម មានទំនងដូចសឹកសត្រូវដែលលើកចូលមកតាមយន្តហោះ ។

ខ) លើកចូលមកតាមទឹកនឹងអាហារដែលយើងបរិភោគ មានទំនងដូចសត្រូវដែលលើករុកចូលមកតាមផ្លូវទឹក ។

គ) វានាំគ្នាជ្រែកចូលទៅតាមសាច់ស្បែក នេះមានទំនងដូចជាសឹកសត្រូវដែលលើកទ័ពចូលមកតាមផ្លូវគោក ។

កាលដែលកងទ័ពប៉ាក់តេរីលើកចូលទៅក្នុងរាងកាយរបស់យើងបានដោយផ្លូវណាមួយហើយ វាតែងតែប្រុងខ្លួននឹងត្រៀមវិធីការពារខ្លួនរបស់វាដូច្នេះ

១) វាចាប់ផ្តើមបង្កើតពូកវាឡើងយ៉ាងរហ័សរួសរាន់ ដូចពោលមកហើយខាងដើមនេះ គឺជាវាបន្ថែមកំឡាំងវាឲ្យមានចំនួនច្រើនកើនឡើងសម្រាប់ប្រុងខ្លួនតទល់នឹងយើង មានទំនងដូចជាសឹកសត្រូវកេណ្ឌពលប្រជុំទាហានចូលប្រចាំការតាមមុខក្រសួងខ្លួនរៀងខ្លួន ។

២) វាធ្វើថ្នាំពិសផ្សាយចេញជុំវិញខ្លួនវា មានទំនងដូចសឹកសត្រូវ

តាំងបន្ទាយជីកស្នាមភ្លោះ ហើយនាំកាំភ្លើងធំទៅតាំងទុកក្នុងទីផ្សេងៗ ដោយជុំវិញ បើសឹកសត្រូវលុកចូលទៅក្នុងបរិវេណនោះ គោងតែត្រូវកំទេចដោយកាំភ្លើងធំមិនខាន ។

៣) វាព្រួសថ្នាំពិសឬបណ្តែតខ្លួនវាឲ្យអណ្តែតចូលទៅក្នុងលោហិត ហើយផ្សាយចេញទៅសព្វសពាង្គកាយរបស់យើង ដើម្បីធ្វើឲ្យអវយវៈនោះៗធ្វើការមិនបានស្រួលតាមមុខក្រសួងរបស់ខ្លួន ទាំងកំលាំងតស៊ូទប់ទល់ក៏ទន់ខ្សោយទៅ មានទំនងដូចជាសឹកសត្រូវបាញ់ចម្រុះមកត្រូវស្រុកយើងដោយកាំភ្លើងធំ ឬដូចជាយន្តហោះរបស់សត្រូវហោះមកទម្លាក់គ្រាប់បែកធ្វើឲ្យទាហានភិតភ័យភ្ញាក់ផ្អើល ហើយពួកស្រុកក៏ច្រួលច្រាល់ ។

៤) វានាំគ្នាចោមស៊ីស្បៀងអាហាររបស់យើង ដែលសម្រាប់ជុំលៀងកាយឬដណ្តើមយកស្បៀងអាហាររបស់យើងទៅ ធ្វើឲ្យយើងទន់ខ្សោយកំលាំងមិនអាចតទល់បានយូរតទៅមុខទៀត នេះមានទំនងដូចជាសឹកសត្រូវវាយកាត់ដណ្តើមយកស្បៀងអាហាររបស់យើងទៅ ។

នេះ

ច្បាប់សុភាសិត

ប្រសើរពេកពិត ប្រែពីគាថា
បន្ទូលព្រះពុទ្ធ បំបាត់ទោសា
ឲ្យអស់ទាំងមហា- ជនផងត្រងត្រាប់ ។

និព្វានបច្ចយោ ហោតុ មេ ។

របស់

ឧកញ៉ាវង្សាសារពេជ្ជ នង ជាងហ្វាងក្រុមរាជបណ្ឌិត

គ្រូនៅកាន់ព្រះបាទសម្តេចព្រះហរិរក្សរាមាឥស្សរាធិបតី

(ព្រះអង្គដួង) ។

(តមក)

៤០ — យោធជនោ អវត្ថិតោ មហាបេតាំ តំយោ គភា ជសុនចំ សត្តអស្សំ បញ្ចមជ្ឈាក ។ អដ្ឋកុញ្ជ:រាទ្វេកោស: ទ្វេអារុឡា ទ្វេករិយាយំ អវមត្តលា កយំអសា- ធុតាំជនេ ។ ពាក្យនេះលោកថា ពុំឲ្យក្រោ នូវក្របីតែមួយមានចង្រៃ ទុក្ខភ័យឯនឹង គោ ៣ សោតគេ ពុំឲ្យក្រោ ។ ឆ្មា៤ នូវផ្លែ ព្រាំមួយឯនឹង សេះប្រាំពីរណា ដំរីប្រាំបី អប្រិយ៍យសា ចុះសក់បែកជា ពីរពុំប្រពៃ ។ ប្រពន្ធពីរណា ដាវពីរពុំជា សោតសឹងចង្រៃ អព្វមង្គល អំពល់ទុក្ខភ័យ ពិតពុំប្រពៃ នៃអ្នកនោះណា ។

៤១ — ឆកាត្តយ: កាត្តំឃរ: ហាដង្សកាកា កាសំឃ-រ: ចកោកិលា មណ្ឌូជរីកា ឃរសីហោ ។ ធារេធមិរ-សាល វិសេសបរិបាល បរមត្តសេដ្ឋោ កណ្ហូបគន់គិត គំនិតអសោចិត្តមោះមោហោ ហេតុតិវឋ្ឋាន ។ កាលណាល្មោតទៅ ទំលើចុះស្មៅ ហើយអ្នកឯប្រាណ ដំណើរអញណា ដូចមហាហង្សបាន ឥតទឹនហង្សមាន អញតាំងបានហោង ។ ក្អែកសោតកាលក់ ហើរទៅទំនា ចុះបណ្តាលផង អ្នកសំឡេងថា ឥតតាវៅហោង មានអគ្គអញស្គង តា-វៅបក្សី ។ កន្ទេបកាលណា បេញពីរន្ធភ់ យំហើយគិតខ្វី អ្នកអគ្គឯងអាច ដូចរាជសីហ៍ បរបេញអំពី គុហាសុវណ្ណ ។

៤២ — ទលិទ្ទសៈ ជនំមរៈ ទូរកាតា ក្សត្រិអរិ
ព្យាបណ្ឌិតា អាចរិយា សច្ចំមរណំ ។ ពាក្យពិតសារសត្យ
សារសច្ចបរមត្ថ បរមសេដ្ឋ អ្នកណាពុំមាន ធនធានទ្រព្យ[១] ទុកស្មើមរ-
ណំ សៅរូបឥតការ ។ ក្សត្រីបើមាន ជំនៀលផល់ប្រាណ សោតសឹង
អសារ អសោចអាសោ លោកហៅស្រីបស្រាល សូន្យសោះឥតការ
ឥតកេរ្តិ៍ស្មើស្លាប់ ។ មួយនាអ្នកប្រាជ្ញ បណ្ឌិតឯងអាច ពុំឈ្លាសវៃ
ឆាប់ អង្គឥតប្រាជ្ញា លោកថាស្មើស្លាប់ សោតសឹងខុនអាប់ អង្គឯង
នោះនៃ ។ មួយអង្គអាចារ្យ ឥតស័ព្ទឥតសារ ឥតសិល្បសាស្ត្រសៃយ
ឥតមានពាក្យសត្យ ភ្លាំងភ្លាត់ហឫទ័យ ស្មោះស្មើក្សណក្ស័យ ដ្បិត
ចិត្តមោហោ ។

៤៣ — យោសុនខំ ឌំសេចាន់ សាយស្សសោ ន
ឌំសេតា- ធំសុនខោ ចបណ្ឌិតោ នាលំការុញ្ញតី ។
ពាក្យពិតឧបមា រីឆ្កែសោតសា- ហាវហានអប្រិយ៍ ខឹងខាំបាទា
អ្នកណាមួយក្តី អ្នកនោះទោះបី ខឹងដល់ប៉ុន្មាន ។ ពុំដែលខឹងប្រែ វិល
ខាំជើងឆ្កែ វិញពុំដែលមាន នេះដូចអ្នកប្រាជ្ញ ឯងអាចញៀយញាណ
ពុំដែលខឹងថ្កាន តបអ្នកពាលោ ។

---

១ លោកសំដៅយកអរិយទ្រព្យទាំង ៧ មានសទ្ធា, សីល ជាដើម ។

៤៨ — ឃកបក្ខា មហាភជា ឃកកាមោ ទេវី មហន្តំ ឃកំយសោ ឆាន្ទុត្តយោ មហាសុខា ។ លោកថាមហាក្សត្រ សោយរាជសម្បត្តិ រក្សារាស្ត្ររដ្ឋ កុំមានហឫទ័យ អាល័យស្នេហា ស្រឡាញ់ករុណា តែអ្នកមួយឡើយ ។ រីឯជាយា អគ្គអគ្គមហា មហេសីហើយ កុំមានចំណង់ ចិត្តចង់ច្រើនឡើយ ដ្បិតក្សត្រត្រាណត្រើយ ឥស្សរសិរី ។ មួយសោតអ្នកណា មួយទីឯចង់ជា ឯកអគ្គមន្ត្រី កុំឲ្យសរសើរ ដំណើរតិតពី ស្រីសុខសួស្ដី អគ្គឯងប្រាកដ ។

ប្រែកបប្រុងប្រៃ ស្រង់ស្រាយបានសេ សិចបួនជាបទ កាកគតិ
ដោយអាចិ ធារធម៌កំណត់ ទើបចង់ជាបទ ព្រហ្មគីតថា:

៤៩ - ធិធិធិរាបិ រដ្ឋវិភជិកា
ធារីវិត្ថា បរុក្ខាពធាលិ ។
រុក្ខោវិប្បតោ ចធសោភក្កេធិ
ឱរបេធុរិ សុភាសិតាកថា ។
លោកថារីស្រះស្ងួត រីឯហែងហួតឥតគន្ធ
ទគរឥតក្សត្រា ស្រីឥតស្បៃដណ្ដប់ប្រាណ ។
រីព្រៃសោតថាបើ មិនមានឈើដុះដោយដាន

(មានត)

# ជំនឿផ្សេងៗ

## ជំនឿមួយក្នុងកាសែតមហាពោធិ

ក្នុងកាសែតមហាពោធិលេខប្រចាំខែយ៉ាំងវិយេ ១៩៤០នេះ យើងមានសេចក្ដីត្រេកអរដោយបានឃើញផលប្រយោជន៍១ ដែលកើតអំពីជាងគំនូរ ជាស្នាដៃរបស់លោក តឹកា ដែលបានគូរដាក់កាតប៉ុស្ដាល់ ស្រាប់តែបានឃើញគំនូរនេះគេយកទៅចុះបោះពុម្ពផ្សាយក្នុងកាសែតមហាពោធិ ។ ឯគំនូរនេះគូរជារូបដំណាងកាលព្រះសម្មាសម្ពុទ្ធទៅថែរក្សាជម្ងឺព្រះបូតិគត្ត-តិស្សត្ថេរ ដូចយើងបានចុះផ្សាយក្នុងកាសែតកម្ពុជសុរិយាលេខ ២ ឆ្នាំនេះ រួចមកហើយ ។

ឯកាសែតមហាពោធិនេះ ជាកាសែតដ៏ថ្លៃថ្លា ១ ក្នុងលោកពុទ្ធសា-សនា ដែលបានបោះពុម្ពផ្សាយជាភាសាអង់គ្លេស ហើយដាក់សុទ្ធតែរឿងល្អៗគួរចង់មើលចង់ស្ដាប់ ។ កាសែតនេះមានមនុស្សមើលទូទៅទាំងស្រុកក្លិង្គ, ក្នុងលង្កា, ស្រុកភូមា, ស្រុកជប៉ុន, ស្រុកចិន, ទ្វីបអាមេរិក, ទ្វីបឩរុប និងស្រុកសៀមក៏មានមនុស្សត្រូវការមើលដែរ ។

យើងមានសេចក្ដីត្រេកអរច្រើន ដែលបានឃើញសតិបញ្ញារបស់លោកតឹក មានពុទ្ធសាសនិកជនជាន់ខ្ពស់ទទួលដឹងព្រួតផងនេះ ៗ យើងមានសង្ឃឹមថាអស់ទាំងជាងគំនូរធំៗដែលបានឃើញគំនូរផ្សេងៗរបស់លោក

តឹក គង់មានសេចក្ដីសរសើរដែរ ក្រែងតែពួកយើងដែលជាជនរួមជាតិជាមួយនឹងលោកតឹកនេះមិនទឹកក្នុកសរសើរស្មោះដែដូចយើងបានពោលមកនេះៗ ។ អស់ទាំងរូបគំនូរល្អៗនឹងសៀវភៅមានបោះពុម្ពរូបប្រកបផងសុទ្ធតែជារបស់ល្អមើលទាំងអស់ ។ យើងមានជាងគំនូរដែលមានថ្វីដៃពូកែបែបនេះតិចណាស់ ដែលធ្វើឲ្យយើងជឿជាក់ថាស្រុកខ្មែរនេះមានមនុស្សជាច្រើនដែលមានការសិក្សាច្រើននឹងមានចំណេះច្រើនបានស្គាល់ស្រុកខ្មែរនេះទូទៅ ដោយសារជាងគំនូរម្នាក់នេះបានបញ្ចេញគំនិតដ៏ខ្ពង់-ខ្ពស់នេះបង្ហាញឲ្យគេបានឃើញ ។

## វិជ្ជារះកាត់របស់ឥណ្ឌូ

នៅមហានគរបារាំងសែស មានបោះពុម្ពសៀវភៅ១ និយាយពីវិជ្ជាពេទ្យ សុទ្ធតែពួកគ្រូពេទ្យបានតែងឡើង ជារឿងមានប្រយោជន៍ណាស់ យើងនឹងដកស្រង់យកត្រង់សេចក្ដីដែលមានប្រយោជន៍ដល់អ្នកមើលទស្សនាវដ្ដីរបស់យើង ក្នុងការព្រានតែងសេចក្ដីនេះ លោកគ្រូពេទ្យហ្វ័រគ៍ (Forque) បានតែងដំណាលរឿងនឹងសេចក្ដីដែលមានឡាក់ឋានតាមវិជ្ជាពេទ្យ លោកបានពោលពីប្រវត្តិរបស់គ្រូពេទ្យដវិក ជាគ្រូពេទ្យដែលមានចំណេះខាងវិជ្ជារះកាត់យ៉ាងចំណាប់ដៃលោកធ្លាប់ធ្វើមកក្នុងសម័យនោះ ។ លោកដវិកលះបង់កេរសម្បត្តិរបស់បិតា ដើម្បីរកសិក្សាខាងវិជ្ជារះកាត់ ។

នៅប្រទេសឥណ្ឌាសម័យនោះ គេចេះវះកាត់កាត់កែក្ដកច្រមុះស្បែក ឬក្ដកត្រចៀក ហើយនឹងវិជ្ជាវះកាត់ដែលជាវិជ្ជាទំនើបថ្មីនៅប្រទេសអឺរ៉ុប ដូចជាវិធីបណ្ដុះផ្សិតក្ដាប់ត្រង់អវយវៈដែលខូចខាតទៅឲ្យគង់ទ្រង់ល្អឡើងវិញ នោះជាចំណេះដែលកើតឡើងមុនដំបូងបង្អស់នៅប្រទេសឥណ្ឌា ។

ឯវិធីវះកាត់យ៉ាងវិសេស ក៏មានពោលទុកក្នុងគម្ពីរជាន់ចាស់ដែលកើតឡើងជាដំបូង និងវិធីគ្រោងថ្មីយ៉ាងវិសេសៗ ក៏មានសំដែងទុកដែរ ។

មានគម្ពីរពីរទៀត ក៏ចំណាប់ចំណាស់ដែរ ជាស្នាដៃរបស់លោកចរកៈ ដែលបានតែងឡើងកាលពី ព. ស. ៤៤៣ និងគម្ពីររបស់លោកស៊ុស្រុតៈ កាលពី ព, ស. ៩៤៣ ។

ក្នុងគម្ពីររបស់លោក ស៊ុស្រុតៈនោះ គេបានឃើញសេចក្ដីថា "គ្រូពេទ្យណាដែលចេះត្រឹមវិធីគ្រោងវិសេសតែមួយផ្លូវ ទុកដូចជាសត្វស្លាបដែលមានស្លាបតែមួយ" ហើយមានបន្ថែមសេចក្ដីតទៅទៀតថា "សិស្សដែលចេះដឹងតែក្នុងគម្ពីរ ទុកដូចជាសត្វលាដែលគេផ្ទុកខ្លឹមចន្ទន៍នៅលើខ្នង បានតែធ្ងន់ ១ មុខ ឥតស្គាល់ដំឡៃឡើយ" ។ លោកស៊ុស្រុតៈបានរៀបរៀងវិធីវះកាត់ ២១មុខ ប៉ុន្តែលោកពោលទុកក្នុងគម្ពីររបស់លោកថា "វិធីដែលវិសេសបំផុតស្រេចនៅលើដៃរបស់ សល្យពេទ្យ (ស្នាដៃរបស់គ្រូពេទ្យ)" ។

គេចាត់ចែងបង្ហាត់បង្រៀនពួកអ្នករៀនវះកាត់ឲ្យរៀនធ្វើពួកសត្វជាមុន លុះបានស្ទាត់ហើយ ទើបគេបង្រៀនឲ្យរៀនចៀរដើមឈើដើមថ្នាំជាចំរៀកល្អិតៗ ហើយគេច្រករបស់អស់នេះទៅក្នុងផ្ដុកដែលពេញទៅដោយទឹក ឬស្រាសក់ ដើម្បីរៀបចំរៀនវិធីវះយកសរសៃខាងក្នុង ហើយគេបង្រៀនវិធីរុំសំពត់ទីងរូបគារមោង (ធ្វើជារូបធៀបនឹងមនុស្ស) ។

នៅក្នុងវគ្គមួយមាននិយាយថា លោកស៊ុស្រ៊ុត: រក្សាពេគប្បាក់ធ្មេញដោយធ្វើព្រួលមួសរុំអប សម្រាប់ជម្ងឺឈឺក្រពះនោម ថ្នស់ធ្មេញប្រជ្រុសត្បាត់ព័ន្ធពោះវៀន (ចុកពោះ) វិធីកាត់វះពេគពកក ។ ឯការធ្វើឲ្យអ្នកជម្ងឺដេកលក់ក្នុងពេលដែលធ្វើការវះកាត់នោះ គេប្រើគ្រឿងថ្នាំដេកលក់ ។

លោកដុកទ័រ ស៊ីលបែរត៍មេឌិយោជី និងលោក ហ៊ុយបែរត៍ ស្ទូសស្ទ័រ បានពោលប្រវត្តិរឿងរ៉ាវរបស់កាមពេគទុកថា:

ជម្ងឺនេះកើតឡើងក្នុងប្រទេសបាក់ងសែសនឹងទ្វីបឌុរុប កាលពី ព.ស. ១៩០០ គេបានសន្មតជាដើមកំណើតដែលជម្ងឺនេះបានកកើតឡើងជាដំបូងបង្អស់ ហើយគេបានជជែកជេញដោលគ្នាពីហេតុផលតាមសេចក្ដីពិតមែន ប៉ុន្តែជម្ងឺនេះគេបានស្គាល់ច្បាស់តាំងពីសម័យព្រេងនាយនៅប្រទេសឥណ្ឌា ប្រទេសអេស៊ីប្ត៍ ប្រទេសក្រិក និងប្រទេសចិនជប៉ុន សុទ្ធតែមានថ្នាំរក្សាពេគនេះមកហើយ គេបានពន្យល់អំពីជម្ងឺនេះសុទ្ធតែមានលក្ខណ:ឃើញច្បាស់ថាជាជម្ងឺកាមពេគទាំងអស់ ។

(នេះហើយទើបគេហៅថា សង្សារចក្រ មានទំនងដូចជាកង់រទេះ តែងវិលវល់ផ្កាប់ផ្ការជាធម្មតា របស់ចាស់ឬវិជ្ជាជាន់ចាស់ តែបាត់បង់ទៅជាយូរអង្វែងហើយមានអ្នកប្រាជ្ញរកឃើញឡើងវិញ គេសន្មតថាជារបស់ទំនើបថ្មី គន្លងមកមិនទាន់បានប៉ុន្មានឆ្នាំ តែគេសន្មតថាជារបស់ចាស់ទៅវិញ) ។

## អំពីបណ្ណាល័យក្នុងប្រទេសបារាំងសែស នឹងប្រទេសអង់គ្លេសនឹងការមើលសៀវភៅ ក្នុងពេលដែលស្រុកមានសង្គ្រាម

បណ្ដាបណ្ណាល័យសំខាន់ៗនៃប្រទេសទាំងពីរនេះ នៅតែបើកឲ្យប្រជាជនមើលសៀវភៅបានជានិច្ច ។ បណ្ណាល័យទាំងនេះ គេបានធ្វើគ្រឿងបង្ការគ្រាប់បែកនឹងភ្លើងឆេះ បណ្ដារបស់ល្អៗដែលមានដំឡៃ នឹងបញ្ជីសៀវភៅផ្សេងៗ សុទ្ធតែមានគ្រឿងបង្ការយ៉ាងមាំមួន ។ នៅក្នុងបណ្ណាល័យធំចំបងមួយនៃក្រុងឡុងដ៍ ប្រទេសអង់គ្លេស បណ្ដាអ្នកមើលសៀវភៅតោងតែពាក់ប្រដាប់បង្ការផ្សែងពុលយ៉ាងប្រញាប់ ប្រសិនបើមានអាណត្តិសញ្ញាប្រាប់ឲ្យដឹងខ្លួនឡើង សុទ្ធតែមានគ្រឿងបង្ការខ្លួនដោយឡែក សម្រាប់ពួកអ្នកមើលសៀវភៅអស់នោះ ។

ក្រុងប៉ារីស នៅក្នុងបណ្ណាល័យធំចំបងមួយនោះ គេបានរៀបចំទីកន្លែង ១ នៅក្នុងដី ជាកន្លែងសម្រាប់មើលសៀវភៅ ក្នុងពេលដែលស្រុកទេសមានចំបាំង ៗ ក្នុងបណ្ណាល័យខ្លះក្រសួងឲ្យខ្ចីសៀវភៅតោងតែរៀបចំជាថ្មីក៏មាន ៗ នៅបណ្ណាល័យដទៃទៀតជាច្រើន គេបានកសាងសម្រាប់បង្ការគង់ទ័ព ដោយធ្វើបន្ទាយទាហាន ទាំងសម្រាប់ពួកមនុស្សដែលផ្លាស់ពីខេត្តក្រៅអាស្រ័យនៅបាន ហេតុនេះបានជាគេឃើញច្បាស់ថាប្រទេសអង់គ្លេសនឹងប្រទេសបារាំងសែស ប្រកាន់ការមើលសៀវភៅជារបស់សំខាន់ទាំងមានផលប្រយោជន៍ទាំងទុកដូចជាការតតាំងនឹងសត្រូវ ជាកិច្ចខានធ្វើពុំបាន ទាំងការជួយថែរក្សាឧត្ដមគតិដ៏បរិសុទ្ធទុក ៗ ក្នុងកញ្ចប់គ្រប់ ៗ កញ្ចប់ដែលគេបញ្ជូនទៅឲ្យទាហានដែលច្បាំងគ្នានោះ តែងមានសៀវភៅ ១ ជានិច្ច ហើយនៅប្រទេសអង់គ្លេសគេបម្រុងនឹងរៀបចំក្រសួងឲ្យខ្ចីនេះ ដោយវិធីធ្វើឲ្យជាទីគាប់ចិត្តដល់អ្នកសុំខ្ចីទាំងអស់គ្នាតាមត្រូវការ ៗ

## ទស្សនាវដ្ដីពុទ្ធចិន្ដា

ក្នុងទស្សនាវដ្ដីបារាំងសែស ១ ហៅថា “ពុទ្ធចិន្ដា” (La pensée Bouddhique) ដែលយើងទើបនឹងបានទទួលនេះ មានសេចក្ដីមួយល្មមយល់បានថាជាសេចក្ដីតែងល្អគួរឲ្យចង់ដឹង គឺមានសេចក្ដីមួយនិយាយ

ពីសមាធិប្ដូណានរបស់ព្រះពុទ្ធ ជាសេចក្ដីប្រែពីមហាសតិបដ្ឋានសូត្រ (ទីឃនិកាយ) មកជាភាសាបារាំងសែស ហើយមានរឿងសង្ខេបមួយនិយាយពីបាឋកថារបស់មាដាមដាវីតនីល ដែលគាត់បានសំដែងក្នុងប្រទេសចិន បាឋកថានេះនិយាយអំពីពុទ្ធសាសនានៅប្រទេសទីបេត៍ ហើយមានរឿងមួយជាសេចក្ដីបង្ហើយខាងចុងនោះ និយាយពីបែបផែនថ្វាយព្រះស្ដូប ។

រួចមានសេចក្ដីអធិប្បាយមួយដែលផងជាតិបារាំងសែសបង្ហាញឲ្យឃើញគំនិតយោបល់អំពីលទ្ធិពុទ្ធសាសនា ទុកជាដំណើងថ្មីមួយនៅក្នុងលោកពុទ្ធសាសនា នៅមាន២រឿងទៀតជាសេចក្ដីសារសើរពីគុណ-សម្បត្តិរបស់អ្នកដែលមានកេរ្ដិ៍ឈ្មោះដែលអនិច្ចកម្មទៅ គឺរឿងមួយនិយាយពីលោក គុតដារត៍ ជាតិអាមេរិកាំង ដែលបានធ្វើដំណើរទៅប្រទេសចិនក្នុងគណៈអ្នកដើរប្រកាសសាសនាគ្រិស្ដ ។

# រឿងព្រេងខ្មែរ – រឿងអាឡេវ (ទី ២)

(តមក)

បញ្ឆោតចោរទាំង ៥០០ នោះថា វែអាគមខ្ញុំនេះ ដែលនឹងរៀននោះ ត្រូវមុជទឹកហើយនឹកសូត្រអត់ដង្ហើមនៅក្នុងទឹកបាន ៧ ថប់ទើបពូកែ ៗ ពួកចោរក៏នាំគ្នាហាត់មុជទឹកសូត្រអាគម ៗ ឯអាឡេវចុះទៅសំពៅ និយាយខ្សឹបប្រាប់ប្រពន្ធឲ្យរៀបខ្លួនហើយទាញពួរយុថ្កាឲ្យខ្លី ផ្ដាំប្រពន្ធថា បើអញរត់ចុះមកពីលើគោកត្រូវទាញពួរយុថ្កាឡើងជាឆាប់ ផ្ដាំស្រេចហើយក៏ត្រឡប់ទៅវិញ លុះដល់ពេលយប់ងងឹតក៏ឲ្យពួកចោរមុជទឹកហើយបង្គាប់ថា បើមុជត្រូវមុជឲ្យព្រមគ្នា បើងើបៗឲ្យព្រមគ្នាទើបអាគមពូកែ ៗ លុះពួកចោរមុជព្រមគ្នាហើយ អាឡេវក៏រត់ចុះទៅសំពៅ ដកយុថ្កាលាក្ដោង ជូនជាខ្យល់ដំនោរមកដល់ អាឡេវបើកក្ដោងយានទាំងសំប៉ាន ទៅចោលចោរទាំង ៥០០ នៅលើកោះនោះ ៗ ឯចោរទាំង ៥០០ ងើបអំពីទឹកឡើង រកមើលអាឡេវមិនឃើញ ក៏សួរគ្នាថា លោកគ្រូទៅណា ហើយនាំគ្នារកក្នុងពន្ធពិធីមិនឃើញ ទើបចុះទៅមើលឯកំពង់ក៏មិនឃើញបាត់ទាំងសំពៅ ពួកចោរទាំង ៥០០ ក៏ដឹងថាអាឡេវបញ្ឆោតហើយ ទើបនាំគ្នាកាត់ឈើឫស្សីធ្វើក្បូនឆ្លង ៗ

ឯអាឡេវក៏បើកសំពៅយកទ្រព្យរបស់ចោរទាំង ៥០០ ដែលនៅក្នុងសំពៅនោះទៅតែពីរនាក់ប្ដីនឹងប្រពន្ធ លុះបើកក្ដោងទៅអស់មួយយប់

មួយថ្ងៃក៏បានដល់ទៅស្រុកមួយ ហើយវារកមើលមនុស្សក្នុងស្រុកនោះ ពុំឃើញមានមនុស្សប្រុស មានតែស្រី ទើបដឹងថាជាស្រុកចោរដែលវាបញ្ឆោតនោះ ហើយវាបោះយុថ្កាឈប់ ។ ឯអស់ប្រពន្ធចោរទាំងនោះ នឹងបានដឹងស្គាល់ថាជាសំពៅរបស់ប្ដីក៏ទេ ដ្បិតកាលដែលប្ដីចេញទៅអំពីផ្ទះតែខ្លួនទទេ លុះបានជួបនឹងសំពៅឈ្មួញក៏ប្លន់យក បានជាប្រពន្ធកូនមិនដឹងមិនស្គាល់ ។ លុះអាឡេវបោះយុថ្ការួចស្រេចហើយ ក៏យកដីសនឹងក្ដារឆ្នួនចេញមកក្រៅហើយគូរវាសចាប់យាម ។ ឯអស់ប្រពន្ធកូនចោរមើលមកឃើញអាឡេវគូរវាសដូច្នោះ ក៏នឹកស្មានថាវាចេះចាប់យាម ទើបសួរថា អ្នកអើយ អ្នកចេះចាប់យាម អាណិតមើលឲ្យប្ដីយើងខ្ញុំបន្តិច ដ្បិតគាត់ទៅរកស៊ីជាយូរខែហើយ ។ អាឡេវឮដូច្នោះហើយក៏ដឹងថាស្រីទាំងនេះជាប្រពន្ធចោរដែលអញបញ្ឆោតនោះប្រាកដ ហើយវាឆ្លើយឡើងថាក្រអីសព្វបើចាប់យាមនោះ ទោះបីមើលសម្ពស្សម្ភារក្លឹកអ្នក: លេខ យ័ន្តអីខ្ញុំក៏ចេះទាំងអស់ អ្នកចង់មើលអំពីរឿងអ្វីយកតែទៀនធូបស្លាម្លូមកបូជាគ្រូ កុំឲ្យសាបអាគមយាមខ្ញុំ តាមគ្រូប្រដៅផ្ដាំមក ។ ឯប្រពន្ធចោរឮអាឡេវថាដូច្នោះ ក៏ម្នីម្នាឡើងទៅផ្ទះជាប្រញាប់ ប្រាប់ប្រពន្ធចោរឯទៀតៗឲ្យរកទៀន ធូប ក្រូ ផ្កា ស្លា ម្លូ ចេក អំពៅ យកទៅជូនគ្រូ ។ អាឡេវទទួលយកជំនូនហើយ តាំងយកក្ដារឆ្នួនមកគូរវាស

ធ្វើជាចាប់យាម គិតប្រមាណក្នុងចិត្តឲ្យត្រូវពេលាលួចពួកចោរទាំង៤០០ នោះមកដល់ផ្ទះ គឺវាគិតប្រមាណគេចំងាយផ្លូវហើយប្រាប់ប្រពន្ធចោរ ថា ប្ដីអស់អ្នកកាល់គ្នានឹងមកដល់ចាប់ក្នុងថ្ងៃស្អែកនេះ ប៉ុន្ដែក្នុងវេលាយប់ នេះនឹងមានព្រាយក្បាលត្រងោល ស្រាតសំពត់វេត់ចូលមកក្នុងផ្ទះបង្កើត ជាទុក្ខព្យាទ៍ធំណាស់ បើដូច្នេះមានតែអ្នកកាល់គ្នាគិតរំងាប់ទុក្ខព្យាទ៍ចេញ ទើបជា ។ ឯអស់ប្រពន្ធកូនចោរទាំង ៤០០ ឮអាឡេវថាដូច្នោះក៏ភិតភ័យ ហើយសួរថា គិតធ្វើដូចម្ដេចនឹងរំងាប់ទុក្ខព្យាទ៍ចេញបាន ។ អាឡេវឆ្លើយ ឡើងថា វាងាយទេការរំងាប់ទុក្ខព្យាទ៍នោះ គឺដល់វេលាព្រលប់កាលណា ត្រូវអស់អ្នកកាល់គ្នានាំកូនចៅកាន់ដំបងព្រនង់ទៅចាំនៅមាត់ទ្វារផ្ទះ បើ ឃើញព្រាយក្បាលត្រងោលហើយអាក្រាតសំពត់វេត់ចូលមកក្នុងផ្ទះ ត្រូវ វាយកុំឲ្យចូលទៅបាន ។ ឯពួកចោរទាំង ៤០០ លុះធ្វើរួចដល់ត្រើយ កាលណា ពេលាថ្ងៃពួនព្រៃ យប់នាំគ្នាដើរកាត់តម្រង់មកផ្ទះ ព្រោះគ្មាន សំពត់ស្លៀកបានជាមិនចេញដើរពេលថ្ងៃ ។ លុះដល់ថ្ងៃកំណត់ដែលអា ឡេវចាប់យាម ក្នុងពេលព្រលប់លពួកចោរក៏មកដល់ផ្ទះខ្លួន ។

(មានត)

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

ឆ្នាំគំរប់ ១៣

ភាគទី ៨

ភ្នំពេញ

ការផ្សាយរបស់ព្រះរាជបណ្ណាល័យ

ព.ស. ២៤៨៣

គ.ស. ១៩៤០

៨:០១

ព្រះរាជបណ្ណាល័យកម្ពុជា

# KAMBUJASURIYÂ

# កម្ពុជសុរិយា

*ជាទស្សនាវដ្ដីចេញផ្សាយពីព្រះរាជបណ្ណាល័យ មួយខែពីរក្បាល*

ឆ្នាំគំរប់ ១៣

*ភាគទី ៨*

គណៈរដ្ឋមន្ត្រីនិងសម្ដេចសង្ឃនាយកទាំងពីរគណៈ
បានអនុញ្ញាតហើយ

*ភ្នំពេញ*

ការផ្សាយរបស់ព្រះរាជបណ្ណាល័យ

ព. ស. ២៤៨៣

គ. ស. ១៩៤០

# បញ្ជីរឿង

ទំព័រ


១ — និយាយអំពីធាតុសមុទ្រ . . . . . . . . . . . . . . . . . . . . ៣

២ — និយាយអំពីសេចក្ដីសំខាន់ ៗ ក្នុងសៀវភៅមួយរបស់ប្រទេសជប៉ុន . . . . . ៨

៣ — ចំពោះប្រទេសជាក់ងសែស . . . . . . . . . . . . . . . . . . ១១

៤ — ច្បាប់សុភាសិត របស់អ្នកឧកញ៉ាវង្សាសារពេជ្ញ (នង) (តមក) . . . . . . . ១៣

៥ — អំពីព្រះពុទ្ធសាសនាក្នុងប្រទេសឥណ្ឌូស៊ីន របស់លោកដុកទ័រអងជ្រើមិកូត់ (តនឹងចប់) . . . . . . . . . . . . . . . . . . . . ១៧

៦ — ពង្សាវតារប្រទេសក្រិក សេចក្ដីប្រែនឹងរៀបរៀងចេញពីគោលជាវិកផ្សេង ៗ ក្នុងពង្សាវតារលោក (តមក) . . . . . . . . . . . . . . . . . ២៤


## រូបក្រៅរឿង


ក្រុងហ្លួងព្រះបាង — ដំរីព្រះរាជទ្រព្យនៅឱកាសចូលឆ្នាំថ្មីប្រទេសលាវ . . . . ១

# TABLE DES MATIÈRES

Pages.

1° Le fond de la mer........................................ 3

2° Extrait du livre intitulé "Japon"........................ 8

3° Pour la France........................................... 11

4° Chbab Subhāsit (Poème Khmèr) par Oknhā Vongsāsāra péch (Nong) suite............................................. 13

5° Le Bouddhisme en Indochine par le Docteur André Migot (suite et fin)............................................ 17

6° Histoire de la Grèce, extraits de divers documents de l'Histoire Universelle (suite).............................. 24

HORS TEXTE:

Luong-Prabang — L'éléphant du Roi........................... 1



ក្រុងហ្លួងព្រះបាង — ដំរីព្រះរាជទ្រព្យដោឪកាសចូលឆ្នាំថ្មីប្រទេសលាវ ។

# និយាយពីបាតសមុទ្រ

ដោយអំណាចវិទ្យាសាស្ត្រទំនើបថ្មីនៃពួកអ្នកប្រាជ្ញដែលខំសិក្សាឲ្យដឹងរឿងរ៉ាវក្នុងបាតមហាសមុទ្រ ហើយនាំមកពន្យល់យើងឲ្យបានដឹងសេចក្ដីដោយច្បាស់លាស់ដូចជារឿងរ៉ាវដែលមាននៅលើផែនដីដែរ ។ គេបានថតយកវត្ថុផ្សេងៗដែលមាននៅក្នុងបាតសមុទ្រហើយធ្វើជាខ្សែកុនឡើង ទើបយើងបានដឹងនឹងឃើញរឿងរ៉ាវអស់នោះដែលមាននៅក្នុងបាតសមុទ្រ ។ មានសៀវភៅ ១ ល្អណាស់ បាននិយាយពន្យល់ពីកិច្ចការក្នុងបាតសមុទ្រដោយច្បាស់លាស់ ។ លោកអ្នកតែងរឿងនេះគឺលោកវិល្លាមស័ន (Williamsan) ដែលជាអ្នករៀបចំធ្វើប្រដាប់ថត ១ ជាដំបូងសម្រាប់យកទៅថតនៅបាតសមុទ្រ ។ លោកបានធ្វើប្រដាប់ ១ យ៉ាងវិសេស សុទ្ធតែកញ្ចក់ (យ៉ាងក្រាស់ដូចជាកូនបន្ទប់ ១) សម្រាប់ចុះទៅឲ្យដល់បាតសមុទ្រ ហើយមានបំពង់ខ្សែខ្យល់ ១ ទន់សម្រាប់បង្ហូតប្រដាប់នោះចុះទៅ ចុងបំពង់ចងភ្ជាប់នឹងទូក បំពង់នេះហើយសម្រាប់បញ្ចេញបញ្ចូលខ្យល់អាកាស ឲ្យពួកអ្នកធ្វើការនៅបាតសមុទ្រនោះ ដោយសារប្រដាប់ដ៏វិសេសសម្រាប់ឲ្យមើលអ្វីៗបាន នឹងគ្រឿងផ្ទុះបញ្ចាំងភ្លើងដោយឡែកទៀតនោះ លោកវិល្លាមស័ននឹងពួកអ្នកធ្វើការរួមជាមួយនឹងលោក អាចថតយករូបផ្សេងៗបានជាច្រើន យកមកធ្វើជាខ្សែកុន

និយាយពីកិច្ចការនៅបាតសមុទ្រ ក្នុងតំបន់ដែលមានក្តុំក្រិបផុតនោះ លោកនិយាយពីគំនរខ្សាច់មានលក្ខណៈជាផ្កាថ្មនោះមានច្រើនណាស់ពាសពេញក្នុងបាតសមុទ្រ ។ មានខ្យល់ព្យុះកើតឡើងដែលបានឃើញក្នុងបាតសមុទ្រនោះ ក្នុងខណៈដែលមានរលកធំៗកើតឡើងលើផ្ទៃទឹក ប៉ុន្តែនៅបាតសមុទ្រនោះមានតែរលកតូចៗទៅវិញ ។ កាលណាមានភ្លៀងធ្លាក់នៅលើផ្ទៃទឹក គេនឹកស្មានថាដូចជាមានគ្រាប់សំណាទម្លុះទឹកចុះទៅ២-៣ សង់ទីម៉ែត្រ ។ កាលណាមានខ្សែទឹករលកមួយរញ្ជួយនៅបាតសមុទ្រ ហើយមានរលកតូចបែកសាយភាយទៅ ហើយគេបានឃើញត្រីធ្លាមហែលទៅយ៉ាងលឿន មានត្រីធ្លាមខ្លះដេកសម្រាកលើគំនរខ្សាច់ ត្របាក់លេបទឹកហាមាត់ធំៗ ។ មានម្តងទៀតនោះ គេបានចុះទៅក្នុងព្រៃផ្កាថ្ម គេបានឃើញត្រីសេក ១ នៅខាងមុខបន្ទប់កញ្ចក់ ខ្លួនវាមានសម្បុរខៀវចាស់ ចំពុះវាដូចជាចំពុះសេក តែមានលក្ខណៈរឹងម៉ឹងដូចជាថ្ម ហើយវាស្ទុះបុកបន្ទប់កញ្ចក់ មានស្នាមក្រឡាដូចជាចោះ ។ អស់ទាំងមើមឈើដែលមាននៅបាតសមុទ្រនោះស្រស់ល្អនឹងមានពណ៌ផ្សេងៗគឺ ក្រហម, ខៀវ, លឿង, ប្រផេះ ។ លោកនិយាយពន្យល់ពីវិធីដែលត្រីធ្លាមត្របាក់ស៊ីអាហារចំណីរបស់វា មានត្រីធ្លាម ១ ឬ ២ វាហាមាត់ត្របាក់បន្ទប់កញ្ចក់ ហើយវាហែលមកក្បែរៗឥតខ្លាច ទុកជាគ្រឿងប្រដាប់នេះ

មានខ្នាតធំហើយធ្ងន់យ៉ាងណាក៏ដោយ ក៏នៅតែកក្រើករញ្ជួយ មានថ្ពាម យ៉ាងខ្នាតធំ ១ នោះមកទាំកកេរដោយធ្មេញដ៏មុត ត្រង់ដែកនឹងកញ្ចក់នៃគ្រឿងប្រដាប់សម្រាប់ធ្វើការនោះ ។ វិធីស៊ីអាហារនៃសត្វថ្ពាមអស់នេះ វាមិនទំពាស៊ីដូចសត្វឯទៀតៗទេ វាច្រើនទាំកាត់ជាកំណាត់ៗ ទើបទាំលេបកន្ត្រាក់ ៗ

នៅស្រុកឈិកាកូ ប្រទេសអាមេរិក លោកអូទ័រព្រមទាំងអ្នកធ្វើការជាមួយនឹងលោក និយាយពីកិច្ចការដែលបានធ្វើនៅបាតសមុទ្រ ក្នុងខណៈដែលបានចុះទៅមើលក្បែរកោះ ១ នោះ នៅកណ្ដាលទីដែលមានសួនច្បារជាតិទឹក ត្រង់កន្លែងដែលចូលទៅក្នុងព្រៃ ១ នៅក្រោមទឹក ។ លោកអូទ័របានពិនិត្យមើលនឹងថតយកអស់ទាំងកិច្ចការសព្វសារពើដែលមាននៅក្នុងបាតសមុទ្រនោះ ដើម្បីយកមកសំដែងនៅស្រុកឈិកាកូ ។

នៅតំបន់នេះមានត្រីជាច្រើន សុទ្ធមានព័ណ៌ផ្សេងៗគ្នា សម្ងំដេកនៅក្នុងគុហាងងឹត ដែលបានឃើញជាដំបូងនោះ គឺបានឃើញត្រី ១ ពួកដូចជានាំគ្នាសម្ងំដេក តែតាមពិតនោះ មិនដេកទេ វាភ្ញាក់ព្រួកជានិច្ចកាលបើមានគ្រោះថ្នាក់មក វាក៏ហែលរត់ពីទីដេកនោះទៅ ។ ការឃើញជាតំរប់ពីស្រោប់តែឃើញពួកត្រីអស់នោះរត់បាត់អស់ទៅ ព្រោះមានត្រីមួយពួកទៀតឈ្មោះស្រកីហាមាត់ប្រគ្រីងហែលសំដៅមក ធ្វើឲ្យទឹករញ្ជួយ

ជាខ្ទាំងចូលហួសទៅដល់កណ្ដាលកន្លែងដែលដេរដាសដោយផ្កាថ្ម ៗ ក្នុងមួយស្របក់នោះ ស្រាប់តែត្រីដែលមានពណ៌ផ្សេងៗអស់នោះ ត្រឡប់មកកន្លែងវាវិញសម្ងំនៅយ៉ាងស្ងាត់ស្ងៀម ឥតកិតភ័យអ្វី ៗ

មានសត្វសមុទ្រ ១ យ៉ាងទៀតហៅថា ប៉ូលីប (Polype) ជាសត្វមានខ្លួនតូចថ្លាយ៉ាងចំឡែកដូចជាកែវ ទុកជាវាមានខ្លួនមិនធំជាងក្បាលម្ជុលខ្ទាស់ក៏ដោយ ខ្លួនវាក៏នៅតែមានថ្អឹងច្រើនស្អកស្កាស់ ៗ កាលណាវាទៅស្វែងរកអាហារក្នុងទឹកសមុទ្រនោះ សត្វប៉ូលីបនេះវាបញ្ចេញប្រមោយ ២ គូដែលនៅជុំវិញខ្លួនវា ទុកដូចជាលំពែងដែលលាបថ្នាំបំពុល វាអាចចាក់ប្ដួយទៅត្រូវសត្វជាអាហាររបស់វា ទុកជាសត្វនោះនៅឃ្លាតឆ្ងាយពីខ្លួនវាក៏ដោយ ៗ សត្វនោះវាស៊ីតែសត្វរស់ៗ ត្រាតែពេញក្រពះវាតាមបំណង់របស់វា ៗ

បន្ទប់កញ្ចក់នៅក្រោមសមុទ្រ ជាកន្លែងដែលអ្នូទ័រធ្វើការនោះជាទីស្រឡះទូលាយគ្រាន់បើដែរ ហើយមានកង្ហារបញ្ចូលខ្យល់អាកាសឲ្យបានមានដង្ហើមដកបានស្រួល ទឹងធ្វើដំណើរក្នុងទឹកបានស្រួល ៗ លោកបានទៅប្រទះឃើញវត្ថុផ្សេងៗ ទឹងកប៉ាល់ដែលលិចបាត់ទៅជាយូរឆ្នាំ ហើយនោះ ក្លាយទៅជាគំនរដែកទឹងឈើ១ដុំនៅក្នុងបាតសមុទ្រ មានថ្មកំបោរទឹងផ្កាថ្មដុះប្រួញប្រាងឡើង ជាទីជ្រកកោននៃសត្វត្រីជាចំនួនច្រើនលាន

នៅក្បែរៗសំបកកប៉ាល់នោះជាទីប្រជុំនៅនៃសត្វត្រី នាំឲ្យមានជារឿងចំឡែកឡើង គឺមានត្រីយ៉ាងច្រើនសំបើមនៅទីនោះ កាលណាមានសត្វធ្លាមមួយបើកភ្នែកសំឡឹងដាក់ហ្វូងត្រីមួយក្រុម ដែលវាត្រូវការធ្វើជាចំណីអាហាររបស់វា ដោយអំណាចឫទ្ធិអំណាចភ្នែកវានោះ ធ្វើឲ្យត្រី ១ ខ្ទាតចេញចាកហ្វូងត្រីនោះមកហើយមានខ្លួនញ័ររំប្រប់ ៗ ក្នុងខណៈដែលត្រីធំៗហាមាត់ឡើងលេបត្រីតូចៗនោះ វាតែងតែហាមាត់ត្របាក់លេបទាល់តែឆ្អែតបាត់ឃ្លាន ៗ

# សេចក្ដីសំខាន់ៗ ក្នុងសៀវភៅមួយដែលនិយាយពីជប៉ុន

ព្រះរាជបណ្ណាល័យទើបនឹងបានទទួលសៀវភៅមួយ ដែលជនជាតិជប៉ុនម្នាក់បានតែងជាភាសាបារាំងសែស ហៅថា "ជប៉ុន Japon" ។

យើងបានមើលសេចក្ដីត្រង់ដែលនិយាយពីប្រយោជន៍ព្រះត្រៃបិដក ដែលបានចម្លងមកពីស្រុកឥណ្ឌា ហើយផ្សាយមកដល់ស្រុកចិន បានបោះពុម្ពផ្សាយជាភាសាចិន ប៉ុន្តែមកដល់សម័យសព្វថ្ងៃនេះ នៅស្រុកឥណ្ឌានឹងស្រុកចិនព្រះត្រៃបិដកមហាយានមានមិនបរិបូណ៌សព្វគ្រប់ទេ ។ ប៉ុន្តែនៅស្រុកជប៉ុនសព្វថ្ងៃនេះ គេបានរក្សាព្រះត្រៃបិដកមានចំនួន ៣០ ឈុតចប់សព្វគ្រប់ បើមានអ្នកត្រូវការចង់រៀនសូត្រគម្ពីរព្រះពុទ្ធសាសនា (ប៉ែកខាងមហាយាន) តោងតែទៅរៀននៅប្រទេសជប៉ុន ។

តាំងពីកណ្ដាលឆ្នាំពុទ្ធសករាជ ១០៥០ មក ព្រះពុទ្ធសាសនាជួយការពារជីវិតសត្វទាំងឡាយក្នុងប្រទេសជាច្រើន ដោយប្រជាជនជ្រួតជ្រាបស្រឡាញ់ពុទ្ធសាសនាទូទៅ ព្រោះហេតុនេះហើយបានជាជនជាតិជប៉ុនមិនប្រើគ្រឿងស្លៀកពាក់ដែលធ្វើពីរោមសត្វដូចជាសំពត់រោមចៀម (ជាដើម) ប៉ុន្តែគេប្រើសូត្រ មានវិធីចិញ្ចឹមនាងធ្វើសូត្រត្បាញសំពត់តាំងអំពីបុរាណកាលយូរមកហើយ គេតែងធ្វើប្រើក្នុងប្រទេសរបស់គេ ។ តាំងពីពុទ្ធសករាជ ២.០០០ ស្រុកចិនបាននាំកប្បាសមកលក់នៅស្រុកជប៉ុនជា

ច្រើន ហើយការធ្វើជំនួញលក់សំពត់អំបោះក៏មានសេចក្ដីចំរើនកើនឡើងជាលំដាប់ ៗ ព្រះពុទ្ធសាសនារបស់ជប៉ុនបានធ្វើឲ្យកើតសេចក្ដីចំរើន ដូចជាព្រះពុទ្ធរូបទឹងគ្រឿងដួងគាំង មានដួងមួយនោះមានខ្នាតធំសំបើមអស្ចារ្យ ធ្វើប្រជាជនឲ្យមានសីលធម៌ល្អ មានចិត្តស្រឡាញ់វង្សត្រកូល មានចិត្តកតញ្ញូ សឹងសំដែងឲ្យឃើញប្រាកដច្បាស់ក្នុងពេលដែលមានជី-វិតរស់នៅនឹងស្លាប់ទៅនៃចៅហ្វាយនាយធំៗ ។ ព្រះពុទ្ធសាសនាបានប្រដៅឲ្យស្គាល់សេចក្ដីទុក្ខ៤ប្រការប្រចាំជីវិតមនុស្សគ្រប់រូប គឺជាតិទុក្ខ១ ជពទុក្ខ១ ព្យាធិទុក្ខ១ និងមរណទុក្ខ ១ ។ ការធ្វើឲ្យមានជ័យជំនះសេចក្ដីទុក្ខទាំង៤ ប្រការនេះ លុះតែខំព្យាយាមប្រឹងប្រែងឲ្យបានដល់វិមុត្តិ ដែលជាចុងផ្លូវនៃលទ្ធិពុទ្ធសាសនានេះ គឺថាត្រូវខំព្យាយាមលះបង់សេចក្ដីទុក្ខទាំងអស់ក្នុងលោកនេះ ក្នុងការរួបរួមសមាគមជាមួយគ្នា ក្នុងការលះបង់ជីវិតរបស់ខ្លួន ដោយទំនងនេះហើយបានជាធ្វើឲ្យយើងបាត់ខ្លាចសេចក្ដីស្លាប់ដែលជាធម្មជាតិមួយដែលមនុស្សគ្រប់ ៗ ស្រុកតែងតែគោតខ្លាច ។ ទំនងនេះហើយជាគ្រឿងបង្ហាត់ចិត្តមនុស្សឲ្យហ៊ានទិងសេចក្ដីស្លាប់ ក្នុងនាមរបស់គ្រួសារទឹងរបស់ប្រទេស ។

អានុភាពរបស់ពុទ្ធសាសនានេះបានចូលជ្រៀតជ្រែកក្នុងចិត្តគំនិតរបស់ជនជាតិជប៉ុនស្ទើរតែគ្រប់ថ្នាក់គ្រប់ជាន់ទាំងអស់ ។

ឯវិជ្ជាពេទ្យបែបនុរូបនោះ ពួកជប៉ុនបានរៀនសូត្រអំពីពួកហុល្លង់ដេស៍ ហើយសៀវភៅជាក្បួនច្បាប់ខាងធ្វើថ្នាំផ្សំថ្នាំក៏បានប្រែពីភាសាហុល្លង់-ដេស៍មកជាភាសាជប៉ុនដែរ តាំងពីពុទ្ធសករាជ ២.៣១៧ ។ លុះដល់មកពុទ្ធសករាជ ២.៣៥២ ទើបពួកជប៉ុនចាប់ផ្តើមរៀនវិជ្ជាពេទ្យជាភាសាអង់-គ្លេស ហើយគេផ្តើមមើលជម្ងឺភ្នែកឡើងជាដំបូងតាមបែបនុរូប ។

លុះមកដល់ពុទ្ធសករាជ ២.៣៦៦ ទើបមានគ្រូពេទ្យជាតិអាល្លឺម៉ង់ ទៅតាំងកន្លែងនៅស្រុកជប៉ុន ហើយបានបើកសាលាបង្រៀនវិជ្ជាពេទ្យមួយទីងបង្រៀនវិជ្ជាផ្សំថ្នាំ ។

លុះដល់មកពុទ្ធសករាជ ២.៣៩៧ ទើបគេបង្កើតសមាគមដោះអុតឡើងក្នុងប្រទេសជប៉ុន ។

# សម្រាប់នគរបារាំងសែស

ជាតិយួនម្នាក់បាននាមជា "អាសង់តិចណិច" ក្នុងក្រសួងសាធារណការ ដែលឈប់ធ្វើការដោយដល់កំណត់ឆ្នាំ ហើយដែលកជការបានគេឲ្យធ្វើការវិញ ចង់ចូលកុសលក្នុងការជំនួយជាតិទៅវិញទៅមក បានសុខចិត្តជូនប្រាក់ខែមួយខែជាជំនួយ ។

អ្នកពិដ្ឋការខាងលើនេះ បានផ្ញើប្រាក់នេះទៅលោក "អ្នកនាយក [illegible] ក្នុងក្រសួងសាធារណការ [illegible] ទៀត ទៅ"មន្ទីរក្រសួងជំនួយបារាំងសែស-ឥណ្ឌូស៊ីន ឲ្យបានដល់ទៅអ្នកដែលបានទទួលកម្មអកុសលក្នុងការចម្បាំង" ។

លោកអាសង់តិចណិចជាតិយួននេះបានសរសេរសំបុត្ររៀបពាក្យយ៉ាងល្អមួយច្បាប់ជូនជាប់ជាមួយនឹងប្រាក់នោះ អ្នកចាំមើលជាការបន្ទាល់សំគាល់ថាដែលលោក (បារី) ហៅថាការធ្វើឲ្យគេស្រឡាញ់ស្ម័គ្រចិត្ត ។

"ដោយខ្ញុំគិតទៅអ្នកមានគុណ ជួយទំនុកបំរុងខ្ញុំទាំងអស់ដែលមានគ្រូបង្រៀនខ្ញុំពីដើមជាច្រើននាក់ នឹងនាយចៅហ្វាយខ្ញុំដែលឈប់ធ្វើការដោយដល់កំណត់ឆ្នាំសព្វថ្ងៃ នៅនគរបារាំងសែសខ្ញុំខានទឹកគិតដល់ការខូចខាតវិនាសអន្តរាយច្រើនណាស់មិនបាន ការចង្រៃវេទនាដែលនគរបារាំងសែសទើបនឹងទទួល" ។

"ដូច្នេះ កាលណាខ្ញុំនឹកគិតទៅអ្នករៀនចំណេះវិជ្ជាដែលគ្មានភ័ព្វសំណាង ខ្ញុំនៅធ្វើព្រងើយមិនកើត ដោយឃើញសេចក្តីទុក្ខលំបាកវេទនារបស់អ្នកទាំងអស់នោះ នៅខណៈដែលយើងកំពុងលេងសប្បាយរីករាយនៅប្រទេសឥណ្ឌូស៊ីន នូវសេចក្តីសុខក្សេមក្សាន្ត ដែលជនទាំងឡាយប្រាថ្នាយ៉ាងខ្លាំង កើតឡើងដោយសារគំនិតប្រាជ្ញាកជការគ្រប់គ្រងផែនដី ។

"ពីដើមខ្ញុំបានរៀនពីគ្រូបង្រៀនច្រើននាក់ ហើយបានទទួលប្រាក់ជំនួយឲ្យរៀនពីកជការទៀត ឥឡូវនេះត្រូវខ្ញុំយកប្រាក់ចូលជួយក្នុងការកសាងជួសជុលបង្កើតថ្មី ហើយនឹងជួយបងប្អូនទាំងឡាយដែលនៅស្រុកជាមួយខ្ញុំ នៅនគរបារាំងសែសដែលគ្មានសំណាងដូចអ្នករៀមច្បងទៅរៀនជាន់មុន" ។

"របស់ដែលខ្ញុំជូនលោកអ្នកនាយកត្រួតត្រាលើការគ្រប់ជំពូក គឺជាប្រាក់ខែតែមួយខែទេ របស់អ្នកកជការឈប់ធ្វើការដោយដល់កំណត់ឆ្នាំដែលកជការកេណ្ឌឲ្យធ្វើការ (គឺប្រាក់ ១៣៥៛,០០ ក្នុងចំនួនទឹកប្រាក់នេះ ១០០៛,០០ សម្រាប់ជួយនគរបារាំងសែស ក្នុងការជួសជុលបង្កើតថ្មី ហើយ ៣៥៛,០០សម្រាប់ជួយពួកប្រទេសឥណ្ឌូស៊ីនជាអ្នករៀនក្រដុតដៃជើងនេះគឺខ្សាច់មួយគ្រាប់បោលទៅក្នុងសមុទ្រប៉ាស៊ីហ្វិក ផ្ទុយទៅប្រាក់រាប់រយកោដិ តែជាសេចក្តីសំដែងឲ្យឃើញសេចក្តីដឹងគុណ សេចក្តីសប្បុរសអាណិតអាសូរ ។ គឺមនុស្សចិត្តស្មោះត្រង់ម្នាក់ឲ្យប្រាក់នេះ" ។

នេះ

# ច្បាប់សុភាសិត

ប្រសើរពេកពិត ប្រែពីគាថា
បន្ទូលព្រះពុទ្ធ បំហុតទេស្មា
ឲ្យអស់ទាំងមហា- ជនផងត្រងត្រាប់ ។

និព្វានប្បច្ចយោ ហោតុ មេ ។

របស់

ឧកញ៉ាវង្សាសារពេជ្រ ផង ចាងហ្វាងក្រុមរាជបណ្ឌិត

*ក្នុងរាជ្យព្រះបាទ សម្ដេចព្រះហរិរក្សរាមាឥស្សរាធិបតី*

(*ព្រះអង្គដួង*) ។

(គខក)

ឈើសោតបើពុំមាន    សន្ទឹកឡើយសឹងសូន្យសោះ ។
មេគោសោតឥតក្សីរ    ក្សិណាទេសទីនៃទឹកដោះ
វីពាក្យពុំពីពេះ    សឹងសូន្យសោះពុំសេដ្ឋា ។

៤៦ — យោធម្មសីលា    ជិតមានកោធោ
វិជ្ជាវិនិតោ    ឧបកោបតាបិ ។
សទារតុដ្ឋា    បរទារវជ្ជី
ភយានិតាភិញ្ញុ    ឧត្តិតសលោកាំ ។

នរអ្នកឯណា    ចិត្តបន្តដោយធម្ម
សីលោវត្តិតំ    រក្សាសីលពុំដែលដាច់ ។
កំហឹងខឹងមានះ    លៃងលាកលះបរិបូណ៌ស្រេច
រួសរាំរៀនសូត្រសេច    ធម៌ពិនិត្យពិនិស្ស័យ ។
ប្រាជ្ញប្រាជប្រជះប្រជាំ    មិនកំដៅអ្នកដទៃ
រៀបបរទារការនៃ    ត្រេកអរនូវបុត្រករិយា ។
ឯងឯអស់អំពល់    ពិតពុំផល់ជិតអគ្គ
អ្នកនោះលោកយគ្រា    នេះទីនេសកិតភ័យខ្លាំង ។

៤៧ — បត្តិមរុក្ខា    ពាណិជ្ជោមរជាវំ
កិត្តិមរសីលំ    រាជាមរសត្តុមា ។

លោកថាសត្វបក្សី   សោតទោះបីទ័ងមរណា
លុះលើមែករុក្ខា   ទើបប្រសើរជាបក្សី ។
រីឈ្មួញសោតមរណា   លើកេត្រាត្រាប់ជលធី
កិត្តិទ្រង់សីលវី-   សេសសោតមរក្នុងសីលសង្ឃ ។
ព្រះមហាក្សត្រធិពជ   ទ្រង់អំណាចមរណាក្នុង
សង្គ្រាមជ័យទ្រើសទ្រង់   កេរ្តិ៍ប្រសើរជាក្សត្រា ។

៤៨ — យោចបុត្តលោ   ទុដ្ឋនោនោសមា-
ទាយទុក្កធ្វា-   ធិតវស្សកាកេ ។
សុជនោគុណៈ   សត្តហាយហាង្ឃ
ចិរបិវុត្តោ   សប្បុរិសសេដ្ឋា ។
អ្នកកាចកាន់យកទោស   ពុំសន្តោសលោកគួរនា
ដូចប្រេកឈ្ពួសយកអា-   សោចសីងល្អក់ទុគ្គន្ធ៍[១] ។
អ្នកសប្បុរស   លោកបោលអស់ទាំងទោសំ
ប្រមូលយកគុណំ   ដូចហង្សចង់ក្សីរគោគ្គា[២] ។

៤៩ — សសេសសេល-   កេងឯករិយា
ញាតិសសេសា   សេលកេវេជ្ជកោ ។
នាអ្នកមួយក្តាប់មាន   ទ្រព្យបើបានបង់ផនោ[៣]

---

១ មានក្លិនអាក្រក់, ស្អុយ ។ ២ បង់ដឹកទឹកដោះ ។ ៣ បង់ទ្រព្យ ។

ចិន្តសិកាមោ　　　ចិត្តចង់បានដូចដែលវិញ ។
មួយធ្លាប់មានភរិយា　　　ស្និទ្ធស្នេហាដោយស្រឡាញ់
បើស្លាប់ភរិយាមិញ　　　ចង់យកភរិយាទៀតណា ។
អ្នកមួយធ្លាប់មានញាតិ　　　បើឃ្លាឃ្លាតព្រាត់ប្រាសគ្នា
ចិត្តចង់គេអ្នកណា　　　សប្បុរសជាញាតិផង ។
អ្នកមួយធ្លាប់ជាធំ　　　បើថ្លស់អំពីយសផ្គង
រីចិត្តអ្នកនោះហោង　　　នៅធំដូចអតីត[១] ។

៨០ — កាដ្ឋកាម្មំពៈ-　　　មរក្ខមឧឧកាំ
ឧដ្ឋសឧច្ចំ　　　វាចាកាម្មំសាស្ត្រា ។
លោកថាឈើណាមួល　　　ពុំទាន់ចូលព្រមរណា
នោះអ្នកប្រាជ្ញលោកថា　　　ពុំទាន់ហៅជាមូលមាន ។
ភូមិណាមួយបើកប　　　តាំងប្រាសប្រាថ្នូលទីឋាន
ពុំទាន់ស្ងួនទឹកបាន　　　លោកពុំហៅជាកបឡើយ ។
ឈើត្រង់សោតបើពុំ　　　ទាន់ផ្ចាត់តម្រង់ជាត្រើយ
ពុំទាន់ហៅត្រង់ឡើយ　　　លុះផ្ចាត់ទើបហៅត្រង់ហោង ។
អ្នកណាមួយស្រដី　　　មានបាឡីគាថាផង
លោកឲ្យជឿជាម្ដង　　　កុំសន្និះចិត្តចិន្តា ។

១ ដូចពីដើម ។

៥១ — ឥមេកាព្យាហិ  កាភេមិចសុក.

សិតំភិតាដ៉ា  បញ្ញាសនិដ្ឋិតំ ៗ

ឥមិនាតេជេ.  ឧបុញ្ញកុសលំ

យាវនិព្វានំ  បច្ចយោហោតុមេ ៗ

(ចប់)

# អំពីពុទ្ធសាសនាក្នុងប្រទេសឥណ្ឌូចិន

របស់លោកដុកទ័រ អង់គ្រេ-មីហ្គូត៍ (តនិងចប់)

មានមួយផ្លូវទៀត ដែលពុទ្ធសាសនាផ្សាយចូលទៅក្នុងប្រទេសតុងកឹងចាស់ (Le kiaotche) ដោយមានពួកអ្នកដំណើរឬពួកលោកសង្ឃពុទ្ធសាសនាពីឥណ្ឌៀបានដើរកាត់ប្រទេសនេះ ដើម្បីចូលទៅប្រកាសសាសនាក្នុងប្រទេសចិន តាំងពីសតវត្សរ៍ដំបូងគ្រិស្តសករាជ ហើយជួនកាលមានលោកសង្ឃជាតិចិនជាច្រើនដែលនាំគ្នាដើរធុតង្គទៅប្រទេសឥណ្ឌៀ និងក្នុងប្រទេសពុទ្ធសាសនា ដែលនៅចន្លោះឥណ្ឌៀនិងអូស្ត្រា-លីជាដើម ។ ក្នុងរឿងនេះ យើងបានដឹងជាប្រាកដដោយសាររឿងរ៉ាវរបស់លោកធុតង្គ (ជាតិចិន) ឈ្មោះយី-ឈិង ដែលយើងបានពោលរួចមកហើយនោះ នៅខាងចុងសតវត្សរ៍ទី ៧ (ព.ស. ៦៤៣) ។ ក្នុងខណៈនេះ ពុទ្ធសាសនារបស់យួនមានមេត្រីយ៉ាងមាំមួននឹងពុទ្ធសាសនារបស់ចិន ។

ក្នុងឆ្នាំ ៩៦៨ (ព.ស. ១៥១១) មានរាជវង្សក្សត្រយួន ១ អង្គព្រះនាម ឌិញ-ទៀន-ហ៉ាង បានរៀបចំគណៈសង្ឃឲ្យមានជាន់មានថ្នាក់ខ្ពស់ទាប ទ្រង់តាំងលោក ង៉ូ-ច័ន-លុឩ ជាអធិបតីគណៈសង្ឃជាន់

នោះ ៗ ក្នុងរាជ្យរបស់ទ្រង់ និងក្នុងរាជ្យក្សត្រជាតំណតមកនៃរាជវង្ស លី ព.ស. ១៥៥៣ ដល់ ១៧៦៣ (១០១០-១២២៥) និងរាជវង្សទ្រឿង ព.ស. ១៧៦៨ ដល់ ១៩៥៦ (១២២៥-១៤១៣) នោះ វត្តអារាម និងគណៈសង្ឃមានសេចក្ដីចំរើនឡើងច្រើននៅក្នុងស្រុក លទ្ធិសាសនា ក៏រីកធំឡើង សាយភាយទៅដោយសារប្រជាជនបានគម្ពីរដីកាមកពី ប្រទេសចិន ៗ មានលក្ខណ៍ជាច្រើនដែលបង្អុលបង្ហាញឲ្យឃើញថា ពុទ្ធសាសនាដែលបានទទួលសេចក្ដីសុខក្សេមក្សាន្តដោយសារការទំនុក បំរុងពីពួកក្សត្រដែលមានក្នុងសម័យនោះ អស់វេលា ៤ សតវត្សរ៍ ៗ

តាំងពីខាងចុងសម័យនោះមក មានកំឡាំងរបស់លទ្ធិមួយមកទទឹង ទាស់នឹងសេចក្ដីចំរើនរបស់ពុទ្ធសាសនា គឺលទ្ធិកុងហ្វុយស្យានិស្ម៍ (ខុង-ជឺ) ដែលជាពួកអ្នកចេះដឹងនិយមហៅថាពួកឡេត្រ ជាអ្នកទទួលកាន់ ប្រតិបត្តិតាម ហើយអំណាចរបស់លទ្ធិនេះផ្ដើមកើតឡើងយ៉ាងពិតប្រាកដ នោះ ក្នុងសម័យរាជវង្ស មីង ក្សត្រជាតិចិន ៗ តែក្ដីឈ្មោះសេចក្ដី គោរពកោតក្រែងពួកឡេត្រនេះតាំងពីសតវត្សរ៍ទី ១៦ (ព.ស ២០៤៣ ដែលពួកក្សត្រលែងជួយទំនុកបំរុងពុទ្ធសាសនាដោយពេញទីទៅ បែរ ជាជួយកំឡាំងដល់ពួកអ្នកមានទ្រព្យសម្បត្តិនឹងពួកអ្នកមានសតិបញ្ញាខាង លទ្ធិសាសនារបស់ខុងជឺ ឬលទ្ធិតៅអ៊ិស្ដ៍វិញ ៗ

# ព្រះពុទ្ធសាសនារបស់យួនក្នុងសម័យបច្ចុប្បន្ននេះ តើមានអាការដូចម្ដេច

ត្រូវតែទទួលដឹងថា ប្រជាជនជាតិយួនជាចំនួនច្រើនដែលប្រកាន់ថាខ្លួនជាអ្នកកាន់ពុទ្ធសាសនានោះ ពួកនេះឥតមានគំនិតគិតគូរខាងលទ្ធិរបស់ព្រះពុទ្ធសោះឡើយ វៀរលែងតែលទ្ធិនេះទៅប្រតិស្ឋាននៅទីដទៃ ៗ សូម្បីការសាសនារបស់ពួកឧបាសកឧបាសិកានិងពួកលោកសង្ឃពុទ្ធសាសនា ១ ចំណែកសឹងមានចំនួនច្រើន ដែលទទួលខ្លួនជាអ្នកកាន់ព្រះពុទ្ធសាសនានោះក៏ដោយ ក៏នៅតែឃើញថាសាសនាដែលពួកយួនយល់មិនបាន ដោយឧបាយកលរបស់ពួកចិននិងពួកទីបេតធ្វើមិនឲ្យយល់បានដោយត្រឹមត្រូវ គឺមិនយល់សេចក្ដីជាខ្លឹមសាររបស់សាសនាដូចម្ដេចឡើយ ។ ប្រវេណីសាសនាដែលគេត្រូវគោរពជាដំបូងទុកជាសរណៈនោះមាន ៣ យ៉ាងគឺ អា-ឌិ-ដា (ព្រះអមិតាភៈ) និង ធិច-កា-មោ-នី (ព្រះពុទ្ធ) នឹង រី-អា (ព្រះមៃត្រយ) ៗ នៅក្បែរខាងព្រះទាំង ៣ អង្គនេះមានព្រះ ក្វាង់-អឹម (អវលោកិតេស្វរៈ) មានព្រះហស្ត ១០០០ គង់នៅនឹងព្រះមៃត្រយមានពោះធំ ទ្រង់ញញឹមប៉ប្រ៉ិម ជារូបបែបភាពចិន ដែលចិននាំចូលមកផ្សាយ មានរូបសាវកពីរអង្គតែងមានជារឿយ ១ ដែរ គឺឈ្មោះ វុឆ-ធូ (មញ្ជុស្រី) នឹង ភោ-ហៀន (ព្រះសមន្តភទ្រ)

លោកអគ្គទី១ជិះសិទ្ធ អគ្គទី២ជិះដ៏រ បន្ទាប់តទៅទៀតទេវតា ក្វាង-ឡុង និងទេវធីតា ក្វាង-យិន ។

ប៉ុន្តែនៅជ្រុងម្ខាងដែលមានពួកទេវតាពុទ្ធសាសនាគង់នៅជិតៗគ្នា ហើយនៅផ្នែកខាងមុខបន្ទប់នោះមានពួកទេវតា តាវអ៊ិស្ត គឺ ឡាវ-ក្វាង (តៅ-ស៊ី) យូ-ហ្វាង ជាអ្នកកាន់សបុំបរិសុទ្ធ ង៉ុក-ហ្វាង ជាចក្រវត្តិខាងថ្កៃរ និងមានសេនាបតីពីរនាក់ គឺ ចាកាំ-ជាវ និងឈាំ-តាវ បើមិនបាច់រាប់តាមយសស័ក្ដិអ្នកតាអស់នោះ គឺ អុង-តាវ ជាអ្នកតារក្សាផ្ទះនិង អុង-យូ-រេប ជាអ្នកតារក្សាជើងក្រាន ។ នៅប្រទេសគុងកីង មានប្រពៃណីកាន់សាសនាតែលោក (តាំ-កូ) ឬ ជូ-យី មានពួកទេវតាស្រីជាចំនួនច្រើន ។

ឯលទ្ធិទី៣ជាលទ្ធិរបស់ខុងជឺ ខាងពួកឡេត្រ ដែលរាជការទទួលរាប់លទ្ធិនេះទុកជារបៀបសាសនាដែលពិតប្រាកដរបស់រាជការ និងលទ្ធិការប្រកាន់អារក្សអ្នកតាតាមថ្នាក់តូច-ធំទាំងពួង ។

ក្នុងទីបំផុត គេបានបន្ថែមលទ្ធិគោរពដូនជីតាជាបុព្វបុរសក្នុងលទ្ធិទាំង ៣ នេះ១ទៀតដែលជាលទ្ធិជ្រួតជ្រាបចូលទៅក្នុងចិត្តប្រជាជនយ៉ាងច្រើនបំផុត ហើយមានការគោរពដល់ខ្មោចបិសាច ដល់អ្នកតារក្សាស្រុក អ្នកតារក្សាភ្នំ អ្នកតារក្សាទ្រព្យសម្បត្តិ ដើមឈើសក្ដិសិទ្ធិ (ដើមពោធិ៍) ជុំថ្ម និងមន្តអាគមតាថាផ្សេងៗទៀតជាអនេកប្រការ ។

ការដែលសាសនាប្រឡូកប្រឡំគ្នានេះ ត្រូវតែមានធម៌ក្នុងលទ្ធិនោះៗ ជាទំនាស់ទឹងគ្នាជានិច្ច ក៏នៅតែមិនបំបែកចិត្តគំនិតរបស់ជាតិយួនឲ្យបែកចេញទៅឡើយ គ្រាន់តែជាទំនាស់ទឹងបែបផនដែលមានក្នុងចិត្តគំនិតយួនដែលស្ងប់រៀបរយ ជាទំនាស់ទឹងសេចក្ដីមិនទៀងទាត់ជាប់ស្រេច ជាទំ-នាស់ទឹងការមិនដឹងជាទឹងរើសកាន់ខាងណា ធ្វើឲ្យចិត្តកន្ទុក ជាទំនាស់ការមិនស្គាល់សេជាតិធម៌អកិធម្ម ជាទំនាស់ទឹងការគួរខ្ពើមចំពោះលទ្ធិវិធីគ្រប់យ៉ាង ដែលនាំឲ្យបានសេចក្ដីលំបាកទឹងឥតប្រយោជន៍ ។ ប៉ុន្តែបែរជាលទ្ធិប្រពៃណីអស់នេះនៅរួបរួមជាមួយគ្នាស្រាបប្លូលក្នុងចិត្តគំនិតរបស់យួនទឹងជាប់ជាដំណតគ្នារៀងៗមកដោយងាយស្រួល ហើយប្រព្រឹត្តទៅតាមសេចក្ដីត្រូវការនៃវិញ្ញាណក្ខន្ធរបស់ខ្លួនដែលជារបស់ប្រចាំត្រកូល ឬប្រចាំនៅទឹងកិច្ចសព្វសារពើ ។

ការដែលលទ្ធិសាសនាប្រឡូកប្រឡំរវើកនេះហើយទើបកើតមានលទ្ធិកៅដាយយ៉ាងច្បាស់ទែងឡើង ចាត់ជាការបង្កើតព្រះអង្គទី ៣ ឡើងក្នុងបូព៌ាប្រទេសក្នុងឆ្នាំ ១៩២៦ ( ព.ស. ២៤៦៩ ) ក្នុងវត្តតៃនិញ ក្នុងវិហារដែលដំកល់គ្រឿងសក្ការបូជាមានទាំងលទ្ធិសាសនាខុងជឺ លទ្ធិអារក្សអ្នកតា លទ្ធិសាសនាគ្រិស្ត លទ្ធិតាវអ៊ីស្ត៍ និងពុទ្ធសាសនា ជាទីប្រជុំរួមលទ្ធិសាសនានានាជាច្រើនដូចបញ្ចេញឈ្មោះមកនេះ ។

កាលពី ២-៣ ឆ្នាំមកហើយនោះ មានការកែប្រែ ១ កើតឡើង ដើម្បីទំនុកបំរុងព្រះពុទ្ធសាសនាក្នុងប្រទេសកូសាំងស៊ីនទីងអណ្ណាម នៅក្រោមឥទ្ធិពលនៃពុទ្ធសមាគម ដែលបានតាក់តាំងឡើងនៅក្រុងហ៊្វេទីងព្រៃនគរ ៗ មានលោកសង្ឃយួន ១ ក្រុមដែលមានចំណេះចេះដឹងច្រើន បានចេញផ្សាយលទ្ធិបរិសុទ្ធត្រឹមត្រូវយកក្នុងពួកគណៈសង្ឃទីងក្នុងវ័យក្មេងណាស់ ហើយបានផ្សាយចេញទៅក្នុងស្រុកបានតិចពេក ថែមទាំងគាំទ្រយ៉ាងខ្លាំងពីអ្នកស្រុកផង ហើយមិនចាំយូរទៅទៀត ៗ ឯ ស្រុកខ្មែរ-ស្រុកបរទេសស្រុកតំណៀ ពុទ្ធសាសនិកជនបានជាគ្នាជួយឧបត្ថម្ភសេចក្តីកែប្រែខាងផ្លូវសាសនាតាមទំនងនេះ ដោយយកចិត្តទុកដាក់ណាស់ (ដូចមើលឃើញសព្វថ្ងៃនេះ) ។

ព្រៃនគរ ណូវែមប្រ៍ ១៩៣៩

ដុកទ័រ អង់ជ្រេ-មីកូត៍

(តមក)

## វគ្គទី ៤

# អំពីការទ្រុឌទ្រោមនៃក្រុងអាថែន្ស

ការដែលស្រុកអាថែន្សមានជ័យជំនះសង្គ្រាមដែលកន្លងមកហើយក្ដី ការដែលស្រុកអាថែន្សកសាងឡើងយ៉ាងរហ័សរួសរាន់ក្រោយសង្គ្រាមនោះក្ដី ធ្វើឲ្យស្រុកអាថែន្សចំរើនរុងរឿងឡើងនិងមានអំណាចមាំមួនជាឯកក្នុងចំណោមស្រុកក្រិកដូចគ្នា ប្រទេសក្រិកជិតខាង ដូចជាថែប្ស និងកូរិន្ធ ក៏នឹកព្រួយខ្លាចអាថែន្សរំលោភមកលើខ្លួន ទើបនាំគ្នាទៅរួបរួមជាមេត្រីនឹងស្ប៉ាត ដើម្បីរាំងរាមិនឲ្យអាថែន្សផ្សាយអំណាចចូលមកបាន ៗ តាមទំនងនេះឃើញថាប្រទេសបែកខ្ញែកចេញជា ២ ពួក គឺក្រិក ១ ពួក នៅខាងប៉េលោប៉ូណែសនិងក្រិកកណ្ដាល មានស្រុកស្ប៉ាតជាប្រមុខ ក្រិក ១ ពួក គឺពួកដែលនៅតាមឆ្នេរសមុទ្រនិងតាមកោះក្នុងសមុទ្រអេសេ មានស្រុកអាថែន្សជាប្រមុខ ទាំងពីរពួកនេះមានហេតុដែលនាំឲ្យឈ្លោះទាស់ទែងប្រណាំងប្រជែងគ្នាមាន ៣ ប្រការគឺ ការប្រណាំងប្រជែងដណ្ដើមយកផលប្រយោជន៍ប្រការ ១ ការប្រណាំងប្រជែងដណ្ដើមយកជាតិក្រិកដែលមានសែស្រឡាយតមកពីពួក ដូរីយាង្ស និងពួកក្រិក

ដែលមានសែស្រឡាយតមកពីពួក អ៊ីអូនីយ៉ាន់ ប្រការ ១ ការប្រណាំងប្រជែងគ្នារវាងការត្រួតត្រាស្រុកដោយអំណាចមន្ត្រី និងអំណាចប្រជារាស្ត្រប្រការ ១ ហេតុទាំង ៣ ប្រការនេះជាជួនទាស់ទែងគ្នាយ៉ាងធំ ។

តាំងអំពីខាងចុងបង្ហើយសង្គ្រាមនោះតមកជាវេលា ១៨ ឆ្នាំ ក៏កើតសង្គ្រាមរវាងពួកក្រិកផងគ្នាឡើង ហេតុដែលនាំឲ្យសង្គ្រាមកើតឡើងនេះ ដោយហេតុអាថែនទៅញុះញង់ស្រុកករស៊ីរ៍ ដែលជាចំណុះរបស់ស្រុកកូរិន្ធ៍នោះឲ្យបង្កការចលាចលឡើង កូរិន្ធ៍ជាបក្ខពួករបស់ស្ប៉ាត ហើយស្រុកទាំងពីរនេះទើបក្លាយទៅជាខ្សែជួនសង្គ្រាមឡើង ហៅថា "សង្គ្រាមប៉េលោប៉ូណែស" ច្បាំងគ្នាអស់វេលា ២៧ ឆ្នាំ គឺចាប់ផ្ដើមតាំងអំពី ព.ស. ១១២ ដល់ ព.ស. ១៣៩ (មុន គ.ស. ៤៣១-៤០៤) ។

អំពីចម្បាំងប៉េលោប៉ូណែស — សង្គ្រាមគ្រានេះអាចបែងចែកជា ៣ ភាគ គឺ ភាគទី ១ ពួកស្ប៉ាតចាប់ផ្ដើមលុកលុយពួកអាថែនចូលមកតាមផ្លូវដើរគោកតាមអាណាចក្រអ័ទ្ទិក ។ ចំណែកខាងពួកអាថែនគ្រាន់តែលើកទ័ពទៅតទល់នឹងពួកស្ប៉ាតតាមផ្លូវដើរគោក តែបែរលើកទ័ពដើរទឹកទៅវាយតាមមាត់សមុទ្រប៉េលោប៉ូណែសទៅវិញ ទុកបណ្ដោយឲ្យសង្គ្រាមដើរគោកធ្វើការទៅតាមយថាកម្ម នេះជាគ្រោងការណ៍ចម្បាំងរបស់ពេរីក្លេសដែលត្រូវការឲ្យពួកអាថែនជាម្ចាស់សមុទ្រយ៉ាងខ្ជាប់ខ្ជួន ។

លុះពួកកងទ័ពស្ប៉ាតកាន់តែរុកកួនទ្រនាន់ចូលមក បណ្ដាប្រជាជនអ្នកស្រុកក្រៅក៏នាំគ្នាតស៊ូលមកចូលក្រុងពេញទាំងស្រុកអាថែន បណ្ដាលឲ្យកើតកាល្បរោគ (ឡាប៉េស្ត) ឡើងក្នុងជំរុំពួកនេះមុន ហើយក៏រាលចូលទៅពាសពេញ បានប្រហារជីវិតប្រជាជនអស់ជាច្រើន ហើយខ្លួនប៉េរីក្លេសដែលជាមេដំហរធំរបស់អាថែនក៏ក្សយជីវិតបង់ដោយកាល្បរោគគ្រានេះ (ព. ស. ១១៤ មុន គ. ស. ៤២៩) ។ លុះប៉េរីក្លេសអនិច្ចកម្មទៅហើយ ក្សែរ៍សែរសែក កេមង ជាទាយាទរបស់អាថែនផ្ទួស បុរស [illegible] អ្នកដឹកនាំស្ប៉ាត [illegible] តាមដាប់ពួកទាហានស្ប៉ាតបានចំនួន ៣០០ នាក់តាមមាត់សមុទ្ទទិសខាងលិចរបស់ប៉េលោប៉ូណែស ។ ចំណែកខាងពួកស្ប៉ាតក៏ព្យាយាមប្រឹងកាត់ស្បៀងរបស់ស្រុកអាថែន ទើបចូលវាយចូលទៅស្រុកត្រាសដែលជាស្រុកធ្វើស្រូវសាលីជាស្រុកជម្រកស្រូវរបស់អាថែន ។ មេទ័ពរបស់ស្ប៉ាតម្នាក់ឈ្មោះប្រាជស៊ីដាស វាយបានស្រុកអ៊ែមហ្វីប៉ូលិស ជាខេត្តរបស់ស្រុកត្រាសនោះបាន ទើប ក្លេអុង មេទ័ពអាថែនលើកទ័ពទៅច្បាំងដោយខ្លួនឯង ដើម្បីដណ្ដើមស្រុកនេះយកមកវិញ តែក្នុងទីបំផុត មេទ័ពទាំងពីរគឺ ប្រាជស៊ីដាស នឹង ក្លេអុង ក៏អនិច្ចកម្មទៅទាំងពីរនាក់ ។

(មានត)

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

ឆ្នាំគំរប់ ១៣

ភាគទី ៩

ពុទ្ធសាសនបណ្ឌិត្យ

INSTITUT BOUDDHIQUE

ភ្នំពេញ

ការផ្សាយរបស់ព្រះរាជបណ្ណាល័យ

ព.ស. ២៤៨៤

គ.ស. ១៩៤១

L
៧:០១

ព្រះរាជបណ្ណាល័យកម្ពុជា

# KAMBUJASURIYÂ

# កម្ពុជសុរិយា

ជាទស្សនាវដ្ដីចេញផ្សាយពីព្រះរាជបណ្ណាល័យ មួយខែពីរក្បាល

ឆ្នាំគំរប់ ១៣

ភាគទី ៩

គណៈរដ្ឋមន្ត្រីនិងសម្ដេចសង្ឃនាយកទាំងពីរគណៈ

បានអនុញ្ញាតហើយ

ភ្នំពេញ

ការផ្សាយរបស់ព្រះរាជបណ្ណាល័យ

ព.ស. ២៤៨៤

គ.ស. ១៩៤១

# បញ្ជីរឿង


ទំព័រ

១ — ការស្រង់យកសេចក្តីខ្លះអំពីសៀវភៅនិយាយអំពីអារ្យធម៌របស់ឥណ្ឌា . . . . ៣

២ — សេចក្តីស្រង់អំពីរឿងមួយនិយាយអំពីការសិក្សា ជាសេចក្តីអធិប្បាយដោយសង្ខេបរបស់ គ. ប. ដើម៉ារកៃត្តិ . . . . . . . . . . . . . . . . . . ៨

៣ — អំពីពង្សាវតារក្រិក រួបរួមអំពីគោលចារិកផ្សេងៗ ក្នុងពង្សាវតារលោក (តមក).. ១៤

៤ — ប្រជុំពាក្យកាព្យខ្មែរ ភាគទី ៤ របស់ឃុនស៊ុមនោម័យ (តមកពីទស្សនាវដ្តីលេខ ១២ ឆ្នាំ ១៩៤០) . . . . . . . . . . . . . . . . . . . . ១៧

៥ — អនាមយកថា របស់ខេមរង្សី (តមក) . . . . . . . . . . . . . . . ២២

៦ — រឿងព្រេងខ្មែរ "រឿងអាឡេវទី ២" របស់អ្នកឧកញ៉ាប្រាជ្ញាធិបតី យិន (តមក). . . . . . . . . . . . . . . . . . . . . . . . ២៥


## រូបក្រៅរឿង


សាមនៀ (ប្រទេសលាវ) ភូមិបាឧបិន គ្រួសារត្រកូលក្បាំ . . . . . . . . . ១

# TABLE DES MATIÈRES


Pages.

1° Quelques notes au sujet d'un livre sur l'Inde civilisatrice... 3

2° Extrait d'un article sur l'éducation par G. C. Démarquette.. 8

3° Histoire de la Grèce, extrait de divers documents de l'Histoire Universelle (suite)........................... 14

4° Recueil des poèmes cambodgiens 4e partie par KHUN SIMANOMAY (suite de la revue n° 12 du 1940)............. 17

5° ANAMAYAKATHA par KHÉMARARANSI (suite)................ 22

6° Conte populaire cambodgien inédit :

" Légende de ALÉV II " par Oknha PRACHNHATHIBADEY (YIN) (suite)........................................ 25

HORS TEXTES :

Sam neua (Laos) — la famille du PHYA................ 1



ស.ម.ផើ្យ ច្រិទេសណារ - ភូមិបាងជន គ្រួសាត្រកូលក្បៀ ។

# អារ្យធម៌របស់ឥណ្ឌា

ផែនទីភូមិសាស្ត្ររបស់ប៉្តូលេម៉េ(១) (Ptolémée) កាលពីពុទ្ធសករាជ ៦៩៣ នោះលោកប៉្តូលេម៉េបានអធិប្បាយពីចំណេះវិជ្ជារបស់ឥណ្ឌា កាលសម័យបុរាណនោះថាជាចំណេះខ្ពង់ខ្ពស់ណាស់ ៗ ប៉ុន្តែផែនទីឥណ្ឌា ដែលលោកប៉្តូលេម៉េធ្វើទុកមកនោះធ្វើដោយស្មានៗមិនទាន់ពិតប្រាកដដូច ផែនទីសព្វថ្ងៃនេះទេ តែមានអ្វីៗសព្វគ្រប់ គឺមានសមុទ្រ, ឈូងសមុទ្រ, ទន្លេ, ស្ទឹងព្រែក, ភ្នំ, ប្រជាជន, ព្រំដែន, ទីក្រុងនឹងអ្វីៗទៀតច្រើន ស្មុគស្មាញ ។ យើងអាចនឹងបានឃើញរឿងខ្លះនោះ មានជាប់នៅនឹង ពង្សាវតាររបស់ឥណ្ឌា ហើយមាននៅនឹងអនុស្សាវរីយ៍ ដែលកសាង ឡើងតាមវិជ្ជាការរបស់ក្រិក ។ តាមទំនងនេះ ដោយសារតែសៀវភៅឬ ផែនទីរបស់លោកប៉្តូលេម៉េនេះហើយ ដែលធ្វើឲ្យយើងបានដឹងស្គាល់អារ្យធម៌របស់ហិណ្ឌូនោះ ផ្សាយចេញទៅយ៉ាងធំទូលាយ ហើយចូលមកក្នុង ប្រទេសឥណ្ឌូស៊ីនទាំងបណ្ដាប្រទេសអាំងស៊ុយឡាំងដ៍ (Insulinde) មាត់ សមុទ្រនៃប្រទេសប៉េគូ ជ្រោយប្រទេសមល្លកា តាមមាត់សមុទ្រអស់នេះ

---

(១) ជាអ្នកប្រាជ្ញជាតិក្រិកនៅក្នុងស្រុកអាលេក្សង់ឌ្រិ ជាអ្នកយកចិត្តទុកដាក់នឹងវិទ្យាសាស្ត្រ មានកេរ្តិ៍ឈ្មោះល្បីល្បាញក្នុងប្រទេសអារ៉ាប់ លោកបានរួបរួមចំណេះវិជ្ជាជាន់ចាស់ចំណែកខាង វិជ្ជាហោរាសាស្ត្រ ជាអ្នកចេះដឹងខាងធម៌ វិជ្ជាលេខនព្វន្តនឹងភ្លេង, កាព្យឃ្លោងនឹងវិជ្ជាហ្វ៊ិស៊ិកជាដើម ។ ក្នុងវចនានុក្រមឡារុសនិយាយថា ច្បាប់ដែលរបស់លោកនេះមានច្រើនណាស់ គឺបានតែង វិជ្ជាតារាសាស្ត្រ ប្រវត្តិសាស្ត្រ លេខ, ភូមិសាស្ត្រនឹងវិជ្ជាភ្លេងជាដើម ។

សុទ្ធតែជាទីតាំងផ្លូវជំនួញជាតិហិណ្ឌូ ដូចជាប្រទេសជ្វាក៏មានពួកហិណ្ឌូទៅតាំងនៅដែរ ហើយមន្ទីរជំនួញដែលបានឃើញនៅជាន់ក្រោយៗនោះ តាមសៀវភៅលោកប៉្តូលេម៉េថា មាននៅលើផែនដីចំណែកអស់នេះ ។

ផ្លូវសមុទ្រនោះហើយធ្វើឲ្យជនជាតិផ្សេងៗកាន់តែជិតគ្នាឡើងហើយ កើតមានកំពង់ជំនួញឡើង ដែលមានជំនួញរបស់ជាតិក្រិកតែងចេញចូលរឿយៗ ។ គ្រានោះមានជាតិក្រិកឪពុកនិងកូនឈ្មោះជម្ពូរក្ខិត មានសទ្ធាជ្រះថ្លានិងគណៈសង្ឃក្នុងព្រះពុទ្ធសាសនា ហើយបានកសាងគុហា ១ ចេតិយ ១ និងអណ្ដូងទឹកជាច្រើន ដើម្បីជាគ្រឿងសក្ការបូជាដល់ព្រះពុទ្ធទាំងឡាយ ។ មានជាតិក្រិកម្នាក់ទៀតនោះ បូជាអណ្ដូងទឹកជាច្រើន មានជាតិក្រិកម្នាក់ទៀតកសាងកេងទាន ១ បូជាព្រះដែរ ប៉ុន្តែគុហាទាំងនោះគេប្រដាប់តាក់តែងរចនាជាបែប ១ របស់ក្រិក-ឥណ្ឌូ មិនមែនដូចជាគុហាធម្មជាតិនៅប្រទេសមគធៈនោះឡើយ គឺជាផលនៃសិល្បកម្ម ដូចជានៅការលី សឹងមានក្បាច់ចម្លាក់យ៉ាងល្អៗដូចជានៅព្រះស្តូបអមរាវតី សឹងប្រដាប់ប្រដាដោយគ្រឿងចម្លាក់ផ្សេងៗជាអនេក ។ ផ្លូវនៃសេចក្ដីចំរើនដ៏ធំទូលាយរបស់លោកនោះ បានចត់ចូលទៅកាន់ប្រទេសឥណ្ឌូយ៉ាងជ្រលិះៗ តាំងពីយូរមកហើយ ឥឡូវនេះអារ្យធម៌នោះមិនបានបំបាត់បង់លក្ខណ៍ដើមទៅទេ ប៉ុន្តែប្រទេសជិតខាងក្ដី អ្នកដែលមកដណ្ដើមយក

ទៅក្តី សឹងយកទៅកែប្រែធ្វើឲ្យបានចំរើនល្អឡើងជាចំណែក ១ ដោយឡែក ៗ

តាមដោយពិតនោះ នៅក្នុងសម័យនីមួយៗនោះ តាមពង្សាវតារដ៏វែងឆ្ងាយ ប្រទេសឥណ្ឌាមិនទាន់បានស្គាល់សេចក្ដីចំរើនរុងរឿង និងការរុករកឃើញម៉ឺងម៉ាត់ដូចនៅក្នុងចន្លោះឆ្នាំនៃពុទ្ធសករាជ ៨៤៣ និង ៩៤៣ នោះឡើយ គឺតាំងពីរាជវង្សក្សត្រិយ៍គុប្ត: បានរៀបចំកសាងមហាអាណាចក្រឡើង ហើយចាត់ចែងការពារនិងបណ្ដុះបណ្ដាលវិជ្ជាអក្សរសាស្ត្រនិងរបៀបចេនាឲ្យចំរើនឡើង ៗ បឋមក្សត្រិយ៍នៃរាជវង្សនេះទ្រង់ព្រះនាមចន្ទ្រគុប្ត: ទ្រង់អភិសេកនឹងក្សត្រី ១ អង្គទ្រង់ព្រះនាមកុមារទេវី ជារាជវង្សនៃពួកក្សត្រិយ៍លិច្ឆវី កាលពីសម័យពុទ្ធកាលនោះ ពួកក្សត្រិយ៍អស់នេះបានរៀបចំរាជការដោយសាមគ្គីធម៌ ធ្វើឲ្យក្រុងវេសាលីនេះចំរើនសុខស្ដួតណាស់ ៗ

ព្រះបាទចន្ទ្រគុប្ត:ទ្រង់ឲ្យបោះពុម្ពប្រាក់រៀលដោយមាស ដែលមានរូបទ្រង់នឹងរូបអគ្គមហេសីជាប់នៅនឹងប្រាក់រៀលនោះ ៗ

ប្រហែលក្នុងពុទ្ធសករាជ ១១៤៣ មានគណៈធម្មទូត ១ ក្រុមមកពីស្រុកចិន ដើរធុតង្គទៅប្រទេសឥណ្ឌាដោយចិត្តសទ្ធាជ្រះថ្លា ដើម្បីទៅមើលព្រះវិហារមហាពោធិ ដែលគេបានកសាងឡើងត្រង់ទីកន្លែងដែលព្រះពុទ្ធជាម្ចាស់បានត្រាស់សព្វញ្ញុតញ្ញាណ ហើយបានឃើញវត្តមួយ

នោះមានលោកសង្ឃពីកោះលង្កាមកកាន់កាប់ថែរក្សាយ៉ាន់ម៉ឹនម៉ាត់ ហើយគេបានស៊ើបរកដើមកំណើតដែលបានកសាងវត្តនេះឡើង បានទទួលពាក្យតបដូច្នេះ "កាលពីដើមនោះ មហាក្សត្រិយ៍ប្រទេសស៊ីឡង់ ទ្រង់ព្រះនាមព្រះស្រីមេឃវណ៌ ជាស្ដេចជាតិតេណ្ឌ ទ្រង់ចាត់បញ្ជូនលោកសង្ឃពីររូបឲ្យទៅមើលវត្តដែលព្រះបាទអសោកទ្រង់កសាងឡើងជិតដើមពោ-ធិព្រឹក្សដែលព្រះពុទ្ធបានត្រាស់ដឹងនោះ វិហារធំហៅថា មហាធាម័ន វិហារ ១ ទៀតហៅថា ឧបសេន លោកពីររូបនេះចូលទៅនមស្សការបល្ល័ង្កពេជ្រក្រោមដើមពោធិព្រឹក្ស ប៉ុន្តែវិហារនោះសំណាក់ពុំបាន ។ លោកពីររូបត្រឡប់មកស្រុកកំណើតរបស់ខ្លួនវិញ ទើបស្ដេចមានព្រះរាជ-ឱង្ការសួរថា លោកទាំងពីររូបទៅនមស្សការដល់ទីបូជនីយស្ថាន បានឮគេនិយាយអ្វីជាមង្គលដល់លោកខ្លះដែរឬទេ? លោកទាំងពីររូបក៏ថ្វាយព្រះពរតបថា នៅស្រុកធំៗនៃជម្ពូទ្វីបនេះ មិនមានប្រទេសណាតាំងនៅក្នុងសន្តិភាពឡើយ ។ ស្ដេចទ្រង់ព្រះសណ្ដាប់សំដីអស់នេះហើយ ទើបទ្រង់ចាត់មនុស្សជារាជបម្រើ ឲ្យនាំយកពេជ្រនិលចិន្តាទៅថ្វាយស្ដេចគុប្ត: ជាគ្រឿងកជបណ្ណាការ ។ ដោយហេតុដូចពោលមកនេះហើយ បានជាមានលោកសង្ឃពីលង្កាទ្វីបទៅគង់នៅប្រចាំក្នុងវិហារនេះ ។

ដែនដីពោធិគយាជាទីដែលមានសិលាចារឹក ២ អន្ទើ ដែលគេបានកសាងទុកជាទីរឭកដល់មហាធាម័ន មានកំណើតដើមនៅលង្កា ។ តាម

ប្រវត្តិសាស្ត្រលង្កានិយាយថា  កាលពីពុទ្ធសករាជ ៩៤៣ រហូតដល់ពុទ្ធសករាជ ២៣៤៣ មានបេញឈ្មោះស្តេច គីតិស្រីមេឃវណ្ណ ដែលទ្រង់សោយរាជ្យ (ក្នុងរវាងពុទ្ធសករាជ ៨៤៧ ទឹង ៨៧៥) ក្សត្រិយ៍អង្គនេះជាស្តេចដែលទ្រង់ជ្រះថ្លាទឹងព្រះពុទ្ធសាសនាណាស់  ក្នុងរាជ្យរបស់ទ្រង់នេះហើយដែលបានព្រះសារីរិកធាតុ  គឺព្រះទន្តធាតុរបស់ព្រះពុទ្ធជាម្ចាស់ដែលគេនាំចូលមកស្រុកសិង្ហល នាំចេញមកពីស្រុកកាលិង្គៈ នៅស្រុកនោះគេតាំងឈ្មោះក្រុង ១ ហៅថា ទន្តបុរៈ (ដើម្បីជាកិត្តិយសដល់ព្រះសារីរិកធាតុនេះ) ។  ហេតុដែលបានព្រះទន្តធាតុមកលង្កាទ្វីបនេះដោយមានក្សត្រីប្រទេសកាលិង្គៈ១អង្គ  បានលបលួចយកព្រះទន្តធាតុនោះដាក់ក្នុងផ្នួងសក់ (មកថ្វាយស្តេចលង្កា) ។ ស្តេចមេឃវណ្ណ ធ្វើពិធីទទួលព្រះទន្តធាតុជាឧឡារិក  ហើយហែហមយ៉ាងអឹកធឹកទៅដំកល់ទុកនៅវិហារដែលរៀបចំទុកដោយឡែក ។ មហាក្សត្រិយ៍អង្គនេះ ទ្រង់តែងកាព្យ ១ ជាភាសាលង្កា ដើម្បីជាកិត្តិយស ហៅថា ទលទាវង្ស ឬប្រវត្តិព្រះទន្តធាតុ ។

(នៅមានត).

# អំពីការសិក្សាស្វែងរកសន្តិភាព ជាសេចក្តីអធិប្បាយ
# ដោយសង្ខេបរបស់លោក គ. ប. ដេម៉អកៃត្តិ

ច្បាប់បុកណាដែលប្រកបដោយហេតុផលដ៏ត្រឹមត្រូវនោះ តែងប្រកាន់ថា កំណើតនៃធម្មជាតិឬអាការណានីមួយ កាលបើមានឫសគល់ជាគោលធំៗមកផ្គុំប្រជុំគ្នាហើយ រមែងកើតមានសេចក្តីចំរើនឡើង ៗ ឯអារ្យធម៌នឹងឋិតថេរនៅបានក៏តោងអាស្រ័យកំឡាំងកម្មជាបច្ច័យ ឯជ័យជំនះដ៏ទៀងទាត់នោះ កើតឡើងដោយកំឡាំងការបង្ហាប់ដ៏មានរបៀបបែបផែន ការមានមេត្រីចិត្តនឹងសាមគ្គីធម៌ក្នុងរវាងមនុស្សម្នាក់ៗនឹងមនុស្សទូទៅ ៗ ឯហេតុនៃការប្រេះឆា បាក់បែក ខូចខាតអន្តរាយអស់នេះកើតឡើងដោយអំណាចនៃអត្តទិដ្ឋិ (យល់តែប្រយោជន៍ខ្លួន) ទើបកើតបែកខ្ញែកបែកជាក្រុមជាពួកតែដោយខ្លួនៗទៅ ៗ ការប្រឹងប្រែងទប់ទល់នឹងជ័យជំនះក្នុងការបរិច្ចាគក្នុងសាមគ្គីធម៌នឹងមេត្រីចិត្តនឹងតាំងនៅបាន លុះត្រាតែលះបង់លទ្ធិប្រកាន់ពួក អត្តទិដ្ឋិនឹងសេចក្តីព្យាបាទចេញ ដែលជាហេតុធ្វើសេចក្តីបរិសុទ្ធិល្អនោះឲ្យប្រែត្រឡប់ទៅជារូបរួមគ្នាខាងផ្លូវអាក្រក់វិញ ដែលពោលតាមបែបអ្នកប្រាជ្ញ (ជំនាន់ថ្មី) ថា ជយោ ពិជ័យសង្គ្រាម (បានដល់ការច្បាំងរាំងដល់) ។

- ការពង្រីកអាណាចក្រដោយចម្បាំងជារបស់ប្រកបដោយកិត្តិយសដ៏ខ្ពង់ខ្ពស់ នេះជាទំនៀមរបស់មនុស្សជាតិ ហើយជាហេតុធ្វើឲ្យមនុស្សស្លូតត្រង់មានសីលធម៌ល្អកើតគំនិតគិតចង់ធ្វើជានាយកលើអ្នកដទៃ ពង្រីកអំណាចក្អេងក្អាងដូចជាលោកឆិត្ល័រ លោក រុស្សូវែលត៍ និងលោកហ្ស៊ីង់ឡ្យាហារ ។ ទុកជាមានសេចក្តីព្យាយាមយ៉ាងម៉ឺងម៉ាត់ក្នុងការប្រើគំនិតទំនងនេះក៏ដោយ ក៏កម្រនឹងមានជ័យជំនះលើមនុស្សសម័យបុរាណបានលុះត្រាតែកាលណាយើងព្យាយាមកំចាត់នូវអត្តទិដ្ឋិ, និស្ស័យខ្ជិលច្រអូសនិងនិស្ស័យគ្រោតគ្រាតទាំងពួងចេញបាន ហើយយើងអាចកាន់យកនូវសន្តិភាពនិងយុត្តិធម៌ក្នុងលោកនេះបាន ។

ជិត ២.០០០ឆ្នាំមកហើយដែលព្រះយេស៊ូបានរំឭកយើងថា កិច្ចការនានាទាំងពួងនៅខាងមុខ ត្រូវតែខ្លួនយើងទទួលយកបំណោចរបស់កម្មណាមួយដែលខ្លួនបានធ្វើដោយខ្លួនឯង (គឺថា ចូរអ្នកធ្វើការដល់អ្នកដទៃចំពោះការណាដែលអ្នកចង់ឲ្យគេធ្វើដល់ខ្លួនអ្នក) ។ ពាក្យនេះជាទុកទមួយយ៉ាងធំដែរ ដែលគួរនាំយកមកប្រើក្នុងការលុបលាងហេតុវិវាទទាស់ទែងគ្នានឹងសង្គ្រាមផ្សេងៗបាន ។ ដម្បូន្មាននេះទុកជាច្បាប់សម្រាប់មនុស្សម្នាក់ៗឬជាតិនីមួយៗ លែងប្រព្រឹត្តបទអាក្រក់ លែងជេរប្រទេចផ្តាសាអ្នកដទៃ

ដែលមានសេចក្ដីសុខក្សេមក្សាន្តមានសន្តិភាព សឹងគ្រប់ៗជាតិត្រូវការប្រាថ្នា តែឥតបានធ្វើការអ្វីឲ្យបានសន្តិភាពនោះសោះ ។

មិនមែនដោយការបង្កើនគ្រឿងអាវុធយុទ្ធភណ្ឌស្អុកស្អះនោះទេ ដែលនាំយកមកប្រើជាបែបសន្តិភាពនេះៗ សូម្បីការជួយជ្រោមជ្រែងហ្នឹង: ដែលនៅទន់ទាប នឹងប្រើត្រឹមយុត្តិធម៌ម្យ៉ាងពុំបានទេ តោងមានមេត្រីចិត្តប្រកបផង សូម្បីតែហេតុដោយហោចទៅនឹងប្រើត្រឹមសេចក្ដីយុត្តិធម៌ក៏ពុំល្មមគ្រប់គ្រាន់ដែរ ។ ប្រសិនបើនានាជាតិនៅតែមានសង្គ្រាមទៅលើកកងទ័ពដែលមានអាវុធយុទ្ធភណ្ឌយ៉ាងសំបើមដូច្នោះ ជាតិអស់នោះនឹងមិនផុតពីសេចក្ដីក្ដៅក្រហាយដែលចងរួបរឹតខ្លួនឯងឡើយ ។ រឿងនេះត្រូវតែអ្នកប្រាជ្ញជាស់ៗរាល់គ្នារិះរកវិធីកែប្រែសេចក្ដីប្រព្រឹត្តិរបស់សាកលពិភពលោកនេះជាថ្មី ដើម្បីដំកល់ទុកនូវយុត្តិធម៌នឹងបង្កើតឲ្យមានរបៀបល្អឡើង នឹងរៀបចំឲ្យជាទីគាប់ចិត្តទូទៅ ។

តាមដោយពិត លទ្ធិដែលនិយាយពីចិត្តវិជ្ជាតែងសំដែងថា បណ្ដាហេតុកេទផ្សេងៗក្នុងលោកនេះ សុទ្ធតែកើតមកពីជីវិតិន្ទ្រិយខាងក្នុងនឹងនិស្ស័យសន្ដានខាងក្នុងចិត្តនៃមនុស្សទាំងឡាយទូទៅ ហេតុនេះបានជាពោលថា គ្រឿងប្រតិសីលធម៌នឹងចិត្តវិជ្ជា រមែងមានអានុភាពជាប់នៅក្នុងផ្ទៃនៃពង្សាវតារ (នានាជាតិ) ជាដរាបមក ។ ហេតុនេះបានជាបាក់ង-

សែសនឹងអង់គ្លេសកាលពីឆ្នាំ ១៩១៤ នគរទាំងពីរដែលមានដំឡៃនៃសីល-ធម៌នឹងចិត្តថ្លានៅលើប្រទេសអាល្លឺម៉ាញ ទើបមានជ័យជំនះដែលមិនគួរឈ្នះ នៅទ្រខ្មាំង ។

ហេតុនេះ ប្រសិនបើយើងប្រាថ្នាសន្តិភាព ត្រូវតែគិតកសាងសមា-គមសម្រាប់មនុស្សដ៏សមរម្យ ហើយការសន្សំអប់រំកម្លាំងសីលធម៌នឹងវិធីប្រតិបត្តិខាងផ្លូវចិត្តឡើង ។ កងទ័ពប៉ែកខាងចិត្តវិញ្ញាណនេះនាំឲ្យចំរើនសុខសន្តិភាពឡើងរាល់ៗថ្ងៃ ហើយសន្តិភាពនេះមានអំណាចតាំងនៅឋិតថេរថេរកាល តាំងនៅលើដីរឹងប៉ឹងបំផុត ។ ជ័យជំនះអស់នេះជាជ័យជំនះយ៉ាងជាប់ស្រេចរបស់សីលធម៌នឹងមេត្តាចិត្តរបស់មនុស្ស ទើបអាចកំចាត់បង់នូវអត្តទិដ្ឋិចេញបាន តែគោងនាំយកមកប្រើក្នុងវង្សត្រកូលរហូតដល់សាលាបង្រៀន ។ ឥឡូវនេះ នៅមិនទាន់មានសំណាក់សិក្សាសីលធម៌ទូទៅនៅឡើយ បើចាត់ឲ្យមានការសិក្សាតាមទំនងនេះដល់នា-នាជាតិទូទៅ សេចក្តីចំរើននឹងកើតឡើងជាប្រាកដមិនខាន ប្រសើរជាងវិធីរបស់អត្តទិដ្ឋិដែលដំកល់នៅលើជើងក្តានោះឯង ក្នុងសម័យឥឡូវ ដំឡៃនៃសីលធម៌លេតខ្សត់ខ្សោយអស់ទៅ នាំឲ្យអស់សង្ឃឹមក្នុងផ្លូវសន្តិភាពព្រមទាំងវឌ្ឍនធម៌ បើទុកជាចំប្រឹងប្រែងស្វែងរកដោយសតិបញ្ញាយ៉ាងល្អិតសុខុមយ៉ាងណា ក៏នៅតែកម្រនឹងធ្វើឲ្យកើតចំរើនឡើងបាន ។

ប្រសិនបើមានគ្រោងការបង្រៀនប្រទេសផ្សេងៗឲ្យទទួលប្រតិ-បត្តិតាមវិធីការនេះ ដែលជាវិធីការមួយដែលអាចដឹកនាំនានាប្រទេសឲ្យមានសន្តិភាពដ៏រឹងប៉ឹងតាំងនៅក្នុងដួងចិត្តរបស់ប្រជាជនតទៅខាងមុខ ដ្បិតជ្រាបចូលទៅក្នុងសតិសម្បជញ្ញៈ ក្នុងករណីយកិច្ចនានា ក្នុងសមាគមសុទ្ធតែមានសីលធម៌ល្អទាំងអស់ ទើបមនុស្សជាតិសព្វថ្ងៃនេះដកខ្លួនថយចេញចាកអន្តរាយដែលមាននៅសព្វថ្ងៃនេះបាន ។

យើងត្រូវតែដាស់ចិត្តគំនិតរបស់យើងឲ្យរឭកនឹកដល់ករណីយកិច្ចផ្សេងៗដែលជាប់ទាក់ទងទៅនឹងអ្នកដទៃ ហើយពិចារណារិះរកហេតុផលដែលនាំឲ្យទាស់ទែងខ្វែងគំនិតគ្នា ។ អារ្យធម៌ដ៏ពិតប្រាកដនោះជារបស់មានដំឡៃថ្លៃថ្នូរល្អណាស់ បើប្រែត្រឡប់ជាឥតថ្លៃទៅវិញ ក៏រមែងក្លាយទៅជាច្បាប់ព្រៃមួយយ៉ាងធំតែម្តង ។

តាមធម្មតា យុត្តិធម៌របស់មនុស្សទឹងដុះឡើងក្នុងដួងចិត្តរបស់មនុស្សនេះលុះតែចិត្តវិជ្ជាមានអានុភាពផ្សាយពន្លឺរស្មីឡើងព្រោងព្រាត ទើបឃ្លាតចេញពីសត្រូវធំទាំងពីរគឺ ៖ មិច្ឆាទិដ្ឋិ (លទ្ធិមិនជឿស្ថានសួគ៌-នរក)១ អត្តទិដ្ឋិ (លទ្ធិយល់តែប្រយោជន៍ខ្លួន-ពួកខ្លួន-ជាតិខ្លួន) ១ ។ ដោយហេតុសេចក្តីខ្វាក់វង្វេងរបស់លទ្ធិម៉ាតេរីយាលិស្ម៍ ទើបធ្វើឲ្យបាត់មេត្តាចិត្តតាមផ្លូវចិត្តវិជ្ជារបស់បណ្តាសត្វដែលមានជីវិតនៅក្នុងលោកនេះ ក្រុមក្នុង

ចិត្តវិជ្ជានេះ បើបានរៀបចំចាត់បង្កើតឲ្យមានរបៀបមាំមួនហើយ នឹងនាំមកនូវសេចក្ដីសុខ-ចំរើន-សេចក្ដីស្និទ្ធស្នេហា នឹងសតិបញ្ញា ព្រមទាំងសីល-ធម៌ដ៏ល្អផង ។

កាលបើបណ្ដុះចិត្តវិជ្ជានឹងសីលធម៌ក្នុងគំនិតរបស់ប្រជាជនខ្លួនទៅដូចពោលមកនេះ នឹងនាំមកនូវសន្តិភាពក្នុងលោក ព្រមទាំងយុត្តិធម៌ដ៏ទៀងទាត់ជាប់ស្រេចផងមិនខាន ។

# ពង្សាវតារក្រិក

(តមក)

លុះដល់មកក្នុង ព. ស. ១២២ ពួកអាថែនទ្រទឹងស្ប៉ាតក៏នាំគ្នាធ្វើសញ្ញាស្ងប់សឹកសង្គ្រាមដោយព្រមព្រៀងគ្នាថា ត្រូវទាំងពីរខាងប្រគល់ទឹកដីដែលខ្លួនវាយបាននោះទៅម្ចាស់ដើមរៀងខ្លួនវិញ ទើបមើលឃើញថា សង្គ្រាមគ្រានេះមិនមានខាងណាចាញ់ខាងណាឈ្នះទេ ប្រហែលការល្បងថ្វីដៃគ្នាមើលប៉ុណ្ណោះអស់វេលា ១០ ឆ្នាំ ។

ក្នុងភាគទី ២ នេះ និយាយពីបុរសម្នាក់ឈ្មោះ អ័លស៊ីប៊ីយ៉ាដ៍ ជាក្មួយរបស់ប៉េរីក្លេស ជាអ្នកមានរូបឆោមល្អនិងមានទ្រព្យធនស្តុកស្តម្ភរបស់ក្រិកក្នុងគ្រានោះ ថែមទាំងជាអ្នកឈ្លៀវឆ្លាតប៉ិននិយាយផង ទើបធ្វើឲ្យប្រជាជនដែលល្ងង់ខ្លៅស្រឡាញ់ពេញចិត្តជាច្រើន ៗ បុរសនេះគិតការធំហួសពេក និយាយពន្យល់ដឹកនាំប្រជាជនអាថែនទ្រឲ្យជឿស៊ប់ថា ប្រសិនបើលើកទ័ពទៅវាយពួកដូរិយ៉ង់នៅកោះស៊ីស៊ីលបាន ទើបអាថែនទ្រមានអំណាចតាមផ្លូវសមុទ្របានគ្រប់ភាគ ស្រុកស្ប៉ាតនោះក៏ហាក់ដូចពងមាន់នៅក្នុងកណ្ដាប់ដៃ ។ យើងបានដឹងហើយថា មនុស្សដែលមានអំណាចជាងគេ គឺមនុស្សដែលនិយាយពូកែជាងគេ ហេតុនេះបានជាប្រជាជនអាថែនទ្រប្រគល់ឲ្យអ័លស៊ីប៊ីយ៉ាដ៍ជាមេទ័ពធំនាំទូកចម្បាំង ១៣៤ ទឹងទាហាន ១០.០០០ នាក់ ទៅធ្វើការតាមដែលគិតទុកនោះ

ដោយជឿថាមុខជាបានសម្រេចជាពិតប្រាកដមិនខាន ។ អ័លស៊ីប៊ីយ៉ាដ៍ចេញទៅមិនទាន់យូរប៉ុន្មាន ស្រាប់តែត្រូវគេចោទថាជាអ្នកមើលងាយទេវរូបដែលជាទីគោរពដែលជាកំហុសយ៉ាងធំមួយក្នុងគ្រានោះ ក៏នឹកខ្លាចពួកអាថែនចាប់ខ្លួនទៅប្រហារជីវិត ទើបភៀសទៅនៅជាមួយនឹងពួកស្ប៉ាត ៗ និស្សាសជាបក្ខពួករបស់អ័លស៊ីប៊ីយ៉ាដ៍ ទទួលធ្វើការនាំទ័ពចេញទៅច្បាំងតាមគ្រោងការនោះ តែត្រូវពួកស្ប៉ាតកាយខ្ជួចខ្ជី ទុកចម្បាំងក៏វិនាសហិនហោចអស់ទៅ ពួកទាហានត្រូវចាប់សម្លាប់នឹងត្រូវជាឈ្លើយសឹកស្ទើរតែមិនមានសល់ត្រឡប់មកអាថែនម្នាក់ នេះហាក់ជាការបរាជ័យគ្រាដំបូងរបស់ពួកអាថែន ហើយជាបរាជ័យដែលនាំមកនូវសេចក្ដីវិនាសដល់ស្រុកអាថែនទាំងមូលផង ។

ក្នុងភាគទី៣ ពួកស្ប៉ាតបានបបួលដឹកនាំពួកស្រុកដែលនិយមវិធីគ្រប់គ្រងដោយមន្ត្រីនោះមកចូលរួមជាមួយគ្នាផង ហើយខណៈនេះពួកស្ប៉ាតដឹងខ្លួនច្បាស់ថា ការដែលនឹងប្រាបប្រាមស្រុកអាថែនឲ្យបានសម្រេចនោះលុះតែខ្លួនមានកងទ័ពជើងទឹកពូកែផង តាមគំនិតនេះហើយ ទើបពួកស្ប៉ាតខំកសាងកងទ័ពជើងទឹកឲ្យមានកំឡាំងមុឹងម៉ាត់ឡើង ហើយកងទ័ពជើងទឹកទាំងពីរខាង ក៏បានច្បាំងតទល់គ្នាយ៉ាងធំសំបើម នៅទិសខាងកើតឆៀងខាងជើងនៃសមុទ្រអេសេ ។ ការដែលពួកស្ប៉ាតខំប្រឹងលើកទ័ពជើងទឹកមកដល់ទីនោះ ដោយបំណងនឹងកាត់ផ្លូវបញ្ជូនស្បៀង

ដែលពួកអាថែនបានទទួលពីស្រុកត្រាស៍ ព្រោះការណ៍នេះ ស្ប៉ាត បានចាប់ផ្ដើមកកាំងពីផ្ដើមច្បាំងគ្នា ។ ក្នុងខណៈនោះ ពួកប៉ែរ្សដែល ចងចិត្តអាឃាតនឹងស្រុកអាថែនតាំងអំពីដើមស្រាប់នោះ ក៏វិលមកចង ស្ពានមេត្រីនឹងពួកស្ប៉ាត បានឲ្យប្រាក់កាសជួយក្នុងចម្បាំងរបស់ ស្ប៉ាត ។ មេទ័ពស្ប៉ាតម្នាក់ឈ្មោះ លីសង់ដ្រ៍ បានចាត់ការវាយទំ-លាយកងទ័ពអាថែនបែកបានហើយក៏ព័ទ្ធស្រុកអាថែន នៅទីបំផុត ស្រុកអាថែនមានអន្តរាយដល់ទៅ ២ ផ្លូវ គឺខាងក្រៅស្រុក សឹកសត្រូវ ព័ទ្ធបាន ខាងក្នុងស្រុកកើតទុរ្ភិក្សអត់បាយ ហើយពួកនាហ្មឺនមន្ត្រីក៏នាំគ្នា ក្បត់នឹងស្រុកទេសរបស់ខ្លួនផង ទើបដល់នូវការបរាជ័យយ៉ាងធំក្រៃ លែង ។ សង្គ្រាមគ្រានេះបានផុតចប់ក្នុង ព.ស. ១៣៩ (មុន គ.ស. ៤០៤) ។ ផលនៃសឹកសង្គ្រាមគ្រានេះ អាថែនត្រូវប្រគល់ស្រុកចំណុះ របស់ខ្លួនឲ្យស្ប៉ាតជាចំនួនច្រើន ហើយអំណាចរបស់អាថែនក៏ផុតរលត់ ដោយប្រការដូច្នេះឯង ។

សង្គ្រាមគ្រានេះ បានធ្វើដោយអាការសាហាវជាបំផុត តាំងពីចាប់ ផ្ដើមច្បាំងគ្នា ពួកស្ប៉ាតចាប់ឈ្លើយបាន ក៏ប្រហារកសម្លាប់ឥតមេត្តាប្រ-ណី លីសង់ដ្រ៍មេទ័ពស្ប៉ាតក្រោយនេះបានបង្គាប់ឲ្យទាហានខ្លួនប្រហារ កពួកទាហានអាថែនដល់ទៅ ៣០០០ នាក់ ឥតមានញញើតរើបន្តិច ឡើយ ។ ពួកស្ប៉ាតដែលជាអ្នកមាននិស្ស័យសន្តានមោះមុតឃោរឃៅ

(មានត)

# ប្រជុំពាក្យកាព្យ

## ភាគទី ៤

*របស់ឃុនស៊ុមនោម័យ*

(មាឧត)

ក្តីស្នេហ៍នេះនឹងប្រៀបឧបមា
បីដូចមច្ឆាពឹងសាគរ
បើទឹកត្រជាក់ស្ម័គ្រស្មោះសរ
ទឹកគខល់ផុតរលត់ជន្ម ៗ

បើទឹកនោះក្តៅពុំត្រជាក់
សត្វដែលសំណាក់កើតទុក្ខធ្ងន់
មិនមានសប្បាយកាយទោរទន់
ស្រពោនស្រពន់គ្រប់វេលា ៗ

សេចក្តីសំរើបមិនដែលស្រស់
បេះតែក្រៀមក្រស់ក្រំគ្រប់គ្រា
ឬបកក្រ្តីហាក់បានក្សាន្តទយា
នេះថែមវេទនាជាចិរន្ត្រយ ៗ

ប្រាសប្រាណដេកទៅតែឯកា
ឈោងចាប់ក្រមាយកមកហើយ
ឈាតឈាដណ្តប់ទុក្ខគ្រាន់ស្បើយ
ក្លិនស្រីនៅឡើយចងចាំបាន ៗ

មិនមានប្រែប្រួលចំឡែកសោះ
ចំពោះជាក្លិនកែវកល្យាណ

ថើបហើយស្បើយទុក្ខពីក្នុងប្រាណ
ចាប់បានផ្ទៃចាន់កាន់ថើបទៀត ។
ក្បៀនកំងតាំងទុក្ខថែមជាថ្មី
ទឹកថ្លៃទ្រងរែងរឹងបង្អៀត
ទុក្ខមួយដែលបងខំឈ្លបឆ្មៀត
មានទៀតឲ្យថ្លៃឈឺចិត្តផ្សា ។
កែវអើយខ្លួនបងពេញហៅខុស
ដោយសារជាប្រុសលោភតណ្ហា
ត្រង់ណោះនេះតាមតែ មគ្គា
ទោសានុទោសប្រណីអើយ ។
អក្ខកធោមយង់អង្គអគ្គរេត
ក្រែងកាយក្លាយភេទក្នុងចិន្តា
កាលដើមថាស៊ីប្បូរដីក៏
ទឹកថាស៊ីស្លាប់ដូចអទ្រិន្ទ្រ ។
មិនខ្លាចទៅក្រុងចមយក្សា
នេះពេញហៅថាក្លាចិត្តមុត
ខ្លួនយើងៗប្រៀបដូចអទ្រិន្ទ្រ
ខ្លួនប្អូនវិសុទ្ធដូចនុសា ។

ស្រឡាញ់ប្រាកដដូចពាក្យស្តី
មិនប្រែចិត្តខ្វីដូចកន្យា
ទឹងទៀងប្រាកដដូចសញ្ញា
ទឹកថាមិនឲ្យកេរ្តិ៍អប្រិយ៍ ៗ

ខ្លួនយើងជាប្រុសមែនពិតហើយ
កែវអើយតែចិត្តដូចក្រើ
មិនឲ្យមានពីរទេប្អូនស្រី
សេចក្តីដូចប្អូនផ្តាំបងថា ៗ

ឲ្យខំរក្សាសីលសត្យញាណ
កុំមានសេចក្តីទឹកបេក្ខា
យើងសោកយើងចាំដូចសញ្ញា
កនិដ្ឋាបែរចិត្តពុំទៀងត្រង់ ៗ

ទុះទុព្រះសុរិយាអស្តង្គត
ទៀបផុតបាំងជ្រុងសុមេរ
បំព្រានស្មើនៅក្ដីថ្វា
សព្វសត្វសកុណាវិលទ្រនំ ៗ

ត្រឡប់ងងឹតសព្វទិសទី
ទៀបទ្ហួងកោរ៍ព្រលប់ធំ

សកុណាពាកព្រៃវិលទ្រនំ
ភមរាពាកបង់ក្រេបកេសរ ៗ
    ចតុប្បាទទ្វេបាទពាកកល់បឹង
ភមរទ្រហឹងសំឡេងខ្ចរ
តម្រេកត្រេកត្រិះហើយសាទរ
សត្វាត្រេកអរគួរសប្បាយ ៗ
    តាកព្រោងប្រុះច្រុះហោស៍
អស់ទាំងមនុស្សម្នាសុខក្នុងកាយ
ឃ្លាតគូបគូមិនមានខ្វាយ
តែប្រាណឯកាយឯកោនៅ ៗ
    កំព្រាវេទនាសែនរំខាន
ហើយថែមទាំងមានសេចក្ដីក្ដៅ
ម៉ោងមួយរៀមព្រួយនឹកដល់ពៅ
ឱថ្ងៃនេះនៅឬទៅណា ៗ
    ឬមួយប្អូននៅក្នុងដំណេក
ទល់ទុក្ខវិវេកឧបេក្ខា
នឹករៀមឬស្ងៀមឬបោរ
ឬមាននរណានាំនិយាយ ៗ

(មានតទៅទៀត)

អនាម័យគាថា

១. ស.

ដោយអ្នកប្រែនិងរៀបរៀង

(តមក)

# អំពីយុទ្ធវិធីរបស់រាងកាយ

កាលបើមានមេរោគចូលមកកាន់រាងកាយយើងៗ បានតាំងការតស៊ូ ទប់ទល់ដោយវិធីដូច្នេះ :

១) ធ្វើកំដៅឲ្យកើតឡើងក្នុងរាងកាយ ដែលយើងហៅថា គ្រុន មាន អាការធ្ងន់-ស្រាល ស្រេចតែមេរោគនោះសាហាវឬមិនសាហាវ ។ កំដៅ នេះមានប្រយោជន៍សម្រាប់សម្លាប់មេរោគ ឬធ្វើឲ្យខ្សោយថយកំឡាំង ចុះទៅ ព្រោះមេរោគផ្សេងៗដែលចូលមកប្រទូសរ៉ាយក្នុងរាងកាយយើង រមែងមានអំណាចច្រើនក្នុងវេលាដែលរាងកាយយើងមានកំដៅអ៊ុនៗ តាម ធម្មតា ប្រសិនបើកំដៅនេះក្តៅហួសកំរិតនេះហើយមេរោគនោះក៏ទ្រាំកំដៅ មិនបាន រមែងដល់នូវសេចក្តីវិនាសទៅ មានខ្ទង់ដូចជាយើងតាំងកាំ-ភ្លើងធំសម្រាប់បាញ់យន្តហោះដែលហោះមកទម្លាក់គ្រាប់បែកតាមផ្លូវអា-កាស ហើយបង្កប់គ្រាប់បែក (មីន) ក្នុងទឹក ដើម្បីបង្ការកប៉ាល់ចម្បាំង របស់សត្រូវដឹកជញ្ជូនអាហារមកឡើងគោកបាន ឬផ្លូវដើរទ័ពរបស់សត្រូវ គ្រប់ច្រក ហើយតាំងកាំភ្លើងធំប្រចាំប៉មសំខាន់ៗ ជាដើម នេះជាការប្រុង

ត្រៀមខ្លួនរបស់រាងកាយយើងក្នុងថ្នាក់ដំបូង ហេតុនេះ បានជារោគដោយច្រើន មានអាការក្តៅជាដំបូង ហើយអាការឯទៀតៗកើតឡើងជាលំដាប់ បើកំដៅនេះមិនហួសពីកំរិត ៤០ ឬមានកំដៅល្មមខ្លួនយើងទ្រាំទ្របាន យើងក៏មិនបាច់ប្រើថ្នាំអ្វីមួយទេ ទុកឲ្យកំដៅនោះថយចុះមកឯងតាមធម្មតា វៀរលែងតែពិនិត្យឃើញថាខានប្រើថ្នាំពុំបាន ដូចជាជម្ងឺដេកមិនលក់ ទៅជាមមើមមាយខុសប្រក្រតី ។ល។ កំដៅមានប្រយោជន៍ច្រើនដល់រាងកាយក្នុងការតស៊ូទឹងមេរោគ ឬមេជម្ងឺ ។

២) កេណ្ឌទាហានឲ្យចូលប្រចាំក្រុមកងសំរាប់ធ្វើការតទល់នឹងពួកសត្រូវ គឺតួលោហិតស ក្នុងលោហិតស ១ ដំណក់ មានតួលោហិតក្រហមប្រមាណ ៤ លានតួ ឯតួលោហិតសនេះមានប្រមាណ ៨ ពាន់តួ មានច្រើនយ៉ាងច្រើនពួក មានមុខក្រសួងផ្សេងៗគ្នា មានទាហានថ្មើជើងប្រមាណ ៧០ % ក្រៅពីនេះជាទាហានកាំភ្លើងធំ ទាហានសេះ ទា-ហានជាងជាដើម ។ ឯពួកលោហិតក្រហមនោះ មានមុខក្រសួងដឹកជញ្ជូនស្បៀងអាហារជាកំឡាំងក្នុងចម្បាំង កាលបើកើតសឹកសង្គ្រាមដល់ខ្លួនយើងឡើងហើយ តួលោហិតសក៏កើតឡើងច្រើនណាស់ដែរ ក្នុងលោ-ហិតមួយដំណក់ អាចមានតួលោហិតសទាំងហ្មឺនទាំងសែន. គឺថារាងកាយយើងកេណ្ឌទាហានបន្ថែម ពួកដែលបម្រុងទុកទាំងប៉ុន្មានក៏ហៅប្រជុំឲ្យចូលមកប្រចាំការទាំងអស់ ។

ក្នុងកាយមនុស្សធំហើយដែលមានទម្ងន់ដល់ទៅ ៦០ គីឡូក្រាម មានគ្រួលោហិតប្រមាណ ៣ លានដំណក់ ក្នុងមួយដំណក់មានពលចម្បាំងប្រមាណ ៨ ពាន់ ពលជួយចម្បាំងមានប្រមាណ ៤ លាន សូមឲ្យគិតលេខមើលចុះ បើលោហិត ៣ លានដំណក់ គេត្រូវមានទាហានជាចំនួនប៉ុន្មានទៅ ? ឯបក្សគេនោះក៏មានចំនួនច្រើនលើសលប់គណនាណាស់ដែរ បើដូច្នេះតើគួរយើងហៅថា មហាយុទ្ធសង្គ្រាមបានឬទេ ? ។

ឯមហាយុទ្ធសង្គ្រាមលោក ក្នុងគ្រាដែលកន្លងមកហើយនោះមានពលចម្បាំងទាំងសងខាងយ៉ាងច្រើនត្រឹម ១០ លាននាក់ប៉ុណ្ណោះ ទើបឃើញថា មហាសង្គ្រាមក្នុងកាយយើងធំជាងឆ្ងាយណាស់ ។

៣ ) កាលបើបានប្រង់ត្រៀមកំឡាំងព្រមមូលគ្នាហើយ ទើបកងកាយបញ្ជូនគ្រួលោហិតសមកព័ទ្ធឡោមមេរោគដោយជុំវិញ នេះដូចជាការបញ្ជូនទាហានទៅតទល់នឹងពួកខ្មាំងសត្រូវ គ្រួលោហិតជំពូកខ្លះស៊ុះទៅចាំស៊ីមេរោគអស់នោះទាល់តែស្លាប់អស់ទៅក៏មាន ។ បើបែរជាតស៊ូនឹងមេរោគពុំបានឬត្រូវថ្នាំបំពុលស្លាប់ ក៏ក្លាយទៅជាខ្ទុះឡើង ខ្ទុះពណ៌សនោះក៏គឺគ្រួលោហិតសនឹងសាច់ស្បែកដែលខូចខាតខ្ទេចខ្ទីអស់ទៅហ្នឹងឯង ។ តាមធម្មតាគ្រួលោហិតស ១ អាចតស៊ូនឹងមេរោគបាន ១០ គ្រួ ។

(នៅមានត)

# រឿងព្រេងខ្មែរ — រឿងអាឡេវ ទី២

(តមក)

ឯកូនប្រពន្ធដែលកាន់ដំបងព្រនង់ចាំនៅមាត់ទ្វារ ឃើញប្ដីគេចូលមកក្នុងផ្ទះ គិតស្មានថាជាព្រាយក្បាលត្រងោលមែន ក៏ពិតវាយទាល់តែផ្លូលសន្ទប់ខ្លះរបួសពិការខ្លះ លុះក្រោយមកទើបបានដឹងថាប្ដីជាអាពុកខ្លួន ហើយនិយាយដំណើរប្រាប់ប្ដីសព្វគ្រប់ ៗ ពួកចោរទាំង ៥០០ ខឹងនឹងអាឡេវខ្លាំងណាស់តែមិនដឹងគិតធ្វើដូចម្ដេច ព្រោះខ្លួនត្រូវដំបងជាដំណាំទាំងអស់គ្នាហើយមិនដឹងជាអាឡេវនៅឯណា ៗ វេលានោះ អាឡេវនៅចាំស្ដាប់ប្រពន្ធកូនចោរវាយប្ដីខ្លួន ដល់ព្រមាត់ស្រែកទ្រហឹងពេញពាសទាំងស្រុក ក៏បើកសំពៅត្រឡប់ទៅស្រុកប្រពន្ធវិញ លុះទៅដល់ហើយអាឡេវនឹងប្រពន្ធឡើងទៅគេជីដូន បានជួបនឹងជីដូនក៏សំពះសូមទោស ហើយប្រគល់របស់ទ្រព្យក្នុងសំពៅទាំងប៉ុន្មានៗជូនជីដូនទាំងអស់ ៗ ឯជីដូនបានឃើញទ្រព្យសម្បត្តិអាឡេវពេញសំពៅក៏បាត់ខឹង បែរជាស្រឡាញ់អាឡេវពប់អានជាចៅប្រសាមែនទែន ៗ អាឡេវរៀបសង់ផ្ទះលោះខ្ញុំកំដរឲ្យបំរើជីដូនក្មេកនឹងប្រពន្ធពាសពេញក្នុងផ្ទះ លុះនៅយូរបន្តិចមកក៏លាជីដូននឹងប្រពន្ធទៅសួរម្ដាយអាពុកវា ជីដូនក្មេកផ្ដាំថាបើចៅទៅកុំនៅយូរពេក ឆាប់ត្រឡប់មកគេជីដូនវិញ ដ្បិតសព្វថ្ងៃនេះកំព្រាឥតមានអ្នកឯណាជាទីពឹងទេ ៗ

ឯប្រពន្ធអាឡេវ ចង់តាមអាឡេវទៅដែរ ហើយនិយាយថាខ្ញុំចង់ទៅជាមួយនឹងអ្នកឲ្យស្គាល់ម៉ែឪបងប្អូនញាតិសន្តានស្រុកទេសអ្នក មួយទៀតខ្ញុំមិនចង់ឲ្យឃ្លាតឆ្ងាយពីអ្នកទេ ដ្បិតថាស្រីប្តីទៅឆ្ងាយហើយកម្រនឹងទុកដាក់រក្សាខ្លួនណាស់ អ្នកផងគេតែងនិន្ទាថាដូចជាស្រីមេម៉ាយចំណាយមាត់គេ ហេតុដូច្នេះបានជាខ្ញុំមិនចង់នៅ ចង់ទៅតាមអ្នកជាប្តី ។ អាឡេវឆ្លើយឡើងថា នាងអើយ បងចង់បាននាងទៅជាមួយដែរ ប៉ុន្តែអាណិតដីដូនដ្បិតគាត់ចាស់ជរាណាស់ហើយ ក្រែងឈឺចាប់យប់ថ្ងៃ គ្មាននរណាថែទាំបីបមរក្សាដុសថ្នាំចាំជម្ងឺ នឹងទុកចិត្តលើមនុស្សម្នាខ្ញុំក៏ជាមិនបានទេ ដូចកាលយើងនាំគ្នារត់ទៅនោះ គាត់សន្ធឹកសន្ធៃឈឺរែរស្គាំងស្គម ទើបនឹងបានគ្រាន់បើ ឥឡូវនេះបើយើងទៅចោលគាត់ទៀត គាត់នឹងឈឺស្លាប់ពុំខានឡើយ ពីមុនបានជាខុសឆ្គាយម្តងរួចទៅហើយ ឥឡូវនេះយើងគិតកុំឲ្យខុសឆ្គាយទៀត ។ ឯប្រពន្ធឮប្តីស្រដីថាដូច្នោះហើយ នឹកអាណិតដីដូន ព្រមឲ្យប្តីទៅ ទើបរៀបស្បៀងស៊ីរៀងតាមផ្លូវសព្វគ្រប់ ហើយសួរប្តីថា អ្នកនឹងយកមនុស្សម្នាទេះសេះឡើទៅប៉ុន្មាន អាឡេវឆ្លើយថាបងមិនយកទៅទេ បងទៅតែម្នាក់ឯង ។ ឯគំនិតអាឡេវបានជាមិនចង់យកមនុស្សម្នាទៅ ពីព្រោះគិតចង់បានប្រពន្ធច្រើន បើនឹងយកមនុស្សតាមក្រែងគេដឹងថាខ្លួនមានប្រពន្ធហើយ នឹងទៅដណ្តឹងកូនគេទៀតក្រែង

(នៅមានត)

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

ឆ្នាំគំរប់ ១៣

ភាគទី ១០

ភ្នំពេញ

ការផ្សាយរបស់ព្រះរាជបណ្ណាល័យ

ព.ស. ២៤៨៤

គ.ស. ១៩៤១

ល:០១

ព្រះរាជបណ្ណាល័យកម្ពុជា

# KAMBUJASURIYÂ

# កម្ពុជសុរិយា

ជាទស្សនាវដ្ដីចេញផ្សាយពីព្រះរាជបណ្ណាល័យ មួយខែពីរក្បាល

## ឆ្នាំគំរប់ ១៣

ភាគទី ១០

គណៈរដ្ឋមន្ត្រីនឹងសម្ដេចសង្ឃនាយកទាំងពីរគណៈ

បានអនុញ្ញាតហើយ

ភ្នំពេញ

ការផ្សាយរបស់ព្រះរាជបណ្ណាល័យ

ព.ស. ២៤៨៤

គ.ស. ១៩៤១

# បញ្ជីរឿង


១ — ប្រវត្តិសង្ខេបនៃព្រះកែវមរកត ខេមររង្សីប្រែនិងរួបរួមពីគោលឯកសារផ្សេងៗ . . . ៣

២ — សេចក្តីសាមគ្គីបារាំងសែសនឹងខ្មែរ. . . . . . . . . . . . . . . . . . ៦

៣ — អាជីវកម្មគឺអ្វី? របស់ខេមររង្សី . . . . . . . . . . . . . . . . . . ៩

៤ — ពង្សាវតារក្រិក ស្រង់ចេញពីគោលឯកសារផ្សេងៗក្នុងពង្សាវតារលោក (តមក). . ១៤

៥ — ប្រជុំពាក្យកាព្យខ្មែរ ភាគទី ៤ របស់ឃុនស៊ុមនោម័យ (តមក) . . . . . . . ១៧

៦ — អនាមយកថា របស់ខេមររង្សី (មានត) . . . . . . . . . . . . . . . ២១

៧ — រឿងព្រេងខ្មែរៈ រឿងអ ឡេវទី ២ របស់អ្នកឧកញ៉ាប្រាជ្ញាធិបតី (យ៉ិន) (តមក) . ២៤


## រូបក្រៅរឿង


សាមឃ្មៀ (ប្រទេសលាវ)-ធាតុចេតិយលាវនៅមឿងពួ . . . . . . . . . . ១

# TABLE DES MATIÈRES

Pages

1° Histoire sommaire du BOUDDHA d'émeraude d'après divers documents par KHEMARARANSI ........................ 3

2° Solidarité franco-khmer et sauvagerie siamoise ............. 6

3° Qu'est-ce qu'un métier par KHEMARARANSI (suite)......... 9

4° Histoire de la Grèce, extrait de divers documents de l'histoire universelle (suite)........................... 14

5° RECUEIL DES POÈMES cambodgiens 4e partie par KHUNSIMA-NOMAY (suite )........................................ 17

6° ANAMAYAKATHA par KHEMARARANSI (suite)................. 21

7° Conte populaire cambodgien inédit :
"Légende de ALÉV II" par Oknha PRAJNADHIPADI YIN (suite).. 24

HORS TEXTE :

Samneua (Laos) — MUONG POUA-THAT...................... 1



សាខនៀ (ប្រទេសលាវ)-ធាតុចេតិយលាវនៅមឿងពួ ។

# ប្រវត្តិសង្ខេបព្រះកែវមរកត

ព្រះកែវមរកតនេះ មានរឿងរ៉ាវពោលទុកក្នុងសាស្ត្រាបុរាណហៅថា រតនពិម្ពវង្ស តែងជាភាសាបាលី មានសេចក្តីដំណាលថា ព្រះពុទ្ធរូបសំខាន់អង្គនេះ ទេវតាសាងថ្វាយព្រះអរហន្ត ១ អង្គ មាននាមថា ព្រះនាគសេន គង់ក្នុងស្រុកបាដលីបុត្រ ជាព្រះអរហន្តមានឥទ្ធិរិទ្ធិបានសម្រេចអភិញ្ញា លោកបានអធិដ្ឋានអារាធនាព្រះសារីរិកធាតុរបស់ព្រះពុទ្ធជាម្ចាស់មកប្រតិស្ឋានទុកក្នុងអង្គព្រះកែវមរកតនេះ ៧ អង្គ គឺនៅក្នុងព្រះមោលី ១ អង្គ ក្នុងនលាដ ១ អង្គ ក្នុងព្រះឧរៈ ១ អង្គ ក្នុងព្រះអង្សាទាំងសងខាងពីរអង្គ ក្នុងព្រះជាណុទាំងសងខាងពីរព្រះអង្គ ឯសាច់កែវក៏បិទជិតស្និទ្ធល្អដូចដើម មិនមានស្នាមប្រេះនាឡើយ ។ ព្រះកែវមរកតនេះ ដំបូងនៅស្រុកបាដលីបុត្រហើយឃ្លាតចេញទៅប្រតិស្ឋាននៅកោះលង្កា ហើយត្រឡប់ចូលមកប្រតិស្ឋាននៅក្រុងកម្ពុជា ស្រុកស្រីអយុធ្យា ស្រុកលៈពៅ ស្រុកកំផែងពេជ្រ ហើយតមកទៅប្រតិស្ឋាននៅស្រុកចៀងក៉ាយ ស្តេចស្រុកចៀងក៉ាយប៉ងនឹងលាក់ព្រះកែវមរកតឲ្យផុតពីកណ្តាប់ដៃសត្រូវ ទើបឲ្យយកកំបោរបូកលាបពេញទាំងអង្គ ហើយលាបម្រ័ក្សណ៍បិទមាសរួចយកទៅបញ្ចុះទុកក្នុងព្រះចេតិយស្រុកចៀងក៉ាយនោះឯង ។

តាមពង្សាវតារមានសេចក្តីពោលទុកតមកថា កាលពីពុទ្ធសករាជ ១៩៧៧ ព្រះកែវមរកតអង្គនេះប្រតិស្ឋាននៅក្នុងព្រះស្តូបចាស់ធំមួយនៅ

ស្រុកចៀងរ៉ាយ ។ កាលព្រះស្តូបនេះត្រូវរន្ទះបាញ់រលំទៅ ទើបអ្នកស្រុកបានឃើញព្រះពុទ្ធរូបបិទមាសថ្មី ១ អង្គនៅក្នុងទីនោះ តែគេយល់ថាជាព្រះពុទ្ធរូបធម្មតា ហើយនាំគ្នានិមន្តទៅដំកល់ទុកក្នុងព្រះវិហារវត្តមួយ លុះកន្លងមក ២-៣ ខែ កំបោរដែលបូកលាបម្រ័ក្សណ៍បិទមាសក៏របេះចេញត្រង់ព្រះនាសិក ។ លោកគ្រូចៅអធិការវត្តនោះបានឃើញជាកែវមានព័ណ៌ខៀវស្រស់ល្អ ក៏បកកំបោរចេញទាំងអស់អង្គ មនុស្សទាំងឡាយក៏បានឃើញច្បាស់ថាជាព្រះកែវគាន់បរិសុទ្ធល្អឥតប្រែធាតុសៅហ្មង ទើបមនុស្សទាំងពួងក្នុងស្រុកចៀងរ៉ាយនិងស្រុកដទៃទៀត ក៏នាំគ្នាចេញទៅនមស្សការថ្វាយបង្គំជាចំនួនច្រើន ចៅហ្វាយស្រុកៗចៀងរ៉ាយ ក៏ធ្វើសំបុត្របកឡើងទៅថ្វាយស្តេចចៀងម៉ៃ ព្រះនាមសាមហ្វាំងកែនៗក៏ចាត់ក្បួនហែទៅទទួលព្រះកែវនិមន្តឲ្យឡើងគង់លើខ្នងដំរីហែទៅស្រុកចៀង-ម៉ៃ ដល់ផ្លូវបែកទៅស្រុកលំប៉ាង ស្រាប់តែដំរីទីនាំងព្រះកែវមរកតផ្អើលរត់ទៅតាមផ្លូវស្រុកលំប៉ាង ទុកជាខ្មោចមាក់ល្បួងលួងលោមដំរីឲ្យស្ងប់ស្រួល ហើយនាំមកដល់ផ្លូវដែលនឹងចូលទៅស្រុកចៀងម៉ៃ ក៏បែរជាផ្អើលវិលទៅតាមផ្លូវស្រុកលំប៉ាងទៀត ដល់គ្រាក្រោយទើបគេរើសរកដំរីយ៉ាងសាំង មកទទួលព្រះកែវមរកតវិញ ។ ដំរីនោះលុះមកដល់ទីនោះក៏ភ្ញាក់ផ្អើលទៅស្រុកលំប៉ាងទៀត ពួកមន្ត្រីតូច-ធំដែលទៅទទួលព្រះកែវបានឃើញហេតុជាចំឡែកអស្ចារ្យដូច្នេះ ទើបមានសំបុត្របកថ្វាយដល់

ស្តេចចៀងហៃ ។ គ្រានោះ ស្តេចស្រុកចៀងហៃទ្រង់នៅជឿប្រកាន់ខ្មោចបិសាចខ្លាំងណាស់ ទ្រង់មានព្រះទ័យទឹកព្រួយវិតក្កថាក្រែងខ្មោចដែលថែរក្សាអង្គព្រះមិនព្រមឲ្យព្រះកែវនិមន្តមកស្រុកចៀងហៃទេដឹង ទើបទ្រង់អនុញ្ញាតឲ្យនិមន្តព្រះកែវមរកតទៅប្រតិស្ឋានទុកក្នុងស្រុកលំប៉ាងវិញ មនុស្សអ្នកស្រុកក៏នាំគ្នាឈូឆរមកនមស្សការធ្វើសក្ការបូជានៅក្នុងស្រុកលំប៉ាងអស់វេលា ៣២ ឆ្នាំ ហើយវត្តនោះក៏ហៅថាវត្តព្រះកែវដកបមកដល់សព្វថ្ងៃនេះ ។

លុះដល់មកក្នុង ព.ស. ២.០១១ ព្រះបាទតិលោកកជ បានគ្រងរាជ្យស្រុកចៀងហៃហើយទ្រង់ត្រិះរិះថា ការដែលក្សត្រចៀងហៃអង្គមុននេះឲ្យនិមន្តព្រះបដិមាករព្រះកែវមរកតទៅប្រតិស្ឋាននៅស្រុកលំប៉ាងនោះមិនសមគួរសោះ គួរតែអញទៅអាពធនាមកដំកល់ទុកក្នុងស្រុកចៀងហៃវិញ ទើបទ្រង់ចាត់ក្បួនហែទៅទទួលព្រះកែវមរកត ហើយទ្រង់សាងអាពមរាជកូដចេតិយថ្វាយ ទ្រង់កសាងព្រះវិហារព្រះកែវឡើង ដោយទ្រង់ធ្វើជាបែបប្រាសាទមានកំពូលផង តែមិនសម្រេចបាន ដ្បិតចេះតែមានរន្ទះបាញ់បាក់បែកទៅ ទុកជាធ្វើឡើងច្រើនលើកច្រើនគ្រា ក៏នៅតែត្រូវរន្ទះបាញ់ ទើបទ្រង់អាពធនាទៅដំកល់ទុកក្នុងវិហារមានស៊ុមខ្លោងទ្វារលៀនចេញមកខាងមុខ ហើយដំកល់ព្រះកែវនៅជិតជញ្ជាំងខាងក្រោយ ប្រកបដោយគ្រឿងសក្ការបូជាផ្សេងៗ មានសន្ទឹកទ្វារបិទ-បើកដូចជាទូ បើកឲ្យ

# សេចក្ដីសាមគ្គីនៃបារាំងសែសនឹងខ្មែរ

ការសែតបានពណ៌នាអំពីការបានធ្វើដោយនូវក្លាហានរបស់ពួកពិ-ជ័យសង្គ្រាមយើង ជាតិបារាំងសែស ជាតិខ្មែរ ជាតិយួន ដែលតយុទ្ធការពារទឹកដីយើងនៅប្រទល់ដែន ។ រឿងខាងក្រោមនេះជារឿងបរិយាយអំពីការច្បាំងតយុទ្ធដែលក្រុមពិជ័យសង្គ្រាមយើងបានតទល់នឹងទាហានសៀមពីខែមុន ។ នៅវេលាដើរល្បាត ១ ដងនោះ មានទាហានខ្មែរម្នាក់ស្ទុះចូលទៅមុខគេដោយក្លាហាន ប៉ុន្តែត្រូវរបួសដួលទៅ នៅចម្ងាយពីទាហាននោះចំនួន ៥០ ម៉ែត្រ សៀមបាញ់កាំភ្លើងមីត្រៃយើរគ្មានឈប់ ។ យ៉ាងនេះតើនឹងទុកឲ្យសៀមបាញ់បន្ថែមឲ្យស្លាប់ទៅឬទេ ? នៅពេលនោះមានទាហានកាប៉ូរ៉ាល់សែហ្វបារាំងសែសម្នាក់បានឃើញគ្រោះថ្នាក់ដែលពួកខ្លួនម្នាក់ត្រូវទទួលរងទុក្ខដូច្នោះហើយក៏ស្ទុះទៅជួយមួយរំពេច ក្រាបលូនរហូតដល់ទាហានរបួសពុំគិតដល់សេចក្ដីស្លាប់ ក្នុងខណៈនោះក៏ខំប្រឹងនាំទាហាននោះបានមករុំដំបៅឲ្យ ហើយបញ្ជូនខ្លួនទៅមន្ទីរពេទ្យ ។

លុះសម្រេចកិច្ចហើយ កាប៉ូរ៉ាល់សែហ្វស្រាប់តែឃើញមួកកាស្ក៏របស់ខ្លួនត្រូវសៀមបាញ់ ៣ គ្រាប់ធ្លាយមួយគ្រាប់ត្រូវស្បែកលលាដ៍ក្បាល ។ ការដែលបានធ្វើទាំងម៉្លេះគង់សៀមនៅខំនិយាយបង្កាច់ថាបារាំងសែសមកស្រុកខ្មែរធ្វើការយកតែផលប្រយោជន៍ខ្លួន រំលោភលើខ្មែរឥតមានអៀន

ទាស តែឯការពិតនោះបាក់ន៍សែសទឹនខ្មែរប្រមូលចន៍បាច់គ្នាការពារកិច្ច ហេតុតែមួយ ហើយបាក់ន៍សែសគ្មានញញើតគិតដល់សេចក្តីស្លាប់ យកជីវិតទៅប្តូរដើម្បីទឹន៍សង្គ្រោះគ្នាទៅវិញទៅមកយ៉ាងដូច្នេះ ។

☼

☼ ☼

# អំពីសៀមបិតខ្មោចបមនុស្សព្រៃ

សៀមអួតខ្លួនថាជាបងប្អូនខ្មែរ ចូរអ្នកស្តាប់រឿងដែលកាប៉ូកាលឈ្មោះ បារ-អ៊ូ ជាសែហ្វប៉ុស្តិ៍នៅប្រទល់ដែន បានពណ៌នាប្តឹងទៅចៅហ្វាយខ្លួនថា ។

នៅថ្ងៃ ៩ ខែដេសមប្រ៍ មានកូនក្មេងម្នាក់អាយុ ១៥ ឆ្នាំ ឈ្មោះឡាវសុង មកដល់ប៉ុស្តិ៍ខ្ញុំ សំលៀកបំពាក់ប្រែឡាក់សុទ្ធតែឈាម វានិយាយប្រាប់ខ្ញុំថា វាបានជូនឈ្មោះរុយាកុលទៅស្រុកសៀម ដើម្បីទឹន៍ប្រាប់ឈ្មោះវង៍ថាកូនស្រីមានជម្ងឺឈឺ ។ ខ្លួនវាហើយទឹន៍គូកនវាឈ្មោះរុយាកុលនេះត្រូវពួកគំរូតសៀមចាប់បាន ។

លុះពួកគំរូតសៀមឆែកឆេរខ្លួនវាទាំង ២ នាក់រួចស្រេចហើយ ក៏បង្គាប់ឲ្យអង្គុយនៅឲ្យស្ងៀម ស្រាប់តែពួកគំរូតសៀមបាញ់វាទឹន៍កាំភ្លើងដែលមានគ្រប់ដៃ ឈ្មោះរុយាកុលដួលស្លាប់ៗរំពេចទៅ ឯឈ្មោះឡាវ

ស៊ុនក៏ធ្វើពុតជាដួលដែរ ប្រយោជន៍ឲ្យគេជឿថាវាស្លាប់ ។ លុះវេលាយប់វាលួចរត់មកស្រុកខ្មែរវិញ ។

មនុស្សអ្នកស្រែនេះហើយនឹងកូនក្មេងនេះវាបានធ្វើអ្វី មានទោសអំពីរឿងអ្វី បានជាបាញ់វា ?

# អាជីវកម្មគឺអ្វី?

(តមក)

## វគ្គទី ៣

### របបចិញ្ចឹមជីវិតក្នុងស្រុក

ហេតុដែលមនុស្សយើងមានរបបចិញ្ចឹមជីវិតផ្សេងៗគ្នានោះ តាមធម្មតាច្រើនតែទាក់ទងនឹងភូមិប្រទេស-ទីតំបន់ដែលខ្លួនអាស្រ័យនៅ ប្រទេសយើងជាប្រទេសមួយដែលមានអាកាសក្តៅនៅក្នុងតណ្ហូស៊ុនបាកាំងសែស រមែងមានភ្លៀងធ្លាក់ចុះតាមរដូវតែរៀងរាល់ឆ្នាំ មានអាណាខេត្តជាងមួយសែនគីឡូម៉ែត្រក្រឡា មានដីរាប មានទីទំនាប មានព្រៃ មានភ្នំ ទន្លេ ស្ទឹង ព្រែក បឹងតូច-ធំនឹងទន្លេសាបជាច្រើន ៗ ឯផ្លូវគមនាគមទាំងខាងក្នុងស្រុកនឹងក្រៅស្រុកក៏ស្រួលឡើងចំរើនឡើងតាមសម័យ ដូចជារថភ្លើង រថយន្ត កប៉ាល់ជាដើម ៗ

បើពោលពីអាជីវកម្មរបស់ប្រជាជនជាតិខ្មែរ ដោយច្រើននិយមធ្វើរបរក្សេត្រកម្ម ដែលជាអាជីវកម្មធំបំផុតក្នុងប្រទេសយើង តែរបរក្សេត្រកម្មរបស់ជនជាតិយើងច្រើនតែធ្វើគ្រាន់តែល្មមស៊ីពាយ មិនធ្វើជារបរធំដុំដូចជាតិដទៃទេ ទុកជាមានខ្លះ ក៏មានចំនួនមិនច្រើនប៉ុន្មានដែរ តែទុកជាធ្វើតិច-ច្រើនយ៉ាងណាក៏ដោយ ក៏នៅមានចំនួនស្រូវមានចំណាយចេញទៅប្រទេសក្រៅជាចំនួនច្រើនតែរៀងរាល់ឆ្នាំ ៗ

របរកសិកម្មដែលធ្វើនៅស្រុកយើងវេលានេះ មានការធ្វើស្រែ, ចំការកប្បាស-ថ្នាំជក់, អំពៅ, ពោត, ម្រេច, ដូង, ម្លូ, ស្លា, និងបន្លែ ឈើផ្លែជាដើម ក្រៅពីរបរកសិកម្ម មានរបរនេសាទត្រីនិងឈើព្រៃជាដើម ។

ការធ្វើស្រែ — គឺការដាំស្រូវដែលជាអាហារប្រចាំជីវិតជាតិយើងរាល់ថ្ងៃ របរធ្វើស្រែនេះជារបរធំបំផុតក្នុងស្រុកខ្មែរ រាស្ត្រតែងធ្វើគ្រប់ៗខេត្ត តែចំនួនស្រែនិងស្រូវច្រើនបំផុតក្នុងស្រុកខ្មែរ គឺខេត្តបាត់ដំបង ព្រោះផ្ទៃផែនដីនៅខេត្តនេះមានដីរាបស្មើ មានដីទំនាបល្មមធ្វើស្រែបានជាច្រើនអន្លើ ទើបរបរស្រូវនៅខេត្តនេះមានចំនួនច្រើនបំផុត ។ គួរកត់ថារបរស្រូវនៅស្រុកខ្មែរទាំងមូលជាបង្គោលធំជាសរសៃជីវិតរបស់ខ្មែរយើង ។

ការធ្វើចំការកប្បាស — ប្រជាជនបានដាំជាច្រើនតាមមាត់ទន្លេមេគង្គ តាំងពីក្រចេះកំពង់ចាមរហូតមកដល់ខេត្តកណ្ដាល ។ តាំងពីដើមមក ប្រជាជនជាតិខ្មែរតែងដាំកប្បាសប្រយោជន៍នឹងយកមកធ្វើជាសំពត់ស្លៀកដណ្ដប់ជាដើមដោយខ្លួនឯង ដល់មកឥឡូវជំនួញសំពត់អាវពីប្រទេសក្រៅមានចំនួនច្រើនហើយសាច់កំណាត់ក៏ច្រើនល្អៗផង ពួកយើងលែងត្បាញសំពត់ស្លៀកខ្លួនឯង បែរជានាំគ្នាទិញសំពត់ពីប្រទេសក្រៅ ។ ស្រីៗជាន់ដើមដែលធ្លាប់ត្បាញហើយចេះត្បាញគ្រប់គ្នាក៏ឈប់ត្បាញអស់ នៅសល់ខេត្តខ្លះ ដូចខេត្តកណ្ដាល ព្រៃវែង ស្វាយរៀង នឹងកំពង់ចាមជាដើម

ស្រីៗ អ្នកស្រុកបេះត្បាញផាមួង ក្រមា សារុង មុង ហូល សារបាប់ផា ដើម លក់ចំណាយជាគ្រឿងចិញ្ចឹមជីវិតក៏មាន ៗ នៅក្រុងភ្នំពេញ រោងការ បង្កើតសាលារចនាមួយសម្រាប់បង្រៀនការរចនា ការគូរពេស ការឆ្លាក់ ការធ្វើគ្រឿងមាសប្រាក់ ធ្វើជាងតម្បាញព្រៃ ហូល ផាដើម គួរពប់ ថាជាគំនិតដ៏ប្រសើរមួយរបស់រោងការ ៗ

ការធ្វើចំការថ្នាំ — ថ្នាំជក់នេះទុកជារបស់ឥតប្រយោជន៍ដល់មនុស្សយើងៗ នៅតែនាំគ្នាជក់ស្ទើរតែគ្រប់គ្នា នៅប្រទេសយើងគេនិយមដាំថ្នាំជក់នេះ ស្ទើរតែគ្រប់ស្រុក តែដែលមានចំនួនច្រើនជាងទីឯទៀតៗ នោះឃើញ មានដាំតាមមាត់ទន្លេមេគង្គដែលមានដីដីជាតិល្អ ទីងដៃទន្លេសាបដែល មានដីដីជាតិល្អដែរ ក្រៅពីនេះ នៅខេត្តឯទៀតៗ ក៏មានដាំដំណាំថ្នាំនេះ ដែរតែមានចំនួនតិច ល្មមប្រើប្រាស់ក្នុងគ្រួសារនឹងចំណាយលក់ដូរបន្តិច បន្តួច ៗ នៅស្រុកយើងសព្វថ្ងៃនេះមិនទាន់មានម៉ាស៊ីនមូរបារីដូចព្រៃនគរ ទេ តែខ្មែរកាន់តែចូលចិត្តជក់ច្រើនឡើងៗ ជានិច្ច ដំនួញថ្នាំខ្មែរកាន់តែ មានចំនួនតិចទៅៗ ៗ ថ្នាំជក់នេះជារបរធំមួយដែរ ព្រោះមនុស្សចូល ចិត្តជក់ទាំងចាស់ទាំងក្មេង ៗ ប្រសិនបើខ្មែរយើងរួមគ្នាធ្វើជាងតាំងសមា-គមបង្កើតម៉ាស៊ីនមូរបារីឡើងហើយចំណាយក្នុងស្រុក ជឿថាគង់មាន ចំណេញច្រើន ៗ

ការធ្វើចំការល្ហុ,សណ្តែក, អំពៅ, ពោត — ដំណាំអស់នេះសុទ្ធតែមានប្រយោជន៍ណាស់ ជារបរធំនាំចេញទៅចំណាយប្រទេសក្រៅជាចំនួនច្រើន តែមានដាំច្រើនតាមមាត់ទន្លេ មាត់ស្ទឹង មាត់ព្រែកទឹងតាមមាត់ទន្លេសាប ក្រៅពីទីអស់នេះក៏មានខ្លះដែរតែមិនច្រើនប៉ុន្មាន គ្រាន់តែល្មមប្រើប្រាស់លក់ដូរក្នុងភូមិតំបន់អស់នោះប៉ុណ្ណោះ ។ អំពៅបើមានចំនួនច្រើនហើយយកមកគាបធ្វើជាស្ករឬបង្កើតម៉ាស៊ីនធ្វើស្ករទើងមានសេចក្តីចំរើនជាមិនខាន ព្រោះប្រទេសជិតខាងយើងសឹងមានសេចក្តីត្រូវការប្រើស្ករជាចំនួនច្រើនដែរ ដូចជាស្ករត្នោតស្រុកយើងដែលអ្នកស្រុកធ្វើតាមទម្លាប់ឥតមានគ្រឿងម៉ាស៊ីនអ្វីឡើយ ក៏នៅចំណាយចេញទៅស្រុកយួនក្នុង ១ ឆ្នាំៗជាចំនួនក្រាស់ក្រៃលដែរ ។ ឯរបរពោតជារបរធំដែរ លក់ចំណាយចេញទៅប្រទេសក្រៅក្នុង ១ ឆ្នាំៗ ជាចំនួនច្រើន ហើយលក់ជាប់មិនសល់រៀងរាល់ឆ្នាំ ។ នៅប្រទេសឲរុប គេចិញ្ចឹមសត្វដូចជាសេះ លាជាដើមដោយម្សៅពោត ហេតុនេះបានជាប្រទេសអស់នោះត្រូវការគ្រាប់ពោតជាចំនួនច្រើនតែរៀងរាល់ឆ្នាំ ។

ការធ្វើចំការម្រេច — ម្រេចមានប្រយោជន៍ផ្សំថ្នាំទឹងផ្សំគ្រឿងសម្លទៀតមានឲជារសឆ្ងាញ់ ជាដំណាំមួយធំបញ្ចូនទៅលក់ប្រទេសក្រៅ មានកស្ត្រនិយមដាំច្រើនតាមដែនដីក្បែរមាត់សមុទ្រនៅកែបក្នុងខេត្តកំពត មាន

ចំការម្រេចជាចំនួនច្រើនបំផុត នៅតំបន់នេះមានចិនហៃណាំដាំម្រេចជាច្រើន ខ្មែរមានខ្លះដែរតែមិនសូវធ្វើចំការធំៗដូចចិនទេ ។ ម្រេចលក់បានថ្លៃណាស់ តែលំបាកថែទាំណាស់ មិនដូចដំណាំឯទៀតៗទេ ។ ក្រៅពីនេះនៅមានដំណាំដទៃៗ ទៀតជាច្រើនយ៉ាងដែលប្រជាជនធ្វើជារបរចិញ្ចឹមជីវិត ដូចជាដូង, ស្លា, ម្លូ, ស្ពៃ, ត្រប់, ម្ទេស ។ល ។ តែមិនបានធ្វើជាជំនួញធំដុំទេ គ្រាន់តែជាគ្រឿងប្រើប្រាស់ក្នុងស្រុកប៉ុណ្ណោះ ។

(មាឌត)

# ពង្សាវតារក្រិក

(តមក)

តាំងអំពីដើមមកនោះមិនជាការបំប្លែកអ្វីទេ ចំណែកខាងពួកអាថែន្សនេះ បំប្លែកបន្តិចដោយហេតុជាអ្នកធ្លាប់រក្សាអារ្យធម៌ទុកដោយល្អមកអំពីដើម លុះមកដល់គ្រានោះត្រឡប់ជាមានអាការសាហាវដូចពួកស្ប៉ាតដែរ គឺមានការកាត់ដៃកាត់ជើងពួកអ្នកទោសសឹកទីងប្រហារជីវិតពួកមន្ត្រីយ៉ាងសាហាវជាដើម ។

ផលនៃសង្គ្រាមគ្រានេះ— ខាងស្រុកស្ប៉ាតមានជ័យជំនះយ៉ាងដាច់ខាត ធ្វើឲ្យអាថែន្សផុតរលត់អំណាចរើខ្លួនមិនរួច ថែមទាំងធ្វើរបៀបត្រួតត្រាបែបប្រជាធិបតេយ្យឲ្យរលត់អស់ជាបណ្ដោះអាសន្នទៅទៀតផង សូម្បីអាណាចក្រដទៃៗទៀតក្រៅពីអាថែន្សទាំងអស់គ្នាផ្លាស់គំនិតគិតឃើញថារបៀបប្រជាធិបតេយ្យមិនល្អ ក៏នាំគ្នាកែប្រែរបៀបត្រួតត្រាស្រុកទៅតាមបែបរបស់ស្ប៉ាត គឺប្រគល់អំណាចត្រួតត្រាស្រុកទេសនៅក្នុងកណ្ដាប់ដៃនៃពួកមន្ត្រី នៅស្រុកអាថែន្សក៏ផ្លាស់របៀបគ្រប់គ្រងស្រុកទៅតាមទំនងនេះដែរ តែមិនមែនធ្វើតាមសេចក្ដីយល់ព្រមរបស់ប្រជាជនទេ ពីព្រោះរដ្ឋាភិបាលប្រជាធិបតេយ្យចាញ់សង្គ្រាមយ៉ាងវិនាសខ្ទេចខ្ទីនោះឯង ។

វិធីគ្រប់គ្រងរបស់អាថែន្សដែលកែប្រែថ្មីនេះ គឺត្រូវមានមន្ត្រីនៅក្នុងគណៈរដ្ឋបាលចំនួន ៣០ នាក់ តាំងជាសភាឬក្រុមជំនុំឡើងហៅថា តីស-

សកា ៗ ប៉ុន្តែវិធីគ្រប់គ្រងបែបនេះមិនតាំងនៅបានប៉ុន្មានទេ ដោយហេតុ ២ប្រការ គឺរាស្ត្រអាថែនស្រមាននិស្ស័យជាប់ចិត្តស្រឡាញ់បែបប្រជាធិបតេ-យ្យនេះជាហេតុ១ ហេតុ១ទៀត គឺពួកមន្ត្រីដែលមានអំណាចក្នុងការនាំគ្នាសង្កត់សង្កិនប្រជារាស្ត្រហួសពេក ដល់ទៅមានបង្គាប់ឲ្យចាប់មនុស្សដែលធ្លាប់នៅក្នុងគណៈត្រួតត្រាបែបប្រជាធិបតេយ្យយកទៅប្រហារជីវិតអស់ចំនួន១៥០០នាក់ ដែលត្រូវបំបរបង់ឲ្យចេញពីស្រុកទៅក៏មានចំនួនជាច្រើនដែរ ៗ នៅទីបំផុត ពួកដែលត្រូវបណ្តេញទៅនោះរួបរួមគ្នា តាំងជាកងទ័ពឡើងបាន មានបុរសម្នាក់ឈ្មោះត្រាស៊ីប៊ុល ជាមេទ័ពលើកទ័ពចូលក្រុងអាថែនបានដោយមានបណ្តារាស្ត្រក្នុងស្រុកចូលដៃផងទើបនាំគ្នាបណ្តេញគណៈរដ្ឋបាលមន្ត្រីចេញអំពីដំណែងបានសម្រេចហើយតាំងរដ្ឋបាលប្រជាធិបតេយ្យឡើងវិញ រដ្ឋបាលថ្មីនេះមានគំនិតល្អ បាននាំគ្នាបោះឆ្នោតក្នុងទីប្រជុំរាស្ត្រថា សូមឲ្យអភ័យទោសដល់បណ្តាមន្ត្រីដែលធ្វើសេចក្តីក្តៅក្រហាយដល់បណ្តារាស្ត្រមកហើយនោះទាំងអស់ ៗ

សូម្បីមានការបោះឆ្នោតឲ្យអភ័យទោសដូច្នេះហើយក៏ដោយ ក៏នៅតែមានបណ្តារាស្ត្រចងគំនុំនឹងពួកមន្ត្រី លបលួចប្រទូសរ៉ាយឥតស្រាកបួនជាមានគ្រោះកម្មអាក្រក់ មហាបុរសរបស់ក្រិកឬរបស់ទុរុបទាំងមូលដែលមានកេរ្តិ៍ឈ្មោះល្បីល្បាញមកដល់សម័យសព្វថ្ងៃនេះ ក៏ត្រូវពួករាស្ត្រ

ហៅថាជាពួកមន្ត្រីដែរ ហើយបានទទួលគ្រោះថ្នាក់អំពីកស្ត្រដល់ក្ស័យជីវិតទៅ ។

មហាបុរសនេះ ឈ្មោះ សូក្រាត អ្នកសិក្សាប្រវត្តិសាស្ត្ររបស់ក្រិកនឹងមើលរំលងប្រវត្តិរបស់លោកនេះទៅមិនសមគួរឡើយ ។

សូក្រាត – លោកនេះកើតក្នុង ព.ស. ៧៥ ជាអ្នកប្រាជ្ញចំឡែកជាងអ្នកប្រាជ្ញទូទៅធម្មតា ព្រោះលោកមិនបានសរសេររឿងក៏ទុកឡើយ តែលទ្ធិរបស់លោកនេះផ្សាយចេញមកហើយមានជាប់មកដល់សព្វថ្ងៃនេះដោយមានសិស្សសំខាន់របស់លោកពីរនាក់ ម្នាក់ឈ្មោះសេណេហ្វុង ម្នាក់ទៀតឈ្មោះប្លាតុង ជាអ្នកនាំមករួបរួមសរសេរឡើងនៅវេលាក្រោយ ។ លោកសូក្រាតនេះជាមនុស្សមានលក្ខណៈសំខាន់ៗច្រើនយ៉ាង គឺជាអ្នកប្រាជ្ញមានសេចក្តីសុចរិតទៀងត្រង់ ជាទាហានដ៏អង់អាច តែមិនព្រមទទួលធ្វើក្នុងក្រសួងរាជការ ជាអ្នកទីទ័លក្រ ទាំងមិនព្រមទទួលប្រាក់រង្វាន់ដែលសិស្សផ្ញើខ្លួនរៀនសូត្រយកមកឲ្យ ហើយមិនបានរៀបចំការរៀនសូត្រឲ្យមានសាលាមាំមួនទេ ។ សូក្រាតជាមនុស្សមានរូបរាងមុខមាត់មិនសមសួនជាទំនាស់យ៉ាងធំនឹងពួកអាថែន ។ តាមធម្មតា សូក្រាតជាមនុស្សស្ងប់ស្ងាត់ គាប់ចិត្តទីវិវេកលាក់ខ្លួនតួនត្រិះរិះពិចារណាខាងផ្លូវបរមត្ថធម៌តែម្នាក់ឯង លុះចេញពីទីពួនសម្ងំមកដើរលេង ទើបមានមនុស្សមកតាមពេមពីខាងមុខខាងក្រោយ ប្រុងត្រងត្រចៀកស្តាប់សំដីទេសនារបស់លោក ។

(មាតត)

# ប្រជុំពាក្យកាព្យ

## ភាគទី ៤

*របស់ឃុនស៊ុមនោម័យ*

(មាឌត)

ប្អូមួយមានមិត្រនិត្យនៅផង
ចរចាសាសងលេងសប្បាយ
ក្រាំងក្រេចក្តីស្ម័គ្រកេកយមាយ
ថ្ងៃអើយរៀមអួលអន់ទុក ។

ប្អូនគិតដែរតែយ៉ាងស្បើយ
ធើយ ៗ ពុំធ្មិតពីចិន្តា
ថ្វារនេះរៀមចង់យល់កក្ត្រា
ឲ្យធូរទុក្ខាណាប្អូនអើយ ។

ទៀបម៉ោងពីរបងតាំងរិតក្ក
សៀតបុកចិន្តាមិនមានស្បើយ
រៀមរឭកទឹកណាស់ណាន្ទួនអើយ
រំខានឥតស្បើយអំពល់ចិត្ត ។

ឈឺធៀបរលង់កុងទុក
ណែនខ្មោចក្តៅផ្សាចិន្តាធ្មិត
សែនរំជួលគួលណាស់អំពល់គិត
រៀមអាណិតទឹកអានាថគនិដ្ឋា ។

រឹងធ្មល់រតែផ្អែតសែនអួលអាក់
វែងវោត្រជាក់តែឯកា

ទោរទន់ស្រពន់អស់កាយា
រៀមកំព្រាសែនហោសញ្ជប់គិត ។
　　នឹកណាស់តែខ្វល់ឥតឧបមា
ចុកសៀតឧកដេកមិនលក់
យប់ស្ងាត់សត្វស្ងៀមរៀមវិតក្ក
គិតគ្រប់ទៅទុក្ខពល់វេលា ។
　　ដល់ម៉ោងបីចិត្តបងគិតព្រួប
ទឹងទៅមិនរួចឡើយទេវតា
ទឹងបានបីបមថ្នមស្ងួនភ្ងា
ឲ្យអស់ចិន្តាណាអូនអើយ ។
　　អនិច្ចាវេទនាតែឯកអង្គ
នៅក្នុងដំណោកវិវេកផ្សា
សង្ស័យអាល័យគិតសង្សារ
លុះដល់វេលាទៀបព្រឹកព្រាង ។
　　ប្រះប្រាណកែះកើយតែខ្នើយខ្នល់
ហាក់ប្រាកដល់ដល់ខ្នើយភ្ងាង
រូបតែជួបជិតស្នាននួននាង
ភ្ងាភ្ងាងដឹងជាក់ភ្ញាក់ចិន្តា ។

ខអញមមើអីដល់ម៉្លេះ

ពុំគួរជួបប្រះឡើយទេវតា

ដល់ជាក្រសោបឱបប្រាក់

ខ្នើយឱបស្មានថាជាថ្លៃបង ។

កម្មអើយកើតទុក្ខក្នុងគ្រានេះ

មិនមានរបេះសេចក្ដីហ្មង

អំពល់ហើយខ្វល់សល់កន្លង

បើម៉្លេះម្រាំងបងនឹងស្បើយទុក្ខ ។

បើប្អូនខ្ញុំខ្លួនមានមេត្តា

ស្នេហាស្រឡាញ់តទៅមុខ

ឲ្យបងអ្នកបានស្បើយល្ហើយទុក្ខ

ទៅមុខគង់នឹងសម្រេចការ ។

នេះហើយជាការក្ដីសុខុម

ចូរមុំនាងគិតកែប្រាជ្ញា

នៃនក(១)មកឲ្យបងស្នេហា

ក្នុងថ្ងៃនេះណាព្រលឹងអើយ ។

---

(១) លៃលក ។ (មានត)

## អនាមយកថា

២. ស.

អ្នកប្រែនិងរៀបរៀង (តមក)

ឯខួរឆ្អឹងខ្នងជាពៅនាទីបង្កើតកូនលោហិតក្រហមនិងសឲ្យមានចំនួនច្រើនល្មមគ្រប់គ្រាន់នឹងប្រើការជានិច្ច តែមានចួនកាលធ្វើបញ្ជូនមិនទាន់ប្ដូរមួយយឺតយូរពេកទៅ គ្រូពេទ្យតោងប្រើវិធីបញ្ចោត គឺចាក់បញ្ចូលមេរោគស្លាប់ៗឲ្យចូលទៅក្នុងរាងកាយ ដើម្បីបញ្ចោតរាងកាយឲ្យមានសេចក្ដីភិតភ័យភ្ញាក់ផ្អើលឡើង ឲ្យខំប្រឹងធ្វើកូនលោហិតសឲ្យមានចំនួនគ្រប់គ្រាន់ឡើង នេះមានទំនងដូចជាយើងកេណ្ឌពលទាហានក្រៅមកប្រចាំការឲ្យមកជួយច្បាំងថែមទៀត ដើម្បីបន្ថែមកំឡាំងកងទ័ពឲ្យមានកំឡាំងខ្លាំងពូកែឡើង តែកូនលោហិតមិនបានទៅតយុទ្ធនឹងមេរោគស្លាប់ៗនោះទេ នាំគ្នាទៅតយុទ្ធតែនឹងមេរោគរស់ៗដោយស្រួល ទើបមានជ័យជំនះដោយងាយ ៗ ឯពួកកូនលោហិតក្រហមនោះមាននាទីជាអ្នកជញ្ជូនស្បៀងអាហារនិងគ្រឿងអាវុធហើយធ្វើនាទីជាអ្នកជួយច្បាំងផង ៗ

៤) រាងកាយយើងធ្វើទឹកម្យ៉ាងឲ្យមានឡើង សម្រាប់ជួយជាកំឡាំងឲ្យកូនលោហិតសធ្វើការកំចាត់មេរោគបានដោយងាយ បើមិនមានទឹកបែបនេះទេកូនលោហិតសក៏ធ្វើការមិនបានស្រួល ទឹកបែបនេះ ប្រៀបដូចជាទា-ហានកាំភ្លើងធំដែលតាំងចាំបាញ់ពួកសឹកសត្រូវឲ្យភ័យស្លន់ ទើបពួកទា-ហានលើកទ័ពលុកចូលទៅរកពួកខ្មាំងសត្រូវបានស្រួលមិនសូវលំបាក ៗ

# តួយ៉ាងដែលមើលឃើញដោយភ្នែកទទេ

តួយ៉ាងរោគដែលយើងល្មមមើលឃើញដោយភ្នែកទទេបាននោះ គឺដំបៅបួសផ្សេងៗបួសកើតឡើងដោយមានបាក់តេរីម្យ៉ាងមានរូបរាងជាចុចៗ ហើយរួមគ្នាជាពួកៗមានទំនងដូចចង្កោមផ្លែទំពាំងបាយជូរ លើកគ្នាចូលមកប្រទូសរ៉ាយរាងកាយយើង ហើយយើងមើលឃើញបួសនោះមានអាការប្រែប្រួលដូច្នេះ :

១) មានកំដៅកើតឡើង ព្រោះភ្នាក់ងាររក្សារាងកាយយើងបន្ថែមឲ្យមានច្រើនឡើង ដើម្បីសម្លាប់មេរោគឬបន្ថយកំឡាំងមេរោគឲ្យទន់ខ្សោយចុះទៅ ។

២) ឡើងសម្បុរក្រហម ព្រោះមានឈាមមករួមប្រជុំគ្នានៅទីនោះជាចំនួនច្រើន ដើម្បីនាំពួកលោហិតសមកតយុទ្ធនឹងមេរោគអស់នោះ ហើយនាំស្បៀងអាហារមកជូនផង ។

៣) មានអាការហើមឡើង ព្រោះមានឈាមនឹងទឹករងៃច្រើនជាងធម្មតាសព្វដង ដើម្បីជាប្រយោជន៍ដូចប្រការទី ២ នោះដែរ និងប្រយោជន៍ដើម្បីឲ្យទឹករងៃជម្រះលាងដេញកំចាត់មេរោគឲ្យអស់ទៅ ។

៤) មានអាការឈឺ ព្រោះមានសរសៃប្រសាទត្រូវគៀបដោយទឹកលោហិតនឹងទឹករងៃមកឃាំងដក់នៅត្រង់កន្លែងនោះ ទាំងសរសៃប្រសាទក៏

កាន់តែមានអាការដឹងខ្លួនច្រើនឡើងដើម្បីឲ្យរាងកាយចាប់ដឹងខ្លួន មិនបាច់ឲ្យមានការប៉ះពាល់ត្រង់កន្លែងដែលឈឺនោះ ។

៤) មានពិការ នៅត្រង់កន្លែងដែលឈឺនោះរមែងពិកពិការប្រើការមិនបានស្រួលឬមិនបានឡើយ គឺថាបើឈឺត្រង់ដៃនឹងប្រើដៃធ្វើអ្វីក៏មិនស្រួលបេះតែតាមទំនងទាំងអស់ នេះធម្មតាតែងបង្គាប់ឲ្យធ្វើដូច្នេះប្រយោជន៍នឹងបង្ការរាងកាយត្រង់កន្លែងដែលឈឺនោះ មិនឲ្យកម្រើកមិនឲ្យរញ្ជួយនឹងបង្ការមិនឲ្យមេរោគឬមេជម្ងឺស្ទុះចូលទៅកាន់ទីដទៃទៀតបានផង ។

ហេតុដែលឬឈឺចាប់កាន់តែខ្លាំងឡើងរមែងមានមកតាមទំនងនេះទាំងអស់ កាលបើយើងដឹងដើមហេតុដូចបានពោលមកហើយនេះ យើងត្រូវតែអនុលោមជាជំនួយជួយរាងកាយ យើងក្នុងពេលដែលមានគ្រោះថ្នាក់ ។ ជម្ងឺបូសដែលមានខ្ទុះកើតឡើងច្រើននោះ គឺតួលោហិតសទៅធ្វើការតយុទ្ធនឹងមេរោគនោះបរាជ័យចាញ់ស្លាប់អស់ជាចំនួនច្រើន ហេតុនេះយើងត្រូវតែរកគ្រូពេទ្យឲ្យវះបាយកខ្ទុះនឹងឈាមកំណាចនោះចេញ ហើយត្រូវប្រយ័ត្នបង្ការកុំឲ្យមេរោគចុះទៅជ្រៀតជ្រែកត្រង់កន្លែងនោះបានទៀត ដោយវិធីចងរុំត្រង់កន្លែងនោះ នឹងទំនុកបំរុងរាងកាយឲ្យមានកំឡាំងច្រើនឡើង ដើម្បីឲ្យរាងកាយធ្វើការតទល់នឹងមេរោគតាមទំនើងខ្លួនឯងវិញប្រសើរជាង ។ ការធ្វើឲ្យកើតរលាកមិនត្រូវទំនងអាចឲ្យទោសបាននៅវេលាក្រោយមិនខាន ។

(មានត)

# រឿងព្រេងខ្មែរ – រឿងអាឡេវទី ២

(តមក)

គេមិនឲ្យ ហើយយកនិយាយនឹងប្រពន្ធថា បងធ្លាប់ដើរតែម្នាក់ឯង តែមានមនុស្សម្នាក្របីគោរទេះទៅជាមួយធងនឹងធ្វើដំណើរមិនរហ័សទាន់ចិត្ត ហេតុដូច្នោះបានជាបងមិនចង់យកទៅ ។ អាឡេវវេចតែប្រាក់នឹងស្បៀងគ្រាន់នឹងស៊ីតាមផ្លូវ ឯជីដូនផ្តាំហើយផ្តាំទៀតថា បើចៅទៅដល់ម្តាយ-អាពុកនៅជាសុខសប្បាយ ចូរចៅឆាប់ត្រឡប់មកវិញហ្ន៎ះចៅណា ។ អាឡេវក៏លាជីដូននឹងប្រពន្ធហើយចេញដំណើរទៅ លុះទៅដល់ផ្ទះអ្នកនេះនាងនោះជាអាពុកម្តាយហើយក៏យកប្រាក់ទៅឲ្យម្តាយអាពុក ៗមានចិត្តត្រេកអរសួរថា កូនទៅណាបាត់យូរដល់ម្ល៉េះ ម្តាយឪពុកចេះតែទន្ទឹងមើលផ្លូវកូនតែសព្វថ្ងៃ អាឡេវប្រាប់ថាខ្ញុំទៅគិតធ្វើការរកស៊ី ដ្បិតម៉ែឪឯងមិនគិតរកស៊ីនឹងគេ ។ អ្នកនេះនឹងនាងនោះឆ្លើយឡើងថាតាមតែកូនគិតចុះ បំណែកខាងម្តាយអាពុករកស៊ីគ្រាន់តែមាត់ ហើយនឹងរក្សាទ្រព្យទុកឲ្យកូន ចូរកូនគិតរកអម្រស់អម្រែបខ្លួនឯងចុះ ។ អាឡេវនៅនឹងម្តាយអាពុកបានពីរបីថ្ងៃ ក៏លាចេញដើរទៅទៀត ។ លុះទៅដល់ស្រុកធំក៏ចូលទៅមើលក្នុងកំពង់សព្វគ្រប់ហើយ ចេញមករកមើលផ្ទះនាម៉ឺនសេដ្ឋី ក៏ឃើញសេដ្ឋីម្នាក់មានផ្ទះធំទ្រនំខ្ពស់ មានទ្រព្យសម្បត្តិច្រើន មានរោងរទេះគោក្របីដំរីសេះមនុស្សម្នា ខ្ញុំកំដរពាសពេញ មានច្បារដំណាំជាឧទ្យាន

មានផើងផ្កាគ្រប់ដំពូកគ្រប់ព័ណ៌ដាក់ហែជាជួរក្នុងច្បារ មានត្រីប្រាក់ត្រីមាស មានស្រះជាំដើមឈូកសឈូកក្រហមព្រលឹតលំចង់ស្បន្ទិ៍ជជុះពាសពេញ ហើយមានកូនក្រមុំមិនទាន់មានប្ដី ។ អាឡេវមានចិត្តស្រឡាញ់ចង់បាន ក៏ចូលទៅកាន់ផ្ទះសេដ្ឋីហើយជំពបសុំខ្លួនទៅធ្វើជាកូនកំឌ ។ សេដ្ឋីឃើញអាឡេវមកសុំខ្លួនទៅធ្វើជាកូនកំឌដូច្នោះ ក៏មានចិត្តអាណិតស្រឡាញ់ហើយសួរថា ឯងនៅស្រុកណា ម្ដាយឪពុកនៅស្រុកណា ។ អាឡេវជំពបសេដ្ឋីថា ខ្ញុំបាទនៅស្រុកឆ្ងាយណាស់ អាពុកម្ដាយខ្ញុំបាទមានទ្រព្យរបស់ខ្ញុំក៏ជា គោក្របីដំរីសេះផ្ទះសំបែងដូចលោកដែរ ប៉ុន្តែគាត់មានជម្ងឺឈឺស្លាប់អស់ហើយ ខ្ញុំបាទតូចចិត្តណាស់មិនចង់នៅជ្រែតជ្រាប់មានម៉ែឪ ឡេវនៅតែម្នាក់ឯង បានជាខ្ញុំបាទបោលផ្ទះសំបែង ទ្រព្យរបស់ មកសុំនៅនឹងលោក តាមតែលោកប្រើធ្វើការងារអ្វីៗខ្ញុំបាទទទួលទាំងអស់ ។ សេដ្ឋីក៏ព្រមទទួលយកអាឡេវឲ្យនៅ ។ តាំងដើមតាំងពីថ្ងៃដែលមកនៅនឹងសេដ្ឋី អាឡេវតែងក្រាក់អំពីព្រឹកបោសផ្ទះថែទាំរបស់ទ្រព្យ រៀបទុកដាក់តាមទីកន្លែងហើយខំធ្វើការដូចជារបស់ខ្លួន ។ សេដ្ឋីឃើញអាឡេវស្វាហ៍ធ្វើការថែទាំរបស់ទ្រព្យមិនមានឲ្យឃ្លេសចិត្តក៏រឹតតែស្រឡាញ់ឡើង ហើយឲ្យអាឡេវត្រួតត្រាជាស់ជើនមនុស្សម្នាខ្ញុំកំដរទាំងអស់ ។ ពល់ជន់វេលាសេដ្ឋីទៅគាល់ស្ដេចបានយកអាឡេវទៅផង លុះទៅជាញឹកញយអាឡេវស្គាល់ពួកក្រមការកូនកំឌទាំងអស់ តមកទៀតក៏ស្គាល់ដល់

នាម៉ឺនធំតូចតាំងពីលោកក្រឡាហោម យោមរាជ ចក្រី វាំង នឹងនាម៉ឺនធំតូចឯទៀត ប៉ុន្តែអាឡេវធ្វើចិត្តជា ទុកជានរណាគុះគិះដៀលដូចម្ដេចក៏មិនចេះខឹងនឹងគេ សូម្បីកូនកុយផងគ្នាធ្វើដូចម្ដេចៗក៏អាឡេវមិនចេះតបមិនចេះខឹងឡើយ ។ កាលណាអាឡេវតាមសេដ្ឋីទៅគាល់ស្ដេចហើយមានគេសួរថាឈ្មោះអី វាប្រាប់ថាខ្ញុំឈ្មោះអាឡេវគេវ ពួកនាម៉ឺនតែឃើញអាឡេវទៅហើយ ក៏ហៅតែអាឡេវគេវៗដូច្នេះឯង ។ លុះវេលាក្រោយមកអាឡេវទៅលេងនៅសាលាជំនុំស្ដាប់ចៅក្រមជំនុំជំរះក្ដីតែសព្វថ្ងៃ ក៏ចេះច្បាប់ទំលាប់ច្រើន ហើយវារើសយកកាកសំបុត្រដែលគេបោះចោលមានទាំងស្នាមត្រាបោះនៅនោះផង តាំងអំពីលោកក្រឡាហោមយោមរាជ នឹងនាហ្មឺនធំតូចទាំងអស់ដែលមានមាសប្រាក់ច្រើន ហើយវាយកក្រមួនមកសូនជាត្រា វាស់នឹងវង់ត្រាកាកសំបុត្រចាស់ហើយឆ្លាក់ឲ្យត្រូវតាមស្នាមត្រាចាស់រួចវាធ្វើជាសំបុត្រសឹងមានឈ្មោះនាហ្មឺនអស់នោះជំពាក់ប្រាក់ ខ្លះ ១០០ណែន ខ្លះ២០០ណែន ខ្លះ៥០០ណែន គ្រប់តែនាហ្មឺនធំតូចទាំងអស់ ហើយបត់ទុកក្នុងហឹបមួយពេញ បើខ្លួនវាមិនទៅ ទៅធ្វើការឯណាៗក្ដី ឬទៅលេងក្ដី វាយកហឹបនោះទៅផ្ញើនឹងប្រពន្ធសេដ្ឋីហើយផ្ដាំថាកុំឲ្យនរណាបើកឲ្យសោះ ដល់វាវិលមកក៏ទៅយកហឹបនោះមកវិញ ធ្វើដូច្នេះតែរឿយៗមក ។

(មានតទៅទៀត)

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

ឆ្នាំគំរប់ ១៣

ភាគ ១១

INSTITUT BOUDDHIQUE

ភ្នំពេញ

ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ

ព.ស. ២៤៨៤

គ.ស. ១៩៤១

ព្រះរាជបណ្ណាល័យកម្ពុជា

# KAMBUJASURIYÂ

# កម្ពុជសុរិយា

ជាទស្សនាវដ្ដីចេញផ្សាយពីព្រះរាជបណ្ណាល័យ មួយខែពីរក្បាល

ឆ្នាំគំរប់ ១៣

ភាគទី ១១

គណៈរដ្ឋមន្ត្រីនិងសម្ដេចសង្ឃនាយក ទាំងពីរគណៈ

បានអនុញ្ញាតហើយ

ភ្នំពេញ

ការផ្សាយរបស់ព្រះរាជបណ្ណាល័យ

ព.ស. ២៤៨៤

គ.ស. ១៩៤១

៤៨:០៧

# បញ្ជីរឿង

១ — អំពីការជាស្ពានដៃរបស់ក្រសួងពុទ្ធសាសនបណ្ឌិត្យៈនៅស្រុកខ្មែរ ស្រុកកូសាំងស៊ីន និងស្រុកលាវ. . . . . . . . . . . . . . . . . . . . . . ៣

២ — វិជ្ជាពេទ្យតាមរបៀបដាន់ដើមរបស់ប្រទេសឥណ្ឌា (មានត). . . . . . . . ៧

៣ — ប្រវត្តិសង្ខេបរឿងព្រះកែវមរកត (តនឹងចប់) . . . . . . . . . . . . . . ១១

៤ — អំពីសេចក្តីខ្លះនិយាយអំពីអារ្យធម៌របស់ឥណ្ឌា សម័យបុរាណ (តមក). . . . ១៤

៥ — ប្រជុំពាក្យកាព្យភាគទី ៤ របស់ឃុនស៊ីទនោម័យ (តនឹងចប់). . . . . . ១៩

៦ — រឿងព្រេងខ្មែរ "រឿងអាឡេវទី ២" របស់អ្នកឧកញ៉ាប្រាជ្ញាធិបតីយិន (តមក) ២៤

## រូបក្រៅរឿង

ឧគរវត្ត — រូបស្ត្រីទេពអប្សរ នៅបណ្ណាល័យ (ហោត្រៃ) ខាងត្បូងនៃខាងលិច ១

# TABLE DES MATIÈRES


Pages.

1° L'Œuvre de l'Institut d'études Bouddhiques au Cambodge, en Cochinchine et au Laos........................ 3

2° Médecine traditionnelle dans l'Inde antique (suite)......... 7

3° Histoire sommaire du BOUDDHA d'émeraude d'après divers documents (suite et fin)........................ 11

4° Quelques notes au sujet de la civilisation de l'Inde antique (suite)........................................ 14

5° Recueil des Poèmes Cambodgiens 4e partie par KHUNSIMINOMAY (suite et fin)........................................ 19

6° Conte populaire Cambodgien inédit: "Légende de ALÉV II "par Oknhā PRAJÑADHIPADI YIN (suite).. 24


HORS TEXTE:


ANGKOR-VAT PORTRAIT ABSARA Partie Sud et Ouest de la Bibliothèque........................................ 1



អង្គរវត្ត — នេះរូបស្ត្រីទេពអប្សរ នៅបណ្ណាល័យ (ហោត្រៃ)
ខាងត្បូងនឹងខាងលិច ។

# អំពីការជាស្ពានដែររបស់ក្រសួងពុទ្ធសាសនបណ្ឌិត្យ នៅស្រុកខ្មែរ ស្រុកលាវ និងស្រុកកូសាំងស៊ីន

កាលមុនបង្កើតក្រសួងពុទ្ធសាសនបណ្ឌិត្យនៅស្រុកខ្មែរ ស្រុកលាវ ការសិក្សាខាងសាលាបាលីគេមិនទាន់បានជ្រើសរើសបោះពុម្ពសៀវភៅអ្វីមួយទេ ម្ល៉ោះហើយអ្នកប្រាជ្ញក្នុងស្រុកទាំងនេះរកអ្វីរៀនឲ្យកើនជឿនតទៅទៀតពុំបាន ហេតុនេះបានជាខ្មែរនិងលាវច្រើនចេញទៅរករៀនសូត្រឯប្រទេសក្រៅនៅជាយូរឆ្នាំ ចួនកាលក៏នៅជាប់រហូតតែម្ដង ៗ ដល់ត្រឡប់មកស្រុកវិញ មិនចង់ឲ្យក្មេចវិជ្ជាដែលបានរៀនមក អ្នកទាំងនោះក៏នៅប្រស្រ័យទៅមកនឹងប្រទេសជិតខាងដែលមានក្បួនច្បាប់ឲ្យខ្លួនរៀនសូត្រ នាំឲ្យចំណេះវិជ្ជានិងសតិបញ្ញាក្នុងព្រះពុទ្ធសាសនាបានចំរើនជឿនឡើង មួយវិញទៀត អ្នកទាំងនោះនិត្យនៅជាមួយនឹងជនជាតិដទៃដែលកាន់គំនិតកិរិយាកាន់សាសនានឹងក្បួនបរមត្ថវិជ្ជាប្រហែលៗ គ្នានឹងបំណងដួងចិត្តយ៉ាងខ្ពស់របស់ខ្លួន ប៉ុន្តែអ្នកទាំងនេះមិនដឹងខ្លួនថាអំពើនេះធ្វើឲ្យភាពកិរិយាលក្ខណៈជាតិខ្លួនប្រែប្រួលបន្តិចម្ដងៗ ហើយកាន់តែបាត់បង់ទៅផង ហេតុដូច្នេះហើយបានជាប្រទេសបារាំងសែសដែលតែងតែគោរពដល់អាស្រ័យធម៌និងសាសនាអ្នកដទៃក្រៅពីជាតិខ្លួនហើយចង់ឲ្យបណ្ដារាស្ត្រដែលបារាំងសែសទំនុកបំរុងមានចំណេះចេះដឹងឡើង យល់

ឃើញថាត្រូវតែជួយរក្សាការពារអារ្យធម៌និងសីលធម៌ចំណេះវិជ្ជារបស់ប្រទេសខ្មែរនិងប្រទេសលាវជាប្រញាប់ មិនត្រូវបណ្តែតបណ្តោយឡើយ ។

កាលឆ្នាំ ១៩១៧ រាជការបារាំងសែសព្រមព្រៀងជាមួយនឹងរាជការខ្មែរបានបង្កើតសាលាបាលីជាន់ខ្ពស់ ដើម្បីប្រមូលព្រះសង្ឃនិងពួកឧបាសកដែលមានចំណេះចេះដឹង ។ គេមានសង្ឃឹមថាដោយសារមានទីកន្លែងរៀនសូត្រនេះ ពួកខ្មែរជាន់ក្រោយៗមកនឹងអាចរៀនបាលីតែក្នុងស្រុកខ្លួនបាន ហើយភាសាបាលីនេះនឹងអាចជួយចំរើនការសិក្សាជាន់ខ្ពស់របស់ជាតិខ្មែរឲ្យបានខ្ពង់ខ្ពស់ឡើងទៅទៀត ។ សាលាបាលីនេះដែលនៅក្រោមសេចក្តីត្រួតត្រានៃសាលាបារាំងសែស នៅចុងបូព៌ាប្រទេស មានគ្រឿងប្រដាប់ល្អលម្មនិងធ្វើការឲ្យបានផលប្រយោជន៍គាប់ប្រសើរមែន ដូចជាកាលឆ្នាំ ១៩២២ មានព្រះសង្ឃគ្រូបង្រៀនពីររូប បាននិមន្តទៅក្រុងហាណូយ ដើម្បីរៀនសំស្ក្រឹតនិងអក្សរសាស្ត្របាលីពង្សាវតារនិងវិជ្ជារចនារបស់ព្រះពុទ្ធសាសនា នៅក្នុងឧកាសលោកតាងហ្វាំងសាលាបារាំងសែសនៅចុងបូព៌ាប្រទេស ការដែលបានខិតខំធ្វើដូច្នេះក៏ពុំអាចនាំសាលាបាលីជាន់ខ្ពស់ឲ្យបានផលប្រយោជន៍ភ្លាមៗដូចសេចក្តីសង្ឃឹមពីមុនមកនោះទេ សាលាបាលីបានជួនសេចក្តីលំបាកជាច្រើនគ្រា ដោយគេធ្វេសប្រហែសមិនបានបោះពុម្ពសៀវភៅជាភាសាខ្មែរដែលសព្វថ្ងៃនេះជារបស់មានប្រយោជន៍

ដល់គ្រូនឹងកូនសិស្សខានមិនបាន ជាតិខ្មែរដែលបេះដូងយ៉ាងឯកដោយ សេចក្ដីទ័ល ក៏គោងពឹងរកសៀវភៅព្រះពុទ្ធពីប្រទេសក្រៅមកប្រើការ ដូចកាលពីដើម ក្រៅពីនេះអ្នកសរសេរសៀវភៅហើយនឹងអ្នកបកប្រែជាច្រើន បានចំប្រឹងធ្វើការសរសេរសៀវភៅដោយចង់យកទៅព្រះពុទ្ធ តែពុញថប់ក្នុងចិត្ត ព្រោះបង់ការនោះចោល ដោយឃើញថាធ្វើមិនកើត ប៉ុន្តែពជការបាកពិសេសបានប្រមែប្រមូលអ្នកដែលមានចិត្តមានបំណងល្អ នោះឡើងវិញ ហើយណែនាំសំរេចចិត្តអ្នកនោះឲ្យព្រះពុទ្ធសៀវភៅជាភាសាខ្មែរ ដោយហេតុពជការបាកពិសេសបានទទួលខ្លួននាំឲ្យអ្នកដែលខានព្យាយាមនោះទុកចិត្តឡើងវិញ ៗ ការព្រះពុទ្ធព្យាយាមរៀបតែមិនកើតសោះទេ ប៉ុន្តែបានចំរើនយ៉ាងរហ័សហើយកាន់តែកើនឡើងៗ ហេតុក្នុងពេលលំបាកជាបំផុតនេះ ។

មរដកអក្សរសាស្ត្រនៅស្រុកខ្មែរ ក៏ដូចជាខាងធម៌អាថ៌ដែរ ជិតបាត់បង់អស់ទៅហើយ ហេតុដូច្នេះបានជាគេត្រូវតែបង្កើតការមួយក្រសួងទៀតប្រយោជន៍ដើម្បីនឹងថែរក្សាមរដកនេះឲ្យគង់វង្សតទៅមុខទៀត ។ គេត្រូវប្រមែប្រមូលគម្ពីរសាស្ត្រជាប្រញាប់ មករៀបឲ្យគង់ឡើងវិញ ។ កាលឆ្នាំ ១៩២៤ ព្រះករុណាក្រុងកម្ពុជាដោយពជការបាកពិសេសជួយឈឺឆ្អាល ទ្រង់បានចេញព្រះរាជប្រកាសសំរេចឲ្យបង្កើតព្រះរាជបណ្ណាល័យនៅស្រុកខ្មែរ ប្រយោជន៍ដល់ថ្ងៃក្រោយ គេនឹងនាំយកគម្ពីរបាលីហើយ

ទឹងសាស្ត្រខ្មែរដែលចារដោយស្លឹករឹតជាច្រើនមកដំកល់ទុក ។ គេប្រគល់ការត្រួតត្រាឲ្យស្ត្រីបារាំងសែសម្នាក់ ដែលជាអ្នកដំណាងសាលាបារាំងសែសនៅចុងបូព៌ាប្រទេស ។

មហាជននៅក្នុងស្រុកទាំងមូល បានយល់ប្រយោជន៍ព្រះរាជបណ្ណាល័យដែលទើបកើតថ្មីនេះ ហើយបានដឹងថាក្រសួងនេះមុខជានឹងនាំឲ្យចំណេះវិជ្ជាជាតិខ្មែរចំរើនឡើង ។ ខែត្រនីមួយ ៗ ខំរកគម្ពីរយកមកដំកល់នៅមន្ទីរនេះ ចង់ឲ្យមានឈ្មោះតាប់ប្រសើរដូចគេ ហើយបណ្តាអ្នកស្រុកបានឃើញគេដង្ហែគម្ពីរហើយនឹងរបស់សំរាប់បូជាព្រះពុទ្ធយកទៅដំកល់ទុកក្នុងកន្លែងនេះ ។ ដោយបានរបស់ដែលគេឲ្យដោយសទ្ធានោះមក បានជាគេបានបង្កើតសារមន្ទីរយ៉ាងតូចមួយក្នុងមន្ទីរទុកសៀវភៅនឹងគម្ពីរនេះ ។

# វិជ្ជាពេទ្យតាមរបៀបជាន់ដើម
# របស់ប្រទេសឥណ្ឌៀ

មានច្បាប់កថា ១ ពួក ដែលលោក* គ្រូពេទ្យជាតិហិណ្ឌូ នៅប៉ុន្នឹសីរី ប្រទេសឥណ្ឌៀបានសំដែង ហើយលោកបានប្រមូលបោះពុម្ពជាសៀវភៅឡើង គួរយើងស្រង់យកសេចក្តីខ្លះមកពោលដើម្បីជាប្រយោជន៍ដល់អ្នកមើលទស្សនាវដ្តីអក្សរខ្មែរនេះ ហើយប្រទេសជាតិនេះ តែងបានទទួលអារ្យធម៌ពីប្រទេសឥណ្ឌៀមកអំពីដើមស្រាប់ ៗ

## ទឹក

ទឹកជារបស់មានប្រយោជន៍ធំបំផុតមួយ ក្នុងជីវិតរបស់ប្រជាជនប្រ-ទេសឥណ្ឌៀ ដូចជាប្រទេសខ្មែរនេះដែរ ពីព្រោះការងូតទឹកជាកិច្ចខានមិនបាន សម្រាប់ជីវិតរបស់មនុស្សយើង ៗ ហេតុដូច្នេះទើបគម្ពីរសាស្ត្ររបស់ឥណ្ឌៀគេបែងចែកវិធីងូតទឹកចេញជា ៣ ផ្នែកគឺ ១- ងូតទាំងអស់គេតែងទៅងូតទឹកពីរដងក្នុងមួយអាទិត្យ ហើយលាបស្រឡាបៈប្រេងសព្វអស់ទាំងខ្លួនផង ២- ការលាងខ្លួនរហូតដល់ត្រឹមក ៣- ការលាងត្រឹមត្រគាកកល់ៗផង ក្នុងពេលដែលគេត្រូវការតាមធម្មតា ៗ

ឯការងូតប្រេងជារបស់មានប្រយោជន៍មែនតាមវិជ្ជាពេទ្យ គម្ពីរសា-ស្ត្រជាន់ចាស់ពោលទុកថា ថ្ងៃសៅរ៍ជាថ្ងៃងូតប្រេងសិទ្ធិនៃពួកមនុស្សប្រុស ថ្ងៃសុក្រជាថ្ងៃងូតប្រេងសិទ្ធិនៃពួកមនុស្សស្រី ៗ ក្បួនហិណ្ឌូប្រដៅទុកថា

ឲ្យផ្លឹកទឹកពីព្រឹកព្រហាមមុនបរិភោគអាហារ ឯប្រេងដែលសម្រាប់ប្រើខ្នួតប្រដាប់ឈើក្បាលនឹងខ្លួននោះសុទ្ធតែជាប្រេងល្អ ៗ គេមិនមែនបេះតែដុសញីក្បាលនឹងប្រេងតែម្យ៉ាងទេ គេយកប្រេងនោះដាក់ទទេៗសព្វអន្លើជាប្រក្រតីផង គឺគេដាក់ប្រេង ៤ ដំណក់ទៅក្នុងត្រចៀក ក្នុងត្រចៀកម្ខាងៗ ៦ ដំណក់ ធ្វើដូច្នេះជាដើម ៗ

ការដុសញីដោយប្រេងនេះ មិនត្រូវធ្វើឲ្យទាល់តែក្តៅទឹងទៅជាកើតទោសទេ ៗ ឯក្អែកទាំងពីរត្រូវយកចិត្តទុកដាក់ថែរក្សាឲ្យហ្មត់ចត់ដោយទៀត ហើយខ្នួតលាបដោយប្រេងជាចំនួនច្រើន ៗ បន្ទាប់ពីនេះត្រូវឈប់បង្អង់ ១ ស្របក់ ទុកឲ្យប្រេងជ្រួតជ្រាបសព្វល្អ ហើយត្រូវផ្លឹកលាងខ្លួនដោយទឹកក្តៅ ការខ្នួតប្រដាប់ដោយប្រេងមុនផ្លឹកទឹកនោះ ត្រូវធ្វើក្នុង ១ អាទិត្យ ១ ដង ឬ ២ ដង លាបស្រឡាបឲ្យសព្វអវយវៈទាំង ៤ គឺ ក្អែក, ត្រចៀក, ចម្មុះ, មាត់ ហើយនឹងដងខ្លួនទាំងអស់ឲ្យសព្វសព្វាង្គកាយ ធ្វើដូច្នេះជាការជួយឲ្យសក់ធាប់ដុះល្អគួរស់ល្អ ធ្វើឲ្យសំឡេងពីរោះក្បោះក្បាយទឹងបំបាត់កេតឈឺក្បាលផង ៗ ឯការផ្លឹកទឹកជានិច្ចនេះធ្វើឲ្យពងកាយស្អាតល្អចំរើនអាហារផង មួយវិញទៀត គួរផ្លឹកទឹកត្រជាក់មុនថ្ងៃរះក្នុងស្ទឹង-ទន្លេ-ព្រែក សម្រាប់ពួកអ្នកដែលធ្វើការដោយគំនិត ៗ គួរផ្លឹកទឹកក្តៅឧ៊ុនៗក្នុងវេលាល្ងាច សម្រាប់អ្នកដែលធ្វើការដោយកំឡាំងកាយដូចជាពួកកម្មករ ៗ មនុស្សគ្រប់ៗគ្នាគួរយកចិត្តទុកដាក់ក្នុងការផ្លឹកទឹកក្នុង ១

ថ្ងៃពីរដងគឺពេលព្រឹកនិងថ្ងៃត្រង់ ។ ឯមនុស្សប្រាសុទ្ធផុតកិលេសដែលត្រូវចូលបរិនិព្វានទោះតែងតែទៅក្នុងទឹកទន្លេដែលស្អាតជានិច្ច លោកតែងងូតទឹកក្នុង ១ ថ្ងៃ ៣ ដង គឺព្រឹក ថ្ងៃត្រង់និងល្ងាច ។

## អំពីទឹកដោះ

ទឹកដោះសម្រាប់ផ្ទុបលៀងជីវិតមនុស្សទាំងអស់ក្នុងលោក ហើយជារបស់សមគួរដល់ការបរិភោគនៃមនុស្សគ្រប់វ័យ ។ គម្ពីរសាស្ត្ររបស់ឥណ្ឌាគេបែងចែកទឹកដោះជា ៣ ប្រភេទគឺ ទឹកដោះមនុស្ស ១ ទឹកដោះសត្វ ១ ទឹកដោះរុក្ខជាតិ ១ ។ គម្ពីរសាស្ត្រនេះពោលទុកថា ទឹកដោះមនុស្សស្រីជាធម្មជាតិប្រសើរណាស់ មានគុណសម្បត្តិច្រើនប្រការ ។ ឯទឹកដោះមេគោ តាមវិជ្ជាពេទ្យជាន់ដើម ថាមានគុណសម្បត្តិប្រហែលនឹងទឹកដោះមនុស្សដែរ ។ បណ្តាទេព្តារបស់ហិណ្ឌូ ទ្រង់ចេះសេពសោយទឹកដោយព្រះអង្គឯង ទ្រង់មានសមុទ្រទឹកដោះដែលទ្រង់ដងយកទឹកអម្រឹតពីសមុទ្រទឹកដោះនោះ សឹងមានរសជាតិដ៏ឆ្ងាញ់ពីសាជាងទឹកឃ្មុំទៅទៀត ។ ក្នុងទឹកទិព្វនៃសមុទ្រទឹកដោះនេះហើយដែលគេតាក់ក្ខីងមនុស្សស្លាប់នៅលើផែនដីដែលជាសមុទ្រទឹកដោះ ព្រឹកឡើងក្រោយថ្ងៃបូជាសពទើបគ្រួសារញាតិមិត្តនាំគ្នាបាចសាចទឹកដោះគោលើទីបូជាសពនោះ ។ ប៉ុន្តែគម្ពីរសាស្ត្រនេះសំដែងទុកថា ការផឹកទឹកដោះច្រើនពេកនាំឲ្យកើតទោសដល់ថ្លើមទៅវិញ ។ ឯពួកទារកដែលទើបនឹងកើតថ្មីគេបង្គាប់ឲ្យ

ប្រើទឹកដោះលាយទឹកឲ្យផឹក ហើយសឹមបន្ថយចំនួនទឹកឲ្យតិចទៅៗ (ឯទឹកដោះឲ្យមានចំនួនច្រើនឡើងៗ) ដរាបដល់ ៩ ខែ ទើបត្រូវឲ្យកូនខ្ចីនេះផឹកទឹកដោះគោសុទ្ធមិនបាច់លាយទឹក ។ តាមគម្ពីរសាស្ត្រថា ត្រូវដាំទឹកដោះគោលាយនឹងខ្ទឹមស ធ្វើឲ្យបាត់ហើមពោះដើរខ្យល់ស្រួល ។ មួយវិញទៀត គេនិយាយពន្យល់ថា យកទឹកដោះគោ បេកពីរបី នឹងស្ករបន្តិច បុកកិនឲ្យល្អិតលាយជាមួយគ្នា ធ្វើជាទឹកអដ្ឋបានក៏មានឱជារសឆ្ងាញ់ដែរ ។

ទឹកដោះគោដែលមានគុណសម្បត្តិល្អស្រស់នោះ លុះតែបរិភោគឲ្យអស់ក្នុងកំណត់ ២ ម៉ោង គត់ពីនោះមកទឹកដោះនោះនឹងទៅជាមានពិសពុលទៅវិញ សូម្បីព្រះសិរៈជាម្ចាស់ ក៏រិះៗ នឹងទទួលគ្រោះថ្នាក់ដោយសារទឹកដោះបែបនេះដែរ ។ ការប្រើទឹកដោះស្រស់អំពីយប់ងឹតជិតព្រឹកនោះ ជាគ្រឿងរក្សាខ្លួនឲ្យស្រួលសប្បាយ ហើយធ្វើឲ្យឈាមស្រស់បស់ល្អ ។ តាមគម្ពីរសាស្ត្រពោលទុកថា ទឹកដោះមេគោសជាថ្នាំបំបាត់កេតលឿង ទឹកដោះមេគោប្រផេះជាថ្នាំរក្សាធាតុឲ្យដើរស្រួលឡើង ។ ពេលវេលាដែលរឹតទឹកដោះជាការសំខាន់ណាស់ ព្រោះមេគោដែលរឹតទឹកដោះនោះមិនត្រូវឲ្យត្រូវកំដៅថ្ងៃ ហើយត្រូវឲ្យស៊ីតែស្មៅខ្ចីៗ នឹងស្រស់ផង ។ តាមសាស្ត្រថា ទឹកដោះគោដែលគេបានធ្វើទៅជាក្រែម (ក្បាលទឹកដោះ) នោះ សម្រាប់លាយអាហារធ្វើឧច្ចារៈឲ្យធូរស្រួល ។

មានតទៅទៀត

# ប្រវត្តិសង្ខេបនៃព្រះកែវមរកត

(តមកទឹងចប់)

មនុស្សទាំងពួងចូលទៅនមស្សការបានមួយជំងមួយកាល ៗ ព្រះកែវមរកតនេះ ប្រតិស្ឋាននៅក្នុងស្រុកឆៀងហ្មៃអស់វេលាយូរប្រមាណ៨៤ឆ្នាំ ៗ

លុះដល់មកក្នុង ព.ស. ២០៩៤ ក្សត្រគ្រងស្រុកឆៀងហ្មៃ១អង្គ ព្រះនាមជ័យជេដ្ឋា ជាព្រះរាជបុត្រព្រះពោធិសារៈ ដែលជាក្សត្រគ្រងក្រុងសតនាគនហុត ដោយហេតុក្សត្រឆៀងហ្មៃអង្គមុននេះ បានលើករាជធីតាឈ្មោះព្រះនាងយ៉ុតខាំ ឲ្យធ្វើជាមហេសីនៃព្រះបាទពោធិសារៈ ទើបមានព្រះរាជបុត្រគឺព្រះជ័យជេដ្ឋាអង្គនេះ លុះព្រះជ័យជេដ្ឋាមានព្រះជន្មាយុ ១៥ ព្រះវស្សា ក្សត្រគ្រងស្រុកឆៀងហ្មៃជាអយ្យកោក៏សោយទិវង្គត មិនមានអ្នកណាទទួលគ្រងរាជ្យជាជំណាតវង្ស ទើបមន្ត្រីតូច-ធំព្រមទាំងគណៈសង្ឃទាំងពួងយល់ព្រមព្រៀងថា ត្រូវទៅសុំព្រះជ័យជេដ្ឋាជាបុត្របងរបស់ព្រះពោធិសារៈហើយជាព្រះរាជនត្តារបស់ក្សត្រឆៀងហ្មៃនោះមកគ្រងក្រុងឆៀងហ្មៃ ៗ លុះអំណើសកាលតមក ព្រះបាទពោធិសារៈក៏ទិវង្គតទៅ ប្អូនៗរបស់ព្រះបាទជ័យៈជេដ្ឋាក៏តទាស់ទែងគ្នាដណ្តើមរាជសម្បត្តិ ទើបគណៈរដ្ឋមន្ត្រីក្រុងសតនាគនហុតព្រមព្រៀងគ្នាទៅអញ្ជើញព្រះបាទជ័យជេដ្ឋាឲ្យយាងត្រឡប់មកស្រុកហ្លួងព្រះបាងវិញ ដើម្បីឲ្យទ្រង់រម្ងាប់ការចលាចល ៗ កាលព្រះជ័យជេដ្ឋាត្រឡប់ទៅនោះមិនទាន់

ដាក់ព្រះទ័យថានឹងបាននៅស្រុកហ្លួងព្រះបាងរហូតទៅឬមួយនឹងត្រ-ឡប់ទៅឆៀងហ្មៃវិញទេ ទើបទ្រង់អញ្ជើញព្រះកែវមរកតទៅជាមួយផង កាលពីឆ្នាំខាល ព. ស.២០៩៥ ដោយទ្រង់គាន់ថា យកទៅបង្ហាញព្រះញាតិវង្សឯស្រុកហ្លួងព្រះបាងឲ្យនមស្សការនឹងធ្វើសក្ការបូជា លុះស្តេចទៅដល់ស្រុកហ្លួងព្រះបាង គណៈរដ្ឋមន្ត្រីនាំគ្នាអញ្ជើញទ្រង់ឲ្យគ្រងរាជ-សម្បត្តិក្រុងសតនាគនហុត ។ ព្រះបាទជ័យជេដ្ឋាទ្រង់យល់ថា បើទ្រង់មិនទទួលគ្រងរាជសម្បត្តិទេ ស្រុកទេសមិនផុតពីសេចក្តីចលាចល ទើបទ្រង់ទទួលសោយរាជ្យនៅស្រុកហ្លួងព្រះបាង ហើយបន្ថែមព្រះនាមទៀតថា ព្រះជ័យជេដ្ឋាធិរាជ ។ ឯមន្ត្រីតូច-ធំខាងស្រុកឆៀងហ្មៃមិនសុខចិត្តនៅជាចំណុះក្រុងសតនាគនហុត ក៏ទៅអញ្ជើញមេកុងមឿងណាយ ជារាជវង្សរបស់ក្សត្រឆៀងហ្មៃអំពីដើមនោះមកឲ្យគ្រងរាជសម្បត្តិស្រុកឆៀងហ្មៃវិញ ទើបកើតចំបាំងនឹងក្រុងសតនាគនហុត ។ ព្រះបាទជ័យជេដ្ឋាធិរាជ ក៏មិនអាចយកជ័យជំនះស្រុកឆៀងហ្មៃបាន ទើបទ្រង់គិតតែថែរក្សាព្រះកែវមរកតមក ក្នុងស្រុកហ្លួងព្រះបាងជាវេលា ១២ឆ្នាំ ។

លុះដល់មកក្នុង ព.ស.២១០៧ ព្រះបាទហង្សាវតីប៊ុរេងណោង មានអំណាចឡើងក្នុងស្រុកមន ព្រះបាទជ័យជេដ្ឋាធិរាជទ្រង់យល់ថាការច្បាំងទប់ទល់ក្នុងស្រុកហ្លួងព្រះបាងនេះមុខជាស៊ូទ័ពសឹកសត្រូវពុំបាន ទើបទ្រង់ផ្លាស់រាជធានីចុះទៅតាំងក្រុងនៅស្រុកវៀងចន្ទន៍ ហើយអារាធនាព្រះកែវ

មរកតទៅជាមួយផង ព្រះកែវមរកតប្រតិស្ឋានទៅស្រុកវៀងចន្ទន៍អស់កាលយូរដល់ ២១៥ ឆ្នាំ ។

លុះមកដល់ ព.ស. ២៣២១ កាលព្រះចៅក្រុងធនបុរី (ប្រទេសថៃ) កើតចម្បាំងនឹងក្រុងសតនាគនហុត ។ គ្រានោះ សម្តេចចៅព្រះយ៉ាមហាក្សត្រសឹក (មេទ័ពថៃ) ឡើងទៅវាយស្រុកសតនាគនហុត វាយបានក្រុងវៀងចន្ទន៍ហើយ ក៏អញ្ជើញព្រះកែវមរកតនឹងព្រះបាងចុះមកកាន់ក្រុងធនបុរី ។ ព្រះចៅក្រុងធនបុរីធ្វើបុណ្យសម្ពោធរួចរៀបរយហើយ ទើបអញ្ជើញព្រះកែវទៅប្រតិស្ឋានទុកក្នុងរោងព្រះកែវក្នុងបរិវេណព្រះរាជវាំងចាស់ ។ លុះព្រះបាទព្រះពុទ្ធយ៉តហ្វាចុឡាលោក (រាជការទី១ ក្រុងបាងកក) ទ្រង់កសាងទីក្រុងបាងកកកាលពីឆ្នាំខាល ព.ស. ២៣២៥ ទើបទ្រង់ឲ្យកសាងរោងឧបោសថ១ក្នុងព្រះរាជវាំងបូជាព្រះកែវ ។ កាលធ្វើរោងឧបោសថសម្រេចហើយ ទើបឲ្យអញ្ជើញព្រះកែវមរកតមកប្រតិស្ឋានទុកក្នុងព្រះឧបោសថវត្តព្រះរតនសាស្តារាម កាលពីថ្ងៃចន្ទ១៤កើតខែផល្គុនឆ្នាំរោង ព.ស. ២៣២៧ ដរាបមកដល់សព្វថ្ងៃនេះ ។

ប្រវត្តិព្រះកែវមរកតចប់ដោយសង្ខេបតែប៉ុណ្ណេះ ។

ខ. ស. អ្នករៀបរៀង

# អារ្យធម៌របស់ឥណ្ឌា

(តមក)

ក្សត្រកោះលង្កាបានបញ្ជូនទូត ១ ក្រុមឲ្យទៅគាល់ក្សត្រសមុទ្រគុប្តៈ ដើម្បីពន្យល់អំពីផ្លូវជួបសាសនោបាយសំខាន់ ៗ ទីមួយ ៗ ដោយត្រូវការឲ្យស្ថាបនាទីគោរពសក់នោះមានមន្ទីរសម្រាប់ស្នាក់ ១ សម្រាប់ទទួលអ្នកដំណើរដែលធ្វើដំណើរមកនមស្ការទីនោះបានគ្រប់ ៗ និកាយនិងគ្រប់ ៗ ជាតិ ទាំងអ្នកបួសទាំងគ្រហស្ថ ១ ។ ក្សត្រអង្គនោះក៏រៀបចំបូជនីយស្ថាន តាមទំនង់នោះ ដោយធ្វើឲ្យមានអំណាចឡើង ខាងរបៀបចេទាប្រសាសនោបាយនិងរបៀបសេដ្ឋកិច្ច ហើយក្សត្រនិងព្រះសង្ឃបានព្រមព្រៀងគ្នាបើកនិងធ្វើការជាសាធារណកុសលតាមលំអានរបស់ព្រះបរមគ្រូ នៅក្នុងតំបន់នានាដែលមិនទាន់ស្គាល់ឈ្មោះនិងមិនដែលស្តេចទៅគង់នៅទីនោះសោះ តាំងអំពីស្រុកមគធៈទៅមថុរា អំពីមថុរាទៅបញ្ចាប់ទៅកស្មីរ ក្នុងអាហ្វហ្កានិស្ថាន់រហូតដល់អាស៊ីកណ្តាល សឹងមានវិហារជាទីធ្វើសក្ការបូជាដើម្បីរំឭកដល់ពុទ្ធដំណើរដែលស្តេចយាងទៅកាន់ទីនោះ ៗ និងហេតុជាទីអស្ចារ្យ ។ គេបានរកឃើញស្នាមព្រះពុទ្ធបាទនៅលើកំពូលភ្នំ ១ នៅស្រុកសីឡង់ ក៏ជាទីដែលព្រះពុទ្ធស្តេចយាងមកទូន្មានយក្ខ ១ ឈ្មោះពរណៈ ។ បូជនីយស្ថានជាន់ដើមសុទ្ធ ៗ ដែលគេបំភ្លេចចោលអស់

ទៅនោះ បានការកេទឹងបានឃើញឡើងវិញ ដោយសាររិដ្ឋាការសម័យថ្មីនេះឯង ។

តាមលោកលេវីថា ជាការយល់ខុសយ៉ាងធំ ក្នុងការបំបែកលង្កាពីប្រទេសឥណ្ឌា ហើយឲ្យធ្វើជាប្រទេស ១ ដោយឡែកដូចសព្វថ្ងៃនេះ ។ តាមដែលមានទៅក្នុងភូមិសាស្ត្ររបស់ពដការ កោះលង្កានោះហើយជាទីប្រជុំរួមផ្លូវបែកទៅតាមផ្លូវធំៗ ដែលចេញទៅក្នុងមហាសមុទ្រឥណ្ឌា ។ ការដែលលង្កាដាច់ចេញពីឥណ្ឌានោះ ជាហេតុធ្វើឲ្យលង្កាក្លាយទៅជាប្រទេសរាជទី ១ របស់ឥណ្ឌា នៅក្នុងឆ្នាំដែលព្រះពុទ្ធជាម្ចាស់ស្តេចចូលបរិនិព្វានទៅនោះ ។

ព្រះបាទអសោកទ្រង់មានព្រះបំណងនឹងផ្សាយធម្មានុភាពចូលទៅក្នុងកោះលង្កានោះ ទើបព្រះរាជបុត្រ ១ អង្គ ព្រះរាជបុត្រី ១ អង្គរបស់ទ្រង់ ទទួលខ្លួននាំយកព្រះពុទ្ធដីកាចេញទៅផ្សាយនៅកោះលង្កា ហើយបានតែងតាំងគណៈសង្ឃឡើងជាដំបូងនៅកោះលង្កានោះ ។ គ្រានោះ ក្សត្រប្រទេសសីឡូន (លង្កា) មានព្រះនាមប្រហែលនឹងព្រះបាទអសោកដែរ គឺព្រះបាទទេវានម្បិយ (ជាទីស្រឡាញ់នៃទេវតាទាំងឡាយ) ។ លង្កាធ្វើការផ្សេងៗ ដូចជាឥណ្ឌាដែរ គឺជីកអណ្តូងធ្វើកំពែងព័ទ្ធជុំវិញ តាំងពាងទឹកសម្រាប់ឲ្យទឹកជាទាន ធ្វើគុហា ស្តូបក្តី សាងវិហារធំៗ សាងកដកំពង់ យ៉ាងធំសំបើម មានតាំងចម្លាក់បេនានឹងគំនូរផ្សេងៗ លុះដល់មកក្នុងឆ្នាំ

ពុទ្ធសករាជ ៥៤៣ ទើបព្រះបាទវដ្តគាមិនីទ្រង់ឲ្យប្រជុំសង្ឃសង្គាយនាធម្មវិន័យ តាមទំនង់ស្តេចកនិស្កៈបានធ្វើនៅប្រទេសឥណ្ឌាខាងជើងឆៀងខាងលិចនោះ ។ តាមពង្សាវតារលង្កា ដំណាលសេចក្តីថា ព្រះភិក្ខុសង្ឃគង់គ្រានោះសុទ្ធតែមានសតិបញ្ញាដ៏ធំទូលាយ បានចេះចាំព្រះត្រៃបិដកដាក់ទទេ ព្រមទាំងអដ្ឋកថា ប៉ុន្តែលោកពិនិត្យឃើញសេចក្តីអន្តរាយសាបសូន្យនៃសតិបញ្ញារបស់សត្វលោកទៅមុខទៀត ទើបប្រជុំសង្ឃអស់នោះរួបរួមព្រះធម្មវិន័យ ។ ការធ្វើសង្គាយនាគ្រានោះបានចារឹកចុះជាតួអក្សររួបរួមធ្វើជាគម្ពីរៗ ឡើង ។

ប្រទេសឥណ្ឌាជាប្រទេសមានកិត្តិយសដោយពិត ដោយមានចំណែក ១ នៃសីលធម៌បានផ្សាយចេញទៅ ដូចជារឿងរ៉ាវរបស់ព្រះសូអាស័ហ្វ បានរីកចេញទៅយ៉ាងធំសំបើមក្នុងលោកនៃអ្នកកាន់សាសនាព្រះគ្រិស្ត និងរឿងរ៉ាវមួយទៀត គឺរឿងរ៉ាវរបស់ព្រះពុទ្ធ ដែលប្រគល់ទុកឲ្យលើដែនដីទិសឯលិចទាំងមូល គឺស្នាមគំនូរចេនាដ៏ប្រសើរទើងខ្ជាប់ខ្ជួន ។ ប្រសិនបើព្រះពុទ្ធសាសនាផ្សាយទៅទិសខាងលិច ដូចជារឿងរ៉ាវរបស់ព្រះសូអាស័ហ្វ កិច្ចការរបស់ពុទ្ធសាសនានៅចុងបូព៌ាប្រទេសនឹងបានទៀងទាត់ហើយចំរើនឆាប់ផង ។

តាំងអំពីពុទ្ធសករាជ ៣៤៣ មានរាជទូតចិនម្នាក់បាននិយាយរឿងរ៉ាវខាងគម្ពីរដីកាក្នុងព្រះពុទ្ធសាសនា ហើយកត់ត្រាទុកក្នុងស្រុកចិននោះ

តអំពីនោះ ទើបពួកអ្នកដំណើរខ្លះ អ្នកជំនួញខ្លះ ពួកទាហានខ្លះ បានជួយផ្សាយឡើងទៀត តែមិនចេញឈ្មោះ ។ គ្រានោះស្រុកចិនមានសមណៈនិងឧបាសកហើយ ។ មានពួករាជទូតរបស់ព្រះចៅចក្រពត្តិចិនព្រះនាម មីងទី (ព.ស. ៦០១-៦១៩) បានទៅនាំយកលោកសង្ឃ ២ រូបពីប្រទេសឥណ្ឌា មកកាន់ក្រុងរបស់ព្រះចក្រពត្តិ ឯលោកសង្ឃទាំងពីររូបក៏មានកេរ្តិ៍ឈ្មោះល្បីល្បាញឡើងប្រាកដនៅក្នុងពង្សាវតារពុទ្ធ-សាសនារបស់ចិន ។ លោកពីររូបនោះមិនមែននាំយកតែត្រឹមគោលធម៌និងលទ្ធិសាសនាមកឲ្យចិនប៉ុណ្ណោះទេ បានទាំងផ្ដើមប្រែគម្ពីរដីកាចេញជាភាសាចិន មានអាយុយឺនយូរមកដល់ ១.១០០ ឆ្នាំ ហើយបានជ្រួតជ្រាបចូលទៅក្នុងសំដីភាសា គំនិតគិតគូរ កិច្ចការប្រចាំជីវិតរបស់ចិន របស់កូរ៉េ និងជប៉ុនទៀតផង ។ នេះហើយជាផលដ៏ចំឡែកបំផុតនៃពុទ្ធសាសនារបស់ឥណ្ឌា ។ ប្រទេសឥណ្ឌាបាននាំយករបស់ដែលចិនមិនទាន់មានមកឲ្យចិន គឺរបស់ណាដែលលោកខុងជឺនិងឡៅឈឺមិនបានប្រគល់ឲ្យចិនសោះឡើយ ។

ដល់មកឆ្នាំ ៩៤២-៩៥៣ នៃពុទ្ធសករាជ មានអ្នកបួសជាតិចិនម្នាក់ឈ្មោះ ហ្វាហៀន (Fa-Hien) ចេញទៅប្រទេសឥណ្ឌា ដល់ទៅក្រុងបាដលីបុត្រនិងលង្កា ។ លោកនេះបាននិយាយពន្យល់ពីរបស់ចំ-ឡែកៗទាំងអស់ដែលលោកបានឃើញ បានចម្លងគម្ពីរនិងរូបគំនូរផ្សេងៗ

លោកនេះនៅតែក្នុងវត្តនិងបណ្ណាល័យផ្សេងៗ លោកសំគាល់ឃើញប្រ-ជាជនជាតិឥណ្ឌៀមិនផឹកស្រាមេរ័យ មិនបរិភោគខ្ទឹមសខ្ទឹមក្រហម ។ នៅក្នុងផ្សារមិនមានកន្លែងលក់សាច់ មិនមានអ្នកជំនួញស្រាមេរ័យ ។ នៅក្រុងបាដលីបុត្រនោះ លោកហ្វាហៀននិយាយសរសើរព្រះរាជវាំងរបស់ព្រះបាទអសោក ។

រាល់ៗឆ្នាំ គេបានធ្វើបុណ្យសម្ពោធថ្វាយព្រះពុទ្ធជាម្ចាស់ (ជាទីរឭកដល់ថ្ងៃប្រសូត បានត្រាស់ និងនិព្វាន) ។ គេបានធ្វើរាជរថជាច្រើនប្រដាប់ដោយទេវរូបនានា ដែលគេរចនាដោយមាស-ប្រាក់-និងកែវពណ៌ផ្សេងៗ ហើយមានបុស្បុកតាំងលើរាជរថ មានព្រះពុទ្ធរូបគង់នៅខាងក្នុង នៅជ្រុងរាជរថគ្រប់ៗជ្រុង មានរូបពោធិសត្វ ១ អង្គឈរប្រចាំ ។ រាជរថដែលគេធ្វើឡើងនេះមានចំនួន ២០ រថ ។ មនុស្សទាំងអស់គ្នានាំគ្នាមកប្រជុំលេងភ្លេង បូជាដោយភ្ញីផ្កានិងគ្រឿងក្រអូប ។ ក្នុងវេលាយប់គេអុជប្រទីបតាមដេរដាសព្វទៅ ។ ពួកអ្នកមានទ្រព្យធនច្រើនក្នុងស្រុកបាននាំគ្នាបើកមន្ទីរពេទ្យ ១ សម្រាប់ឲ្យពួកអ្នកទីទ័លក្រ មនុស្សអនាថានិងមនុស្សជម្ងឺក្នុងស្រុក មកព្យាបាលជម្ងឺ ឬសុំថ្នាំបានតាមត្រូវការ មានគ្រូពេទ្យពិនិត្យសួរអ្នកជម្ងឺជាដើម ។ល។

កិច្ចការអស់នេះហើយ ដែលយើងបានមើលឃើញមាននៅក្នុងប្រ-ទេសឥណ្ឌៀ ក្នុងពុទ្ធសករាជ ៩៤៣ នោះ ។

(មានត)

# ប្រជុំពាក្យកាព្យ

## ភាគទី ៤

*របស់ឃុនស៊ីមៈនោម៉យ*

(តមកទឹងចប់)

អនិច្ចាចិត្តអើយអីដល់ម៉េះ
ដូច្នេះជីវិតឃើញជាក្ស័យ
ព្រោះជីវិតសង្ខារសែនសង្ស័យ
កែវថ្លៃបូស្គាប់បង់ថ្លៃទុក្ខ ។

ពុទ្ធោហើយថែមទាំងក្រៀងធំ
ទាក្រៀមក្រំសំស្រៀតចុក
ជីវិតបានដោយខ្លួនមិនបួនមុខ
កើតទុក្ខកេក្ស៊ីប្រៀបពុំបាន ។

នេះគឺជាកម្មផងខ្លួនហើយ
កែវអើយដូចកុំសង្កត់ប្រាណ
នឹងគិតដូចម្តេចក៏មិនបាន
រំខានចិត្តណាស់មាសបងអើយ ។

សព្វថ្ងៃកើតទុក្ខមុខក្រៀមក្រស់
គ្មានស្រើបគ្មានស្រស់ស្រាលត្រង់ណា
សើចលេងតែមាត់ចិត្តខ្លោចផ្សា
ទុក្ខគង់ទាក់ណែនស្មើរឆ្ងាយ ។

រួចនេះដល់នោះមកថ្មីៗ
ផ្អប់ផ្អួនពីរបីមិនមានស្បើយ

វេហាហល់ចិត្តណាស់ហើយ
កម្មអើយពៀរព្រេងអីដល់ម៉្លេះ ៗ
កាលបានឃើញមុខមួយវេលា
ចិត្តអើយខ្លោចផ្សាទ្រូងស្ទើរប្រេះ
រន្ធត់សែនខ្វល់ចិត្តអីម៉្លេះ
កាន់តែដូច្នេះទប់ពុំបាន ៗ
សព្វថ្ងៃខ្លួនបងដូចសមុទ្រ
មៀងមើលដងរឹតមិនយល់ត្រើយ
មួយឆ្នាំជួបម៉្វៃឃ្លាតវិញហើយ
ម៉្លេះសមកន្ដើយបងអសារ ៗ
អនិច្ចាទុក្ខព្រួយព្រោះក្ដីអាល័យ
កាត់ផ្ទៃវិតែកែស្នេហ៍ក្នុងហ្ឫទ័យ
ព្រួយគិតរឹតពុំស្បើយល្ហើយដល់មួយថ្ងៃ
តែងសង្រែងតែងសង្រៃក្ដីកាងខ្នាង ៗ
បងពេកនឹកដល់ប្អូនស្ងួនកន្យា
លុះវេលាជាទីងហៀបទៀបព្រឹកព្រាង
ស្ដាប់សព្ទសត្វយំទៅដោយយ៉ាង
ទៀបទីងស្វាងហើយទើបសត្វយំថ្លាស់ថ្លើយ ៗ

ដោយគូរនៅជាសុខសព្វព្រឹក្សា

ភ្ញាក់កាលណាឃើញនៅមុខខ្ញុំបាទស្បើយ

តែខ្លួនបងកំព្រាសោះទុកតែខ្ញុំ

ទុកម្នាអើយធ្វើកម្មអ្វីក៏ដល់ម៉្លេះ ។

សារមេត្រីតែងដោយក្តីពិសារទំ

ផ្ញើមកត្រង់រង់ឲ្យដឹងពីចិន្តា

ពីចិត្តបងគិតមូលមួយត្រួយជ័រ

ពុំចង់ឃ្លាឲ្យជាឃ្លាតមួយគ្រា ។

តែរៀមកាត់ដោយជាតិសត្វកើតក្នុងកម្ម

វេងតែចាំទ្រាំតែទុក្ខជាប្រក្រតី

ទឹងបៀសចាកពីសង្សារនារោកិយ

ទោះប្រុសស្រីវែងដូចគ្នាពល់រូប៉ា ។

មោ៉ងប្រាំបួនដួនជាគេខ្វងយាមរៃប្រែប្រាណ

ចិត្តគិតស្មានដូចបានជួបថ្ងើមថ្ងៃ

ដោយជាសុខលក់ស៊ុនហួសដល់ថ្ងៃ

ចិត្តគិតថ្លែដោយខ្វល់ដល់ក្តីវេទនា ។

(ឃុនស៊ីមនោមៃ)

អនិច្ចា ព្រះសុរិយា ជិតព្រលប់

ទៀបយប់ភ្លៀងអុរជោកនៅពសុធា

ហឹងក្អាត់យំថ្ងូរឆ្លើយគ្នា

ជួបគូជិតគូស្រស់ស្រើបចិត្ត ។

តែបងរងកម្មទ្រាំតែទុក្ខ

គ្មានសុខមុខគួរឲ្យអាណិត

បងស្នេហ៍ប្រែខានពុំបានជិត

រែងគិតរឹងកើតតែទុក្ខា ។

រំពឹងរកកលុខ្វល់ក្នុងចិត្ត

ទឹកចង់ឲ្យជិតម្រក់សនា

គិតណាស់អំពល់ខ្វល់ប្រាញ់

សែនមហាវិតក្កទុក្ខពុំស្បើយ ។

រួបរួមមកអស់តែប៉ុណ្ណោះ ។

# រឿងព្រេងខ្មែរ--រឿងអាឡេវ ទី ២

(តមក)

លុះដល់ថ្ងៃក្រោយទៀត អាឡេវរៀបនឹងទៅធ្វើការក៏យកហិបទៅផ្ញើនឹងប្រពន្ធសេដ្ឋីហើយផ្ដាំថា អ្នកប្រយ័ត្នរក្សាទុកឲ្យល្អកុំឲ្យនរណាបើកមើលលេង ៗ ឯប្រពន្ធសេដ្ឋីទឹកឆ្ងល់នឹងហិបអាឡេវណាស់ ក៏បើកមើល ឃើញសំបុត្រពេញក្នុងហិប ហើយណាមើលសំបុត្រអស់នោះឃើញសេចក្ដីក្នុងសំបុត្រថា ពួកនាហ្មឺនជំពាក់ប្រាក់សឹងមានចំនួនគ្រប់គ្នាទាំងអស់ហើយបោះត្រាផង លុះបើមើលសំបុត្រទាំងអស់ឃើញសុទ្ធតែនា-ហ្មឺនជំពាក់ប្រាក់ជាច្រើនណាស់ដូច្នោះ ក៏យកហិបសំបុត្រនោះទៅបង្ហាញសេដ្ឋីជាប្ដី ឯសេដ្ឋីបានឃើញសំបុត្រអាឡេវសព្វគ្រប់ហើយ ក៏និយាយនឹងប្រពន្ធថា កាលអាឡេវវាមកនៅនឹងយើងនោះអញបានសួរវាពីម្ដាយអាពុកនៅឯណា វាប្រាប់ថាគ្មានម្ដាយអាពុកទេស្លាប់អស់ទៅហើយ ៗ វាប្រាប់អញថា កាលដែលម្ដាយអាពុកវានៅរស់នៅឡើយនោះ មានទ្រព្យសម្បត្តិដូចជាយើងនេះដែរ ឥឡូវនេះមកឃើញសំបុត្រអស់នាហ្មឺនជំពាក់ប្រាក់វាច្រើនម្ល៉េះ នេះសឹងត្រូវនឹងពាក្យវានិយាយពីមុននោះប្រាកដមែន ឯគំនិតប្រាជ្ញាវាសមជាមនុស្សមានពូជ មួយទៀតការងារទាំងអស់ក្នុងផ្ទះយើងសព្វថ្ងៃនេះក៏បានវាជួយជាស់តឿនថែទាំមើលរក្សាដឹងបាត់ដឹង

គង់ដឹងខ្លួនដឹងថា មានតែកញ្ចឹងហើយទុកដូចជាកូន ឥឡូវកូនស្រីយើង
មួយនេះពេញក្រមុំល្មមមានប្ដីហើយ ពួកស្ដេចនាហ្មឺនមកដណ្ដឹងចង់បានជា
ច្រើនណាស់ហើយ យើងមិនត្រូវចិត្តបានជាយើងមិនព្រមឲ្យ ឥឡូវនេះបើ
យើងឲ្យទៅអាឡេវនោះយើងខ្មាសគេណាស់ ដ្បិតវាជាមនុស្សកំព្រាក្បាល
មួយមកនៅក្នុងស្រុកឆ្ងាយ គ្មាននរណាស្គាល់ពូជពង្សវង្សាជាល្អអាក្រក់
បើយើងមិនឲ្យកូនយើងជាប្រពន្ធវាដូចជាទឹកស្ដាយ ដ្បិតគំនិតមារយាទ
វាជាល្អហើយជួយឈឺឆ្អាលក្នុងការងារយើង ដូចជាការងាររបស់ខ្លួនវាដែរ
ដំណើរនេះគេបើគិតណាស់ ៗ ឯប្រពន្ធសេដ្ឋីឆ្លើយឡើងថា ត្រង់កិច្ចដែល
ធ្វើមិនឲ្យខ្មាសគេនោះវាងាយទេ យើងទឹងរៀបការក្នុងវេលាយប់ហើយ
រៀបបន្តិចបន្តួចសោះកុំឲ្យខ្ចាប់ព្រឹង យើងផ្សំផ្គុំឲ្យជាប្ដីប្រពន្ធគ្នាទៅ បើ
ដល់យូរទៅហើយគេដឹងនោះយើងក៏អស់ខ្មាសគេហើយ ពីព្រោះវាមាន
បំណុលវាក៏ច្រើនដែរ ៗ ហេតុតែសំណាងព្រេងរបស់អាឡេវទើងកូនក្រមុំ
សេដ្ឋីនោះទឹងបានគ្នាជាប្ដីប្រពន្ធ ក៏សេដ្ឋីគិតឃើញព្រមដូចពាក្យប្រពន្ធ
ពន្យល់ក៏ព្រមឲ្យកូនក្រមុំជាប្រពន្ធអាឡេវ សេដ្ឋីហៅអាឡេវមកប្រាប់ថា
ដ្បិតតាំងអំពីថ្ងៃដែលឯងមកនៅនឹងអញ ៗ មើលទៅគំនិតមារយាទចិត្តថ្លើម
ឯងឈឺឆ្អាលក្នុងការងារអញដូចជាកូនបង្កើត បើដូច្នេះអញឲ្យកូនក្រមុំអញ
ជាប្រពន្ធឯង ៗ ឯអាឡេវឮសេដ្ឋីប្រាប់ថាឲ្យកូនក្រមុំជាប្រពន្ធដូច្នោះ ក៏

មានចិត្តត្រេកអរណាស់ សេដ្ឋីក៏ហៅកូនក្រមុំមករៀបសម្ពះមេបាចាស់ទុំ រៀបសែនព្រេនតាមសណ្ដាប់បុរាណជាប្ដីប្រពន្ធគ្នាទៅ ។

លុះការរួចពីរបីថ្ងៃ ប្រពន្ធអាឡេវគិតទៅគាល់ស្ដេចឯក្នុងវាំងបាន និយាយប្រាប់អាឡេវជាប្ដី ។ ឯអាឡេវក៏និយាយផ្ដាំប្រពន្ធថា បងទៅចាំនៅសាលាជំនុំ បើនាងឃើញបងបោយដៃហៅត្រូវនាងលើកជើងពានស្លាមក លុតជង្គង់ហុចស្លាពានឲ្យបង ។ ទទួលយកហើយនាងសំពះត្រឡប់ទៅវិញចុះ លុះនិយាយផ្ដាំប្រពន្ធសព្វគ្រប់ហើយ ក៏ស្លៀកសំពត់ពាក់អាវចាស់ដូចកាលធ្វើការពីមុន ហើយទៅអង្គុយលេងនៅសាលាជំនុំ ពួកនាហ្មឺនសព្វមុខមន្ត្រីនូវចៅក្រមសាលាភ្នាក់ងារក្រមការនូវឃុនម៉ឺនមហាតលិកក៏មកពាសពេញ ឃើញអាឡេវអង្គុយនៅសាលាហើយ នាម៉ឺនខ្លះត្បកក្បាល ខ្លះទះខ្នងទាញដៃ ខ្លះឲ្យអាឡេវធ្វើត្លុកក្រមាច់លេង ដ្បិតធ្លាប់លេងពីមុនមកដូច្នេះឯង ។ ឯអាឡេវជាមនុស្សមានប្រាជ្ញាចេះក្រមាច់កំប្លែងលេងឲ្យគេចូលចិត្ត មិនចេះខឹងនឹងនរណាទេ ព្រោះនាម៉ឺនសព្វមុខមន្ត្រីនូវឃុនម៉ឺនមហាតលិកនូវក្រមការភ្នាក់ងារប្រើវាដូចម្ដេចក្ដី លេងដូចម្ដេចក្ដី ក៏មិនចេះខឹងមិនចេះប្រកែក ឲ្យអាក់អន់ចិត្តអ្នកឯណា តាំងតែពីដើមមកដូច្នេះឯង ហើយពួកនាហ្មឺនមិនដឹងជាអាឡេវបានកូនក្រមុំសេដ្ឋីមកធ្វើជាប្រពន្ធផង ។

(នៅមានត)

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

ឆ្នាំគំរប់ ១៣

ភាគទី ១២

ភ្នំពេញ

ការផ្សាយរបស់ព្រះរាជបណ្ណាល័យ

ព.ស. ២៤៨៤

គ.ស. ១៩៤១

: 09

ព្រះរាជបណ្ណាល័យកម្ពុជា

# KAMBUJASURIYÂ

# កម្ពុជសុរិយា

ជាទស្សនាវដ្ដីចេញផ្សាយពីព្រះរាជបណ្ណាល័យ មួយខែពីរក្បាល

ឆ្នាំគំរប់ ១៣

ភាគទី ១២

គណៈរដ្ឋមន្ត្រីនិងសម្ដេចសង្ឃនាយកទាំងពីរគណៈ
បានអនុញ្ញាតហើយ

BIBLIOTHÈQUE ROYALE DU CAMBODGE

ភ្នំពេញ

ការផ្សាយរបស់ព្រះរាជបណ្ណាល័យ

ព.ស. ២៤៨៤

គ.ស. ១៩៤១

# បញ្ជីរឿង


១ — អំពីព្រះពុទ្ធសាសនាក្នុងសមុទ្រខាងត្បូង គឺកោះជ្វា, បាលី នឹងកោះសុមាត្រា . . ៣

២ — ការងារថ្មីៗរបស់ពុទ្ធសាសនបណ្ឌិត្យនៅស្រុកខ្មែរ កូសាំងស៊ីន នឹងស្រុកឡាវ (តនឹងចប់) . . . . . . . . . . . . . . . . . . . . . . . ៦

៣ — វិជ្ជាពេទ្យតាមរបៀបដាច់ដើមរបស់ប្រទេសឥណ្ឌា (តមកនឹងចប់) . . . . ១០

៤ — ពង្សាវតារប្រទេសក្រិក ស្រង់យកអំពីពោលពារិកផ្សេងៗ ក្នុងពង្សាវតារលោក (តមក) . . . . . . . . . . . . . . . . . . . . . . . . . ១៣

៥ — អនាមយកថា របស់ខេមរង្សី (តមក) . . . . . . . . . . . . . . . ១៧

៦ — អាជីវកម្មគឺអ្វី ? របស់ខេមរង្សី (តនឹងចប់) . . . . . . . . . . . . ២០

៧ — រឿងព្រេងខ្មែរ "រឿងអាឡេវទី ២" របស់ឧកញ៉ាប្រាជ្ញាធិបតីយិន (តនឹងចប់) . . ២៣


## រូបក្រៅរឿង


ខេត្តសៀមរាប-ស្រុករលួស ប្រាសាទព្រះគោ នេះសសរទ្វារចូលទិសខាងកើត ១

# TABLE DES MATIÈRES


Pages.

1° Le Bouddhisme dans les mers du Sud, à Java, Bali et Sumatra. 3

2° L'Œuvre de l'Institut d'études Bouddhiques au Cambodge, en Cochinchine et au Laos (suite)........................ 6

3° Médecine traditionnelle dans l'Inde antique (suite et fin)..... 10

4° Histoire de la Grèce, extrait de divers documents de l'histoire Universelle (suite)..................................... 13

5° Anāmayakathā par Khemararaṅsi (suite)................. 17

6° Qu'est ce qu'un métier ? — par Khemararaṅsi (suite et fin).. 20

7° Conte populaire cambodgien inédit :

" Légende de Alév II " par Oknha Prājñādhipadī Yin (suite et fin)........................................ 23


HORS TEXTE :


Siemréap — Srok Roluos — Prasat Préas ko Porte d'entrée Est........................................ 1



ខេត្តសៀមរាប - ស្រុករលួស

ប្រាសាទព្រះគោ នេះសសរក្រឡឹងមូល ទ្វារចូលទិសខាងកើត

# អំពីព្រះពុទ្ធសាសនានៅកោះជ្វា
# កោះបាលីនិងកោះសុមាត្រា

## ក្នុងសមុទ្រខាងត្បូង

ក្នុងរឿងរាមាយណៈមាននិយាយចេញឈ្មោះទ្វីបជ្វាសឹងហោមកេម ដោយកោះមាស កោះប្រាក់ ព្រមទាំងស្រុកទាំង ៥ ដទៃទៀត កោះនេះប្រាកដថាមានអារ្យធម៌របស់ឥណ្ឌាផ្សាយចូលទៅរហូតដល់ទីនោះ មុនពុទ្ធសករាជ ៩៥០ ។ តាមរឿងរ៉ាវរបស់អ្នកធូតង្គជាតិចិនឈ្មោះហ្វាហៀន ដែលបានចូលទៅសំណាក់នៅទីកោះជ្វា ៥ ខែ កាលពីពុទ្ធសករាជ៩៥៥ ហើយបានកត់ទុកក្នុងសេចក្ដីកយការថា គេប្រកាន់តាមបែបសាសនាព្រាហ្មណ៍ ទឹងបែបព្រះពុទ្ធសាសនា ដែលគេជឿកាន់នោះមិនគួរនាំមកថ្លែងទេ ។

សម្រាប់កោះសុមាត្រា កាលពី ព. ស. ១១៤៣ យើងបានដឹងដំណឹងអំពីកោះនេះ ដោយសារអ្នកធូតង្គជាតិចិនម្នាក់ទៀតឈ្មោះ អ៊ី-ឈិង បានកត់ត្រាទុកអំពីដំណើរពុទ្ធសាសនាដែលមាននៅក្នុងក្រុងនៃទីកោះនេះ ៗ លោកនេះបានចូលទៅសំណាក់នៅទីកោះនេះ ២ លើកក្នុង ព.ស. ១២១៤ ហើយក្នុងលើកទីពីរនៅជាវេលា ៥ ឆ្នាំ រហូតដល់ ព. ស. ១២៣៨ ដើម្បីសិក្សារបៀបពុទ្ធសាសនាទីងប្រែគម្ពីរសំស្ក្រឹត ៗ លោក

នេះពោលថា ស្តេចនៃកោះនេះនឹងពួកអាមាត្យរាជបរិវារ សុទ្ធតែជាអ្នកកាន់ព្រះពុទ្ធសាសនា ហើយនៅទីក្រុងនោះមានព្រះសង្ឃប្រមាណជាង ១.០០០អង្គ ជាទីប្រជុំសិក្សារៀនសូត្រមួយ ដែលគេបង្ហាត់បង្រៀនទាំងសិក្សាអស់ទាំងរឿងរ៉ាវ ដែលគេបានបង្ហាត់បង្រៀននៅប្រទេសឥណ្ឌា ៗ ពួកពុទ្ធសាសនិកជនអស់នោះ ប្រកាន់តាមនិកាយមូលសាវស្តិវាទនៃហីន-យាន ខាងពួកប្រកាន់តាមបែបមហាយានមានចំនួនតិចជាង ៗ មានសេច-ក្តីពោលរ៉ាវថា ព្រះពុទ្ធសាសនាចូលទៅក្នុងកោះសុមាត្រានោះមុនសម័យដែលលោក អ៊ី.ឈិង ចូលទៅជាយូរអង្វែងមកហើយ ហើយគណៈធម្មទូតបានប្រកាសផ្សាយលទ្ធិសាសនាដែលជាបែបហីនយាននៅប្រទេសឥណ្ឌាខាងជើង ដែលចេះដឹងនឹងរៀនសូត្រគម្ពីរដីកាជាភាសាសំស្ក្រឹត ៗ គេឃើញថាក្នុងសម័យនោះ លទ្ធិមហាយានចាប់ផ្តើមផ្សាយចូលទៅក្នុងកោះនេះដែរ ៗ នៅកោះជ្វាមានសិលាចារឹក ១ កើតឡើងក្នុងពុទ្ធសករាជ ១៣២១ នោះធ្វើឲ្យយើងបានដឹងថា លទ្ធិពុទ្ធសាសនាបែបមហាយានបានលុកលុយចូលទៅពេញទាំងកោះ ហើយនាំឲ្យកើតផលចំរើនរុងរឿង ដោយបុរាណវត្ថុពុទ្ធសាសនាយ៉ាងដើតៗ ព្រមទាំងរូបផ្សេងៗនិងរូបព្រះពោធិសត្វ និងក្បាច់ចម្លាក់ចេនាជាច្រើនជាតកនឹងរឿងពុទ្ធប្បវត្តិ ៗ

នៅក្នុងកោះបាលី ទុកជាមានសាសនាមហាម៉ាត់លុកលុយចូលមក តាំងទៅក៏ដោយ ពួកអ្នកស្រុកនៅតែបានថែរក្សាទំនៀមប្រពៃណី នៅជាពាក់កណ្ដាលពុទ្ធសាសនា ពាក់កណ្ដាលសាសនាសិវៈ លទ្ធិទាំងពីរនេះទុកជាសាបរលាបទៅជាច្រើនណាស់ហើយក៏ដោយ ក៏នៅតែមានឫសគល់ដើមរបស់ឥណ្ឌូសល់នៅខ្លះដែរ ។

១. ស.

# អំពីការជាស្នាដៃរបស់ក្រសួងពុទ្ធសាសនបណ្ឌិត្យ នៅស្រុកខ្មែរ ស្រុកកូសាំងស៊ីន និងស្រុកលាវ

(តមក)

អ្នកប្រាជ្ញទាំងព្រះសង្ឃទាំងឧបាសកដែលធ្វើការក្នុងមន្ទីរនេះ បានសើរើគម្ពីរអស់នោះមើល ហើយបានរៀបចំគម្ពីរជាងមួយពាន់តាមរបៀបត្រឹមត្រូវ ក្នុងគ្រានោះ គេបានចាត់ការឲ្យចំឡងដាក់ស្លឹករឹតប្រយោជន៍នឹងបំពេញគម្ពីររឿងណាដែលដាច់ដោចមិនគ្រប់ខ្សែ ក្រោយពីនោះបន្តិចមក គេបង្កើតក្រសួងមួយសំរាប់ឲ្យខ្ចីគម្ពីរនឹងសាស្ត្រាអក្សរ ទើបក្រសួងនេះគេស្គាល់ច្រើនចូលចិត្តគ្រប់គ្នាមួយរំពេច ហើយរហូតដល់សព្វថ្ងៃនេះ ពិតមែនតែមានសៀវភៅបោះពុម្ព ក្រសួងឲ្យខ្ចីនេះ មានស្ត្រីខ្មែរចូលចិត្តជាច្រើន ៗ ព្រះរាជបណ្ណាល័យ ហើយនឹងសារមន្ទីរដែលមានព្រះសង្ឃនឹងឧបាសកធ្វើការ បានបណ្ដាលឲ្យជននៅខែត្រក្រៅនឹងជនជាតិខ្មែរនៅស្រុកកូសាំងស៊ីន ស្ម័គ្រចិត្តចូលមកមើលជាច្រើន គេដឹងថានៅស្រុកកូសាំងស៊ីនខាងទិសនិរតីមានជនជាតិខ្មែរច្រើនជាង ៤៥០.០០០នាក់ ៗ នៅព្រះរាជបណ្ណាល័យមានលេខានុការម្នាក់ចាំទទួល ហើយស្នើអ្នកដែលចូលមកនោះគ្រប់នាក់ឲ្យដឹងថាគេចូលចិត្តត្រូវការអ្វី គេមានយោបល់ដូចម្ដេច នៅវេលាដែលបានមកឃើញនេះ ព្រោះអ្វីគប្បី

ធ្វើឲ្យអ្នកចូលមកមើលព្រះរាជបណ្ណាល័យគាប់ចិត្តស្រួលដូចនៅក្នុងលំនៅរបស់ខ្លួន ឬដូចបានប្រជុំគ្នានៅក្នុងវត្តរបស់ខ្លួន កាលបានពិនិត្យស៊ើបសួរដំណឹងដូច្នេះហើយ គេក៏បានយល់ឃើញថា អ្នកទាំងអស់ដែលមកឃើញព្រះរាជបណ្ណាល័យ មានចិត្តស្ម័គ្រចង់រៀនចំណេះមែន ព្រោះអ្វីគ្រប់គ្នាមានបំណងដូចគ្នាថាចង់ឲ្យមានសៀវភៅបោះពុម្ពជាអក្សរខ្មែរសេចក្តីដែលប្រែមកពីអក្សរសាស្ត្របាលី ពីព្រោះឥឡូវនេះការដែលចំឡងគម្ពីរដាក់លើស្លឹករឹតនោះយូរណាស់ គម្ពីរគេទុកដូចជារបស់លំអមានដំឡៃថ្លៃពេកហើយធំប្រវែងប្រវាង ដាក់ស្រួលតែនៅក្នុងវត្ត ។

កាលពីឆ្នាំ ១៩២៦ ព្រះរាជបណ្ណាល័យបានចេញផ្សាយទស្សនាវដ្តីអក្សរសាស្ត្រមួយហៅថា "កម្ពុជសុរិយា" ក្នុងទស្សនាវដ្តីមួយក្បាលៗមានរឿងច្រើនហើយទាំងរឿងផ្សេងៗ សំរាប់អ្នកចង់ចេះដឹងហើយទាំងសំរាប់អ្នកប្រាជ្ញ ព្រះរាជបណ្ណាល័យបានបោះពុម្ពផ្សាយរឿងព្រេងខ្មែរជាច្រើនផ្សាយសេចក្តីប្រែពីបាលីហើយនិងសៀវភៅសំរាប់បង្ហាញពន្យល់ការផ្សេងៗ សៀវភៅទាំងអស់នោះគេបោះពុម្ពម្តងចំនួនច្រើនពាន់ច្បាប់ ប៉ុន្តែដោយគេចូលចិត្តសៀវភៅនេះច្រើន ព្រះរាជបណ្ណាល័យក៏បានបោះពុម្ពសាជាថ្មីវិញជាច្រើនលើកច្រើនគ្រា ។ រូបមានប្រយោជន៍ណាស់ក្នុងការសិក្សា ហេតុដូច្នេះបានជាព្រះរាជបណ្ណាល័យបានឲ្យបោះផ្សាយរូបភាព

មានព័ណ៌ផ្សេងៗជាច្រើន ដើម្បីនឹងប្រែបន្តិចម្តង ជំនួសរូបដែលទិញពីស្រុកក្រៅមក ដោយខ្លាចក្រែងជាតិខ្មែរចូលចិត្តស្រឡាញ់របស់ជាតិក្រៅៗ ហើយរបស់ជាតិខ្លួនសព្វថ្ងៃនេះដោយសារគុណការផ្សាយរូបព្រះរាជបណ្ណាល័យ វត្តហើយនឹងក្រសួងផ្សេងៗទាំងអស់នៅស្រុកខ្មែរសុទ្ធតែមានរូបព្រះករុណាមួយៗកល់ខ្លួនៗ

កាលឆ្នាំ ១៩២៨ លោកនាយកស្រុកកូសាំងស៊ីន បានសុំរាជការទំ-នុកបំរុងស្រុកខ្មែរ ឲ្យអនុញ្ញាតឲ្យលោកតាំងហ្វាង ព្រះរាជបណ្ណាល័យធ្វើដំណើរទៅពិនិត្យមើលសតិបញ្ញាជនជាតិខ្មែរនៅក្នុងខែត្រទិសនីរតី ក្នុងស្រុកកូសាំងស៊ីន ដល់អញ្ជើញមកពីធ្វើដំណើរវិញ លោកតាំងហ្វាង ព្រះរាជបណ្ណាល័យ ក៏បានធ្វើកំណត់មួយអធិប្បាយអំពីសីលធម៌និងសតិ-បញ្ញារបស់ជនជាតិខ្មែរដែលនៅស្រុកកូសាំងស៊ីន ដល់បញ្ចប់សេចក្តីលោកនិយាយសង្កត់ថា បើមិនណែនាំជនជាតិខ្មែរនោះឲ្យកាន់ជាតិខ្លួនខ្ជាប់ទេ មុខជានឹងបាត់សាបសូន្យអស់ឬនឹងថយៗទៅនៅក្នុងព្រៃផ្សៃ ឬមុខជាជាតិយួននឹងស្រូបបំបាត់ទាំងអស់មិនលែងឡើយ ហេតុដូច្នេះគេត្រូវបង្រៀនលោកសង្ឃឲ្យចេះដឹងជាដើមៗ ដោយយល់ឃើញសេចក្តីនេះលោកនាយកស្រុកកូសាំងស៊ីន ក៏បានចំណាយប្រាក់ប្រគេនលោកសង្ឃឲ្យមករៀន គេបានបញ្ជូនលោកសង្ឃខ្មែរមកក្រុងភ្នំពេញដើម្បីនឹងឲ្យរៀនសូត្រតាមរបៀបការដែលគេបង្កើតដោយឡែកសំរាប់លោកសង្ឃខ្មែរនៅ

ស្រុកយួន ជាប្រយោជន៍ឲ្យលោកអស់នោះចូលមកនៅរៀនក្នុងកន្លែងសុទ្ធសឹងតែខ្មែរសុទ្ធ ដើម្បីនឹងរៀនភាសារបស់ជាតិហើយនឹងសីលធម៌របស់ព្រះពុទ្ធឲ្យបានល្អសាជាថ្មីវិញ កល់តែឆ្នាំមានលោកដែលកជការចេញសោហ៊ុយឲ្យមករៀននៅស្រុកខ្មែរ ត្រឡប់ទៅកាន់វត្តអាពមលោកវិញហើយបង្ហាត់បង្រៀនកូនក្មេងនៅក្នុងភូមិ អំពីចំណេះវិជ្ជាដែលលោកទើបនឹងបានរៀនសូត្រមក ។

ការសិក្សាភាសាខ្មែរនៅស្រុកកូសាំងស៊ីន ក៏កើតឡើងយ៉ាងដូច្នេះការរៀនភាសាខ្មែរនេះចូលស៊ិបក្នុងក្រសួងសិក្សាស្រុកយួន ហើយក្រសួងនេះក៏បានទទួលយល់ព្រមការនេះ ។

(នៅមានត)

# វិជ្ជាពេទ្យតាមរបៀបជាន់ដើម
# របស់ប្រទេសឥណ្ឌា

(តមកពីនបប់)

ឯក្រមខេះមានអំណាចបំបាត់រោគដកដង្ហើមមិនស្រួល អស់កំឡាំង និងរោគឯទៀតៗ ។ តាមគម្ពីរសាស្ត្រថា ទឹកដោះមេក្របីធ្វើឲ្យពករូស ព្រោះមានបើរ (ខ្លាញ់) ច្រើនពេក យើងមិនត្រូវប្រើទេ ។ ទឹកដោះមេចៀមក៏ដូចជាទឹកដោះមេក្របីដែរ ចំណែកខាងទឹកដោះមេពពែវិញ មានគុណសម្បត្តិល្អសម្រាប់រក្សាក្មេងដែលស្គាំងស្គម ឲ្យមានកំឡាំងនិងមានសាច់ឈាមល្អ ។ ទឹកដោះមេលាគេទុកជាថ្នាំមួយយ៉ាង សម្រាប់កំចាត់កាមរោគ(រោគស្រី) ។ ទឹកដោះមេសេះជាថ្នាំបំប៉ុនកំឡាំងយ៉ាងវិសេស ។ ទឹកដោះមេដំរី សម្រាប់រក្សាកាយឲ្យល្អល្អះ និងធ្វើឲ្យបានចំរើនខាងផ្លូវសតិបញ្ញា ។ ទឹកដោះមេខ្លា សម្រាប់រក្សារោគរបេងរ៉ាំរ៉ៃនិងរោគឃ្លង់ ។ ទឹកដោះមេគោដែលធ្វើឲ្យខាប់កកជាដុំៗ សម្រាប់ប្រើក្នុងពេលបរិភោគអាហារនោះ ជាថ្នាំរំលាយអាហារមួយយ៉ាងល្អដែរ ។ ទឹកដោះខាប់នេះជាថ្នាំដ៏ប្រសើរល្អណាស់ ។ ជាតិបើរដែលធ្វើពីទឹកដោះគោក៏ល្អណាស់ដែរ តែឯបើរមេក្របីមិនល្អទេ នាំឲ្យកើតរោគទុព្វលភាពទៅជាខ្វិនបាន ។ បើរដែលធ្វើពីទឹកដោះមេចៀមជាថ្នាំបំបាត់រោគគ្រុនលស់ ។

ក្នុងចំពួកទឹកដោះរុក្ខជាតិផ្សេងៗ ដែលគេស្គាល់ជាច្រើនបំផុតនោះគឺ ទឹកដូង ដែលជារបស់សម្រាប់ប្រើជាធម្មតាក្នុងផ្ទះបាយ, ទឹកដូងនេះជាថ្នាំបាយមួយយ៉ាងទន់ៗ ជួយកំឡាំងបេះដូង ហើយគេនិយមប្រើជាថ្នាំមួយមុខទៀត គឺត្រូវផឹកទឹកដូងមួយរំពេចក្នុងពេលដែលមានពស់ចឹក អាចជួយរម្ងាប់ពិសពស់បានដែរ ។ ជ័រព្រៃ (មានសម្បុរសហើយខាប់ដូចទឹកដោះដែរ) គេប្រើសម្រាប់រុំមុខដំបៅដែលមានខ្ទុះ ជាថ្នាំកែរោគធ្មេញ បង្ការរោគស្ពឹករួយស្រពាន់ និងកែរោគឈឺចង្កេះជាដើម ។ ជ័រដើមបម្បី គេប្រើជាថ្នាំបង្កាត់ ជាថ្នាំបំបាត់រោគដំបៅពងបែក ។ ទឹកដមក្នុងគ្រាប់កប្បាស ជាថ្នាំបង្ការរោគទឹកនោមផ្អែម ។ ទឹកដមក្នុងគ្រាប់ផ្លែអាកៀនសម្រាប់កែរោគមួលនិងរោគចុះរាក ។ ទឹកដោះផ្លែអាម៉ង់ដ៍ តាមសាស្ត្រាថាជារបស់ឲ្យទោសចំពោះអ្នកដែលកើតរោគឯទៀតៗ តែក៏មានគុណសម្បត្តិធ្វើឲ្យចំរើនខាងផ្លូវសតិបញ្ញាខ្លះដែរ ។ ទឹកដោះស្រូវសាលីសម្រាប់ក្មេងទឹកប្រមាត់និងរោគស្គាំងស្គមនាំឲ្យកើតរបេង ។

ទឹកត្នោតជាគ្រឿងផឹកម្យ៉ាង តាមសាស្ត្រាថាជាថ្នាំក្មេងរោគចុះរាក របេងរីងរៃ ។ ប្រសិនបើស្រីមានគភ៌ផឹកក្នុង ១ អាទិត្យ ២ ឬ ៣ ដង តាមគម្រាថាកូនដែលកើតមកមានសម្បុរភ្លឺស្រស់ល្អ ។ ឯទឹកត្នោតនឹងផ្លាស់ប្រែរសជាតិកាលកន្លងហួស ២–៣ ម៉ោង ។

ក្នុងគម្ពីរសាស្ត្រហាមមិនឲ្យផឹកសុរាដែលធ្វើពីស្រូវ ដោយដាច់ខាត ៗ ឯសុរាដែលធ្វើពីចេក មានលក្ខណៈដូចជាផ្លែឈើនានាដែលត្រាំទុកជាយូរធ្វើឲ្យមានរសជាតិខ្លាំងជាមេរ័យ ធ្វើឲ្យស្រវឹងតែបន្តិចបន្តួច ៗ គម្ពីរសាស្ត្រនេះរៀបរាប់ប្រភេទស្រូវថាមាន ២៤ ប្រភេទ ហើយពោលថាស្រូវឆៅគឺស្រូវដែលមិនទាន់ហាលឲ្យស្ងួតសម្រាប់ធ្វើជាអាហារ និងស្រូវមានអាយុពី ២ ខែដល់ ៣ ខែហើយច្រូតកាត់បាន ដ្បិតស្រូវថ្មីធាតុកើង យើងរំលាយបានដោយកម្រ និងធ្វើឲ្យចុះរាគតាមរដូវផង ៗ ស្រូវក្រហមសម្រាប់ទំនុកបំរុងកំឡាំងកាយឲ្យមុំមាំ ៗ សណ្តែកអង្គុយ សម្រាប់បំរុងក្រពះអាហារដែលខ្សោយកំឡាំង ៗ ដើមងប់ (Myrobolan) មានគុណសម្បត្តិក្នុងរោគបានច្រើនប្រការ តាមគម្ពីរសាស្ត្រថារក្សាជម្ងឺបានច្រើនយ៉ាង ដូចជារោគចុះរាគកូនក្មេងនិងការពោះសក់ស្បូនជាដើម ៗ

ទ. ស.

# ពង្សាវតារក្រិក

(តមក)

ពួកអឺរ៉ុបប្រកាន់ថា សូក្រាតនេះជាជនជាតិអឺរ៉ុបដំបូងដែលបានទូន្មានប្រដៅសីលធម៌ដ៏ត្រឹមត្រូវទៀងទាត់ គោលចារិកធម៌ខាងដើមរបស់លោកអ្នកប្រាជ្ញនេះប្រដៅថា "ចូរអ្នកស្គាល់ខ្លួនរបស់ខ្លួន(ឲ្យជាក់ច្បាស់)" លោកសូក្រាតនិយាយពន្យល់អំពីវិញ្ញាណថា ជាធម្មជាតិមិនចេះរលត់មិនចេះសូន្យទេ មនុស្សយើងស្លាប់ទៅ មកកើតថ្មីទៀត ហើយនៅក្នុងលោកនេះមានព្រះដែលទ្រង់មានរិទ្ធិអំណាចខ្ពង់ខ្ពស់បំផុត ។

ចួនជាពាក្យប្រៀនប្រដៅរបស់សូក្រាតរំលងហួសថ្នាក់សីលធម៌ ដល់ទៅមានការតិះដៀលរដ្ឋធម្មនុញ្ញរបស់អាថែន ទើបត្រូវពួកកស្ត្រចោទប្រកាន់ថាជាពួកមន្ត្រី ថែមទាំងចំពន្យល់មនុស្សឲ្យខូចសេចក្តីជ្រះថ្លាទឹងលទ្ធិប្រជាធិបតេយ្យ ទើបត្រូវចាប់ខ្លួនទៅជំនុំជម្រះនៅសាលាវិនិច្ឆ័យ ដំបូងពួកចៅក្រមមិនបានកាត់សេចក្តីឲ្យប្រហារជីវិតទេ តែសូក្រាតនិយាយលែងខាយចំអកពួកចៅក្រមៗខឹងក៏នាំគ្នាវិនិច្ឆ័យឲ្យប្រហារជីវិតទៅ ។

ស្រុកអាថែនក្នុងវេលានោះ ការប្រហារជីវិតមនុស្ស គឺបង្គាប់ឲ្យផឹកថ្នាំពុល សូក្រាតបានផឹកថ្នាំពុលនៅកណ្តាលប្រជុំជន អនិច្ចកម្មក្នុងកំណត់អាយុ ៧០ ឆ្នាំ (មុន គ.ស. ៣៩៩) ។

កាលបើបានជ្រាបប្រវត្តិរបស់សូក្រាតខ្លះហើយ យើងគួរជ្រាបប្រវត្តិរបស់អ្នកប្រាជ្ញ ៤ នាក់ទៀត ដូចមានសេចក្តីសារសេព្វជាលំដាប់តទៅនេះ:

១—អ៊ីសូក្រាត (Iosocrate) កើតក្នុង ព.ស. ១០៧ អនិច្ចកម្មក្នុង ព.ស. ២០៥ អាយុ ៩៨ ឆ្នាំ ។ ដាន់ដំបូងជាមនុស្សខ្លាចហើយមានសូរសំឡេងមិនពីរោះ ទើបអ្នកផងមិននិយមស្តាប់សំដីដែលលោកនិយាយ តែតមកបានខំរៀនវិជ្ជានិយាយ ត្រាតែទៅជាអ្នកនិយាយយ៉ាងពូកែម្នាក់ ហើយជាអ្នកតែងទទួលទានស៊ីឈ្នួលតែងពាក្យថ្លែងការណ៍ជូនសាលា ត្រាតែបានមាសប្រាក់គ្រាន់បើឡើង ៗ បុរសនេះមានការទាក់ទងយ៉ាងស្និទ្ធនឹងព្រះបាទហ្វីលិប ក្សត្រមាសេដូន (Macédoine) ជាអ្នកទទឹងទាស់មិនយល់ព្រមឲ្យស្រុកអាថែនប្រកាសសង្គ្រាមនឹងព្រះបាទហ្វីលិប តែទប់មិនជាប់សង្គ្រាមក៏កើតឡើង កងទ័ពព្រះបាទហ្វីលិបឈ្នះកងទ័ពអាថែន ។ អ៊ីសូក្រាតក៏មានសេចក្តីតោមនស្សអត់អាហារស្លាប់ទៅ ។ សុន្ទរកថារបស់លោកនេះដែលមានកេរ្តិ៍ឈ្មោះល្បីល្បាញមកដល់សម័យឥឡូវនេះ គឺបទសរសើរក្រុងអាថែន ដែលលោកអ្នកប្រាជ្ញនេះបានរៀបចំតែងនឹងដុសខាត់រំលីងពាក្យពេចន៍អស់វេលាដល់ ១៥ ឆ្នាំ មុននឹងនាំយកមកនិយាយក្នុងទីប្រជុំជន ។

២.– ប្លាតុង (Platon) កើតក្រោយអឺស្ហ្គ្រាត៧ឆ្នាំ ជាអ្នកបានសិក្សាមកយ៉ាងម៉ាំមួនខាងអក្សរសាស្ត្រលេខ នឹងបេះតែងកាព្យឃ្លោងតាំងតែអំពីវ័យនៅក្មេង លុះដល់អាយុ ២០ ឆ្នាំបានផ្ញើខ្លួនធ្វើជាសិស្សរបស់សូក្រាត ហើយនៅរៀនសូត្រក្នុងសំណាក់សូក្រាត ១០ ឆ្នាំ ។ លុះសូក្រាតអនិច្ចកម្មទៅ បានធ្វើដំណើរទៅក្នុងស្រុកផ្សេងៗ នៃប្រទេសគ-តាលី, អហ្វ្រិក នឹងអេស៊ីប្ត ហើយត្រឡប់មកស្រុកវិញ ទើបចាប់ផ្តើមតាំងសាលាវិទ្យាល័យក្នុងក្រុងអាថែន្ស ហេតុនេះបានជាលោកពប់ថាប្លាតុងជាបុរសដំបូងដែលបានចាត់តាំងវិទ្យាល័យឲ្យមានឡើង មានមនុស្សជាន់ខ្ពស់ៗ មកចូលរៀនជាច្រើន អ្នកដែលមករៀនក្រោយៗ នេះត្រឡប់ជាមានកេរ្តិ៍ឈ្មោះប្រហែលនឹងប្លាតុង ឬជាងប្លាតុងក៏មាន ដូចជាអឺស្ហ្គ្រាតដែលពោលមកហើយ ទុកជាអារិស្តូត នឹងសេនាក្រាត ក៏សុទ្ធតែជាសិស្សក្នុងវិទ្យាល័យរបស់ប្លាតុង ។ កេរ្តិ៍ឈ្មោះរបស់ប្លាតុងមិនមែនផ្សាយចេញទៅចំពោះតែក្នុងពួកអាថែន្សប៉ុណ្ណោះទេ សូម្បីអាណាចក្រដទៃៗទៀត ក៏មានសេចក្តីពប់អាន មានមកសុំឲ្យព្រាងច្បាប់ឲ្យក៏មាន ប្លាតុងចំកៀសខ្លួនចៀសវាងមិនឲ្យទាក់ទិននឹងការងាររបស់ផែនដីដរាបដល់អនិច្ចកម្មកាលអាយុ ៨២ ឆ្នាំ ក្នុង ព.ស. ១៩៦ ។

៣.- សេនាក្រាត កើតក្នុង ព.ស. ១៣៧ អនិច្ចកម្មក្នុង ព.ស. ២២៩ (អាយុ ៩២ ឆ្នាំ) ជាសិស្សរបស់ប្លាតុងដែរ លុះប្លាតុងអនិច្ចកម្មទៅហើយ

សិស្សរបស់ប្លាតុនម្នាក់ទទួលនាទីបង្រៀនវិទ្យាល័យតមកទៀតជាវេលា ២៤ ឆ្នាំ លោកនេះបានតែងរឿងទុកជាច្រើន ដែលមានមនុស្សនិយមរហូតមកដល់សម័យសព្វថ្ងៃនេះ ។

៤- អារិស្តូត កើតក្នុងអាណាចក្រម៉ាសេដ្វាន ក្នុងព.ស. ១៥៩ អនិច្ចកម្មក្នុងព.ស. ២២១ អាយុ ៦២ ឆ្នាំ បានមកសិក្សាវិជ្ជាការនឹងប្លាតុង នៅស្រុកអាថែនជាវេលា ២០ ឆ្នាំ លុះប្លាតុងអនិច្ចកម្មទៅ ក៏ត្រឡប់ទៅម៉ាសេដ្វាន ដោយទឹកអន់ចិត្តដែលខ្លួនមិនបានធ្វើជាអាចារ្យបង្រៀនវិទ្យាល័យជំនួសប្លាតុង ។ កាលបានត្រឡប់ទៅដល់ម៉ាសេដ្វានហើយ ក៏តាំងខ្លួនជាគ្រូបាអាចារ្យធំតាល់តែមានកេរ្តិ៍ឈ្មោះល្បីល្បាញយ៉ាងសំបើម ។ កាលពី ព.ស.២០០ ព្រះបាទហ្វីលិហ្វក្សត្រម៉ាសេដ្វានទ្រង់តាំងឲ្យធ្វើជាអាចារ្យបង្រៀនព្រះរាជឱរស គឺព្រះបាទអាឡេក្សាន់ដ្រ័មហារាជ ឡាយព្រះហស្តដែលព្រះបាទហ្វីលិហ្វទ្រង់ប្រទានដល់អារិស្តូតនោះមានសេចក្តីថា "សេចក្តីចំរើនរបស់អាឡេក្សាន់ដ្រ័នោះ មិនមែនដោយហេតុកើតមកជាព្រះរាជឱរសរបស់ក្សត្រហ្វីលិហ្វទេ តាមដោយពិតនោះគឺកើតមកក្នុងសម័យអារិស្តូតទេតើ" ។ កាលព្រះបាទហ្វីលិហ្វទិវង្គតទៅហើយ អារិស្តូតអត់ទ្រាំនឹងសេចក្តីឈ្នានីសឫស្យានឹងការពោលបង្ខុសរបស់ពួកសត្រូវពុំបាន ក៏ចេញទៅនៅខេត្រអ៊ុយបេ ហើយអនិច្ចកម្មក្នុងស្រុកនោះទៅ ។

(មានត)

អនាមយកថា

(តមក)

បទទី ៦

# អំពីការដេកលក់

ការដេកលក់ជាកិច្ចវត្តយ៉ាងសំខាន់មួយ សម្រាប់បុរសស្ត្រីគ្រប់រូបគ្រប់នាម ប្រសិនបើមិនមានការដេកសម្រាកហើយ រាងកាយហេតុដល់ខួរក្បាលរបស់យើងនឹងមានអាការព្រួយស្រពន់ កំឡាំងកាយ-កំឡាំងចិត្តហើយនឹងទ្រុឌទ្រោមថយខ្សោយចុះទៅជាលំដាប់ នឹងបណ្ដាលឲ្យកើតរោគផ្សេងៗជាមិនខាន ។ យើងរាល់គ្នាគង់ដឹងច្បាស់ហើយថា ការដេកលក់ស៊ប់ឲ្យល្មមនឹងសេចក្ដីត្រូវការរបស់រាងកាយនេះជាការខានមិនបានទេ ចូរមើលអ្នកអត់ដំណេកយប់ដោយមានកិច្ចរវល់ ហើយថែមទាំងអត់ដំ-ណេកក្នុងវេលាថ្ងៃផងចុះ តើមានអាការដូចម្ដេចខ្លះ? ហេតុនេះទើបឃើញថា ការដេកលក់ស៊ប់ជាកិច្ចសំខាន់បំផុត ក្នុងការទំនុកបំរុងរាងកាយឲ្យមានកំឡាំង នឹងបានសេចក្ដីសុខ តែការដេកលក់ស៊ប់របស់មនុស្សយើងនេះត្រូវការវេលាវែង-ខ្លី-តិច-ច្រើននោះ ស្រេចតែអាយុរបស់បុរសស្ត្រីនោះៗជាប្រមាណ ដូចមានកំណត់ខាងក្រោមនេះ គឺ:

កើតមកក្នុង១ខែដំបូង១ថ្ងៃត្រូវដេក ២០ ម៉ោង

— ៦— — ១៦-១៨—

— ១ខួប — ១៤-១៥—

— ២— — ១១-១២—

កើតមកក្នុង ៣ ខួបដល់ ៥ ខួប ១ ថ្ងៃ ត្រូវដេក ១០-១១ ម៉ោង

តាំងពី ៥ ខួបដល់ ១០ ខួប — ៩-១០ —

— ១០ ឆ្នាំដល់ ២០ ឆ្នាំ — ៨-៩ —

— ២០ — ៤០ — — ៧-៨ —

— ៤០ ឆ្នាំឡើងទៅ — ៦-៧ —

ការកំណត់វេលាដេកតាមចំនួនដូចពោលមកនេះ ទើបល្មមគ្រប់គ្រាន់នឹងសេចក្ដីត្រូវការរបស់កាយ ហើយត្រូវដេកឲ្យលក់ស៊ប់ទៀតផង ៗ មួយវិញទៀត បើយើងនឹងដេកឲ្យលើសកំណត់នេះពុំបានឡើយ ៗ ឯការដេកថ្ងៃនឹងដេកយប់នោះមានផលខុសគ្នាយ៉ាងណា យើងនឹងពណ៌នាជាលំដាប់តទៅ

## សរីរសាស្ត្រនៃការដេកលក់

កាលបើយើងអស់សេចក្ដីដឹងខ្លួនទៅខ្វះឬអស់ទៅតែម្ដង ទើបយើងហៅថា "ការដេកលក់" ករៈវេលាយើងដេកលក់នេះ ក៏គឺពេលដែលកង

កាយត្រូវការឈប់សម្រាកពីការនឿយហត់ ខុសពីពេលភ្ញាក់រឭក ដែលជាខណៈអវយវៈផ្សេងៗនាំគ្នាធ្វើការងារតាមមុខក្រសួងរៀងខ្លួនគ្រប់ចំណែក ។

ការដេកលក់ស៊ប់ឬខណៈដែលរាងកាយឈប់សម្រាកនេះ មិនមែនអវយវៈផ្សេងៗគ្រប់ចំណែកឈប់ធ្វើការងារព្រមគ្នាទាំងអស់ទេ ចំណែកដែលឈប់ក៏ឈប់ទៅ ដូចជាខួរក្បាលនៅត្រង់ថ្ងាសឈប់គិត ចក្ខុប្រសាទឈប់ឃើញ ។ ចំណែកដែលបន្ថយការងារឲ្យតិចចុះទៅ ក៏បន្ថយឲ្យតិចទៅ ដូចជាសួតក៏នៅតែស្រូបខ្យល់ដកដង្ហើម, បេះដូងនៅតែធ្វើការស្រូបលោហិត ទាំងពីរមុខនេះឈប់ខានធ្វើការសោះមិនបានឡើយ (បើសិនបើជាឈប់ខានធ្វើការមិនមែនដេកលក់តាមធម្មតាទេ) ។ ក្នុងខណៈដែលដេកលក់ មានការប្រែប្រួលក្នុងរាងកាយដូច្នេះ:

ការដកដង្ហើម — មានអាការយឺតហើយជ្រៅជាងធម្មតា ប្រើឆ្អឹងជំនីរច្រើនជាងពោះយឺតៗឆាប់ៗជារយៈៗ ដកដង្ហើមចេញមានរយៈខ្លី ទំនងលាន់ឮខ្លាំងជាងពេលដែលភ្ញាក់រឭក ។

ត្របកភ្នែក — ក្រឡាប់ឡើងទៅលើ ខាងក្នុងកែវភ្នែករៀវតូចទៅ ។

កន្ត្រាក់ឆ្លង់ — មានអាការថយតិចទៅឬអស់ទៅតែម្តង ។

(មានត)

# អាជីវកម្មគឺអ្វី?

(តមក)

ព្រៃឈើ — ស្រុកខ្មែរយើងនៅទិសខាងជើង មានឈើព្រៃជាច្រើន ដូចជាក្រចេះ កំពង់ចាម កំពង់ធំ ត្បូងឃ្មុំ គឺឈើស្រឡៅ ឈើទាល ហេងជាដើម នៅទិសខាងលិច ដូចជាកំពង់ស្ពឺ កំពត ពោធិ៍សាត់ ក៏មានព្រៃឈើជាច្រើនដែរ របរឈើនេះជាជំនួញធំមួយដែលលក់ចេញទៅប្រទេសក្រៅ ។

នេសាទកម្ម — ការចាប់ត្រីជារបរធំមួយក្នុងស្រុកខ្មែរ ព្រោះមានទន្លេសាបមួយធំហើយមានបឹងតូច-ធំឯទៀតជាចំនួនច្រើន ទន្លេមេគង្គនិងស្ទឹងព្រែកក៏មានច្រើនដែរ ដែលជាលំនៅនៃមច្ឆាជាតិនានាទាំងតូចទាំងធំ តែខ្មែរជាម្ចាស់ស្រុកមិនបានកាន់កាប់របរអស់នេះផ្ទាល់ខ្លួនទេ ព្រោះជាអ្នកកាន់ពុទ្ធសាសនាយ៉ាងម៉ឺងម៉ាត់ វៀងខ្ពើមរអើមដល់អំពើបាណាតិបាត ទើបបណ្ដោយឲ្យចិន-យួន-ចាមធ្វើពេញដៃ ឯខ្មែរចាំតែទិញពីចិន-យួន-ចាមយកមកទទួលទានទាំងធ្វើបុណ្យទានផ្សេងៗ ។ បណ្ដាត្រីទឹកសាបក្នុងប្រទេសឥណ្ឌូស៊ីនបារាំងសែសនេះ ស្រុកខ្មែរជាស្រុកបរិបូណ៌ដោយត្រីទឹកសាបជាច្រើនបំផុត ។ របរត្រីទឹកសាបនេះក្រៅពីលក់ដូរក្នុងស្រុកយ៉ាងបរិបូណ៌ ហើយលក់ចេញទៅប្រទេសក្រៅមានចំនួនទឹកប្រាក់មិនតិច

តិចឡើយក្នុង ១ ឆ្នាំ ៗ តែប្រាក់អស់នោះមិនបានហូរចូលក្នុងថង់ខ្មែរបែរជាហូរចូលក្នុងថង់របស់ចិន យួន-តាមទាំងអស់ ៗ

ហត្ថកម្ម – របរចិញ្ចឹមជីវិតផ្នែកនេះក្នុងស្រុកយើងមិនទាន់បរិបូណ៌នៅឡើយ ធ្វើគ្រាន់តែប្រើប្រាស់នឹងលក់ដូរក្នុងស្រុកប៉ុណ្ណោះ មិនមានចំនួនល្មមធ្វើជាជំនួញលក់ចេញទៅប្រទេសក្រៅបាន ដូចជាៈធ្វើប្រដាប់សម្រាប់ស្រែ, កាំបិត, ពូថៅ, ធ្វើពានឆ្នាំង, ឥដ្ឋ, គ្រឿង, កន្ទេល, កញ្ជើ, ល្អី, ចង្អេរ, កញ្ច្រែង, ជាងឈើ, ជាងគ្រឿង, ជាងមាស, ជាងប្រាក់, ជាងស្មិត, ជាងស្បាច់, ជាងគំនូរ នឹងជាងដែកជាដើម តែរបរអស់នេះមិនទៅក្នុងកណ្ដាប់ដៃខ្មែរទាំងអស់ទេ មានចិន-យួនដណ្ដើមយកទៅធ្វើខ្លះក៏មាន ដូចជាធ្វើឥដ្ឋ, គ្រឿងនឹងកាំបិតពូថៅជាដើម ៗ

ពាណិជ្ជកម្ម – គឺការលក់ដូរបានខាងជំនួញដូរប្រែទាំងឡាយជារបរធំមួយក្នុងស្រុកឬក្នុងលោកទាំងមូល ប៉ុន្តែអនិច្ចា ប្រជាជនជាតិខ្មែរយើងហាក់ដូចជាខ្សត់ខ្សោយណាស់ត្រង់មុខរបរជំនួញនេះ ព្រោះនៅទីប្រជុំជន មិនថាក្នុងក្រុងឬខេត្តក្រៅទេ យើងសំឡឹងមើលឃើញតែជនជាតិចិន-យួនតាំងហាង-ពនលក់ដូរដេរដាស ឯខ្មែរមានចំនួនអ្នកលក់ដូរតិចជាងបំផុត ៗ ឯរបស់ដែលចិន-យួនលក់ដូរនោះសោតទៀតក៏មិនមែនរបស់ដែលកើតឡើងក្នុងស្រុកខ្មែរដែរ ច្រើនតែរបស់ពីប្រទេសក្រៅនាំចូលមក

លក់ក្នុងស្រុកខ្មែរ ព្រោះរបរហត្ថកម្ម ធ្វើរបស់ក្នុងស្រុកចំណាយមិនទាន់ចំរើនបរិបូណ៌ ហេតុដូច្នេះបានជាការលក់ដូរគ្រប់ជំពូកតែងអាស្រ័យតាមប្រទេសស្ទើរតែទាំងអស់ ។

ក្រៅពីនេះ នៅមានរបរមួយមុខទៀតគឺជាកម្មករ បានខាងការទទួលធ្វើការស៊ីឈ្នួល តែសព្វថ្ងៃនេះនៅមានចំនួនតិចហើយមិនសូវបញ្ចេញមុខបញ្ចេញមាត់ប៉ុន្មានទេ ដែលថ្ងៃថ្មីមានមនុស្សនិយមធ្វើជាបំផុតក្នុងវេលានេះ គឺការធ្វើកសិការ ឬធ្វើស្មៀនតាមសមាគមនិងហាងដំនួញផ្សេងៗ តែបើយើងពិនិត្យទឹកដីអាកាសក្នុងស្រុកយើងដោយសព្វគ្រប់ទៅ ទើបឃើញថារបរក្សេត្រកម្ម ឬកសិកម្មជារបរធំបំផុតក្នុងស្រុក ហេតុនេះ បើជនជាតិខ្មែរកាន់កាប់មុខក្រសួងនេះដោយម៉ឺងម៉ាត់ត្រាតែមានហត្ថកម្ម ៖ សិប្បកម្មកើតឡើង យើងយល់ថានឹងនាំប្រទេសជាតិទៅកាន់សេចក្តីចំរើន តាមសម័យមិនខាន ។

ព. ស.

# រឿងព្រេងខ្មែរ រឿងអាឡេវទី ២

(តមកពីគលប់)

ពួកនាហ្មឺនគិតស្មានថាអាឡេវជាមនុស្សផ្តេសផ្តាស ដើរសុំទានគេស៊ី គេលំនៅគ្មាន បានជានាំគ្នាមាក់ងាយក ៗ លុះដល់កូនសេដ្ឋីជាប្រពន្ធអាឡេវ ជិះអង្រឹងស្នែងហើយមានមនុស្សម្នាខ្ញុំកំដរកាន់ប្រអប់មាសប្រាក់ ដើរពេញពាសផ្លូវមក នាម៉ឺនទាំងអស់ក៏និយាយគ្នាថា នែ៎មើលកូនក្រមុំសេដ្ឋីល្អណាស់ ដើរចូលក្នុងវាំង នាម៉ឺនខ្លះលាន់មាត់ថាល្អមែន កូនស្តេចកូននាម៉ឺនដណ្តឹងជាច្រើនហើយមិនបាន ៗ ឯអាឡេវឮនាម៉ឺននិយាយគ្នាថាកូនស្តេចកូននាម៉ឺនដណ្តឹងកូនក្រមុំសេដ្ឋីៗមិនព្រមឲ្យដូច្នោះ ក៏ឆ្លើយឡើងថា បើអស់លោកថាដណ្តឹងកូនក្រមុំសេដ្ឋីឲ្យកូនលោកមិនបាន លោកចាំមើលខ្ញុំបាទវិញ លោកកូនក្រមុំសេដ្ឋីចេញមកអំពីក្នុងវាំង ខ្ញុំបាទនឹងហៅឲ្យចូលមកហើយឲ្យយកស្លាមកឲ្យខ្ញុំបាទស៊ី លោកហ៊ានភ្នាល់ឬទេ ៗ ពួកនាម៉ឺនឮអាឡេវថាដូច្នោះក៏មិនជឿ ដ្បិតមិនដឹងថាសេដ្ឋីឲ្យកូនក្រមុំទៅជាប្រពន្ធអាឡេវនោះ មួយទៀត មិនដឹងថាអាឡេវក៉ក្រមាច់លេងផ្តេសផ្តាសតែដោយផ្ទះនាម៉ឺន លោកទៅផ្ទះវិញមិនបានលេងផ្តេសផ្តាសទេ បានជាមាក់ងាយក៏ខ្លាំងណាស់ ហើយមិនដឹងថាអាឡេវមានប្រាជ្ញាច្រើនដល់ម្លឹងនោះ ទើបនាំគ្នានិយាយភ្នាល់នឹងវាថា បើឯងហៅកូន

ក្រមុំសេដ្ឋីចូលមកយកស្លាម្ហូបមកឲ្យឯងស៊ីបាន អញហ៊ានភ្នាល់នឹងឯង ប៉ុន្តែឯងគ្មានអ្វីដាក់ភ្នាល់នឹងអញទេ អាឡេវត្រូវពួកនាម៉ឺនថាដូច្នោះក៏ឆ្លើយទៀងថា លោកកុំព្រួយប្រែសាសន៍នឹងខ្ញុំបាទ បើខ្ញុំបាទចាញ់លោក ខ្ញុំបាទធ្វើសំបុត្រនៅបំរើជាខ្ញុំលោកដល់អស់ជីវិត តាមចិត្តលោកប្រើធ្វើ ខ្ញុំបាទទទួលធ្វើទាំងអស់ ៗ នាម៉ឺនសព្វមុខមន្ត្រីទាំងអស់ឮអាឡេវថាដូច្នោះ ក៏អរគ្រប់គ្នា ដោយចង់បានអាឡេវមកធ្វើជាខ្ញុំ ដ្បិតវាចេះនិយាយកួតករក្រមាប់កំប្លែងលេង មួយទៀតមាកងាយថាវាជាមនុស្សពោលមៀត ធ្វើម្តេចនឹងហៅកូនសេដ្ឋីចូលមកបាន ហើយនិយាយគ្នាថា យើងយកអាឡេវធ្វើជាខ្ញុំគ្រាន់និយាយកួតករក្រមាប់លេង ហើយយើងបែកគ្នាប្រើលេងសប្បាយ បើវាចង់បានរបស់ទ្រព្យប្រាក់មាសប៉ុន្មាន យើងឲ្យវាដាក់ក្នុងសំបុត្រភ្នាល់គ្នាតាមចិត្តវាចុះ ដ្បិតវាមុខជាចាញ់យើងហើយ ៗ អាឡេវនឹងពួកនាហ៊ឺនក៏ធ្វើសំបុត្រចុះចក្ខុ ផ្តិតដៃភ្នាល់គ្នាតាមដំណើរសព្វគ្រប់ហើយ ទើបពួកនាម៉ឺនប្រាប់អាឡេវថា ឯងចង់បានមាសប្រាក់ប៉ុន្មាន ដំរីចង់គួប សេះចង់បានទាំងគ្រឿងដែលជិះមកនេះប៉ុន្មាន ចូរដាក់ក្នុងសំបុត្រតាមចិត្តឯងចុះ ៗ ឯអាឡេវក៏សរសេរដាក់ក្នុងចក្ខុផ្តិតដៃដែលភ្នាល់គ្នាឲ្យខាងតែច្រើនទាំងមាសទាំងប្រាក់ទាំងដំរីទាំងសេះគ្រប់គ្រឿង ហើយជូនទៅពួកនាម៉ឺនឲ្យមើលគ្រាន់ហើយទទួលយកមកវេចមួយសំពាយក្រវាត់ទុកហើយទៅ

អន្ទុយចាំនៅមាត់ទ្វារសាលា បន្តិចឃើញកូនសេដ្ឋីជាប្រពន្ធវះចេញមក ពីក្នុងវាំង ក៏គំហោយដៃហៅថា នាងយកស្វាមកឲ្យបងស៊ី ឯកូនសេដ្ឋីពុ ប៉ុហៅឲ្យយកស្វាមកដូច្នោះ ក៏ម្ដីមាចុះពីអង្រឹងស្នែង ហើយដាក់ស្វានៅ លើដើមពានយកមកឲ្យប្ដី អាឡេវក៏ទទួលយកស្វាស៊ីហើយក៏នាំប្រពន្ធ នូវខ្ញុំកំដរឡើងជិះសេះដំរីដែលតែងគ្រឿងគ្រប់ស្រាប់ ទៅកាន់ផ្ទះសេដ្ឋី ជាឪពុកក្មេក អាឡេវនិយាយផ្ដាំថា បើលោកឪពុកលោកម្ដាយឬអ្នកឯ-ណាជាមនុស្សនៅក្នុងផ្ទះក្ដី ក្រៅផ្ទះក្ដី ឬអ្នកជិតខាងក្ដី គេសួរថាបានដំរីសេះ ពីណាមក ឲ្យដំកចឲ្យប្រាប់ថា ទារបំណុលអំពីគេ ៗ ឯពួកនា-ម៉ឺនសព្វមុខមន្ត្រីក្រមការភ្នាក់ងារនូវឃុនម៉ឺនមហាតលិកដែលស្គាល់ចាញ់ អាឡេវស្រាប់តែភ័យក្នុងសរសៀងខ្លួនស្ដាយរបស់ទ្រព្យនឹងដំរីសេះជាជំនិះ ជាប់ជិះជាលំអត្រូវចិត្ត ស្ទុះស្ទឹនតែគ្រឿងមាសនឹងប្រាក់ពន់ពេកណាស់ ហើយនិយាយគ្នាថា យើងបង់គំនិតនឹងអាឡេវហើយ ៗ ឯអាឡេវនឹង ប្រពន្ធនូវខ្ញុំកំដរជិះដំរីសេះមានក្របមានអាននូវគ្រឿងប្រដាប់ស្ទុះស្ទឹនតែ មាសនឹងប្រាក់ លុះទៅដល់ផ្ទះហើយ សេដ្ឋីជាឪពុកក្មេកម្ដាយក្មេក នូវ អស់មនុស្សម្នាក្រមការភ្នាក់ងារក្នុងផ្ទះឃើញដំរីសេះពាសពេញមកដូច្នោះ ក៏ទឹកឆ្ងល់ ហើយសេដ្ឋីប្រើមនុស្សឲ្យទៅសួរអាឡេវៗក៏ប្រាប់ថាទារបំ-ណុលអំពីគេមក ៗ ឯសេដ្ឋីជាឪពុកក្មេកម្ដាយក្មេកក៏ទឹកអរនិយាយគ្នាថា

យើងអស់ខ្មាសគេហើយ ។ ចាប់ដើមអំពីថ្ងៃនេះទៅ សេដ្ឋីប្តីប្រពន្ធក៏រឹតតែស្រឡាញ់អាឡេវលើសអំពីមុនឡើងទៀត ឯអាឡេវក៏ទៅទារប្រាក់អំពីពួកនាម៉ឺនសព្វមុខមន្ត្រីតែសព្វថ្ងៃ ដញ្ជូនយកមកហើយក៏គិតធ្វើការរកស៊ីដួសសេដ្ឋីអាពុកក្មេកម្តាយក្មេកមិនឲ្យព្រួយចិត្តគ្រប់បំពួក លុះនៅយូរមកសេដ្ឋីចាស់ដកអស់អាយុទៅ អាឡេវក៏បានជាសេដ្ឋីធំក្នុងនគរនោះឯង ។

យើងនិយាយអំពីរឿងអាឡេវទី ២ ជានិទានរឿងព្រេងជាដំណាលៗគ្នាមក បើលោកអ្នកឯណាមើលហើយកុំសើចកុំយំនឹងយើងឡើយ ។

ចប់រឿងអាឡេវទី ២ តែប៉ុណ្ណេះ ។